កំពង់ផែស្វយ័តភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍ប្រចាំឆ្នាំ

# ២០១៧











## ANNUAL REPORT 2017

ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ

Listed Company

Your Convenience and Efficiency Are Our Primary Concerns

# របាយការណ៍
# ប្រចាំ ឆ្នាំ២០១៧
# របស់កំពង់ផែស្វយ័តភ្នំពេញ

# ទស្សនវិស័យ និងបេសកកម្ម

## ទស្សនវិស័យ

- ទស្សនវិស័យរបស់ ក.ស.ភ. គឺរក្សាភាពជាអ្នកគ្រប់គ្រងក្នុងអាជីវកម្មដឹកជញ្ជូនតាមដងទន្លេ មេគង្គ និងដើរតួនាទីជាបណ្តាញដឹកជញ្ជូនតាមផ្លូវទឹកប្រកបដោយប្រសិទ្ធភាព សមត្ថភាព និងតម្លាភាព ដើម្បីភ្ជាប់ទំនាក់ទំនងជាមួយដៃគូពាណិជ្ជកម្មក្រៅប្រទេស។

## បេសកកម្ម

- បេសកកម្មរបស់ ក.ស.ភ. គឺគ្រប់គ្រង អភិវឌ្ឍ ធ្វើប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធផែ និងបម្រើ សេវាកម្មចម្បង និងសេវាកម្មពាក់ព័ន្ធដទៃទៀត ដើម្បីធានាឱ្យមាននិរន្តរភាពនៃការលូតលាស់ផ្នែកសេដ្ឋកិច្ច និងការរីកចម្រើនក្នុងសង្គមជាតិទាំងមូល។

## ១. ព័ត៌មានហិរញ្ញវត្ថុសង្ខេប ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប និងកម្មសិទ្ធិភាពភាគហ៊ុនិកធម្មតា

### ១.១. ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| បរិយាយ | | ៣១ ធ្នូ ឆ្នាំ២០១៧ | ៣១ ធ្នូ ឆ្នាំ២០១៦ |
|---|---|---|---|
| **ស្ថានភាពហិរញ្ញវត្ថុ** | | | (ពាន់រៀល) |
| ទ្រព្យសកម្មសរុប | | ៦៨០.៨៦០.៨៥៩ | ៦៥៩.៥៥៦.៩១៤ |
| បំណុលសរុប | | ១៤០.១៥៩.១៥០ | ១៣៨.៤០៧.២៣០ |
| មូលធនសរុប | | ៥៤០.៣០១.៣០៩ | ៥២១.១៤៩.៦៨៤ |
| **លទ្ធផលហិរញ្ញវត្ថុ** | | | (ពាន់រៀល) |
| ចំណូលសរុប | | ៧៦.២៧៣.៧១៧ | ៦៦.០៦៥.៦១០ |
| ចំណេញមុនបង់ពន្ធ | | ២៥.០១២.១៩២ | ១៩.២៧៨.៣៦២ |
| ចំណេញសុទ្ធក្រោយបង់ពន្ធ | | ២១.៦៨៨.៦១៤ | ១៦.៥៦៦.១៩២ |
| **អនុបាតហិរញ្ញវត្ថុ** | | | |
| អនុបាតសាធនភាព (ភាគរយ) | | ២៣,៨៣ | ១៨,៩៣ |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត (ចំនួនដង) | ២,៨៦ | ៣,៨៧ |
| | អនុបាតចរន្តលឿន (ចំនួនដង) | ២,៨៦ | ៣,៨៧ |
| អនុបាតចំណេញភាព | ផលចំណេញក្នុងមួយឯកតាទ្រព្យសកម្ម (ភាគរយ) | ៣,១៩ | ២,៥១ |
| | ផលចំណេញក្នុងមួយឯកតាមូលធន (ភាគរយ) | ៤,០១ | ៣,១៨ |
| | គំលាតចំណេញដុល (ភាគរយ) | ៦៥,៧៤ | ៦៥,៥២ |
| | គំលាតចំណេញភាព (ភាគរយ) | ២៨,៤៤ | ២៥,០៨ |
| | ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ១.០៨៨,៥៥ | ៨០០,៩០ |

## ១.២. ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប (គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧)






## ការបែងចែកប្រភេទចំណូលធៀបនឹងចំណូលសរុបពី ផលអាជីវកម្ម និងសេវាកម្ម




## ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ ២០១៧ (ពាន់រៀល)



## ប្រាក់ចំណេញសម្រាប់ ឆ្នាំ២០១៧ ធៀបនឹងផែនការ ឆ្នាំ២០១៧ (ពាន់រៀល)




## ប្រាក់ចំណេញតាមបណ្ដាឆ្នាំនីមួយៗ ចាប់ពីឆ្នាំ២០១៣ ដល់ឆ្នាំ ២០១៧ (ពាន់រៀល)



## ១.៣. កម្មសិទ្ធិភាព ភាគហ៊ុនិកធម្មតា (គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧)

| ភាគហ៊ុន | ចំនួនភាគហ៊ុន | កម្មសិទ្ធិភាព |
|---|---|---|
| **ភាគហ៊ុនប្រភេទ("គ")** | | |
| ១.រដ្ឋ តំណាងដោយ (ស.ហ.វ.) | **៩៣.៧៦៩.១២០** | **១០០%** |
| **ភាគហ៊ុនធម្មតា (ប្រភេទ "ខ")** | | |
| ១. រដ្ឋ តំណាងដោយ (ស.ហ.វ.) | **១៦.៥៤៧.៤៩២** | **៨០%** |
| **ភាគហ៊ុនធម្មតា (ប្រភេទ "ក")** | | |
| ១. ESOP | ៣៤៣.៧៤៨ | ១,៦៦% |
| ២. ភាគហ៊ុនិកឯកជន | ៣.៧៩៣.១២៥ | ១៨,៣៤% |
| **សរុបភាគហ៊ុនធម្មតា(ប្រភេទ "ក")** | **៤.១៣៦.៨៧៣** | **២០%** |

** ភាគហ៊ុនធម្មតា សរុប (២០.៦៨៤.៣៦៥ភាគហ៊ុន)។*





បម្រែបម្រួលតម្លៃភាគហ៊ុន (គិតជារៀល) និងបរិមាណជួញដូរ (ភាគហ៊ុន) ភាគហ៊ុនប្រភេទ ក
១០០០០០
៨០០០០
៦០០០០
៤០០០០
២០០០០
០
៦០០០
៥០០០
៤០០០
៣០០០
២០០០
១០០០
ថ្លៃបិទ
ទំហំជួញដូរ (ភាគហ៊ុន)

## ២. សមាសភាពក្រុមប្រឹក្សាភិបាល



**កឧត្តម ហ៊ី បាវី**
**ប្រធានក្រុមប្រឹក្សាភិបាល**
និងជាអគ្គនាយក ក.ស.ភ.



**ឯកឧត្តម សួន រចនា**
**សមាជិកក្រុមប្រឹក្សាភិបាល**
តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន



**ឯកឧត្តម កែន សម្បត្តិ**
**សមាជិកក្រុមប្រឹក្សាភិបាល**
តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



**ឯកឧត្តម ប៉ែន សុវិជាតិ**
**សមាជិកក្រុមប្រឹក្សាភិបាល**
តំណាងក្រសួងពាណិជ្ជកម្ម



**លោក ហ្គី អានវ៉ានិថ**
**សមាជិកក្រុមប្រឹក្សាភិបាល**
អភិបាលឯករាជ្យ



**លោក ឌិត សុចល**
**សមាជិកក្រុមប្រឹក្សាភិបាល**
អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន



**លោកស្រី ជួន សុខេម**
**សមាជិកក្រុមប្រឹក្សាភិបាល**
តំណាងនិយោជិត ក.ស.ភ.

## ៣. សេចក្តីថ្លែងរបស់អគ្គនាយក និងជាប្រធានក្រុមប្រឹក្សាភិបាល

សម្រាប់ការអនុវត្ត ឆ្នាំ២០១៧ ចំណូលសរុបពីផលអាជីវកម្ម និងសេវាកម្មចំនួន ៧៦.២៧៣.៧១៧ ពាន់រៀល (១៨.៨៥៦.២៩៦ដុល្លារអាមេរិក) សម្រេចបាន ១០៧,៨៥% នៃការគ្រោងផែនការឆ្នាំ២០១៧ ដែលបានកំណត់ត្រឹមចំនួន ៧០.៧២៥.៣១០ពាន់រៀល និងទទួលបានប្រាក់ចំណេញសុទ្ធក្នុងការិយបរិច្ឆេទសរុបចំនួន ២១.៦៨៨.៦១៨ពាន់រៀល (៥.៣៦១.៨៣៣ ដុល្លារអាមេរិក) សម្រេចបាន ១៩២,០៩% នៃការគ្រោងផែនការឆ្នាំ២០១៧ ដែលបានកំណត់ត្រឹមចំនួន ១៥.២៦៣.៨១០ ពាន់រៀល។ ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិក្នុងឆ្នាំ២០១៧ (basic earning per share) គឺចំនួន ១.០៨៨,៥៥ រៀល (០,២៦ដុល្លារអាមេរិក)។

សមិទ្ធិផលខាងលើអាស្រ័យដោយ ក.ស.ភ. តែងប្រកាន់ភ្ជាប់នូវការយកចិត្តទុកដាក់ក្នុងការបម្រើសេវាកម្មប្រតិបត្តិការផែជូនអតិថិជនប្រកបដោយតម្លាភាព និងភាពឆាប់រហ័ស ដើម្បីឆ្លើយតបយ៉ាងមានប្រសិទ្ធភាព និងទំនុកចិត្តខ្ពស់ចំពោះតម្រូវការរបស់អតិថិជន។ ជាក់ស្តែង ក.ស.ភ. បានប្រើប្រាស់គ្រប់យន្តការតាមរយៈការពង្រឹងគុណភាពសេវាកម្ម ការពង្រីកសមត្ថភាពលើកដាក់ និងផ្ទេរផ្ទុក ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការជួសជុលថែទាំ ការងារជលធារសាស្ត្រ និងការងារបំពាក់គ្រឿងចក្រ និងឧបករណ៍ថ្មីៗជាដើម។

### ៣.១. ទិសដៅការងារអនុវត្តចម្បងរបស់ ក.ស.ភ.

- បន្តអនុវត្តផែនការសកម្មភាពការងារតាមផែនការដែលបានគ្រោងទុកសម្រាប់ ឆ្នាំ២០១៨
- ធានាគុណភាព តម្លៃ តម្លាភាព ប្រសិទ្ធភាព និងភាពឆាប់រហ័ស នៃការផ្តល់សេវាកម្មជូនអតិថិជន
- ពង្រីកសេវាកម្ម និងអាជីវកម្មដែលមានស្រាប់ ឱ្យមានលក្ខណៈកាន់តែទូលំទូលាយ និងបង្កើតឱ្យមានសេវាកម្មថ្មីបន្ថែមទៀតដែលពាក់ព័ន្ធនឹងវិស័យកំពង់ផែ និងភ័ស្តុភារកម្ម
- ពង្រឹងការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងបុគ្គលិក ដើម្បីឆ្លើយតបនឹងការវិវឌ្ឍរបស់អង្គភាពស្របទៅនឹងការផ្លាស់ប្តូរចរន្តភារូបនីយកម្ម និងការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព
- ពង្រឹងកិច្ចសហប្រតិបត្តិការភាពជាដៃគូយុទ្ធសាស្ត្រ ជាមួយបណ្តាកំពង់ផែក្នុងតំបន់ និងបណ្តាកំពង់ផែដទៃទៀតនៅលើពិភពលោក
- បង្កើនឧត្តមភាពប្រកួតប្រជែងដោយស្មោះត្រង់ ជាមួយកំពង់ផែក្នុង និងក្រៅប្រទេស
- ខិតខំ និងបន្តផ្តោតការយកចិត្តទុកដាក់លើការធ្វើទំនើបកម្មប្រតិបត្តិការផែ ឱ្យស្របតាមស្តង់ដារ និងប្រព័ន្ធបច្ចេកវិទ្យា
- ចូលរួមក្នុងសកម្មភាពសង្គម និងសហគមន៍មូលដ្ឋាន។

### ៣.២. ការអនុវត្តការងាររបស់ក្រុមប្រឹក្សាភិបាល

សម្រាប់ឆ្នាំ២០១៧ ក. ស. ភ. បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលចំនួន ៥លើក ដូចខាងក្រោម៖

*១. កិច្ចប្រជុំក្រុមប្រឹក្សាភិបាល លើកទី៤ អាណត្តិទី៦ ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៧*

- បានពិនិត្យ និងអនុម័តលើរបាយការណ៍ស្តីពីលទ្ធផលការងារអាជីវកម្ម/សេវាកម្មឆ្នាំ២០១៦

- បានពិនិត្យ និងសម្រេចឯកភាពលើការស្នើសុំតែងតាំង និងផ្ទេរភារកិច្ចថ្នាក់ដឹកនាំមួយចំនួនរបស់ ក. ស. ក. ដូចខាងក្រោម៖
    - ផ្ទេរភារកិច្ចឯកឧត្តម ណែម ធីម ពីអគ្គនាយករងអាជីវកម្ម/ប្រតិបត្តិការផែ មកជាអគ្គនាយករងរដ្ឋបាល/ហិរញ្ញវត្ថុ
    - តែងតាំងលោកស្រី ហ៊ឺ ផានិន ជាអគ្គនាយករងអាជីវកម្ម/ប្រតិបត្តិការផែ ជំនួសឯកឧត្តម ណែម ធីម ដែលបានផ្ទេរភារកិច្ចទៅជាអគ្គនាយករងរដ្ឋបាល/ហិរញ្ញវត្ថុ បន្ទាប់ពីលោកជំទាវ គឹម សែន ចូលនិវត្ត
    - ផ្ទេរភារកិច្ច និងតែងតាំងថ្នាក់ប្រធាននាយកដ្ឋានមួយចំនួន ដែលនៅទំនេរ រួមមាន៖
      - តែងតាំង លោក តោ នី ជាប្រធាននាយកដ្ឋានសេវាកម្មនាវាចរណ៍
      - ប្រគល់ភារកិច្ចជូន លោក គង់ សុធា ជាប្រធាននាយកដ្ឋានបុគ្គលិក/ធនធានមនុស្សវិញ
      - ផ្ទេរភារកិច្ច លោក ជី វិចិត្រ ពីប្រធាននាយកដ្ឋានបុគ្គលិក/ធនធានមនុស្ស ទៅជាប្រធាននាយកដ្ឋានវិស្វកម្ម
      - តែងតាំង លោក ហ៊ិន សុខាល័យ ជាប្រធានស្តីទីនាយកដ្ឋានផែនការ/ទីផ្សារ
- បានពិនិត្យ និងសម្រេចយល់ព្រមជាគោលការណ៍បន្តកិច្ចសន្យាជូនទីប្រឹក្សាអម ក. ស. ក. ចំនួន ៦រូប នាពេលបច្ចុប្បន្ន និងបានសម្រេចយល់ព្រមជាគោលការណ៍តែងតាំងអគ្គនាយករង ចំនួន ២ រូប គឺលោកជំទាវ គឹម សែន និងឯកឧត្តម ណែម ធីម ជាទីប្រឹក្សាអម ក. ស. ក. បន្ទាប់ពីចូលនិវត្ត រហូតដល់បំណាច់ឆ្នាំ២០១៨
- បានពិនិត្យ និងសម្រេចយល់ព្រមជាគោលការណ៍ឱ្យ ក. ស. ក. អនុវត្តតាមគោលការណ៍របស់រាជរដ្ឋាភិបាលដំឡើងប្រាក់ឧបត្ថម្ភប្រពន្ធ ១៥.០០០ រៀល និងកូន ១០.០០០ រៀល និងមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សចាប់ពី ១.០០០.០០១ រៀល
- បានពិនិត្យ និងសម្រេចឯកភាពឱ្យ ក. ស. ក. បន្តជួលសេវា របស់ក្រុមហ៊ុនសវនកម្មឯករាជ្យKPMG សម្រាប់ការធ្វើសវនកម្ម និងសេវាត្រួតពិនិត្យលើរបាយការណ៍ប្រចាំ ត្រីមាសនីមួយៗ សម្រាប់ឆ្នាំ ២០១៧ បន្តទៀត
- បានពិនិត្យ និងធ្វើការវាយតម្លៃខ្ពស់លើកិច្ចសហប្រតិបត្តិការរវាង ក. ស. ក. និងក្រុមហ៊ុនយុនណានសេងមៅ អ៊ិនវេសម៉ិន (ខេមបូឌា) ឯ.ក ដើម្បីវិនិយោគដីទីលានស្តុកសំបកកុងតឺន័រ (ICD) ឱ្យទៅជាមជ្ឈមណ្ឌលផ្គត់ផ្គង់គ្រឿងសំណង់ (CMSC)
- បានពិនិត្យ និងសម្រេចឱ្យ ក. ស. ក. ពិគ្រោះយោបល់ជាមុនជាមួយគណៈកម្មការមូលបត្រកម្ពុជា (គ. ម. ក.) លើសេចក្តីព្រាងតារាងពេលវេលា និងកម្មវិធីការងារសម្រាប់បែងចែក ភាគលាភឆ្នាំ ២០១៦ និងដំណើរការរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី២ មុននឹងដាក់ជូនអង្គប្រជុំក្រុមប្រឹក្សាភិបាល (នៅដើមខែមីនា ឆ្នាំ២០១៧) នាពេលក្រោយដើម្បីធ្វើការសម្រេចជាផ្លូវការ។

### ២. កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៥ អាណត្តិទី៦ ថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៧

- បានពិនិត្យ និងអនុម័តលើរបាយការណ៍លទ្ធផលហិរញ្ញវត្ថុ សម្រាប់ការិយបរិច្ឆេទ២០១៦ ដែលបានធ្វើសវនកម្មដោយសវនករឯករាជ្យ KPMG

- បានពិនិត្យ និងសម្រេចលើការកំណត់បែងចែកប្រាក់ថ្លៃងសរសើរជូនថ្នាក់ដឹកនាំ និងនិយោជិក ក. ស. ភ. ស្មើនឹងចំនួន ៣ខែ នៃប្រាក់បៀវត្សរ៍សរុបជាមធ្យមប្រចាំឆ្នាំ និង ការបែងចែកប្រាក់ចំណេញចូលមូលនិធិនានាប្រចាំឆ្នាំ២០១៦
- បានពិនិត្យ និងសម្រេច លើការបែងចែកភាគលាភជូនភាគហ៊ុនិក ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតប្រភេទ "ក" និងប្រភេទ "ខ" ឆ្នាំ២០១៦ និងភាគលាភបង្គរឆ្នាំ២០១៥
- បានពិនិត្យ និងសម្រេចលើកាលបរិច្ឆេទ របៀបវារៈ និងទីកន្លែង នៃការរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី២ របស់ ក. ស. ភ.
- បានពិនិត្យ និងសម្រេចអនុញ្ញាតឱ្យក្រុមហ៊ុន CHEAN CHHOENG THAI GROUP ធ្វើការសិក្សាលម្អិតអំពីគម្រោង, អំពីផលសេដ្ឋកិច្ចនៃគម្រោង, អំពីផលប៉ះពាល់ពាក់ព័ន្ធពីគម្រោង និងលើកគម្រោងជាក់ស្តែងដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេច ហើយក្នុងករណីចាំបាច់ នឹងអនុញ្ញាតឱ្យ ក. ស. ភ លើកសំណើជូនក្រសួងអាណាព្យាបាលទាំងពីរ ដើម្បីពិនិត្យ សម្រេច។

### ៣. កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៦ អាណត្តិទី៦ កាលពីថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៧

- បានពិនិត្យ និងអនុម័តរបាយការណ៍សកម្មភាពការងាររយៈពេល ៦ខែ ឆ្នាំ២០១៧
- បានពិនិត្យ និងអនុម័តរបាយការណ៍របស់សវនករឯករាជ្យ KPMG ប្រចាំត្រីមាសទី២ ឆ្នាំ២០១៧
- បានពិនិត្យ និងអនុម័តរបាយការណ៍របស់សវនកម្មផ្ទៃក្នុងប្រចាំត្រីមាសទី២ ឆ្នាំ២០១៧
- បានពិនិត្យ និងសម្រេចលើការជ្រើសរើសយកក្រុមហ៊ុនសវនកម្មឯករាជ្យ BDO ដើម្បីធ្វើការត្រួតពិនិត្យលើរបាយការណ៍ប្រចាំត្រីមាសនីមួយៗ និងធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំសម្រាប់រយៈពេល ៣ ឆ្នាំ ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២០
- បានពិនិត្យ និងឯកភាពឱ្យ ក. ស. ភ. បន្តជួលសេវារបស់ក្រុមហ៊ុន Ernst & Young សម្រាប់គណនាប្រាក់សោធននិវត្តន៍របស់បុគ្គលិក ក. ស. ភ. រយៈពេល ៣ ឆ្នាំ ចាប់ពីឆ្នាំ២០១៧ រហូតដល់ឆ្នាំ២០១៩
- បានពិនិត្យ និងពិភាក្សាលើគម្រោងអភិវឌ្ឍន៍មជ្ឈមណ្ឌលពាណិជ្ជកម្មធំៗ "THE CITY GATE" របស់ក្រុមហ៊ុនចៀន ឈឹង ថៃ គ្រុប នៅលើទីតាំងចំណតផែបណ្តែត TS១ និងចំណតផែថ្មTS៣
- បានពិនិត្យ និងសម្រេចលើការកែសម្រួលសមាសភាពគណៈកម្មាធិការតែងតាំង នៃក្រុមប្រឹក្សា-ភិបាល
- បានពិនិត្យ និងសម្រេចលើការស្នើសុំពន្យារពេលបង់ថ្លៃជួលដីនៅទីលានស្តុកទុកសំបកកុងតឺន័រ (ICD) របស់ក្រុមហ៊ុន យុនណាន សេងម៉ៅ អ៊ិនវេសម៉ិន ឯ.ក (ខេមបូឌា)
- បានពិនិត្យ និងសម្រេចដាក់នាយកដ្ឋានសវនកម្មផ្ទៃក្នុង ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការសវនកម្ម នៃក្រុមប្រឹក្សាភិបាល ក. ស. ភ.
- បានពិនិត្យ និងសម្រេចលើសំណើសុំជំរះបញ្ជីគ្រឿងចក្រ និងសម្ភារចាស់ៗ ចេញពីបញ្ជីដោយអចលនទ្រព្យរបស់ ក. ស. ភ. ស្នើសុំការសម្រេចពីក្រសួងអាណាព្យាបាលទាំងពីរ និងអនុញ្ញាតឱ្យ ក. ស. ភ. ធ្វើលិខិតស្នើសុំឧបត្ថម្ភរថយន្តរដ្ឋបាលចំនួន ៣ គ្រឿងជូនអតីតអគ្គនាយករង ក. ស. ភ. ចំនួន ៣ រូបទៅក្រសួងអាណាព្យាបាលទាំងពីរ

- បានពិនិត្យ និងសម្រេចអនុញ្ញាតឱ្យ ក. ស. ភ. អនុវត្តការងាររៀបចំពង្រឹងទីលានផ្ទុកសំបកកុងតឺន័រ LM១៧ នៅលើទំហំ ១ ហិកតា បន្ថែម ប៉ែកខាងត្បូងនៃអគាររដ្ឋបាល ដោយធ្វើនិយ័តឥណទានថវិកាពីគម្រោងមិនទាន់ចាំបាច់ពាក់ព័ន្ធ សម្រាប់ការអនុវត្តគម្រោងនេះ
- បានពិនិត្យ និងសម្រេចអនុញ្ញាតឱ្យ ក. ស. ភ. ធ្វើការសិក្សាជាមួយក្រុមហ៊ុន Solar Partner Asia (Cambodia) Ltd. លើលទ្ធភាពធ្វើកិច្ចសហប្រតិបត្តិការ ដើម្បីបង្កើតប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ដោយពន្លឺព្រះអាទិត្យនៅចំណតផែកុងតឺន័រ LM១៧
- បានពិនិត្យ និងសម្រេចអនុញ្ញាតឱ្យ ក. ស. ភ. ធ្វើការសិក្សាជាមួយក្រុមហ៊ុនមកពីខេត្ត Anhui នៃសាធារណរដ្ឋប្រជាមានិតចិន លើលទ្ធភាពធ្វើកិច្ចសហប្រតិបត្តិការបង្កើតចំណតផែលើកដាក់ ផ្ទេរផ្ទុក ថ្មងថ្ម ស៊ីម៉ងត៍ និងវត្ថុធាតុដើមគ្រឿងសំណង់ក្នុងស្រុក
- បានពិនិត្យ និងសម្រេចអនុញ្ញាតឱ្យ ក. ស. ភ. ធ្វើការសិក្សាជាមួយក្រុមហ៊ុន Mekong Oryza Trading Co., Ltd. លើលទ្ធភាពធ្វើកិច្ចសហប្រតិបត្តិការបង្កើតឃ្លាំងត្រជាក់ សម្រាប់ប្រមូល ផ្លែឈើវេចខ្ចប់នាំចេញ
- បានពិនិត្យ និងសម្រេចអនុញ្ញាតឱ្យ ក. ស. ភ. ធ្វើការសិក្សាជាមួយក្រុមហ៊ុន Green Trade លើលទ្ធភាពធ្វើកិច្ចសហប្រតិបត្តិការ ដើម្បីបង្កើតរោងចក្រកែច្នៃស្រូវ អង្ករ (Rice Processing Facility) តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP) សម្រាប់ការនាំចេញអង្ករ និង កសិផលផ្សេងៗ
- បានពិនិត្យ និងសម្រេចអនុញ្ញាតឱ្យ ក. ស. ភ. ធ្វើការសិក្សាលើករណីក្រុមហ៊ុន Mekong Sentosa Logistics (MSL) ដែលមានបំណងបញ្ឈប់អាជីវកម្ម ថាតើ ក. ស. ភ. គួរទទួលយកការងារនេះបន្ត ឬយ៉ាងណា។

### ៨.កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ជាវិសាមញ្ញលើកទី៧ អាណត្តិទី៦ នាថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧

- បានពិនិត្យ និងអនុម័តលើរបាយការណ៍ស្តីពីលទ្ធផលការងារបឋមរយៈពេល ៩ខែ ឆ្នាំ២០១៧ របស់ ក. ស. ភ.
- បានពិនិត្យ និងសម្រេចតែងតាំង លោក តោ នី ជាអគ្គនាយករងរដ្ឋបាល/ហិរញ្ញវត្ថុ ជំនួសឯកឧត្តម ណែម ធីម ដែលចូលនិវត្ត និងផ្ទេរភារកិច្ចលោក គុល សុខុម ពីប្រធាននាយកដ្ឋានប្រតិបត្តិការចំណតផែTS៣ មកជាប្រធាននាយកដ្ឋានសេវាកម្មនាវាចរណ៍ជំនួសលោក តោ នី
- បានពិនិត្យ និងគាំទ្រលទ្ធផលនៃកិច្ចប្រជុំរបស់គណៈកម្មការអន្តរក្រសួង លើការសិក្សាវាយតម្លៃទីតាំងចំណតផែថ្មTS៣ និងចំណតផែបណ្តែតTS១ របស់ ក. ស. ភ. ដែលត្រូវជួលឱ្យក្រុមហ៊ុន ចៀន ឈឹង ថៃ គ្រុប
- បានពិនិត្យ និងសម្រេចពិចារណាលើការបង្កើនភាគលាភ ជូនភាគហ៊ុនិកមានសិទ្ធិបោះឆ្នោតប្រភេទ "ក" ក្នុងចំនួន ៦% សម្រាប់ឆ្នាំ២០១៧ បើលទ្ធផលអាជីវកម្ម/ហិរញ្ញវត្ថុប្រចាំឆ្នាំ២០១៧ សម្រេចបានតាមការប៉ាន់ស្មានទុក
- បានពិនិត្យ និងសម្រេចឱ្យក្រុមហ៊ុន យុនណាន សេងមៅ អ៊ិនវេសមិន (ខេមបូឌា) ឯ.ក ប្តូរឈ្មោះគម្រោងពី "មជ្ឈមណ្ឌលផ្គត់ផ្គង់គ្រឿងសំណង់ (CMSC)" ទៅជា "មជ្ឈមណ្ឌលពាណិជ្ជកម្ម Triumph កម្ពុជា" ដោយត្រូវអនុវត្តតាមនីតិវិធីច្បាប់ជាធរមាន។

### ៥. កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៨ អាណត្តិទី៦ នាថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧

- បានពិភាក្សា និងអនុម័តផែនការអាជីវកម្ម សេវាកម្ម និងហិរញ្ញវត្ថុ ឆ្នាំ២០១៨ របស់ ក. ស. ភ.
- បានពិនិត្យ និងសម្រេចអនុញ្ញាតឱ្យ ក. ស. ភ. ធ្វើកិច្ចសហការជាមួយក្រុមហ៊ុន Infunde Development Pte. Ltd. លើការសិក្សាគម្រោងផ្គត់ផ្គង់ថាមពលអគ្គិសនី ដើរដោយពន្លឺព្រះអាទិត្យ (Solar Power) នៅចំណតផែកុងតឺន័រ LM១៧។

## ៣.៣. ការកំណត់ទិសដៅសម្រាប់ ឆ្នាំ២០១៨

ទស្សនវិស័យទៅអនាគត ក.ស.ភ. នឹងកំណត់ទិសដៅសម្រាប់អនុវត្តរួមមាន៖

- បន្តពង្រឹងការអភិវឌ្ឍធនធានមនុស្ស
- បន្តជំរុញការបង្កើតមជ្ឈមណ្ឌលភ័ស្តុភារកម្ម ឃ្លាំងទំនើប និងឃ្លាំងត្រជាក់
- បន្តជំរុញការបង្កើតតំបន់គាំទ្រកំពង់ផែ
- បន្តជំរុញការបង្កើតសេវាកម្ម Line ទៅកាន់ផែមេដទៃ ក្រៅពីផែកៃម៉េប
- បន្តជំរុញការនាំចូលទំនិញដែលប្រើប្រាស់រួចមួយទឹក (ទំនិញជជុះ) តាមរយៈ ក.ស.ភ.
- បន្តយកចិត្តទុកដាក់លើការបំពាក់គ្រឿងចក្រលើកដាក់ទំនើបៗ នៅចំណតផែកុងតឺន័រLM១៧
- បន្តពង្រឹងសមត្ថភាពលើកដាក់ទំនិញចាក់ធារ និងបង្កើតចំណតផែសម្រាប់ទំនិញចាក់ធារ
- ធ្វើទំនើបកម្ម និងពង្រីកចំណតផែអ្នកដំណើរ និងទេសចរ (TS១)
- បន្តពង្រឹងសមត្ថភាពលើកដាក់ទំនិញកសិកម្ម តាមចំណតផែនៃបណ្ដាខេត្តផ្នែកខាងលើនៃទន្លេមេគង្គ
- ថែទាំផ្លូវនាវាចរណ៍ និងធ្វើការប្ដូមស្លាកទីតាំងប្រឡាយស្ដៅ សម្រួលការដឹកជញ្ជូនទំនិញ រវាងខេត្តនានានៅតាមភូមិភាគឦសាន មកភ្នំពេញតាមទន្លេមេគង្គ និងតាមព្រំប្រទល់កម្ពុជា-វៀតណាម។

ក.ស.ភ. មានជំនឿចិត្ត និងគោលជំហរយ៉ាងមុតមាំក្នុងការអនុវត្តការងារប្រចាំថ្ងៃ និងប្រតិបត្តិការនៅតាមបណ្ដាចំណតផែនានា ឱ្យមានតម្លាភាព ឱ្យមានភាពឆាប់រហ័ស ដើម្បីបង្កើននូវទំនុកចិត្ត និងការទាក់ទាញ នៃការផ្ដល់សេវាកំពង់ផែប្រកបដោយស្តង់ដារជូនដល់អតិថិជន។

ក.ស.ភ. សូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះក្រសួងអាណាព្យាបាលទាំងពីរ គឺក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងភាគហ៊ុនិកទាំងអស់ ដែលជានិច្ចជាកាល តែងតែគាំទ្រ និងទុកចិត្តដល់សកម្មភាពការងាររបស់ ក.ស.ភ. រៀងរហូតមក។

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨

**ប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយក**

**ហ៊ី-បាវី**

# មាតិកា


ទស្សនវិស័យ និងបេសកកម្ម

ព័ត៌មានស្តីពីហិរញ្ញវត្ថុសង្ខេប និងក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប i

សមាសភាពក្រុមប្រឹក្សាភិបាល ix

សេចក្តីថ្លែងរបស់អគ្គនាយក និងជាប្រធានក្រុមប្រឹក្សាភិបាល x

**ផ្នែកទី១ : ព័ត៌មានពាក់ព័ន្ធនឹងកំពង់ផែស្វយ័តភ្នំពេញ** ៣

១-ព័ត៌មានទូទៅអំពីកំពង់ផែស្វយ័តភ្នំពេញ ៤

២-ដំណើរការធុរកិច្ចសង្ខេប ៤

៣-ស្ថានភាពទីផ្សារ ៩

៤-ស្ថានភាពប្រកួតប្រជែង ១៤

៥-ផែនការអនាគតសម្រាប់ ឆ្នាំ២០១៧ ១៦

**ផ្នែកទី ២ : ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច** **១៨**

១-លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក ១៩

២-ការប្រែប្រួលសំខាន់ៗពាក់ព័ន្ធនឹងប្រតិបត្តិការធុរកិច្ច ២៤

៣-រចនាសម្ព័ន្ធចំណូល ២៥

**ផ្នែក ៣ : អភិបាលកិច្ចសាជីវកម្ម** **២៦**

១-ភាគហ៊ុនិក ២៧

២-អង្គការលេខ ៣៣

៣-ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនានា ៣៤

៤-បុគ្គលិកជាន់ខ្ពស់ ៤៦

៥-ការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់ ៦៩

៦-លាភការ ឬប្រាក់បំណាច់ចំពោះអភិបាល និងបុគ្គលិកជាន់ខ្ពស់ ៧០

៧-ក្រមសីលធម៌សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ ៧៣

៨-សិទ្ធិភាគីពាក់ព័ន្ធ ៧៨

**ផ្នែកទី ៤ : បញ្ជីរាយនាមភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតចំនួនច្រើនលើសលប់ និងភាគហ៊ុនិក កាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន** **៧៩**

១-ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ ៨០

២-ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន ៨០

**ផ្នែកទី ៥ : ព័ត៌មានអំពីការជួញដូរមូលបត្ររបស់ ក.ស.ភ.** **៨១**

១-ព័ត៌មានអំពីមូលបត្រកម្មសិទ្ធិ ៨២

២-ថ្លៃ និងបរិមាណជួញដូរ ៨២

**ផ្នែកទី ៦ : របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង** ៨៣
**ផ្នែកទី៧ : របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យ** ៩៤
**ផ្នែកទី៨ : ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ** **១៥៩**
១-ប្រតិបត្តិការជាមួយភាគហ៊ុនិក ១៦០
២-ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬប្រតិបត្តិការសំខាន់ៗ
ជាមួយបុគ្គលដែលអភិបាល ឬបុគ្គលិកជាន់ខ្ពស់មានផលប្រយោជន៍ ១៦០
៣-ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ ១៦០
៤-ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់កំពង់ផែស្វយ័តភ្នំពេញ
ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់ ក.ស.ភ. ដែលមានទំនាក់ទំនងរបស់បុគ្គលទាំងនោះកើតមាន
នៅក្នុងប្រតិបត្តិការ ឬការចាត់ចែងណាមួយដែលធ្វើឡើងដោយ ក.ស.ភ. ១៦០
៥-ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គល
ធ្លាប់ជាអភិបាលក្នុងរយៈពេល ២ឆ្នាំ ចុងក្រោយ ១៦១
៦-ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ ឬកម្រៃវិជ្ជាជីវៈ សម្រាប់សេវាដែលខ្លួន
បានផ្តល់តាមរយៈក្រុមហ៊ុនណាមួយដល់ ក.ស.ភ. ១៦១
៧-ប្រតិបត្តិការសំខាន់ៗជាមួយភាគីជាប់ពាក់ព័ន្ធផ្សេងទៀត ១៦១
**ផ្នែកទី ៩ : ការវិភាគរបស់ថ្នាក់ដឹកនាំ** **១៦២**
១-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ១៦៣
២-កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ១៧៧
៣-ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ១៧៩
៤-ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ១៨០
៥-ផលប៉ះពាល់ពីអតិផរណា ១៨០
៦-គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រដ្ឋាភិបាល ១៨០
**ផ្នែកទី ១០ : ស្ថិតិប្រចាំឆ្នាំសង្ខេបពីលទ្ធផលអាជីវកម្ម របស់ ក.ស.ភ.** **១៨២**
**ផ្នែកទី ១១ : ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន** **១៨៤**

# ផ្នែកទី១
# ព័ត៌មានពាក់ព័ន្ធនឹងបុគ្គលបោះឆ្នោត

## ១. ព័ត៌មានទូទៅអំពីកំពង់ផែស្វយ័តភ្នំពេញ

ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ : **កំពង់ផែស្វយ័តភ្នំពេញ (ក. ស. ភ.)**

ជាអក្សរឡាតាំង : **PHNOM PENH AUTONOMOUS PORT (PPAP)**

- អក្សរកូដ : **KH1000040001**
- អាសយដ្ឋាន : **អគារលេខ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**
- លេខទូរស័ព្ទ : **+៨៥៥ (0) ២៣ ៩២៧ ៨០២** លេខទូរសារ : **+៨៥៥ (0) ២៣ ៩២៧ ៨០២**
- គេហទំព័រ : **www.ppap.com.kh** អ៊ីម៉ែល : **ppapmpwt@online.com.kh**
- លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម : **CO.៧១៧៥ Et/២០០៤**
  កាលបរិច្ឆេទ : **២៣/វិច្ឆិកា/២០០៤**
- លេខអាជ្ញាបណ្ណអាជីវកម្ម : **០១២៧ ពណ.ចប**
  កាលបរិច្ឆេទ : **០៥/មករា/២០១៥**
- សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន លេខ : **០៧៤/១៥/គ.ម.ក./ស.ស.រ**
  ឈ្មោះបុគ្គលតំណាងបុគ្គលបោះផ្សាយ : **ឯកឧត្តម ហ៊ី បាវី**

## ២. ដំណើរការធុរកិច្ចសង្ខេប

កំពង់ផែស្វយ័តភ្នំពេញ (ក. ស. ភ.) គឺជាកំពង់ផែអន្តរជាតិមួយក្នុងចំណោមផែអន្តរជាតិទាំងពីររបស់ប្រទេសកម្ពុជា ដែលបម្រើសេវានាំចូល នាំចេញកុងតឺន័រ និងទំនិញទូទៅ។ ដូចនេះ ក្នុងនាមជាប្រតិបត្តិករផែ និងអាជ្ញាធរផែ ក. ស. ភ. កំពុងផ្តល់សេវាកម្មផែចម្បងៗ និងសេវាកម្មពាក់ព័ន្ធសំខាន់ដទៃទៀតដែលជាដំណើរការធុរកិច្ចរបស់ ក. ស. ភ.។

### *ក- ប្រតិបត្តិការក្នុងនាមជាប្រតិបត្តិករផែ*

ក្នុងនាមជាប្រតិបត្តិករផែ ក. ស. ភ. មានភារកិច្ចបម្រើសេវាសំខាន់ៗ រួមមាន ៖

- ផ្តល់សេវាលើកដាក់ទំនិញ ការស្តុកទំនិញ ការច្រេកនិងរើទំនិញ ការផ្ទេរនិងផ្ទុក និងការដឹកជញ្ជូនទំនិញកុងតឺន័រ សម្រាប់ការនាំចេញ និងនាំចូលទំនិញឆ្លងប្រទេស
- ផ្តល់សេវាកណ្តាធារកិច្ច នាំនាវាចេញ-ចូល
- ផ្តល់សេវាចំណតផែអ្នកដំណើរ និងទេសចរ TS១
- សេវាកម្មនាវាសណ្តោង សេវាកម្មចង/ដោះពួរនាវា។

### *ខ- ប្រតិបត្តិការក្នុងនាមជាអាជ្ញាធរផែ*

ក្នុងនាមជាអាជ្ញាធរផែ ក. ស. ភ. មានតួនាទី៖

- ថែទាំផ្លូវនាវាចរណ៍ បំពាក់ឧបករណ៍ជំនួយដល់ការធ្វើនាវាចរណ៍ ដូចជាពោងសញ្ញា និងបង្គោលសញ្ញាសម្គាល់ទិសនាវាចរណ៍ រៀបចំការចូលចតនាវា និងថែរក្សាបរិស្ថានក្នុងមណ្ឌលអាជីវកម្មផែភ្នំពេញ
- ចាត់វិធានការធានាការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធវិស័យកំពង់ផែ និងការដឹកជញ្ជូននានាតាមផ្លូវទឹក។

### គ. សេវាកម្ម/អាជីវកម្ម ផ្សេងទៀត

ជាមួយនឹងការផ្តល់សេវាកម្មស្នូលលើការងារប្រតិបត្តិផែ និងអាជ្ញាធរផែ ក. ស. ភ. ក៏មានសេវាកម្ម/អាជីវកម្មបន្ទាប់បន្សំផ្សេងទៀត ដែលអាចបង្កើតឲ្យមានចំណូលបន្ថែមដូចជា៖

- សេវាកម្មបូមស្តារ៖ ក. ស. ភ. មានម៉ាស៊ីន និងគ្រឿងចក្របូមស្តារចំនួន ២គ្រឿង សម្រាប់ផ្តល់សេវាកម្មបូមស្តារដើម្បីចាក់បំពេញខ្សាច់ជូនដល់អតិថិជន
- សេវាកម្មគ្រប់គ្រងអាជីវកម្មខ្សាច់៖ ក. ស. ភ. ទទួលបានអាជ្ញាបណ្ណបូមស្តារប្រឡាយនាវាចរណ៍ និងធ្វើអាជីវកម្មខ្សាច់នៅទីតាំងចំនួន ២ ដោយអនុលោមតាមប្រកាសលេខ ០១ និង ០២ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែ និងថាមពល
- សេវាកម្មវាស់ស្ទង់ និងបំពាក់ពោង៖ ក. ស. ភ. មានទទួលផ្តល់សេវាកម្មវាស់ស្ទង់ និងបំពាក់ពោងតាមតម្រូវការរបស់អតិថិជន
- សេវាកម្មថែទាំ/ជួសជុលសំបកកុងតឺន័រ៖ ក. ស. ភ. មានទទួលផ្តល់សេវាកម្មថែទាំ/ជួសជុលសំបកកុងតឺន័រគ្រប់ប្រភេទទៅតាមតម្រូវការរបស់អតិថិជន
- ការជួលអចលនទ្រព្យ និងគ្រឿងចក្រផ្សេងៗ៖ ក្រៅពីការប្រើប្រាស់អចលនទ្រព្យ និងគ្រឿងចក្រសម្រាប់បម្រើឲ្យការងារអាជីវកម្ម និងប្រតិបត្តិការ អចលនទ្រព្យ និងគ្រឿងចក្រទាំងនោះក៏ត្រូវបានប្រើប្រាស់ និងចាត់ចែងសម្រាប់ការជួល ដើម្បីបង្កើនចំណូលបន្ថែមជូនដល់ ក. ស. ភ. ផងដែរ។

### ឃ- មណ្ឌលអាជីវកម្មផែ

យោងតាមអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០០៩ មណ្ឌលអាជីវកម្មរបស់ ក. ស. ភ. មានប្រវែង ១៦០គីឡូម៉ែត្រ លាតសន្ធឹងពីខេត្តត្បូងឃ្មុំ (ចំណតផែទន្លេបិទ UM២) ទៅដល់អ្នកលឿង។ ក្នុងនាមជាអាជ្ញាធរ ក. ស. ភ. មានតួនាទីគ្រប់គ្រងចំណតផែឯកជននានា នៅក្នុងមណ្ឌលអាជីវកម្ម ដោយរាប់បញ្ចូលទាំងចំណតផែប្រេង និងចំណតផែទំនិញរាយដទៃទៀត។ ដោយឡែក ក. ស. ភ. គ្រប់គ្រង និងប្រតិបត្តិការដោយផ្ទាល់ទៅលើចំណតផែចម្បង ចំនួន ៤ រួមមាន៖

#### ឃ.១. ចំណតផែកុងតឺន័រ LM១៧

នៅដំណាក់កាលទី១ ក. ស. ភ. បានសាងសង់ចំណតផែកុងតឺន័រ LM១៧ លើផ្ទៃដីទំហំ ១០ហិកតា នៃផ្ទៃដីសរុប ៣០ហិកតា។ ក. ស. ភ. កំពុងប្រើប្រាស់ចំណតផែនេះ ធ្វើជាចំណតផែចម្បងសម្រាប់ទំនិញ

កុងតឺន័រ។ ចំណតផែនេះ មានសមត្ថភាពលើកដាក់កុងតឺន័របាន ១៥០.០០០ TEUs ក្នុងមួយឆ្នាំ។ ចំណតផែកុងតឺន័រ LM១៧ មានស្ពានផែ ដែលមានបណ្តោយប្រវែង ៣០០ម៉ែត្រ ទទឹង ២២ម៉ែត្រ និងបំពាក់ដោយដងយោង TCC ចំនួន ៣គ្រឿង រថស្ទូច RTG ចំនួន ៨គ្រឿង និងគ្រឿងចក្រលើកដាក់លើទីលាន (Reach Stacker & Constacker) ចំនួន ៥គ្រឿង និងរថយន្ត ៣០គ្រឿងបាននឹងកំពុងបំពេញការងារប្រតិបត្តិការ។

| | |
|---|---|
| **អាសយដ្ឋាន** | ភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល |
| **ទីតាំងចំណតផែ** | ស្ថិតនៅតាមដងទន្លេមេគង្គត្រើយខាងលិច ចម្ងាយ ២៥គីឡូម៉ែត្រ ពីទន្លេចតុមុខ ហើយស្ថិតក្នុងទីតាំងនៃរយៈទទឹងខាងជើង ១១°២៨'២៣.៦" និងរយៈបណ្តោយខាងកើត ១០៥°០៨'៤៩.៨" |
| **ទំហំផ្ទៃដីសរុប** | ៣១៨.២៤៩ម៉ែត្រការ៉េ |
| **ទំហំផ្ទៃដី ចុះបញ្ជី** | ៣០១.០៧៩ម៉ែត្រការ៉េ |
| **ទំហំផ្ទៃដីកំពុងធ្វើប្លង់កម្មសិទ្ធិ** | ១៧.១៧០ម៉ែត្រការ៉េ |
| **ចំណតនាវា** | មាន ៣ ចំណត សម្រាប់នាវាចំណុះ ៥.០០០ DWT |
| **ទីតាំងបោះយុថ្កា** | ទីតាំងបោះយុថ្កា របស់ចំណតផែកុងតឺន័រ LM១៧ ស្ថិតក្នុងរយៈទទឹងខាងជើង ១១°២៨'២៨.១៥" និងរយៈបណ្តោយខាងកើត ១០៥°៩'២.៣២" ចន្លោះជម្រៅទឹកពី ៨ម៉ែត្រ ទៅ ១៧ម៉ែត្រ។ បាតទន្លេមានដីភក់ និងខ្សាច់ ហើយចរន្តទឹកមានកម្លាំងខ្លាំងនៅរដូវវស្សា។ |
| **រលក** | ផលប៉ះពាល់មានចាប់ពីខែកុម្ភៈ ដល់ ខែមេសា ដោយកម្ពស់រលកមានចាប់ពី ០.២០ម៉ែត្រ ដល់ ០.៤៥ម៉ែត្រ គិតនៅខែធ្នូ ឆ្នាំ២០១៥ |
| **ជម្រៅស៊ីទឹកនាវា** | ជម្រៅស៊ីទឹកនាវា ប្រែប្រួលពីកម្រិតអប្បបរមា ៤.៥ម៉ែត្រ ក្នុងខែមីនា ដល់កម្រិតអតិបរមា ៥.៥ម៉ែត្រ ក្នុងខែកញ្ញា (ជម្រៅទឹកសម្រាប់ធ្វើនាវាចរមកចំណតផែកុងតឺន័រ LM១៧ អាស្រ័យជម្រៅទឹក នៅច្រកគូទីរ) |
| **ម៉ោងប្រតិបត្តិការ** | ៧ថ្ងៃ/២៤ម៉ោង |
| **គ្រឿងចក្រលើកដាក់** | ដងយោង (Traveling Cargo Crane) រថស្ទូច (Rubber Tyred Gantry) គ្រឿងចក្រលើកដាក់លើទីលាន (Reach Stacker & Sky Stacker) |

*<u>សម្គាល់៖</u> *ទំហំដីអាចខុសគ្នារវាងទំហំផ្ទៃដីសរុប និងទំហំផ្ទៃដីចុះបញ្ជី ដោយសារការកាត់ចេញនូវដីចំណីផ្លូវ និងចំណីទន្លេ។*

### *ឃ.២. ចំណតផែពហុបំណង TS៣*

ចំណតផែពហុបំណង TS៣ ជាចំណតផែចម្បងសម្រាប់ទំនិញរាយ និងទំនិញកុងតឺន័រឆ្លងកាត់។ ដោយសារសមត្ថភាពពង្រីកទីលានចំណតផែពហុបំណង TS៣ នៅមានកម្រិត ដើម្បីទទួលកំណើនចរាចរកុងតឺន័រប្រចាំឆ្នាំ ក.ស.ភ. បានវិនិយោគលើការអភិវឌ្ឍចំណតផែកុងតឺន័រ LM១៧។ ចាប់តាំងពីចំណតផែកុងតឺន័រ LM១៧ ត្រូវបានស្ថាបនារួចរាល់ ចំណតផែ TS៣ ត្រូវបានក្លាយទៅជាចំណតផែពហុបំណង សម្រាប់បម្រើការលើកដាក់ទំនិញរាយ កុងតឺន័រ និងប្រើជាចំណតផែអ្នកដំណើរ និងទេសចរ។

| | |
|---|---|
| **អាសយដ្ឋាន** | អគារលេខ ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| **ទីតាំងចំណតផែ** | ស្ថិតនៅតាមដងទន្លេសាប ត្រើយខាងលិច ចម្ងាយ ៣,២គីឡូម៉ែត្រ ពីទន្លេចតុមុខ ហើយស្ថិតក្នុងទីតាំងនៃរយៈទទឹងខាងជើង ១១°៣៤' ៥៩,៦៨" និងរយៈបណ្តោយខាងកើត ១០៤°៥៥' ១៧,៤១" |
| **ទំហំផ្ទៃដីសរុប** | ៩៨.៤៣៨,៧៦ ម៉ែត្រការ៉េ |
| **ទំហំផ្ទៃដីចុះបញ្ជី*** | ៣២.៨៥៤ ម៉ែត្រការ៉េ |
| **ចំណតនាវា** | មាន ៣ ចំណត សម្រាប់នាវាចំណុះ ៥.000 DWT |
| **ទីតាំងបោះយុថ្កា** | ទីតាំងអាចបោះយុថ្កាបាន គឺនៅទន្លេសាបខាងមុខចំណតផែ និងមួយកន្លែងទៀតនៅទន្លេចតុមុខ ដែលស្ថិតក្នុងរយៈទទឹង ខាងជើង ១១°៣៣'៤៦,៩៨" និងរយៈបណ្តោយខាងកើត ១០៤°៥៦'៣៤,៥៧" មានជម្រៅទឹកពី ៥ម៉ែត្រ ទៅ១៥ម៉ែត្រ។ បាតទន្លេមានដីភក់ និងខ្សាច់ ដែលអាចបោះយុថ្កាជាប់បានល្អ |
| **រលក** | ផលប៉ះពាល់ មានចាប់ពីខែកុម្ភៈ ដល់ខែមេសា ដោយកម្ពស់រលកមានចាប់ពី ០,១០ម៉ែត្រ ដល់ ០,៣៥ម៉ែត្រ គិតនៅខែធ្នូ ឆ្នាំ២០១៥ |
| **ជម្រៅស៊ីទឹកនាវា** | ជម្រៅស៊ីទឹកនាវាប្រែប្រួលពីកម្រិតអប្បបរមា ៤,៥ម៉ែត្រ ក្នុងខែមីនា ដល់កម្រិតអតិបរមា៥,៥ម៉ែត្រ ក្នុងខែកញ្ញា (ជម្រៅទឹកសម្រាប់ធ្វើនាវាចរមកចំណតផែពហុបំណង៣ អាស្រ័យលើជម្រៅទឹក នៅច្រកគូទីវ) |
| **ម៉ោងប្រតិបត្តិការ** | ៧ថ្ងៃ/២៤ម៉ោង |
| **គ្រឿងចក្រលើកដាក់** | ដងយោងចល័ត (Mobile crane និង Crawler crane) ដងយោងបណ្តែត (Floating crane) |

*<u>សម្គាល់</u>៖ *ទំហំដីអាចខុសគ្នារវាងទំហំផ្ទៃដីសរុប និងទំហំផ្ទៃដីចុះបញ្ជី ដោយសារការកាត់ចេញនូវដីចំណីផ្លូវ និងចំណីទន្លេ។*

### *<u>ឃ.៣ ចំណតផែទន្លេបិទ UM ២</u>*

ក.ស.ភ. បានចុះហត្ថលេខាលើកិច្ចព្រមព្រៀង នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ ជាមួយក្រុមហ៊ុន *មៀង លីហោង អ៊ិនវេសមិន* ដើម្បីធ្វើកិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍចំណតផែទន្លេបិទ។ កិច្ចព្រមព្រៀងនេះ មានសុពលភាពរយៈពេល ២០ឆ្នាំ គិតចាប់ពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ រហូតដល់ថ្ងៃទី២១ ខែតុលា ឆ្នាំ២០៣២។ យោងតាមកិច្ចព្រមព្រៀងនេះ ក.ស.ភ. ទទួលខុសត្រូវលើសេវាកម្មលើកដាក់ក្រោមដងយោង រីឯដៃគូឯកជនទទួលខុសត្រូវលើការផ្តល់សេវាកម្មស្តុកទំនិញ។ ចំណូលពីថ្លៃឈ្នួលទាំងនេះ ត្រូវគិតដាច់ដោយឡែកពីគ្នា ផ្អែកលើប្រភេទសេវាកម្ម ដែលផ្តល់ដោយភាគីនីមួយៗ។ ក.ស.ភ. មិនទាន់ទទួលបានសិទ្ធិជាម្ចាស់គ្រប់គ្រងទីតាំងដីនោះនៅឡើយទេ ប៉ុន្តែ ក.ស.ភ. បានសាងសង់ផែបណ្តែត និងបំពាក់ដងយោងចល័ត និងរថចូក។ គោលបំណងសំខាន់ក្នុងការបង្កើតចំណតផែនេះ គឺដើម្បីធ្វើជាកន្លែងប្រមូលផ្តុំកសិផល និងលើកកម្ពស់ការដឹកជញ្ជូនតាមផ្លូវទឹក។ បច្ចុប្បន្ន ដំឡូងមី ជាប្រភេទផលិតផលសំខាន់ ដែលត្រូវបាននាំចេញតាមចំណតផែនេះ។

| | |
|---|---|
| **អាសយដ្ឋាន** | ភូមិដូនមៅលើ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ |
| **ទីតាំងចំណតផែ** | ចំណតផែទន្លេបិទUM២ ស្ថិតនៅតាមដងទន្លេមេគង្គត្រើយខាងកើត ចម្ងាយ ១០៣ គីឡូម៉ែត្រ ពីទន្លេចតុមុខ ហើយស្ថិតក្នុងទីតាំងនៃរយៈទទឹងខាងជើង ១១°៥៧'៤៧,៧៣" និងរយៈបណ្តោយខាងកើត ១០៥°២៨' ៣៣,១៣" |
| **ទំហំផ្ទៃដី** | ទំហំតូច ចំណតនៅតាមច្រាំងទន្លេប្រវែង ១០០ម៉ែត្រ (ដោយមានបំពាក់ ប៉ង់តុង ដងយោងចល័ត និងកុងវ៉ូយ័រ) |
| **ចំណតនាវា** | ចំនួន ១ (ប៉ង់តុងបណ្តែតទំហំ ៦ម៉ែត្រ x ២៨ម៉ែត្រ) |
| **ទីតាំងបោះយុថ្កា** | ទីតាំង ដែលអាចបោះយុថ្កានៅចំណតផែទន្លេបិទ UM២ ស្ថិតនៅក្នុងរយៈទទឹងខាងជើង ១១°៥៨'៤៣,៤១" និងរយៈបណ្តោយខាងកើត ១០៥°២៨' ៩,៥៨" ក្នុងចន្លោះជម្រៅទឹកពី ៦ម៉ែត្រ ទៅ ២០ម៉ែត្រ។ នារដូវវស្សា នៅបាតទន្លេមានដីភក់ និងខ្សាច់ ហើយមានចរន្តទឹកមានកម្លាំងខ្លាំង។ |
| **រលក** | មិនមានផលប៉ះពាល់ |
| **ជម្រៅស៊ីទឹកនាវា** | ជម្រៅស៊ីទឹកនាវា ប្រែប្រួលពីកម្រិតអប្បបរមា ៤,៥ម៉ែត្រ ក្នុងខែមីនា ដល់កម្រិតអតិបរមា ៥,៥ម៉ែត្រ ក្នុងខែកញ្ញា (ជម្រៅទឹកសម្រាប់ធ្វើនាវាចរមកចំណតផែទន្លេបិទ គឺអាស្រ័យទៅលើជម្រៅទឹក នៅច្រកគូទីរ) |
| **ជម្រៅទឹកផ្លូវនាវាចរ** | ចាប់ពីទន្លេចតុមុខទៅដល់ខេត្តត្បូងឃ្មុំ តាមប្រឡាយស្តៅមានទទឹង៦០ម៉ែត្រ និងបណ្តោយ ៣៥០០ម៉ែត្រ។ ជម្រៅទឹក មានជម្រៅ ៥ម៉ែត្រ ក្នុងរដូវប្រាំង (ដោយមានការថែទាំទៀងទាត់) |
| **ម៉ោងប្រតិបត្តិការ** | ៧ថ្ងៃ/២៤ ម៉ោង |
| **គ្រឿងចក្រលើកដាក់** | ដងយោងចល័ត (Mobile crane) ដងយោងបណ្តែត (Floating crane) និង កុងវ៉ូយ័រ (Conveyer) |

### *ឃ.៤. ចំណតអ្នកដំណើរ និងទេសចរ TS១*

ចំណតផែអ្នកដំណើរ និងទេសចរ TS១ ជាចំណតផែអ្នកដំណើរចម្បងរបស់ ក.ស.ភ.។ ចំណតផែនេះត្រូវបានប្រើប្រាស់ ដើម្បីធ្វើជាចំណតផែអ្នកដំណើរក្នុងស្រុក ក៏ដូចជាទៅកំពង់ផែនៃប្រទេសវៀតណាម។ ក្នុងឆ្នាំ២០១៦ ចំនួនអ្នកដំណើរឆ្លងកាត់ចំណតផែអ្នកដំណើរ និងទេសចរ TS១ មានចំនួន ៣៣,៨៦១នាក់។ តួលេខនេះ រាប់បញ្ចូលទាំងអ្នកដំណើរ ពីភ្នំពេញទៅចំណតផែក្នុងស្រុកនានា ពីភ្នំពេញទៅប្រទេសវៀតណាម ព្រមទាំងអ្នកទេសចរ ដែលធ្វើដំណើរឆ្លងកាត់តាមដងទន្លេមេគង្គ ក្បែររាជធានីភ្នំពេញ។

| | |
|---|---|
| **អាសយដ្ឋាន** | វិថីព្រះស៊ីសុវត្ថិ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| **ទីតាំងចំណតផែ** | ចំណតអ្នកដំណើរ និងទេសចរ TS១ ស្ថិតនៅតាមដងទន្លេសាបត្រើយខាងលិចចម្ងាយ ២គីឡូម៉ែត្រ ពីទន្លេចតុមុខ ហើយស្ថិតក្នុងទីតាំងរយៈទទឹងខាងជើង ១១°៣៤'៣២,៤៥" និងរយៈបណ្តោយខាងកើត ១០៤° ៥៥'៣៦,៨៨។ |
| **ទំហំផ្ទៃដីសរុប**<br>**ទំហំផ្ទៃដីចុះបញ្ជី*** | ១.៦៩៩ ម៉ែត្រការ៉េ<br>៦.៦៧៦ ម៉ែត្រការ៉េ |

| | |
|---|---|
| ចំណតនាវា | មានប៉ង់តុងចំនួន ២គ្រឿង |
| ទីតាំងបោះយុថ្កា | ទីតាំងអាចបោះយុថ្កាបាន នៅខាងមុខចំណតផែ តំបន់ទន្លេសាប និងមួយទីតាំងទៀតនៅតំបន់ទន្លេចតុមុខ ស្ថិតក្នុងរយៈទទឹងខាងជើង ១១°៣៣'៤៦,៩៨" និងរយៈបណ្តោយខាងកើត ១០៤°៥៦'២៤,៥៧" ចន្លោះជម្រៅទឹកពី ៥ម៉ែត្រ ទៅ ១៥ម៉ែត្រ។ នាវដូវវស្សា បាតទន្លេមានដីភក់ និងខ្សាច់ ដែលជាផ្ទៃមានកម្លាំងទប់ជាប់ល្អ ហើយជម្រើសទីតាំងទី២ ដើម្បីបោះយុថ្កាមានចរន្តទឹកខ្លាំង។ |
| រលក | ផលប៉ះពាល់មានចាប់ពីខែកុម្ភៈ ដល់ខែមេសា ដោយកម្ពស់រលកមានចាប់ពី ០,១ម៉ែត្រ ដល់ ០,៣៥ម៉ែត្រ គិតនៅខែធ្នូ ឆ្នាំ២០១៥ |
| ជម្រៅស៊ីទឹក | ជម្រៅស៊ីទឹកប្រែប្រួលពី ៤,៥ម៉ែត្រ ក្នុងខែមីនា ដល់ ៥,៥ម៉ែត្រ ក្នុងខែកញ្ញា (ជម្រៅស៊ីទឹកសម្រាប់នាវាចរាចរមកចំណតផែពហុបំណង TS៣ គឺអាស្រ័យទៅលើជម្រៅស៊ីទឹក នៅច្រកគូទីវ) |
| ប្រតិបត្តិការ | ៧ថ្ងៃ/២៤ម៉ោង |
| គ្រឿងចក្រលើកដាក់ | មានប៉ង់តុងចំនួន ២គ្រឿង ដោយមានស្ពានតភ្ជាប់ទៅច្រាំងទន្លេ |

*<u>សម្គាល់</u>៖ *ទំហំដីអាចខុសគ្នារវាងទំហំផ្ទៃដីសរុប និងទំហំផ្ទៃដីចុះបញ្ជី ដោយសារការកាត់ចេញនូវដីចំណីផ្លូវ និងចំណីទន្លេ។*

## ៣. ស្ថានភាពទីផ្សារ

ទីផ្សាររបស់ ក.ស.ភ. គឺពឹងផ្អែកសំខាន់ទៅលើតម្រូវការក្នុងប្រទេស និងក្រៅប្រទេស។ ជាក់ស្តែងតម្រូវការក្នុងប្រទេសគឺពឹងផ្អែកទៅលើតម្រូវការរបស់ប្រជាជន សហគ្រាស រោងចក្រ ឧស្សាហកម្ម និងសំណង់អាគារផ្សេងៗជាដើម ប៉ុន្តែដោយប្រទេសកម្ពុជាពុំទាន់មានផលិតកម្មគ្រប់គ្រាន់ដើម្បីផ្គត់ផ្គង់តម្រូវការក្នុងស្រុកបាន ដូចនេះ ការនាំចូលពីក្រៅប្រទេសគឺ មានភាពចាំបាច់ខ្លាំង ដើម្បីបំពេញសេចក្តីត្រូវការនៅក្នុងស្រុក។ តួយ៉ាងដូចជាវិស័យកាត់ដេរ និងសំណង់អាគារផ្សេងៗគឺ មានតម្រូវការនាំចូលវត្ថុធាតុដើមពីក្រៅប្រទេសដើម្បីផ្គត់ផ្គង់ចង្វាក់ផលិតកម្ម និងសំណង់នៅក្នុងស្រុក។ ដោយឡែកចំពោះ ទីផ្សារក្រៅប្រទេសវិញ គឺពឹងផ្អែកទៅលើចរន្តសេដ្ឋកិច្ចសកល ទំហំកូតាដែលបានផ្តល់ឲ្យប្រទេសកម្ពុជា និងការបញ្ជាទិញផ្សេងៗ ដោយក្នុងនោះ សហរដ្ឋអាមេរិក ប្រទេសចិន និងប្រទេសជប៉ុនគឺជាទីផ្សារធំសម្រាប់ការបញ្ជារទិញ និងធ្វើការដឹកជញ្ជូនតាមចំណតផែកុងតឺន័រ របស់ ក.ស.ភ.។

ជាមួយគ្នានេះដែល ផ្អែកតាមរបាយការណ៍នាយកដ្ឋានផែនការ/ទីផ្សារ បរិមាណកុងតឺន័រឆ្លងកាត់ ក.ស.ភ. នៅក្នុងឆ្នាំ២០១៧នេះបានកើនឡើង ២២% បើធៀបទៅនឹងឆ្នាំ២០១៦។ កំណើនខ្ពស់នៅក្នុងឆ្នាំ២០១៧ អាស្រ័យដោយការនាំចូលគ្រឿងសំណង់រហូតដល់៥២% និងគ្រឿងវាយនភ័ណ្ឌកាត់ដេរ២០% បើធៀបទៅ នឹងបរិមាណទំនិញនាំចូលសរុបតាមរយៈចំណតផែកុងតឺន័ររបស់ ក.ស.ភ. ក្នុងឆ្នាំ២០១៧ ប៉ុន្តែបើធៀបទៅនឹងឆ្នាំ២០១៦ ការនាំចូលគ្រឿងសំណង់កើនឡើង៣០% ផ្ទុយទៅវិញការនាំចូលគ្រឿងវាយនភ័ណ្ឌមានការធ្លាក់ចុះ៩%។ ដោយឡែកចំពោះការនាំចេញតាមចំណតផែកុងតឺន័ររបស់ ក.ស.ភ. វិញ គឺការនាំចេញវាយនភ័ណ្ឌមាន៨៣% និងអង្ករ១១% ក្នុងឆ្នាំ២០១៧ បើធៀបទៅនឹងឆ្នាំ២០១៦ ការនាំ

ចេញវាយនភ័ណ្ឌកើនឡើង១៩% និងអង្ករកើនឡើង៣០% នេះបើយោងតាមក្រាហ្វិកលេខ២ លេខ៣ លេខ៤ និងលេខ៥ របស់នាយកដ្ឋានផែនការ/ទីផ្សារ។

ក្រាហ្វិកលេខ១




*(ប្រភព៖ របាយការណ៍ប្រចាំ ឆ្នាំ ២០១៧ របស់នាយកដ្ឋានផែនការ/ទីផ្សារ ក.ស.ភ.)*

ក្រាហ្វិកលេខ២




ក្រាហ្វិកលេខ៣




*(ប្រភព៖ របាយការណ៍ប្រចាំ ឆ្នាំ ២០១៧ របស់នាយកដ្ឋានផែនការ/ទីផ្សារ ក.ស.ភ.)*

ក្រាហ្វិកលេខ៤

## បរិមាណទំនិញនាំចូលតាមច្រក ក.ស.ន. ឆ្នាំ២០១៦ និងឆ្នាំ២០១៧ (ពីអ៊ីយូ)




| | គ្រឿងសំណង់ | ម្ហូបអាហារ និងភេសជ្ជៈ | គ្រឿងវាយនភ័ណ្ឌ | បរិក្ខារក្នុងផ្ទះ | គ្រឿងម៉ាស៊ីន | ថ្នាំពេទ្យ | ផលិតផលផ្សេងៗ |
|---|---|---|---|---|---|---|---|
| ២០១៦ | ២២៨២៩ | ៤៣២៩ | ១១៦២០ | ៣៤៥៤ | ១២៩២ | ១៥០៥ | ៤១៨១ |
| ២០១៧ | ២៩៦២៨ | ៤២៣៩ | ១១០៩៩ | ៣៤២៤ | ១២០៤ | ១៥៧០ | ១៥៣៦១ |
| អត្រាប្រែប្រួលជាភាគរយ | ៣០% | -២% | -៤% | -១% | -៧% | ៤% | ៣៧% |

*(ប្រភព៖ របាយការណ៍ប្រចាំ ឆ្នាំ ២០១៧ របស់នាយកដ្ឋានផែនការ/ទីផ្សារ ក.ស.ភ.)*

ក្រាហ្វិកលេខ៥

## បរិមាណទំនិញនាំចេញតាមច្រក ក.ស.ន. ឆ្នាំ២០១៦ និងឆ្នាំ២០១៧ (ពីអ៊ីយូ)




| | ម្ហូបអាហារ និងភេសជ្ជៈ | គ្រឿងវាយនភ័ណ្ឌ | អង្ករ | ផ្សេងៗ |
|---|---|---|---|---|
| ២០១៦ | ១៣៩៨ | ៥៥៨៣៧ | ៦៥១៥ | ២៣៣១ |
| ២០១៧ | ១៦២០ | ៦៦៤៧៥ | ៨៤៥០ | ៣៥៩៨ |
| អត្រាប្រែប្រួលជាភាគរយ | ១៦% | ១៩% | ៣០% | ៥៤% |

ក្រាហ្វិកលេខ២៦

**ចំណែកទីផ្សារនាំចូលទំនិញតាមចក្រ ក.ស.ឧ. ឆ្នាំ២០១៦ និង២០១៧ (ធីអ៊ីយូ)**




| | ប្រទេសចិន | ប្រទេសវៀតណាម | ប្រទេសម៉ាឡេស៊ី | ប្រទេសជប៉ុន | សហគមអ៊ឺរ៉ុប | សហរដ្ឋអាមេរិក | ប្រទេសផ្សេងៗ |
|---|---|---|---|---|---|---|---|
| ២០១៦ | ៦៦% | ១៤% | ៤% | ២% | ៤% | ១% | ៨% |
| ២០១៧ | ៧០% | ៩% | ៣% | ២% | ៤% | ៣% | ៩% |
| អត្រាប្រែប្រួលជាភាគរយ | ២២% | -២៣% | -១៧% | -១៥% | ២៤% | ២៥៣% | ២៧% |

ក្រាហ្វិកលេខ២៧

**ចំណែកទីផ្សារនាំចេញទំនិញតាមចក្រ ក.ស.ឧ. ឆ្នាំ២០១៦ និង២០១៧ (ធីអ៊ីយូ)**




| | ប្រទេសចិន | ប្រទេសវៀតណាម | ប្រទេសម៉ាឡេស៊ី | ប្រទេសជប៉ុន | សហគមអ៊ឺរ៉ុប | សហរដ្ឋអាមេរិក | ប្រទេសផ្សេងៗ |
|---|---|---|---|---|---|---|---|
| ២០១៦ | ១៤% | ៦% | ១% | ១៧% | ៧% | ៥១% | ៣% |
| ២០១៧ | ១៨% | ៥% | ១% | ១៥% | ៥% | ៥៣% | ៣% |
| អត្រាប្រែប្រួលជាភាគរយ | ៥១% | ១% | ៩% | ៤% | -១៥% | ២៦% | ២៨% |

*(ប្រភព៖ របាយការណ៍ប្រចាំ ឆ្នាំ ២០១៧ របស់នាយកដ្ឋានផែនការ/ទីផ្សារ ក.ស.ភ.)*

យោងតាមក្រាហ្វិកលេខ២៦ និងលេខ២៧ ប្រទេសដែលផ្គត់ផ្គង់ទំនិញ និងវត្ថុធាតុដើមសម្រាប់ផ្គត់ផ្គង់តម្រូវការរបស់ប្រជាជន និងចង្វាក់ផលិតកម្មក្នុងប្រទេសដោយការនាំចូលតាមចំណតផែកុងតឺន័រ របស់ ក.ស.ភ. នោះ គឺការនាំចូលពីប្រទេសចិនមាន៧០% និងប្រទេសវៀតណាមមាន៩% នេះបើធៀបទៅនឹងការនាំចូលពីបណ្ដាលប្រទេសផ្សេងៗនៅក្នុងឆ្នាំ២០១៧ ប៉ុន្តែបើធៀបទៅនឹងឆ្នាំ២០១៦ គឺការនាំចូលពីប្រទេសចិនកើន២២% ដោយឡែកការនាំចូលពីប្រទេសវៀតណាមធ្លាក់ចុះ២៣%។ ចំណែកទីផ្សារនៃការនាំចេញវិញ គឺការនាំចេញទៅកាន់សហរដ្ឋអាមេរិកមាន៥៣% ប្រទេសចិនមាន១៨% និងប្រទេសជប៉ុនមាន១៥% បើធៀបទៅនឹងការនាំចេញទៅកាន់បណ្ដាលប្រទេសផ្សេងៗនៅក្នុងឆ្នាំ២០១៧ ប៉ុន្តែបើធៀប

ទៅនឹងឆ្នាំ២០១៦ ការនាំចេញទៅកាន់សហរដ្ឋអាមេរិកកើនឡើង២៦% ប្រទេសចិនកើនឡើង៥១% និងប្រទេសជប៉ុនកើនឡើង៤%។

ជារួមអត្រាកំណើនកុងតឺន័រឆ្លងកាត់ ក.ស.ភ. នៅក្នុងឆ្នាំ២០១៧ នេះ គឺផ្អែកលើហេតុផលដូចខាងក្រោម:

- អត្រាកំណើនរបស់ប្រជាជនរបស់ប្រទេសក្នុងរង្វង់១,៦%ក្នុងមួយឆ្នាំ និងស្របជាមួយអត្រាកំណើនសេដ្ឋកិច្ច GDPនៅតែរក្សាបន្តកំណើន ៧%ក្នុងមួយឆ្នាំ ដូចនេះអត្រាកំណើនទាំងនេះគឺជាប្រភពនៃកំណើនតម្រូវការ និងលទ្ធភាពក្នុងការទិញទំនិញនៅលើទីផ្សារ។ ប៉ុន្តែដោយសារប្រទេសកម្ពុជា នៅពុំទាន់មានផលិតកម្មគ្រប់គ្រាន់ ដើម្បីផ្គត់ផ្គង់តម្រូវការក្នុងស្រុក ដូចនេះប្រទេសកម្ពុជាត្រូវធ្វើការបញ្ជារទិញទំនិញពីក្រៅប្រទេសដើម្បីបំពេញតម្រូវការក្នុងស្រុក។ តួយ៉ាងនៅក្នុងឆ្នាំ២០១៧នេះ ទំនិញជាម្ហូបអាហារ និងភេសជ្ជៈមាន៧% បរិក្ខាក្នុងផ្ទះ៦% និងថ្នាំពេទ្យ៣% ត្រូវបាននាំចូលតាមចំណតផែកុងតឺន័ររបស់ ក.ស.ភ. បើធៀបទៅនឹងការនាំចូលសរុបសម្រាប់ឆ្នាំ២០១៧
- អត្រាកំណើននៃវិស័យអចលនទ្រព្យ គេហដ្ឋាន និងសំណង់អាគារផ្សេងៗនៅក្នុងប្រទេសកម្ពុជា បានជម្រុញឲ្យប្រទេសកម្ពុជាត្រូវធ្វើការនាំចូលនូវគ្រឿងសំណង់ជាច្រើនដើម្បីផ្គត់ផ្គង់នូវកំណើនអចលនទ្រព្យខាងលើ ដោយក្នុងនោះការនាំចូលគ្រឿងសំណង់តាមចំណតផែកុងតឺន័រ របស់ ក.ស.ភ. មាន៥២% បើធៀបទៅនឹងការនាំចូលសរុបក្នុងឆ្នាំ២០១៧ ប៉ុន្តែបើធៀបទៅនឹងឆ្នាំ២០១៦ កើនឡើង៣០%។
- ការបញ្ជារទិញទំនិញជាវាយនភ័ណ្ឌពីសហរដ្ឋអាមេរិកបានកើនឡើងជាគំហុកនៅក្នុងឆ្នាំ២០១៧ ដោយក្នុងនោះការនាំចេញតាមចំណតផែកុងតឺន័ររបស់ ក.ស.ភ. មាន៥៣% ក្នុងចំណោមការនាំចេញសរុបក្នុងឆ្នាំ២០១៧ ប៉ុន្តែបើធៀបទៅនឹងឆ្នាំ២០១៦ ការនាំចេញនេះកើនឡើង២៦%។ នៅពេលដែលអត្រាកំណើន នៃការនាំចេញទំនិញជាវាយនភ័ណ្ឌមានការកើនឡើង ដូចនេះការនាំចូលវត្ថុធាតុដើមជា វាយណភ័ណ្ឌជាស្វ័យប្រវត្តក៏ត្រូវតែមានការកើនឡើងដែល ដោយក្នុងនោះការនាំចូលពី ប្រទេសចិនតាមចំណតផែកុងតឺន័រ របស់ ក.ស.ភ. មាន៧០%បើធៀបទៅនឹងការនាំចូលពីបណ្តាលប្រទេសផ្សេងៗទៀតនៅក្នុងឆ្នាំ២០១៧ ប៉ុន្តែបើធៀបទៅនឹងឆ្នាំ២០១៦មានការកើនឡើង២២%។
- តាមរយៈទំនាក់ទំនងល្អក្នុងន័យពាណិជ្ជកម្ម សេដ្ឋកិច្ច និងនយោបាយ រវាយប្រទេសចិន និងប្រទេសកម្ពុជា និងដោយកំណើនសេដ្ឋកិច្ចរបស់ប្រទេសចិននៅតែរក្សារកំណើន៦,៩% នៅក្នុងឆ្នាំ២០១៧ នេះយោងតាមគេហទំព័រhttps://en.wikipedia.org/wiki/Economy_of_China អាស្រ័យដូចនេះការបញ្ជារទិញទំនិញពីប្រទេសចិន និងធ្វើការដឹកជញ្ជូនតាមចំណតផែកុងតឺន័រ របស់ ក.ស.ភ. មាន១៨% បើធៀបទៅនឹង ការនាំចេញទៅកាន់ទីផ្សារក្រៅប្រទេសសរុបក្នុងឆ្នាំ២០១៧ ប៉ុន្តែបើធៀបទៅនឹងឆ្នាំ២០១៦មានការកើនឡើង៥១%។

ដោយឡែកចំពោះអត្រាកំណើនសេដ្ឋកិច្ចរបស់ប្រទេសជប៉ុនវិញគឺមានកំណើន១,៦%នេះ បើយោងតាមគេហទំព័រ https://en.wikipedia.org/wiki/Economy_of_Japan តាមរយៈកំណើននេះ ជប៉ុនបានធ្វើការបញ្ជាទិញទំនិញពីប្រទេសកម្ពុជា និងធ្វើការដឹកជញ្ជូនទំនិញនាំចេញតាម ចំណតផែកុងតឺន័ររបស់ ក.ស.ភ. មាន១៥% ក្នុងចំណោមទីផ្សារក្រៅប្រទេសដែលនាំចេញសរុបក្នុងឆ្នាំ២០១៧ ប៉ុន្តែបើធៀបទៅនឹងឆ្នាំ២០១៦ គឺមានការកើនឡើង៤%។

តាមរយៈក្រាហ្វិកខាងលើ ស្ថានភាពទីផ្សាររបស់ ក. ស. ភ. សម្រាប់ ឆ្នាំ២០១៧នេះ គឺមានការកើនឡើងគួរឲ្យកត់សម្គាល់ ដោយក្នុងនោះបរិមាណកុងតឺន័រឆ្លងកាត់ ក.ស.ភ. បានកើនឡើងរហូតដល់ ២២% បើធៀបទៅនឹងឆ្នាំ២០១៦។ តាមរយៈកំណើននេះពិតជាបានបង្ហាញឲ្យឃើញថា ស្ថានភាពទីផ្សាររបស់ ក.ស.ភ. នៅតែបានដើរតួនាទីយ៉ាងសំខាន់ និងជាច្រកទ្វារសម្រាប់ការដឹកជញ្ជូនទំនិញឆ្លងកាត់ដែលពុំអាចខ្វះបាន។

## ៤- ស្ថានភាពប្រកួតប្រជែង

ក.ស.ភ. គឺជាចំណតផែអន្តរជាតិតាមដងទន្លេតែមួយគត់ក្នុងការផ្តល់សេវាកម្មចំណតនាវា និងសេវាកម្មលើកដាក់ទំនិញជាកុងតឺន័រ និងទំនិញទូទៅជូនអតិថិជន។ បរិមាណកុងតឺន័រឆ្លងកាត់ ក.ស.ភ. ក្នុងឆ្នាំ២០១៧នេះមានអត្រាកំណើន២២%បើធៀបទៅនឹងឆ្នាំ២០១៦។ ប្រសិនបើពិនិត្យទៅលើស្ថានភាពដៃគូប្រគួតប្រជែងវិញ កំពង់ផែស្វយ័តភ្នំពេញ នៅតែដើរតួនាទីសំខាន់ និងរឹងមាំបំផុតក្នុងវិស័យកំពង់ផែដែលជាច្រកសំខាន់សម្រាប់ការដឹកជញ្ជូនទំនិញឆ្លងកាត់នៅតាមដងទន្លេ។ ខាងក្រោមនេះគឺជាកត្តាបង្ហាញឲ្យឃើញពីឧត្តមភាពប្រកួតប្រជែងរបស់ ក.ស.ភ. លើការផ្តល់សេវាកម្មកំពង់ផែ៖

### ៤.១. ទីតាំងភូមិសាស្ត្រ

ក. ស. ភ. ស្ថិតនៅទីតាំងភូមិសាស្ត្រប្រកបដោយសក្តានុពល និងយុទ្ធសាស្ត្រ ដោយនៅចំបេះដូងនៃរាជធានីភ្នំពេញដែលជាមជ្ឈមណ្ឌលពាណិជ្ជកម្ម ឧស្សាហកម្ម រោងចក្រ អ្នកប្រើប្រាស់ និងជាកន្លែងប្រមូលផ្តុំទៅដោយកម្លាំងពលកម្ម។ ការដឹកជញ្ជូនតាម ក. ស. ភ. ផ្តល់ភាពងាយស្រួល រហ័ស និងចំណាយតិច ក្នុងការចែកចាយ និងផ្គត់ផ្គង់ទំនិញដល់អ្នកប្រើប្រាស់។ ជាមួយគ្នានេះដែរ ទីតាំងរបស់ ក. ស. ភ. គឺនៅជិត និងមាន រយៈចំងាយនៃការដឹកជញ្ជូនជិតជាងចំណតផែដទៃទៀត នៅក្នុងប្រទេសកម្ពុជា ដូចជាការដឹកជញ្ជូនទំនិញឆ្លងកាត់ទៅកាន់ប្រទេសវៀតណាម ប្រទេសចិន ប្រទេសជប៉ុន និងសហរដ្ឋអាមេរិកជាដើម។ ដែលប្រទេសទាំង៤នេះគឺមានទំហំពាណិជ្ជកម្មធំ ជាមួយប្រទេសកម្ពុជាបើធៀបទៅនឹងប្រទេសដទៃទៀត។

### ៤.២. សេវាកម្ម

ក. ស. ភ. នៅតែរក្សាបាននូវគោលការណ៍របស់ ក. ស. ភ. ដោយផ្តោតទៅលើ គុណភាពល្អ សុវត្ថិភាព សេវាកម្មរហ័ស២៤ម៉ោង និងតម្លៃមានភាពប្រកួតប្រជែងជូនដល់អតិថិជន។

### ៤.៣. តម្លៃសេវាកម្ម

ក. ស. ភ. នឹងផ្តល់នូវតម្លៃដែលមានលក្ខណៈប្រកួតប្រជែង និងបន្តរក្សារផ្តល់ជូនតម្លៃអនុគ្រោះដល់អតិថិជនទៅលើសេវាកម្មលើកដាក់កុងតឺន័រ និងសេវាកម្មចំណតនាវា។ បើក្រុមហ៊ុនដឹកជញ្ជូនកុងតឺន័របានកាន់តែច្រើន នោះការគិតថ្លៃលើកដាក់នឹងទទួលបានការលើកទឹកចិត្តក្នុងការបញ្ចុះតម្លៃ។

ជាមួយគ្នានេះដែល ក. ស. ភ. នៅតែរក្សារផ្តល់តម្លៃដែលមានភាព បទបែនដល់អតិថិជនដែលបានទទួលសេវាកម្មពីក.ស.ភ.។ យុទ្ធសាស្ត្រតម្លៃដែលមានភាពបទបែងនេះហើយ ជាចំនុចខ្លាំងរបស់ ក. ស. ភ. ក្នុងការទាក់ទាញអតិថិជន។

ក. ស. ភ. បានផ្តល់តម្លៃអនុគ្រោះដល់សេវាកម្មលើកដាក់ និងការរក្សារទុកកុងតឺន័រដែលផ្ទុកទំនិញ ប្រភេទជាផលិផលកសិកម្ម ។ ជាពិសេស ក. ស. ភ. បានផ្តល់តម្លៃអនុគ្រោះមិនគិតថ្លៃចំពោះថ្លៃច្រកទ្វារថយន្តដែលដឹកជញ្ជូនកុងតឺន័រផ្ទុកទំនិញជាអង្ករឆ្លងកាត់ ក. ស. ភ.។

លើសពីនេះ ក. ស. ភ. នៅតែបន្តផ្តល់សេវាកម្មប្រតិបត្តិការផែ ២៤ម៉ោង/៧ថ្ងៃ ដោយពុំគិតកម្រៃសេវាបន្ថែមម៉ោងនោះទេ។

### ៤.៥. ការផ្សព្វផ្សាយរបស់ ក. ស. ភ.

ក. ស. ភ. នៅតែរក្សារបន្តការផ្សព្វផ្សាយ និងប្រើប្រាស់មធ្យោបាយផ្សេងៗដើម្បីផ្តល់ព័ត៌មានដល់អតិថិជនឱ្យបានគ្រប់គ្រាន់ និងស្គាល់កាត់តែច្បាស់អំពី ក. ស. ភ. ដើម្បីងាយស្រួលដល់ការសម្រេចចិត្តក្នុងការប្រើប្រាស់សេវាកម្មរបស់ ក. ស. ភ.។ ជាក់ស្តែង អតិថិជន អាចទទួលនូវព័ត៌មានសេវាកម្មរបស់ ក. ស. ភ. តាមរយៈមធ្យោបាយផ្តល់ព័ត៌មានជាច្រើន រួមមានៈ

- ទី១. ការចុះផ្សាយព័ត៌មាន តាមគេហទំព័រ ប្រតិទិន នាមប័ណ្ណ ខិតប័ណ្ណ វត្ថុអនុស្សាវរីយ៍ និងសៀវភៅព័ត៌មានពាណិជ្ជកម្ម (របស់សភាពាណិជ្ជកម្មកម្ពុជា)
- ទី២. ការផ្សព្វផ្សាយព័ត៌មាន នៅតាមសិក្ខាសាលា ក្នុងវគ្គបណ្តុះបណ្តាល និងការប្រជុំផ្សេងៗ
- ទី៣. តាមរយៈការផ្សព្វផ្សាយព័ត៌មានសាជីវកម្មរបស់ ក. ស. ភ. តាមរយៈផ្សារមូលបត្រកម្ពុជា
- ទី៤. យុទ្ធសាស្ត្រចុះផ្សព្វផ្សាយដោយផ្ទាល់ជាមួយអតិថិជនជាក្រុមហ៊ុនដឹកជញ្ជូននានា
- ទី៥. ការផ្លាស់ប្តូរបច្ចុប្បន្នភាពនូវព័ត៌មានសេវាកម្ម និងគម្រោងអភិវឌ្ឍន៍ផែ នៅក្នុងក្របខណ្ឌនៃការប្រជុំរបស់សមាគមកំពង់ផែអាស៊ាន (APA) រវាងសមាជិកកំពង់ផែអាស៊ាន។

មធ្យោបាយផ្សព្វផ្សាយទាំងនេះ ជាប្រភពព័ត៌មានគ្រប់ជ្រុងជ្រោយ ដែលជួយឱ្យអតិថិជនបានស្គាល់ និងទាក់ទាញការប្រើប្រាស់សេវាកម្មរបស់ ក. ស. ភ. នៅលើទីផ្សារ។

**៤.៦.** ការដាក់ចេញនូវវិធានការរបស់រាជរដ្ឋាភិបាលដើម្បីពង្រឹងលើការត្រួតពិនិត្យលើមធ្យោបាយដឹកជញ្ជូនលើសទម្ងន់នៅតាមផ្លូវគោក។ ការចាត់វិធានការនេះ ជាឱកាសមួយដែលបានជម្រុញឲ្យមានកំណើននៃការដឹកជញ្ជូនតាមផ្លូវទឹកព្រោះថា ការដឹកជញ្ជូនតាមផ្លូវគោក អតិថិជនត្រូវចំណាយច្រើន និងដឹកជញ្ជូនបានចំនួនតិច ជាពិសេស គ្រោះថ្នាក់ចរាចរតាមដងផ្លូវដែលអាចជម្រុញ ឲ្យអតិថិជនចំណាយថ្លៃដឹកជញ្ជូនកាន់តែច្រើន ខណៈពេលដែលការដឹកជញ្ជូនតាមផ្លូវទឹក នឹងផ្តល់ផលចំណេញច្រើនដល់អតិថិជន ដូចជាការ

ដឹកជញ្ជូនបានបរិមាណច្រើន ចំណាយថ្លៃដើមតិច និងពុំប៉ះពាល់ខ្លាំងដល់បរិដ្ឋានដូចការដឹកជញ្ជូនតាមផ្លូវគោកឡើយ។

ដូចនេះ ស្ថានភាពប្រកួតប្រជែងរបស់ ក. ស. ភ. សម្រាប់ ឆ្នាំ២០១៧នេះ នៅតែមានភាពរឹងមាំ ទាក់ទាញ និងឈានទៅមុខជានិច្ច ដើម្បីទាក់ទាញអតិថិជនឲ្យនៅតែបន្តប្រើប្រាស់សេវាកម្មរបស់ ក. ស. ភ.។

## ៥-ផែនការអនាគតសម្រាប់ឆ្នាំ ២០១៨

ខាងក្រោម គឺជាគម្រោងអនាគតដែលមានតម្លៃវិនិយោគលើសពី ១០០.០០០ ដុល្លារអាមេរិក ដែលនឹងត្រូវវិនិយោគក្នុងរយៈពេល ១ឆ្នាំ ទៅ ៥ឆ្នាំខាងមុខ។

*ក. គម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផែដំណាក់កាលទី២ របស់ចំណតផែកុងតឺន័រ LM១៧*

| ឈ្មោះ | គម្រោងនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផែដំណាក់កាលទី២ |
|---|---|
| **បរិយាយ** | ចន្លោះពី ឆ្នាំ២០១២ ដល់ ឆ្នាំ២០១៧ ចំនួនកុងតឺន័រដែលឆ្លងកាត់ជាមធ្យមកើនឡើងប្រហែល ១២,៥០% រៀងរាល់ឆ្នាំ។ ដោយសារតែ កុងតឺន័រដែលឆ្លងកាត់បច្ចុប្បន្ននៅ LM១៧ មានចំនួន ១៨៤.៨០៥TEUs ក្នុងឆ្នាំ២០១៧ ក.ស.ភ. ព្យាករណ៍ថាចំនួនកុងតឺន័រនឹងបន្តកើនឡើងដល់ ២០០.០០០TEUs ក្នុងឆ្នាំ២០១៨។ ដើម្បីទទួលបានកំណើននេះ ក.ស.ភ. ត្រូវធ្វើការពង្រីកបបនីយភណ្ឌផែ និងបរិក្ខារបន្ថែមទៀត |
| **ជំហានទី១ នៃដំណាក់កាលទី២ ពីឆ្នាំ (២០១៦-២០១៨)** | |
| **គោលបំណង** | ធានាសមត្ថភាពលើកដាក់របស់ផែក្នុងការទទួលកំណើនកុងតឺន័រឆ្លងកាត់ជារៀងរាល់ឆ្នាំ |
| **លទ្ធផលរំពឹងទុក** | បង្កើនសមត្ថភាពលើកដាក់របស់ចំណតផែកុងតឺន័រLM១៧ ដល់កម្រិត ៣០០.០០០TEUs ក្នុងមួយឆ្នាំ |
| **ទីតាំងគម្រោង** | ភាគខាងកើតចំណតផែកុងតឺន័រ LM១៧ |
| **ទំហំនៃគម្រោង** | ៥ ហិកតា |
| **ភ្នាក់ងារអនុវត្តគម្រោង** | កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.) |
| **ថវិកាត្រូវចំណាយ** | - ពង្រីកទីលានកុងតឺន័រ បរិមាត្រផ្ទៃសរុប (១៧.៨៥០ ម៉ែត្រការ៉េ) ដោយចាក់ថ្មម៉ិចៈ ៤៩៩.៨០០ ដុល្លារអាមេរិក<br>- សាងសង់ផ្លូវសម្រាប់រថស្ទូច RTG ចំនួន ៤ ខ្សែ (ប្រវែង ៥៤៤ ម៉ែត្រ)៖ ៨៦៩.១៣០ដុល្លារអាមេរិក<br>- សាងសង់ផ្លូវសម្រាប់រថយន្តកុងតឺន័រ ចំនួន ២ ខ្សែ (ប្រវែង ២៧២ម៉ែត្រ)៖ ៣៤៤.៣៩០ ដុល្លារអាមេរិក<br>- បំពាក់រថស្ទូច RTG ចំនួន ៤ គ្រឿង៖ ៥.៨០០.០០០ ដុល្លារអាមេរិក<br>- សាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹក និងអគ្គិសនី៖ ៧៥៤.០០០ ដុល្លារអាមេរិក<br>- សាងសង់ទំនប់ (៣០០ម x ៣១ម)៖ ១.៧៤៨.៨៥៨ ដុល្លារអាមេរិក<br>- សាងសង់របង (៧៥០ ម)៖ ៧៩.៨២៨ ដុល្លារអាមេរិក |

| ឈ្មោះ | គម្រោងនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផែដំណាក់កាលទី២ |
|---|---|
| ប្រភពហិរញ្ញវត្ថុ | - មូលធនទទួលបានពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង<br>- មូលនិធិបម្រុងរបស់ ក.ស.ភ. |
| រយៈពេលអនុវត្តគម្រោង | ២០១៦-២០១៨ |
| កម្មសិទ្ធិដី | កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.) |
| បញ្ហាសង្គម | ការអនុវត្តគម្រោងដំណាក់កាលទី២នៃចំណតផែកុងតឺន័រLM១៧ នឹងបង្កើតការងារបន្ថែម តាមរយៈការជ្រើសរើសបុគ្គលិកបន្ថែម |
| បញ្ហាបរិស្ថាន | គ្មានការបង្ហាញណាមួយដែលបញ្ជាក់ថាអាចមានផលប៉ះពាល់ដល់ផ្នែកបរិស្ថានឡើយ |
| សកម្មភាព តាមដាន | បង្កើតក្រុមការងារដើម្បីតាមដានការអនុវត្តគម្រោង |
| ការអនុវត្តក្នុងឆ្នាំ២០១៧គិតត្រឹមថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៧ | ក្រុមហ៊ុនសៀង ហៃ គ្រុប ចាប់ផ្ដើមរៀបការដ្ឋានសាងសង់ និងទំលាក់ឌីណាម៉ិចបង្ហាប់ទីលាន |



# ផ្នែកទី២

# ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ១. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែកសម្រាប់ ឆ្នាំ២០១៧

### ១.១. តារាងស្ថិតិបរិមាណទំនិញ និងនាវាឆ្លងកាត់ ក.ស.ក.

| ល.រ | បរិយាយ | ឯកតា | ផែនការ ឆ្នាំ២០១៧ | អនុវត្ត ឆ្នាំ២០១៧ | អនុវត្ត ឆ្នាំ២០១៦ | អនុវត្ត ឆ្នាំ ២០១៥ | ប្រៀបធៀប (%) | កើន/ថយ (%) | |
|---|---|---|---|---|---|---|---|---|---|
| ក | ខ | គ | ១ | ២ | ៣ | ៤ | ៥=(២/១) | ៦=(២/៣)-១០០% | ៧=(៣/៤)-១០០% |
| I | **បរិមាណទំនិញ និង ប្រេងឥន្ធនៈឆ្លងកាត់** | តោន | ២.៤៥០.០០០ | ២.៧៥៧.៦៦១ | ២.៤០៩.៦៣២ | ២.១៦១.៣៥១ | ១១៣% | +១៤% | +១១% |
| | ក. បរិមាណទំនិញឆ្លងកាត់ | - | ១.៣៩០.០០០ | ១.៥៩១.៥២៥ | ១.២៧០.៨១៦ | ១.១៩៦.៨២៧ | ១១១% | +២១% | +៦% |
| | - ទំនិញនាំចូល | - | ៩៣០.០០០ | ៩៨៦.៧៨៧ | ៨៣៣.៨២៧ | ៧៧៨.៩៥៧ | | | |
| | - ទំនិញនាំចេញ | - | ៤៦០.០០០ | ៥៥៩.៧៣៨ | ៤៣៦.៥៨៩ | ៤១៧.៨៧១ | | | |
| | ខ. បរិមាណទំនិញលើកដាក់ចល័ត | - | ៣៦០.០០០ | ៥០២.១៩៥ | ៤៤៨.៣៨៩ | ២៩៩.០៣០ | ១៣៩% | +១២% | +៥០% |
| | - ទំនិញលើកដាក់ក្នុងផែ | - | ៦០.០០០ | ២១.១៩០ | ៦៥.១២៣ | ១៥.០៣១ | | | |
| | - ទំនិញលើកដាក់ក្រៅផែ | - | ៣០០.០០០ | ៤៨១.០០៥ | ៣៨៣.២៦៦ | ២៨៣.៩៩៩ | | | |
| | គ.បរិមាណប្រេងឥន្ធនៈ និងហ្គាសឆ្លងកាត់ | - | ៧០០.០០០ | ៧១៣.៩៤១ | ៦៩០.៨២៧ | ៦៦៥.៨៩៣ | ១០២% | +៣% | +៤% |
| | **បរិមាណកុងតឺន័រឆ្លងកាត់** | TEU | ១៦១.០០០ | ១៨៤.៨០៥ | ១៥១.៧៨១ | ១៤៤.៨១៣ | ១១៥% | +២២% | +៥% |
| | -មានទំនិញ | - | ១១៩.០០០ | ១៣៦.៩៨៤ | ១១៥.២៧៩ | ១០៤.៥០៧ | | | |
| | -គ្មានទំនិញ | - | ៤២.០០០ | ៤៧.៨២១ | ៣៦.៥០២ | ៤០.៣០៦ | | | |
| II | **បរិមាណទំនិញលើកដាក់** | តោន | ១.៧៥០.០០០ | ២.០៩៣.៧២០ | ១.៧១៨.៨០៥ | ១.៤៩៥.៨៥៨ | ១១៧% | +១៩% | +១៥% |
| | -ប្រគល់ផ្ទាល់ | - | ៣៦០.០០០ | ៥០២.១៩៥ | ៤៤៨.៣៨៩ | ២៩៩.០៣០ | | | |
| | -ឆ្លងកាត់ឃ្លាំង - ទីលាន | - | ១.៣៩០.០០០ | ១.៥៩១.៥២៥ | ១.២៧០.៨១៦ | ១.១៩៦.៨២៧ | | | |
| III | **បរិមាណនាវាសរុប** | គ្រឿង | ១.៧១៥ | ១.៦៧៦ | ១.៦៧៩ | ១.៥៩៦ | ៩៨% | +០,១៨% | +៥% |
| | -នាវា-សាឡង់បណ្តាប្រទេសផ្សេងៗ | - | ១.១៥០ | ១.០៨៣ | ១.០៧៥ | ៩៩០ | | | |
| | -នាវា-សាឡង់កម្ពុជា | - | ៩៥ | ៧១ | ១០២ | ១០១ | | | |

| ល.រ | បរិយាយ | ឯកតា | ផែនការ ឆ្នាំ២០១៧ | អនុវត្ត ឆ្នាំ២០១៧ | អនុវត្ត ឆ្នាំ២០១៦ | អនុវត្ត ឆ្នាំ ២០១៥ | ប្រៀបធៀប (%) | កើន/ថយ (%) | |
|---|---|---|---|---|---|---|---|---|---|
| ក | ខ | គ | ១ | ២ | ៣ | ៤ | ៥=(២/១) | ៦=(២/៣)-១០០% | ៧=(៣/៤)-១០០% |
| | -នាវា-សាឡង់ប្រេងឥន្ធនៈ | - | ៤៧០ | ៥២២ | ៥០២ | ៥០៥ | | | |
| IV | **បរិមាណនាវាអ្នកដំណើរទេសចរក្នុងស្រុក (ចេញ-ចូល)** | ជើង | **១.៩៨០** | **២.៧០៦** | **២.០៩៦** | **៣.២០៧** | **១៣៧%** | **+២៩%** | **-៣៥%** |
| | - ភ្នំពេញ-សៀមរាប សៀមរាប-ភ្នំពេញ | - | ៨០ | ២៣៦ | ៧២ | ២៨៧ | | | |
| | - នាវាទេសចរណ៍ក្នុងក្រុង | - | ១.៩០០ | ២.៤៧០ | ២.០២៤ | ២.៩២០ | | | |
| V | **បរិមាណអ្នកដំណើរ និងទេសចរក្នុងស្រុក (ចេញ-ចូល)** | នាក់ | **១០.៩០០** | **១៣.៨៨០** | **៩.៩០៤** | **២២.១៨១** | **១២៧%** | **+៤០%** | **-៥៥%** |
| | - ភ្នំពេញ-សៀមរាប សៀមរាប-ភ្នំពេញ | - | ៣.៩០០ | ៥.៦៧៨ | ៣.៧០១ | ១១.០០៦ | | | |
| | - ទេសចរណ៍ក្នុងក្រុង | - | ៧.០០០ | ៨.២០២ | ៦.២០៣ | ១១.១៧៥ | | | |
| VI | **បរិមាណនាវាអ្នកដំណើរបរទេស និងទេសចរឆ្លងកាត់ (វៀតណាម)** | ជើង | **១.៩០០** | **២.១២២** | **១.៥៩៤** | **២.៣៨៧** | **១៥២%** | **+៣៣%** | **-៣៣%** |
| | - ចំនួននាវាភ្នំពេញ-ចូវដុក-ភ្នំពេញ | - | ៨០០ | ១.៤៩៩ | ៩៩៧ | ១.៧៨៣ | | | |
| | - ចំនួននាវាទេសចរណ៍ | - | ៦០០ | ៦២៣ | ៥៩៧ | ៦០៤ | ១០៤% | +៤% | -១% |
| | **បរិមាណអ្នកដំណើរបរទេស និងទេសចរឆ្លងកាត់ (វៀតណាម)** | នាក់ | **២៥.៥០០** | **៣៣.១៣៣** | **២៩.៤១៦** | **៣៦.៧០៨** | **១៣០%** | **+១៣%** | **-២០%** |
| | - ចំនួននាវាភ្នំពេញ-ចូវដុក-ភ្នំពេញ | - | ៣.៥០០ | ៦.៤១៨ | ៤.១៧៤ | ១១.៦៧៥ | | | |
| | - ចំនួនភ្ញៀវទេសចរណ៍ | - | ២២.០០០ | ២៦.៧១៥ | ២៥.២៤២ | ២៥.០៣៣ | ១២១% | +៦% | +១% |

*)ប្រភព៖ នាយកដ្ឋានផែនការ/ទីផ្សារ ក.ស.ភ.(*

- បរិមាណទំនិញ-ប្រេងឥន្ធនៈឆ្លងកាត់ ក.ស.ភ. ក្នុងឆ្នាំ២០១៧ មានចំនួន ២.៧៥៧.៦៦១ តោន កើនឡើង ១៤% ធៀបនឹងការអនុវត្តក្នុងឆ្នាំ២០១៦ (២.៤០៩.៦៣២ តោន) សម្រាប់រយៈពេល១២ខែ ឆ្នាំ២០១៧ នេះ ក.ស.ភ. សម្រេចបាន ១១៣% ធៀបនឹងផែនការឆ្នាំ២០១៧ (២.៤៥០.០០០តោន)

- នាវាឆ្លងកាត់ ក.ស.ភ. ក្នុងឆ្នាំ២០១៧ មានចំនួន ១.៦៧៦គ្រឿង ថយចុះ ០,១៨% ធៀបនឹងការអនុវត្តក្នុងឆ្នាំ២០១៦ (១.៦៧៩គ្រឿង) សម្រាប់រយៈពេល១២ខែ ឆ្នាំ២០១៧ ក.ស.ភ. សម្រេចបាន ៩៨% ធៀបនឹងផែនការឆ្នាំ២០១៧ (១.៧១៥គ្រឿង)
- នាវាអ្នកដំណើរ និងទេសចរណ៍អន្តរជាតិក្នុងឆ្នាំ២០១៧ មានចំនួន ៦២៣ជើង កើនឡើង ៨% ធៀបនឹងការអនុវត្តក្នុងឆ្នាំ២០១៦ (៥៩៧ជើង) សម្រាប់រយៈពេល១២ខែ ឆ្នាំ២០១៧ នេះ ក.ស.ភ. សម្រេចបាន ១០៨% ធៀបនឹងផែនការឆ្នាំ២០១៧ (៦០០ជើង)
- បរិមាណកុងតឺន័រក្នុងឆ្នាំ២០១៧ មានចំនួន ១៨៤.៨០៥TEUs កើនឡើង ២២% ធៀបនឹងការអនុវត្តក្នុងឆ្នាំ២០១៦ (១៥១.៧៨១ TEUs) សម្រាប់រយៈពេល១២ខែ ឆ្នាំ២០១៧ នេះ ក.ស.ភ. សម្រេចបាន ១១៥% ធៀបនឹងផែនការឆ្នាំ២០១៧ (១៦១.០០០TEUs)
- បរិមាណអ្នកដំណើរ និងទេសចរឆ្លងកាត់ ក.ស.ភ. ក្នុងឆ្នាំ២០១៧ មានចំនួន ២៦.៧១៥នាក់ កើនឡើង ៦% ធៀបនឹងការអនុវត្តក្នុងឆ្នាំ២០១៦ (២៥.២៨២នាក់) សម្រាប់រយៈពេល១២ខែ ឆ្នាំ២០១៧ ក.ស.ភ. សម្រេចបាន ១២១% ធៀបនឹងផែនការឆ្នាំ២០១៧ (២២.០០០នាក់)។

# ក្រាហ្វិក ស្តីពីការប្រៀបធៀបការអនុវត្ត ឆ្នាំ២០១៧ - ២០១៥ និងផែនការឆ្នាំ២០១៧



## ១.២. ការអនុវត្តការងារជលធារសាស្ត្រ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងបំពាក់គ្រឿងចក្រ

- *ការងារជលធារសាស្ត្រ*

- សម្រាប់ឆ្នាំ២០១៧ ការងារគ្រប់គ្រងលើដំណើរការបូមស្តារ ដើម្បីយកខ្សាច់ផ្គត់ផ្គង់តម្រូវការប្រើប្រាស់ក្នុងស្រុក ដែលបូមចេញពីទីតាំងប្រឡាយស្តៅតាឯក និងទីតាំងប្រឡាយខ្សុំកោះកែវ មានបរិមាណសរុបចំនួន ៦៤៩.៨០៥ម៉ែត្រគ្រីគុណ។

- *ការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធ*

- តម្លើងធ្នើសម្រាប់ដាក់ឯកសារ ទំហំ ៦០ម៉ែត្រ គុណនឹង ៣,៤ម៉ែត្រ កំពស់ ២,៤ម៉ែត្រ ចំនួន ៣គ្រឿង សម្រាប់អង្គភាពវិក្កយបត្រនៅចំណតផែកុងតឺន័រLM១៧ ដាក់ឯកសារ។
- តម្លើងទ្វាររោងស្កេន ដើម្បីសម្រួលដល់ការងារស្កេនកុងតឺន័រ នៅចំណតផែកុងតឺន័រLM១៧។
- សាងសង់ច្រាំងទន្លេប្រវែង ៥៦០ម៉ែត្រនៅប្លុង់ B នៅចំណតផែកុងតឺន័រLM១៧
- សាងសង់ទីលានស្តុកកុងតឺន័រជំហានទី២ (ប្លង់ B) នៅចំណតផែកុងតឺន័រLM១៧ ដែលអនុវត្តដោយក្រុមហ៊ុន សៀង ហៃ គ្រុប ជាអ្នកទទួលការសាងសង់
- សាងសងទីលានចាក់ថ្មម៉ិចទំហំ ១២.០០០ម៉ែត្រក្រឡា ស្ថិតនៅប្លង់B នៅចំណតផែកុងតឺន័រ LM១៧ ដើម្បីស្តុកសំបកកុងតឺន័រ
- សាងសង់លានស្តុកកុងតឺន័រទំហំ ១០ម x ២៩០ម x ០,៣ម ស្ថិតនៅតាមបណ្តោយផ្លូវ NCT ទៅ MSL ដើម្បីជួយសម្រួលដល់ការស្តុកកុងតឺន័ររបស់អតិថិជន។

- *ការងារទិញ/បំពាក់គ្រឿងចក្រ ឬឧបករណ៍ថ្មី*

- ទិញកន្ទុយសណ្តោងរ៉ឺម៉កដឹកកុងតឺន័រទំហំ ៤០' ចំនួន ១២គ្រឿង ដើម្បីជួយសម្រួលដល់ការងារដឹកជញ្ជូនកុងតឺន័រនៅចំណតផែកុងតឺន័រLM១៧។
- ទិញឧបករណ៍ Firewall Fortinet 100D (S/N : FG100D3G16831933) ចំនួន ១គ្រឿង បំពាក់នៅចំណតផែTS៣ ដើម្បីការពារប្រព័ន្ធកុំព្យូទ័រពីការចំលងមេរោគ
- ទិញឧបករណ៍ Microsoft Surface Pro 4 Tablet: Intel Core I5 2.4G S/N: 054817364653 ចំនួន ២គ្រឿង ដើម្បីជួយសម្រួលដល់ការងារផ្នែកព័ត៌មានវិទ្យា សម្រាប់ប្រើប្រាស់នៅចំណតកុងតឺន័រTS៣ និង ចំណតផែកុងតឺន័រLM១៧
- ទិញឧបករណ៍ IBM Storwize V3700 2.5-inch Storage Controller Unit ចំនួន ១គ្រឿង សម្រាប់ផ្ទុកទិន្នន័យសម្រាប់ប្រព័ន្ធ TOS system នៅចំណតផែកុងតឺន័រLM១៧ ។
- ទិញឧបករណ៍ប្រភេទ Three Phase Automatic Compensation Voltage Stabilize 500KVA ចំនួន ២គ្រឿង សម្រាប់ទប់បម្រែបម្រួលតង់ស្យុងនៅចំណតផែកុងតឺន័រLM១៧។
- រថយន្ត Toyota Hilux Revo ពណ៌ស ផលិតឆ្នាំ២០១៧ សម្រាប់ប្រើប្រាស់លើការងាររដ្ឋបាល

- កន្ទុយសណ្តោងរ៉ឺម៉កដឹកកុងតឺន័រទំហំ៤០' ចំនួន ២៥គ្រឿង ដើម្បីជួយសម្រួលដល់ការងារដឹកជញ្ជូនកុងតឺន័រនៅចំណតផែកុងតឺន័រLM១៧
- រ៉ូឡូ Vibrating Roller Bomag ម៉ាក BW 211D-3 yellow, (Chasis NO 101580371474, Engine NO U767146H) ចំនួន ១គ្រឿង ដើម្បីជួយសម្រួលដល់ការងារកិនបង្ហាប់ទីលាននៅចំណតផែកុងតឺន័រLM១៧
- វិនិយោគលើការទិញដីនៅចំណតផែកុងតឺន័រLM១៧ ក្នុងទំហំ ៧.០៣៩,៥៥ម៉ែត្រក្រឡា និងទិញដីទំហំ ១២.៥៤៥,២០m២ សម្រាប់ត្រៀមអភិវឌ្ឍជាទីតាំងចំណតផែរណបដែលមាននៅកោះរកា
- តម្លើងធ្នើរធ្វើអំពីអាលុយមីញ៉ូម ទំហំ ២,៥ ម៉ែត្រ គុណនឹង ២ ម៉ែត្រ ចំនួន ៩ ឈុត សម្រាប់ដាក់គ្រឿងបន្លាស់ក្នុងឃ្លាំងនៃចំណតផែកុងតឺន័រTS៣
- បំពាក់ទូការិយាល័យកុងតឺន័រ (AUSCO) ទំហំ ៣ម៉ែត្រ x ៣ម៉ែត្រ x ១២ម៉ែត្រ ចំនួន ១គ្រឿង សម្រាប់ការងារប្រតិបត្តិការ នៅចំណតផែកុងតឺន័រLM១៧។
- ទិញប៉ុង់តុងទំហំ ១៥ម x ៤២ម x ២.៥ម ចំនួន២គ្រឿង ដើម្បីត្រៀមបំរុងបំពាក់គ្រឿងចក្រលើកដាក់ ផ្តល់សេវាកម្មលើកដាក់តាមដងទន្លេជូនអតិថិជន

## ២. ការប្រែប្រួលសំខាន់ៗ ពាក់ព័ន្ធនឹងប្រតិបត្តិការធុរកិច្ច

សម្រាប់ ឆ្នាំ២០១៧ នេះ ក.ស.ភ. ពុំមានការប្រែប្រួលសំខាន់ៗ ពាក់ព័ន្ធនឹងប្រតិបត្តិការធុរកិច្ចនោះទេ។

## ៣- រចនាសម្ព័ន្ធចំណូល

| បរិយាយ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | |
|---|---|---|---|---|
| | ពាន់រៀល | ប្រៀបធៀបនឹងចំណូលសរុប | ពាន់រៀល | ប្រៀបធៀបនឹងចំណូលសរុប |
| ចំណូលលើកដាក់ក្រោមដងយោង(Stevedoring) | ៣១.២៩៨.០៦២ | ៤១,០៣% | ២៧.១៩៥.៧៨០ | ៤១,១៦% |
| ចំណូលលើកដាក់លើទីលាន(LOLO) | ២៦.៦៨៩.៣៥១ | ៣៤,៩៩% | ២១.៦៩៩.៤៧៤ | ៣២,៨៥% |
| ចំណូលពីកិច្ចការផែ(Port dues& charges) | ១២.៨០៤.៩២៩ | ១៦,៧៩% | ១១.៦៤៩.៥៣៨ | ១៧,៦៣% |
| ចំណូលពីច្រកទ្វារ | ២.៧១១.៤៨១ | ៣,៥៥% | ២.២២៩.៥១១ | ៣,៣៧% |
| ចំណូលពីថ្លៃឈ្នួលស្តុកទំនិញ/កុងតឺន័រ | ១.៧២៣.៤៦៥ | ២,២៦% | ១.៩៣៩.១៩០ | ២,៩៤% |
| ចំណូលពីថ្លៃឈ្នួលគ្រប់គ្រងអាជីវកម្មខ្សាច់ | ១៥៥.៦៣១ | ០,២០% | ១.២៩១.៨១៧ | ១,៩៦% |
| ចំណូលពីការវាស់ស្ទង់ | ៧៧៣.១៨៦ | ១,០១% | ៣៧.៨១៩ | ០,០៦% |
| ចំណូលពីការដឹកជញ្ជូន | ២.៩៨៥ | ០,០០% | ៦.៥២១ | ០,០១% |
| ចំណូលពីថ្លៃឈ្នួលថ្លឹងកុងតឺន័រ | ១១៣.៧៨២ | ០,១៥% | ១៥.៩៦៥ | ០,០២% |
| ចំណូលពីសេវាកម្មជួសជុល និងថែទាំកុងតឺន័រ | ៨៨៥ | ០,០០% | - | ០,០០% |
| **សរុប:** | **៧៦.២៧៣.៧១៧** | **១០០,០០%** | **៦៦.០៦៥.៦១០** | **១០០,០០%** |

# ផ្នែកទី៣
# អភិបាលកិច្ចសាជីវកម្ម

## ១-ភាគហ៊ុនិក

### ក- ការការពារសិទ្ធិរបស់ភាគហ៊ុនិក

សិទ្ធិរបស់ភាគហ៊ុនិក ត្រូវបានធានាដោយមហាសន្និបាតភាគហ៊ុនិក ដោយក្រុមប្រឹក្សាភិបាល និងដោយអគ្គនាយកដែលមានកំណត់នៅក្នុងលក្ខន្តិកៈរបស់ ក.ស.ភ. ដូចខាងក្រោម៖

- ភាគហ៊ុនិកប្រភេទ "ក" និងប្រភេទ "ខ" មានសិទ្ធិបោះឆ្នោតពេញលេញ ដោយ ១ភាគហ៊ុន ស្មើនឹង ១សម្លេង ក្នុងមហាសន្និបាតភាគហ៊ុនិករបស់ ក.ស.ភ. ទៅលើបញ្ហាដែលបានលើកឡើងក្នុងការប្រជុំ ដែលក្នុងនោះមានដូចជា លទ្ធផលសកម្មភាពការងារប្រចាំឆ្នាំ គម្រោងផែនការវិនិយោគប្រចាំឆ្នាំ ការបោះឆ្នោតជ្រើសរើសអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិ ព្រមទាំងទៅលើបញ្ហា ដែលពាក់ព័ន្ធផលប៉ះពាល់ដល់ប្រយោជន៍របស់ភាគហ៊ុនិក ដូចជាការកាត់បន្ថយការតម្លើង ឬការកែប្រែផ្សេងទៀតទៅលើដើមទុនរបស់ ក.ស.ភ. ឬការផ្លាស់ប្តូរសិទ្ធិដែលពាក់ព័ន្ធនឹងប្រភេទមូលបត្រដែលមានក្នុងដើមទុនរបស់ក្រុមហ៊ុន ឬការទិញមកវិញ ការទទួលយកដោយ ក.ស.ភ. នូវមូលបត្រណាមួយ ឬមូលបត្រដទៃទៀតរបស់ ក.ស.ភ. ការរំលាយបញ្ចូលគ្នារវាង ក.ស.ភ. និងក្រុមហ៊ុនដទៃទៀត ការរំលាយ ឬការជម្រះបញ្ជី ក.ស.ភ. ការធ្វើវិសោធនកម្មលក្ខន្តិកៈ។ ដោយឡែក ភាគហ៊ុនិកប្រភេទ "គ" មិនមានសិទ្ធិបោះឆ្នោតនោះទេ លើកលែងតែពាក់ព័ន្ធនឹងបញ្ហាមួយចំនួនដូចជា ការរំលាយបញ្ចូលគ្នារវាង ក.ស.ភ. និង ក្រុមហ៊ុនដទៃទៀត ការរំលាយ ឬការជំរះបញ្ជី ក.ស.ភ. ការធ្វើវិសោធនកម្មលក្ខន្តិកៈ។
- ភាគហ៊ុនិកប្រភេទ "ក" និងប្រភេទ "ខ" មានសិទ្ធិទទួលភាគលាភដែលប្រកាសដោយក្រុមប្រឹក្សា-ភិបាលរបស់ ក.ស.ភ.។ លើសពីនេះទៀត ភាគហ៊ុនិកប្រភេទ "ក" ត្រូវបានធានានូវទិន្នផលភាគលាភប្រចាំឆ្នាំអប្បបរមាក្នុងអត្រា ៥% ក្នុងរយៈពេល ៥ឆ្នាំ។ រីឯ ភាគហ៊ុនិកប្រភេទ "គ" មិនមានសិទ្ធិទទួលបានភាគលាភនោះទេ។
- ភាគហ៊ុនិករបស់ ក.ស.ភ. មានសិទ្ធិទទួលបាននូវព័ត៌មានដែលទាក់ទងនឹង ក.ស.ភ. តាមរយៈការផ្តល់ព័ត៌មានទាន់ពេល ព័ត៌មានដែលផ្សព្វផ្សាយនៅលើគេហទំព័ររបស់ ក.ស.ភ. របាយការណ៍សមាយិករួមមានរបាយការណ៍ប្រចាំត្រីមាស និងរបាយការណ៍ប្រចាំឆ្នាំ ព្រមទាំងព័ត៌មានដទៃទៀត តាមការស្នើសុំរបស់ភាគហ៊ុនិក។
- ភាគហ៊ុនិករបស់ ក.ស.ភ. មានសិទ្ធិបុព្វក្រ័យក្នុងការជាវបានមុននូវភាគហ៊ុនថ្មីដែលក្នុងប្រភេទតែមួយជាមួយនឹងភាគហ៊ុនដែលខ្លួនកំពុងកាន់កាប់ ដែលបោះចេញដោយ ក.ស.ភ. ស្របតាមសមាមាត្រនៃការកាន់កាប់ភាគហ៊ុនរបស់ខ្លួន។
- ភាគហ៊ុនិកប្រភេទ "ក" និងប្រភេទ "ខ" មានសិទ្ធិទទួលបានទ្រព្យសម្បត្តិដែលនៅសល់ បន្ទាប់ពីមានការជម្រះបញ្ជី ការរំលាយ ឬការបញ្ចប់របស់ ក.ស.ភ. បន្ទាប់ពីភាគហ៊ុនិកប្រភេទ "គ" ដែលមានសិទ្ធិបុរិមាក្នុងការទទួលទ្រព្យសម្បត្តិដែលនៅសល់នេះ។
- ភាគហ៊ុនិកប្រភេទ"ខ" មានសិទ្ធិធ្វើបរិវត្តន៍ភាគហ៊ុនទាំងអស់របស់ខ្លួនទៅជាភាគហ៊ុនប្រភេទ"ក" ដោយ ១ ភាគហ៊ុនប្រភេទ"ខ" ទៅជាភាគហ៊ុនប្រភេទ"ក" លុះត្រាតែមានលក្ខខណ្ឌ៖

- បន្ទាប់ពីរយៈពេល ៥ឆ្នាំ ចាប់ពីពេល ក.ស.ភ. បានចុះបញ្ជីលក់លើទីផ្សារមូលបត្រកម្ពុជា
- ភាគលាភអប្បបរមាដែលធានាជូនភាគហ៊ុនិកប្រភេទ"ក" ត្រូវបានបែងចែករួចរាល់
- សិទ្ធិបរិវត្តន៍ ត្រូវអនុវត្តចំពោះភាគហ៊ុនប្រភេទ"ខ" ទាំងអស់ដោយក្នុងនោះមានភាគហ៊ុនប្រភេទ"ខ"ដែលបោះផ្សាយ និងដែលត្រូវបានអនុញ្ញាតឱ្យបោះផ្សាយ។

*ខ- ការបែងចែកប្រភេទភាគហ៊ុនិក (គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧)*

| បរិយាយ | សញ្ជាតិ | ប្រភេទភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|---|
| តិចជាង ៥% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ២១០ | ៩២៦.៩០៥ | ៤,៤៨% |
| | | នីតិបុគ្គល | ៤ | ៨៣៤.១០២ | ៤,០៣% |
| | មិនមានសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ៧៨ | ៨០២.៣៦១ | ៣,៨៨% |
| | | នីតិបុគ្គល | ៥ | ៣៤២.៥៧៨ | ១,៦៦% |
| ចាប់ពី ៥% ដល់តិចជាង ៣០% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | មិនមានសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | ១ | ១.២៣០.៩២៧ | ៥,៩៥% |
| ចាប់ពី ៣០% ឡើងទៅ | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | ១ | ១៦.៥៤៧.៤៩២ | ៨០% |
| | មិនមានសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |

*គ- អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិតដែលកាន់កាប់មូលបត្រកម្មសិទ្ធិរបស់ ក.ស.ភ.*

| ភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ* |
|---|---|---|---|
| អភិបាល | ៥ | ១២៣.៨៦៣ | ០,៦០% |
| បុគ្គលិកជាន់ខ្ពស់ | ១១ | ១០១.៦៤៧ | ០,៤៩% |
| និយោជិត | ៧៨ | ១១៨.២៣៨ | ០,៥៧% |
| ***សរុប*** | ***៩៤*** | ***៣៤៣.៧៤៨*** | ***១,៦៦%*** |

**ទិន្នន័យភាគរយត្រូវបានយកចំនួនមូលបត្រប្រៀបធៀបនឹងចំនួនមូលបត្រមានសិទ្ធិបោះឆ្នោតសរុប (២០.៦៨៤.៣៦៥)។*

*ឃ-ការផ្លាស់ប្តូរភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន និងភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់*

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ពុំមានការផ្លាស់ប្តូរភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន និងភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ទេ។

*ង- អត្តសញ្ញាណភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនចាប់ពី ៥ភាគរយឡើងទៅ ស្ថិតក្នុងស្ថានភាពអសាធនភាព*

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ពុំមានភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនចាប់ពី ៥ភាគរយឡើងទៅ ស្ថិតក្នុងស្ថានភាពអសាធនភាពនោះទេ។

### *ច- កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក*

សម្រាប់ឆ្នាំ២០១៧ ក.ស.ភ. បានរៀបចំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកលើកទី២ នាថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧ នៅទីស្នាក់ការកណ្តាល (ចំណតផែ TS៣) ដែលមានរបៀបវារៈដូចខាងក្រោម៖

❖ **របៀបវារៈ** ៖ បទបង្ហាញស្តីពីលទ្ធផលការងារអាជីវកម្ម និងហិរញ្ញវត្ថុប្រចាំឆ្នាំ២០១៦ និងទិសដៅការងារឆ្នាំ២០១៧

- **លទ្ធផលការងារទូទៅសម្រេចបាន នៅឆ្នាំ២០១៦**
  - បានបំពាក់គ្រឿងចក្រលើកដាក់លើទីលាន ចំនួន ៤គ្រឿង
  - ថែទាំ និងបូមស្តារប្រឡាយនាវាចរណ៍ជាប្រចាំ
  - គ្រប់គ្រងអាជីវកម្មខ្សាច់នៅប្រឡាយស្តៅ-តាឯក និងប្រឡាយខ្សុំ-កោះកែវ
  - សហការជាមួយក្រុមហ៊ុន Global Logistic Service Co., Ltd. (GLS) លើសេវាកម្មដឹកជញ្ជូនដោយប្រើប្រាស់ផ្លូវទឹកតាមទន្លេមេគង្គក្រោម (នៅទឹកដីកម្ពុជា) និងទន្លេបាសាក់ (នៅទឹកដីវៀតណាម) និងការតភ្ជាប់ទៅកំពង់ផែមេកៃម៉េបនៅប្រទេសវៀតណាម និងកំពង់ផែមេនៅប្រទេសសិង្ហបុរី តាមរយៈកំពង់ផែកាន់ថឺ (ប្រទេសវៀតណាម)
  - សហការជាមួយក្រុមហ៊ុន Viet Sac Port Service Co., Ltd. លើសេវាកម្មជួសជុលថែទាំសំបកកុងតឺន័រ នៅចំណតផែកុងតឺន័រLM១៧
  - សហការវិនិយោគជាមួយក្រុមហ៊ុន យុនណាន សេងមៅ អ៊ិនវេសម៉ិន (ខេមបូឌា) ឯ.ក ដើម្បីអភិវឌ្ឍជាមជ្ឈមណ្ឌលផ្គត់ផ្គង់គ្រឿងសំណង់ នៅទីលានស្តុកសំបកកុងតឺន័រ (ICD) បានបំពាក់គ្រឿងចក្រលើកដាក់លើទីលាន (RTG) ចំនួន ៤គ្រឿង ដើម្បីបង្កើនសមត្ថភាពលើកដាក់ ជាមួយនឹងការទទួលកំណើនកុងតឺន័រឆ្លងកាត់ជារៀងរាល់ឆ្នាំ
  - បានបូមស្តារ និងគ្រប់គ្រងអាជីវកម្មខ្សាច់ ដែលទទួលបានពីការបូមស្តារ ព្រមទាំងបានថែទាំផ្លូវនាវាចរណ៍ជាប្រចាំលើទីតាំងចំនួនពីរកន្លែង គឺប្រឡាយស្តៅ-តាឯក និងប្រឡាយខ្សុំ-កោះកែវ ដើម្បីផ្តល់លទ្ធភាពឱ្យនាវាអាចដឹកកុងតឺន័របានកាន់តែច្រើន។
- **លទ្ធផលអាជីវកម្ម ឆ្នាំ២០១៦**
  - បរិមាណកុងតឺន័រឆ្លងកាត់មានចំនួន ១៥១.៧៨១TEUs
  - បរិមាណនាវាដឹកទំនិញឆ្លងកាត់មានចំនួន ១.៦៧៩គ្រឿង
  - បរិមាណនាវាអ្នកដំណើរ និងទេសចរណ៍អន្តរជាតិមានចំនួន ១.៥៩៤គ្រឿង
  - និងបរិមាណទំនិញ និងប្រេងឥន្ធនៈឆ្លងកាត់មានចំនួន ២.៤០៩.៦៣២តោន។
- **លទ្ធផលហិរញ្ញវត្ថុ ឆ្នាំ២០១៦**
  - ផលអាជីវកម្ម-សេវាកម្មសរុបមានចំនួន ៦៦.០៦៥.៦១០ពាន់រៀល
  - ចំណាយសរុបមានចំនួន ៥៣.៤២២.៣៣៣ពាន់រៀល
  - ប្រាក់ចំណេញសុទ្ធមានចំនួន ១៦.៥៦៦.១៩២ពាន់រៀល
- **ទិសដៅការងារក្នុង ឆ្នាំ២០១៧**
  - អភិវឌ្ឍធនធានមនុស្ស
  - ពង្រីក និងអភិវឌ្ឍចំណតផែរណបតាមដងទន្លេ
  - បង្កើតតំបន់ភ័ស្តុភារកម្ម និងឃ្លាំងទំនើប
  - អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធចំណតផែកុងតឺន័រ LM១៧ ដំណាក់កាលទី២

- បន្តបូមស្តារ និងថែទាំប្រឡាយនាវាចរណ៍
- បំពាក់គ្រឿងចក្រលើកដាក់បន្ថែម ដើម្បីធានាប្រសិទ្ធភាពប្រតិបត្តិការលើកដាក់
- ចាប់ផ្តើមគម្រោងបង្កើតរោងចក្រកែច្នៃស្រូវ អង្ករ និងឃ្លាំងត្រជាក់នៅចំណតផែកុងតឺន័រ LM១៧ ក្រោមទម្រង់ភាពជាដៃគូ រវាងរដ្ឋ និងឯកជន
- បន្តសហការជាមួយប្រទេសវៀតណាម ដើម្បីបូមស្តារផ្លូវនាវាចរណ៍ពីចំណតផែកុងតឺន័រ LM១៧ ដល់ព្រំប្រទល់ កម្ពុជា-វៀតណាម (ភ្នមសំណរ) និងពីភ្នមសំណរ ដល់កំពង់ផែកាន់ថឺ នៃប្រទេសវៀតណាម។

- **ផែនការអាជីវកម្ម ឆ្នាំ២០១៧**
  - បរិមាណទំនិញ-ប្រេងឥន្ធនៈឆ្លងកាត់គិតជាតោនចំនួន ២.៨៥០.០០០តោន
  - បរិមាណនាវាឆ្លងកាត់ចំនួន ១.៧១៥គ្រឿង
  - បរិមាណកុងតឺន័រចំនួន ១៦១.០០០TEUs

## *ឆ- គោលនយោបាយភាគលាភ*

### *ឆ-១- គោលនយោបាយភាគលាភរបស់ ក.ស.ភ.*

ដើម្បីលើកទឹកចិត្តដល់វិនិយោគិនដែលទិញភាគហ៊ុនប្រភេទ"ក" របស់ ក.ស.ភ. ក្រុមប្រឹក្សាភិបាលបានអនុម័តគោលនយោបាយភាគលាភពិសេស ដែលធានានូវទិន្នផលភាគលាភអប្បបរមាប្រចាំឆ្នាំស្មើនឹងចំនួន ៥% នៃទំហំវិនិយោគដោយគិតតាមថ្លៃមូលបត្រនៃ IPOសម្រាប់រយៈពេល ៥ឆ្នាំបន្ទាប់ពីការចុះបញ្ជីលក់លើទីផ្សារមូលបត្រកម្ពុជា។ ការធានាទិន្នផលភាគលាភអប្បបរមាស្មើនឹងចំនួន ៥% នេះគឺនឹងផ្តល់ជូនចំពោះមូលបត្រកម្មសិទ្ធិដែលមានសិទ្ធិបោះឆ្នោតប្រភេទ"ក" តែប៉ុណ្ណោះ។ រាជរដ្ឋាភិបាល ដែលជាភាគហ៊ុនិកកាន់កាប់មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតប្រភេទ"ខ" និងមូលបត្រកម្មសិទ្ធិគ្មានសិទ្ធិបោះឆ្នោតប្រភេទ"គ" មិនទទួលបានការធានាភាគលាភនេះទេ ។ ភាគលាភអប្បបរមានេះត្រូវបានធានានូវទិន្នផលភាគលាភប្រចាំឆ្នាំ អាចជាសាច់ប្រាក់ ឬជាភាគហ៊ុន។

ក្នុងករណីដែលភាគលាភអប្បបរមាត្រូវបានធានាជាសាច់ប្រាក់ គឺស្មើនឹងអត្រា ៥% នៃចំនួនភាគហ៊ុនប្រភេទ"ក" សរុបដែលបានកាន់កាប់មុនថ្ងៃអិចឌីវិឌិនដ៍(Ex-DividendDate)គុណនឹងថ្លៃធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។

ប្រសិនបើភាគលាភអប្បបរមាត្រូវបានធានា ពុំអាចត្រូវបានបែងចែកពេញលេញក្នុងឆ្នាំសារពើពន្ធណាមួយទេ នោះចំណែកនៃភាគលាភអប្បបរមាត្រូវបានធានានឹងត្រូវបង្គរទៅឆ្នាំបន្ទាប់ ឬទៅពេលវេលាសមស្របណាមួយដែលសម្រេចដោយក្រុមប្រឹក្សាភិបាល។

ក្នុងករណីដែល ក.ស.ភ. បែងចែកភាគលាភអប្បបរមាត្រូវបានធានា ជាភាគហ៊ុន នោះចំនួនភាគហ៊ុនអប្បបរមាត្រូវបានធានា ត្រូវគណនាដោយយកភាគលាភអប្បបរមាត្រូវបានធានា ចែកនឹងថ្លៃបិទការជួញដូរ១ថ្ងៃ នៅមុនថ្ងៃអិចឌីវិឌិនដ៍(Ex-DividendDate)។

ក្រោយពីបានអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដោយក្រុមប្រឹក្សាភិបាល បើពិនិត្យឃើញថាមានប្រាក់ចំណេញ នោះក្រុមប្រឹក្សាភិបាលនៃ ក.ស.ភ. អាចសម្រេចបែងចែកប្រាក់ចំណេញនោះដើម្បី៖

- ទូទាត់នូវការខាតបង់ឆ្នាំសារពើពន្ធមុន
- ក្រោយពីបានទូទាត់នូវការខាតបង់ឆ្នាំសារពើពន្ធមុនហើយប្រសិនបើនៅមានប្រាក់ចំណេញ នោះក្រុមប្រឹក្សាភិបាលអាចប្រើប្រាស់ប្រាក់ចំណេញនេះសម្រាប់៖
  - ថ្លែងសរសើរដល់ថ្នាក់ដឹកនាំនិងនិយោជិតតាមលក្ខខណ្ឌខាងក្រោម៖
    - បើប្រាក់ចំណេញនៅសល់មានចំនួនចាប់ពី៥% ដល់ ១០%នៃចំណាយដំណើរការរបស់ ក.ស.ភ. សរុបក្នុងឆ្នាំនោះ ប្រាក់ថ្លែងសរសើរត្រូវស្មើនឹង ១ខែនៃប្រាក់បៀវត្សរបស់ថ្នាក់ដឹកនាំនិងនិយោជិតម្នាក់ៗសរុបជាមធ្យមប្រចាំឆ្នាំ
    - បើប្រាក់ចំណេញនៅសល់មានចំនួនលើសពី១០% ដល់ ២០% នៃចំណាយដំណើរការ សរុបរបស់ក.ស.ភ. ក្នុងឆ្នាំនោះ ប្រាក់ថ្លែងសសើរត្រូវស្មើនឹង ២ខែនៃប្រាក់បៀវត្សរបស់ថ្នាក់ដឹកនាំនិងនិយោជិត សរុបជាមធ្យមប្រចាំឆ្នាំ
    - បើប្រាក់ចំណេញលើសពី២០% នៃចំណាយដំណើរការសរុបរបស់ ក.ស.ភ. ក្នុងឆ្នាំនោះ ប្រាក់ថ្លែងសសើរស្មើនឹង ៣ខែនៃប្រាក់បៀវត្សរបស់ថ្នាក់ដឹកនាំនិងនិយោជិត សរុបជាមធ្យមប្រចាំឆ្នាំ។
  - បង្កើតមូលនិធិបម្រុងតាមច្បាប់ចំនួន ៥% និងមូលនិធិបម្រុងសេរីចំនួន ៥% នៃប្រាក់ចំណេញសុទ្ធ
  - មូលនិធិ ៥% លើប្រាក់ចំណេញសម្រាប់បម្រើផលប្រយោជន៍សង្គម ដែលត្រូវកត់ត្រាចូលក្នុងបន្ទុកក្នុងឆ្នាំដែលធ្វើប្រត្តិការចំណាយនោះ
  - ប្រាក់ចំណេញដែលសល់ក្រោយការបែងចែកខាងលើ ត្រូវបែងចែកជាភាគលាភឱ្យភាគហ៊ុនិក ទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល
  - ប្រាក់ចំណេញនៅសល់ចុងក្រោយ ត្រូវបង្វិលចូលមូលនិធិអភិវឌ្ឍន៍ ក.ស.ភ.។

### *ឆ-២- ព័ត៌មានប្រវត្តិសាស្ត្រអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ*

❖ **ការបែងចែកភាគលាភសម្រាប់ឆ្នាំ២០១៥**

យោងតាមកិច្ចប្រជុំលើកទី១៧ អាណត្តិទី៥ របស់ក្រុមប្រឹក្សាភិបាល ក.ស.ភ. នាថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ក្រុមប្រឹក្សាភិបាលរបស់ ក.ស.ភ. បានសម្រេចធ្វើការបែងចែកភាគលាភសម្រាប់ឆ្នាំ២០១៥ ជាសាច់ប្រាក់ ជូនភាគហ៊ុនិកដែលកាន់កាប់មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតប្រភេទ "ក" ដោយយកមូលដ្ឋានភាគលាភអប្បបរមាចំនួន ៥% ចែកនឹង ១០ (១/១០) ហើយភាគលាភសរុបត្រូវបែងចែក (Total Dividend) មានចំនួន ១០៥.៩០០.៧៧៥រៀល (មួយរយប្រាំលាន ប្រាំបួនរយពាន់ ប្រាំពីរយចិតសិបប្រាំរៀលគត់) ហើយភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (Dividend Per Share)មានចំនួន ២៥,៦០រៀល (ម្ភៃប្រាំរៀល និងហុកសិបសេន) ព្រមទាំងបានសម្រេចបង្គរភាគលាភសម្រាប់ឆ្នាំ២០១៥ ដោយទុកបូកជាមួយភាគលាភអប្បបរមា ឆ្នាំ២០១៦ ដែលនឹងធ្វើការទូទាត់ នៅក្នុងអំឡុងខែមីនា ឬ ខែមេសា ឆ្នាំ២០១៧ ដោយផ្អែកលើហេតុផល ដូចខាងក្រោម៖

១- ក.ស.ភ. ទើបតែបានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិជាផ្លូវការនៅដំណាច់ ឆ្នាំ២០១៥ ប៉ុណ្ណោះ

២- ក.ស.ភ. ត្រូវការប្រាក់ចំណេញរក្សាទុក សម្រាប់អនុវត្តផែនការអភិវឌ្ឍន៍ ឆ្នាំ២០១៦ របស់ខ្លួន។

❖ **ការបែងចែកភាគលាភសម្រាប់ឆ្នាំ២០១៦**

យោងតាមកិច្ចពិភាក្សាក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៥ អាណត្តិទី៦ នាថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៧ អង្គប្រជុំបានសម្រេចលើការបែងចែកភាគលាភជូនភាគហ៊ុនិក ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតប្រភេទ "ក" របស់ ក.ស.ភ. ប្រចាំឆ្នាំ២០១៦ និងភាគលាភបង្គរឆ្នាំ២០១៥ ដូចខាងក្រោម៖

១. ភាគលាភដែលបែងចែកជូនភាគហ៊ុនិកកាន់កាប់មូលបត្រមានសិទ្ធិបោះឆ្នោតប្រភេទ "ក"

- ប្រភេទភាគលាភដែលត្រូវបែងចែក៖ ជាសាច់ប្រាក់
- រយៈពេលភាគលាភ៖ ប្រចាំឆ្នាំ២០១៦
- អនុបាតនៃការបែងចែកភាគលាភ៖ ៦,៣៩%
- ភាគលាភសរុបដែលត្រូវបែងចែក៖ ១.០៥៩.០៣៩.៤៨៨ រៀល
- ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ៖ ២៥៦ រៀល
- កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលបានភាគលាភ៖ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧

២. ភាគលាភបង្គរប្រចាំឆ្នាំ២០១៥ ចំនួន ១០៥.៩០៣.៩៤៩ រៀល (ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិមានចំនួន ២៥,៦០ រៀល និងអនុបាតនៃការបែងចែកភាគលាភចំនួន ០,៨២% នឹងធ្វើការទូទាត់ជាមួយភាគលាភឆ្នាំ២០១៦។ ភាគហ៊ុនិកដែលមានសិទ្ធិទទួលបានភាគលាភបង្គរឆ្នាំ២០១៥ គឺជាភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជីឈ្មោះភាគហ៊ុនិក ដែលប្រកាសយោងតាមកាលបរិច្ឆេទកំណត់ទុកនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧។ ភាគលាភសរុប (ប្រចាំឆ្នាំ២០១៦ និងភាគលាភបង្គរឆ្នាំ២០១៥) មានចំនួន ១.១៦៤.៩៤៣.៤៣៧រៀល នឹងបានទូទាត់រួចរាល់នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧។

❖ **ការបែងចែកភាគលាភសម្រាប់ឆ្នាំ២០១៧**

យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាលក្នុងកិច្ចប្រជុំលើកទី១០ អាណត្តិទី៦ នាថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ អង្គប្រជុំបានសម្រេចលើការបែងចែកភាគលាភប្រចាំឆ្នាំ ២០១៧ ជូនភាគហ៊ុនិក ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតប្រភេទ "ក" របស់ ក.ស.ភ. ដូចខាងក្រោម៖

- ភាគលាភដែលត្រូវបែងចែក៖ ជាសាច់ប្រាក់
- រយៈពេលភាគលាភ៖ ប្រចាំឆ្នាំ២០១៧
- អនុបាតនៃការបែងចែកភាគលាភ៖ ៥,៨៦%
- ភាគលាភសរុបដែលត្រូវបែងចែក៖ ១.២៧០.៨៤៧.៣៨៦ រៀល
- ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ៖ ៣០៧ រៀល
- កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលបានភាគលាភ៖ ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨
- កាលបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភ៖ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៨

# ២.អង្គការលេខ (ឆ្នាំ២០១៧)




សម្គាល់:
- ប្រធានការិយាល័យ និងប្រធានសេវាដ្ឋាន ជាជំនួយការឲ្យប្រធាននាយកដ្ឋាន (គ្មានអនុប្រធាននាយកដ្ឋាន)
- ប្រធានការិយាល័យ = ប្រធានសេវាដ្ឋាន = ប្រធានអង្គភាពលទ្ធកម្ម
- ប្រធានអង្គភាព = អនុប្រធានការិយាល័យ = អនុប្រធានសេវាដ្ឋាន

## ៣. ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនានា

### *ក. សមាសភាពក្រុមប្រឹក្សាភិបាល*

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទ ក្លាយជាអភិបាល | កាលបរិច្ឆេទ បញ្ចប់អាណត្តិបច្ចុប្បន្ន |
|---|---|---|---|---|
| ១. | ឯកឧត្តម **ហ៊ី បាវី** | ប្រធាន | ២២ មិថុនា ២០១៦ | ២១ មិថុនា ២០១៩ |
| ២. | ឯកឧត្តម **សួន រចនា** | សមាជិក | ២២ មិថុនា ២០១៦ | ២១ មិថុនា ២០១៩ |
| ៣. | ឯកឧត្តម **កែន សម្បត្តិ** | សមាជិក | ២២ មិថុនា ២០១៦ | ២១ មិថុនា ២០១៩ |
| ៤. | ឯកឧត្តម **ប៉ែន សុវិជាតិ** | សមាជិក | ២២ មិថុនា ២០១៦ | ២១ មិថុនា ២០១៩ |
| ៥. | លោក **ហ៊្វី អានវ៉ានិថ** | សមាជិក | ៦ មិថុនា ២០១៦ | ៥ មិថុនា ២០១៩ |
| ៦. | លោក **ឱត សុចល** | សមាជិក | ៦ មិថុនា ២០១៦ | ៥ មិថុនា ២០១៩ |
| ៧. | លោកស្រី **ជួន សុខេម** | សមាជិក | ២២ មិថុនា ២០១៦ | ២១ មិថុនា ២០១៩ |

*ឈ្មោះលេខាធិការរបស់កំពង់ផែស្វយ័តភ្នំពេញ គឺលោក **គង់ ចាន់នី** ប្រធានលេខាធិការដ្ឋាន។*

### *ខ. ប្រសិនបើអភិបាលណាម្នាក់ ជាអភិបាល ជាភាគហ៊ុនិក ជាកម្មសិទ្ធិករ ឬសហកម្មសិទ្ធិកររបស់ក្រុមហ៊ុន ឬរបស់សហគ្រាសផ្សេងទៀត*

| ល.រ | ឈ្មោះរបស់អភិបាល | ឈ្មោះក្រុមហ៊ុនពាក់ព័ន្ធ | អភិបាល ឬភាគហ៊ុនិក ឬ កម្មសិទ្ធករ ឬសហកម្មសិទ្ធិករ |
|---|---|---|---|
| ១ | ឯកឧត្តម **សួន រចនា** | ក្រុមហ៊ុន Star Shipping | ភាគហ៊ុនិក |
| ២ | លោក **ហ៊្វី អានវ៉ានិថ** | ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា (FTB) | អភិបាល |

### *គ- តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល*

ក្រុមប្រឹក្សាភិបាលមានតួនាទី និងភារកិច្ចកំណត់ទិសដៅអភិវឌ្ឍន៍ និងត្រួតពិនិត្យការគ្រប់គ្រងទូទៅរបស់ ក. ស. ភ.។ ក្នុងក្របខណ្ឌនេះ ក្រុមប្រឹក្សាភិបាល មានអំណាច៖

- សម្រេចលើផែនការអភិវឌ្ឍន៍ ក្នុងក្របខណ្ឌនៃការតម្រង់ទិស កំណត់ដោយរាជរដ្ឋាភិបាល
- ពិនិត្យអនុម័តផែនការអាជីវកម្ម សេវាកម្ម ផែនការហិរញ្ញវត្ថុ និងវិនិយោគរបស់ ក. ស. ភ.
- អនុម័តលើរបាយការណ៍សកម្មភាពការងារ និងរបាយការណ៍គណនេយ្យ ហិរញ្ញវត្ថុប្រចាំឆ្នាំ
- កំណត់ការចាត់ចែង និងភារកិច្ចទូទៅរបស់ ក. ស. ភ.
- ចាត់ចែងឱ្យដំណើរការនូវគណៈកម្មាធិការ និងគណៈកម្មការដូចមានកំណត់ដោយអត្ថបទស្តីពីការបង្កើត ក. ស. ភ. ឬដោយលក្ខន្តិកៈរបស់ ក. ស. ភ. និងបង្កើតបន្ថែមទៀតប្រសិនបើចាំបាច់
- សម្រេចចំនួនក្របខណ្ឌបុគ្គលិក ដែលអនុញ្ញាតសម្រាប់ ក. ស. ភ.

- វាយតម្លៃក្នុងចន្លោះពេលទៀងទាត់ នូវកម្រិតទំហំនៃការធ្វើឱ្យសម្រេចនូវគោលដៅដែលកំណត់ដោយ ក. ស. ភ. និងដាក់ចុះនូវវិធានការសម្រាប់កែលម្អចាំបាច់
- សម្រេចតាមសំណើរបស់អគ្គនាយក នូវរចនាសម្ព័ន្ធ និងបទបញ្ជាផ្ទៃក្នុងរបស់ ក. ស. ភ. ព្រមទាំងលក្ខន្តិកៈ និងកាំបៀវត្ស ប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗ និងលាភការសម្រាប់បុគ្គលិក ដោយអនុលោមតាមច្បាប់ និងបទបញ្ញត្តិទាំងឡាយជាធរមាន
- កំណត់របបផែនការជ្រើសរើស ការតម្លើងឋានៈ និងការផ្តល់លាភការសម្រាប់ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់
- ជ្រើសរើស និងកំណត់លាភការសម្រាប់ផ្តល់ឱ្យស្នងការគណនី
- ធ្វើសំណើកែសម្រួលលក្ខន្តិកៈ
- កំណត់ថ្លៃឈ្នួលពាក់ព័ន្ធនឹងការធ្វើអាជីវកម្ម សេវាកម្មលើកំពង់ផែ
- អនុម័តលើលទ្ធកម្មនានា យោងតាមច្បាប់ និងបទបញ្ញត្តិជាធរមាន
- សម្រេចលើការបើក និងបិទគ្រប់ការិយាល័យ សេវាដ្ឋាន សាខា ទីភ្នាក់ងារ ឬតំណាងទាំងអស់ដែលចាំបាច់សម្រាប់អនុវត្តឱ្យសម្រេចគោលដៅ និងភារកិច្ចរបស់ ក. ស. ភ.
- អនុម័តរាល់កិច្ចសន្យាទាំងឡាយណាដែលពុំអាចអនុវត្តតាមតារាងថ្លៃឈ្នួល និងតាមប្រកាសស្តីពីការគ្រប់គ្រងលទ្ធកម្មនៃសហគ្រាសសាធារណៈដែលអគ្គនាយកឆ្លងយោបល់ក្រុមប្រឹក្សាភិបាល។

# ក្រុមប្រឹក្សាភិបាល



ឯកឧត្តម **ហ៊ី ធាវី**
**ប្រធានក្រុមប្រឹក្សាភិបាល**
**អគ្គនាយកកំពង់ផែស្វយ័តភ្នំពេញ**

- *ជនជាតិ* ខ្មែរ
- *សញ្ជាតិ* ខ្មែរ
- *ថ្ងៃខែឆ្នាំកំណើត* ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៥៥
- *ប្រវត្តិនៃការសិក្សា*
  - ឆ្នាំ១៩៧៤ បានបញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិនៅវិទ្យាល័យដូនពេញ
  - ឆ្នាំ២០០៨ បានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែករដ្ឋបាលធុរកិច្ចពីសកលវិទ្យាល័យ Charles Sturt ប្រទេសអូស្ត្រាលី
  - ឆ្នាំ២០០៩ បានបញ្ចប់ថ្នាក់បណ្ឌិតផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច ពីសកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យាកម្ពុជា។
- *បទពិសោធន៍ការងារ*
  - ឆ្នាំ១៩៧៩ បានចាប់បម្រើការងារនៅ ក. ស. ភ. រហូតមកដល់បច្ចុប្បន្ន
  - ពីឆ្នាំ២០០០ - បច្ចុប្បន្ន ជាអគ្គនាយក និងជាប្រធានក្រុមប្រឹក្សាភិបាល ក. ស. ភ.។



ឯកឧត្តម **សួន វចនា**
**សមាជិកក្រុមប្រឹក្សាភិបាល**
**តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន**

- *ជនជាតិ* ខ្មែរ
- *សញ្ជាតិ* ខ្មែរ
- *ថ្ងៃខែឆ្នាំកំណើត* ថ្ងៃទី៧ ខែមិថុនា ឆ្នាំ១៩៥៤
- *ប្រវត្តិនៃការសិក្សា*
  - ឆ្នាំ១៩៧៣ បានបញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិនៅវិទ្យាល័យ ១៨ មីនា

(បច្ចុប្បន្នវិទ្យាល័យព្រះយុគន្ធរ)

- ឆ្នាំ១៩៧៥ បានបញ្ចប់ការសិក្សាពីមហាវិទ្យាល័យវេជ្ជសាស្ត្រ។

- *<u>បទពិសោធន៍ការងារ</u>*
  - ឆ្នាំ២០០៩ - បច្ចុប្បន្ន ជារដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន
  - ឆ្នាំ២០១៥ - បច្ចុប្បន្ន ជាសមាជិកក្រុមប្រឹក្សាភិបាល នៃ ក. ស. ភ.។



ឯកឧត្តម **កែន សម្បត្តិ**

**សមាជិកក្រុមប្រឹក្សាភិបាល**

**តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

- *<u>ជនជាតិ</u>* ខ្មែរ
- *<u>សញ្ជាតិ</u>* ខ្មែរ
- *<u>ថ្ងៃខែឆ្នាំកំណើត</u>* ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៦៨
- *<u>ប្រវត្តិនៃការសិក្សា</u>*
  - ឆ្នាំ១៩៩៥ បានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកសេដ្ឋកិច្ច ពីសកលវិទ្យាល័យ Lomonosov State ប្រទេសរុស្ស៊ី
  - ឆ្នាំ២០០០ បានបញ្ចប់ថ្នាក់អនុបណ្ឌិត ផ្នែកគោលនយោបាយសាធារណៈ ពីសកលវិទ្យាល័យ Saitama ប្រទេសជប៉ុន
  - ឆ្នាំ២០០៨ បានបញ្ចប់ថ្នាក់បណ្ឌិតផ្នែកសេដ្ឋកិច្ចពីសកលវិទ្យាល័យ International ប្រទេសអង់គ្លេស។
- *<u>បទពិសោធន៍ការងារ</u>*
  - ឆ្នាំ២០០៩ -២០១៣ បំពេញតួនាទីជាទីប្រឹក្សា និងនាយករងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  - ឆ្នាំ២០១៣-បច្ចុប្បន្ន +ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
    + ជាសមាជិកក្រុមប្រឹក្សាភិបាល ក. ស. ភ.។



ឯកឧត្តម **ប៉ែន សុវិជាតិ**
**សមាជិកក្រុមប្រឹក្សាភិបាល**
**តំណាងក្រសួងពាណិជ្ជកម្ម**

- *ជនជាតិ* ខ្មែរ
- *សញ្ជាតិ* ខ្មែរ
- *ថ្ងៃខែឆ្នាំកំណើត* ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៦៣
- *ប្រវត្តិនៃការសិក្សា*
  - ឆ្នាំ១៩៩០ បានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកសេដ្ឋកិច្ចពីវិទ្យាស្ថានសេដ្ឋកិច្ច ប្រទេសកម្ពុជា
  - ឆ្នាំ១៩៩៧ បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកពាណិជ្ជសាស្ត្រ ពីសកលវិទ្យាល័យ New England ប្រទេសអូស្ត្រាលី។
- *បទពិសោធន៍ការងារ*
  - ឆ្នាំ១៩៩៨ - ២០០០ បំពេញតួនាទីជា អនុប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម
  - ឆ្នាំ២០០០ - ២០០៧ ជាអនុប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា
  - ឆ្នាំ២០០៧ - ២០១២ ជាប្រធាននាយកដ្ឋានផ្តល់ព័ត៌មាន និងផ្ទៀងផ្ទាត់ច្បាប់នៃក្រសួងពាណិជ្ជកម្ម
  - ពីដើមឆ្នាំ២០១២ - ឆ្នាំ២០១៤ បានបម្រើការងារជាអគ្គនាយករងនៃអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស
  - ពីឆ្នាំ២០១៤-បច្ចុប្បន្ន
    + ជាអគ្គនាយក នៃអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេសនៃក្រសួងពាណិជ្ជកម្ម
    + ជាសមាជិកគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញាកម្ពុជា
    + ជាសមាជិកក្រុមប្រឹក្សាភិបាល ក.ស.ភ.។



លោក **ហ្គី អានវ៉ានិថ**
**សមាជិកក្រុមប្រឹក្សាភិបាល**
**អភិបាលឯករាជ្យ**

- *ជនជាតិ* ខ្មែរ
- *សញ្ជាតិ* ខ្មែរ
- *ថ្ងៃ ខែ ឆ្នាំកំណើត* ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៥៣

- *ប្រវត្តិនៃការសិក្សា*
  - ១៩៥៩-១៩៧០ — បានបញ្ចប់ការសិក្សានៅវិទ្យាល័យ ដេកាត (Lycée Descartes) រាជធានីភ្នំពេញ ប្រទេសកម្ពុជា
  - ១៩៧២ — គណិតវិទ្យា ភាសាបារាំង នៅមហាវិទ្យាល័យ ស្តេនីឡា (Stanislas) ទីក្រុងម៉ុងរ៉េអាល់ ប្រទេសកាណាដា
  - ១៩៧៦ — B.A.Sc. វិស្វកម្មឧស្សាហកម្ម, សាលាពហុបច្ចេកទេសនៃសកលវិទ្យាល័យ ម៉ុងរ៉េអាល់ បាក់កាឡូរ៉េអា (Universite de Montreal Baccalaureat) ប្រទេសកាណាដា
  - ឆ្នាំ១៩៨០ — អនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្ម នៅសកលវិទ្យាល័យ វេស្ទើន អុងតារីយ៉ូ (Western Ontario University) ទីក្រុងឡុង ប្រទេសកាណាដា។
- *បទពិសោធន៍ការងារ*
  - សីហា ១៩៧៦-សីហា ១៩៧៨ — ជំនួយការប្រធានផ្នែកបច្ចេកទេស នៃ Bechtel Quebec Ltd/ James Bay Energy Corporation
  - មិថុនា ១៩៨០-មីនា ១៩៨២ — មន្ត្រីវិភាគឥណទាន នៃធនាគារ តូរ៉ុនតូ ដូមីញ៉ាន ក្រុងតូរ៉ុនតូ ប្រទេសកាណាដា
  - មីនា ១៩៨២-សីហា ១៩៨៣ — មន្ត្រីតំបន់ នៃធនាគារ តូរ៉ុនតូ ដូមីញ៉ាន ក្រុងតូរ៉ុនតូ
  - សីហា ១៩៨៣-ឧសភា ១៩៨៤ — ជំនួយការនាយក នៃធនាគារ តូរ៉ុនតូ ដូមីញ៉ាន ក្រុងតូរ៉ុនតូ
  - ឧសភា ១៩៨៤-ឧសភា ១៩៨៦ — មន្ត្រីផ្នែកគណនេយ្យ (សាជីវកម្ម និងធនាគាររដ្ឋាភិបាល) នៃធនាគារ តូរ៉ុនតូ ដូមីញ៉ាន ក្រុងតូរ៉ុនតូ
  - មិថុនា ១៩៨៦-ធ្នូ ១៩៨៨ — នាយកផ្នែកគណនេយ្យ (សាជីវកម្ម និងធនាគាររដ្ឋាភិបាល) នៃធនាគារម៉ុងរ៉េអាល់ ក្រុងម៉ុងរ៉េអាល់
  - ធ្នូ ១៩៨៨-ឧសភា១៩៩៤ — ជំនួយការរតនាភិបាល នៃ The Laurentian Group Corporation ក្រុងម៉ុងរ៉េអាល់
  - មិថុនា ១៩៩៤ -មីនា២០០៤ — នាយក និងជាប្រធានផ្នែកសាជីវកម្មនៃធនាគារ Credit Agricole Indosuez ភ្នំពេញ
  - មេសា ២០០៣-កក្កដា ២០០៤ — អគ្គលេខាធិការ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
  - កក្កដា ២០០៤-មិថុនា ២០០៥ — ប្រធានខុទ្ទកាល័យ ក្រសួងសាធារណៈការ និងដឹកជញ្ជូន
  - មិថុនា ២០០៥-ធ្នូ ២០០៥ — នាយកជាន់ខ្ពស់នៃធនាគារ ANZ Royal ភ្នំពេញ
  - ធ្នូ ២០០៥-មេសា ២០០៩ — អគ្គនាយករង និងជាសមាជិកក្រុមប្រឹក្សាភិបាល នៃធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា
  - មីនា ២០០៣-បច្ចុប្បន្ន — សាស្ត្រាចារ្យគម្រោងមូលនិធិអភិវឌ្ឍន៍តំបន់ទន្លេមេគង្គ (MPDF)/IFC
  - មេសា ២០០៩-បច្ចុប្បន្ន — អគ្គនាយក និងជាសមាជិកក្រុមប្រឹក្សាភិបាល នៃធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា
  - មិថុនា២០១៦-បច្ចុប្បន្ន — សមាជិកក្រុមប្រឹក្សាភិបាល ក. ស. ភ.។



លោក **ឱត សុចល**
**សមាជិកក្រុមប្រឹក្សាភិបាល**
**អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន**

- *ជនជាតិ* ខ្មែរ
- *សញ្ជាតិ* ខ្មែរ
- *ថ្ងៃ ខែ ឆ្នាំកំណើត* ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៩

- *ប្រវត្តិនៃការសិក្សា*
  - ឆ្នាំ១៩៩៦ មធ្យមសិក្សាទុតិយភូមិ វិទ្យាល័យកំពង់ថ្ម ខេត្តកំពង់ធំ
  - ឆ្នាំ១៩៩៦-២០០០ បរិញ្ញាបត្រជំនាញគណនេយ្យ នៅសកលវិទ្យាល័យ ជាស៊ីមកំចាយមារ ខេត្តព្រៃវែង
  - ឆ្នាំ២០០២-២០០៤ សញ្ញាបត្រថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងអាជីវកម្ម ជំនាញហិរញ្ញវត្ថុ នៅសកលវិទ្យាល័យ Wuhan University of Technology នៃប្រទេសចិន។

- *បទពិសោធន៍ការងារ*
  - តុលា ២០០១-ឧសភា ២០០៥ មន្ត្រីត្រួតពិនិត្យដល់ទីកន្លែង និងលើឯកសារនៃនាយកដ្ឋានត្រួតពិនិត្យនៃធនាគារជាតិនៃកម្ពុជា
  - ឧសភា២០០៥-តុលា ២០០៦ ប្រធានផ្នែកទំនាក់ទំនងខាងហិរញ្ញប្បទានពាណិជ្ជកម្មនៃនាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុសម្រាប់អាជីវកម្មនៃធនាគារ ANZ Royal
  - វិច្ឆិកា ២០០៦-មីនា២០០៨ ប្រធានផ្នែកទំនាក់ទំនងជាន់ខ្ពស់ទទួលបន្ទុកផ្នែកសាជីវកម្មនៃធនាគារ ANZ Royal
  - មេសា ២០០៨-តុលា២០០៩ ប្រធានផ្នែកទំនាក់ទំនងនៃនាយកដ្ឋានកសិកម្ម និងពាណិជ្ជកម្មនៃធនាគារ ANZ Royal ប្រទេសញូហ្សេឡែន
  - តុលា ២០០៩-មីនា ២០១០ នាយកនាយកដ្ឋានសហគ្រាសធុនតូច និងមធ្យម នៃធនាគារ ANZ Royal
  - មេសា ២០១០-មីនា ២០១៦ នាយកនាយកដ្ឋានសេវាកម្មធនាគារសម្រាប់ពាណិជ្ជកម្ម នៃធនាគារ ANZ Royal
  - មីនា ២០១៦-បច្ចុប្បន្ន អគ្គនាយករងនៃធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា
  - មិថុនា ២០១៦-បច្ចុប្បន្ន សមាជិកក្រុមប្រឹក្សាភិបាល ក. ស. ភ.។



លោកស្រី **ជួន សុខេម**
**សមាជិកក្រុមប្រឹក្សាភិបាល**
**តំណាងនិយោជិតកំពង់ផែស្វយ័តភ្នំពេញ**

- *ជនជាតិ* ខ្មែរ
- *សញ្ជាតិ* ខ្មែរ
- *ថ្ងៃ ខែ ឆ្នាំកំណើត* ថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៦៨
- *ប្រវត្តិនៃការសិក្សា*
  - ឆ្នាំ១៩៩២ បានបញ្ចប់មធ្យមសិក្សាទុតិយភូមិ ពីវិទ្យាល័យបាក់ទូក
  - ឆ្នាំ២០០៧ បានបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកគណនេយ្យ/ហិរញ្ញវត្ថុ ពីសកលវិទ្យាល័យធនធានមនុស្ស
  - ឆ្នាំ២០០៨ បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែករដ្ឋបាលសាធារណៈ ពីសកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា។
- *បទពិសោធន៍ការងារ*
  - ឆ្នាំ១៩៩៣-សីហា ២០០៥ បុគ្គលិកការិយាល័យគណនេយ្យ/ហិរញ្ញវត្ថុ
  - សីហា ២០០៥-តុលា ២០០៨ ប្រធានក្រុមនៃអង្គភាពលទ្ធកម្ម ក. ស. ភ.
  - តុលា ២០០៨-សីហា ២០១០ អនុប្រធានការិយាល័យរដ្ឋបាល ក. ស. ភ.
  - សីហា ២០១០-សីហា ២០១៥ ប្រធានការិយាល័យរដ្ឋបាល ក. ស. ភ.
  - សីហា ២០១៥-បច្ចុប្បន្ន ប្រធាននាយកដ្ឋានរដ្ឋបាល ក. ស. ភ.
  - មិថុនា ២០១៦-បច្ចុប្បន្ន សមាជិកក្រុមប្រឹក្សាភិបាល ក. ស. ភ.។

### *ឃ- សេចក្តីសម្រេច និងលទ្ធផលការងាររបស់ក្រុមប្រឹក្សាភិបាល*

សម្រាប់ឆ្នាំ២០១៧ ក. ស. ភ. បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលចំនួន ៥លើក ដូចខាងក្រោម៖

### *១. កិច្ចប្រជុំក្រុមប្រឹក្សាភិបាល លើកទី៤ អាណត្តិទី៦ ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៧*

- បានពិនិត្យ និងអនុម័តលើរបាយការណ៍ស្តីពីលទ្ធផលការងារអាជីវកម្ម/សេវាកម្មឆ្នាំ២០១៦
- បានពិនិត្យ និងសម្រេចឯកភាពលើការស្នើសុំតែងតាំង និងផ្ទេរភារកិច្ចថ្នាក់ដឹកនាំមួយចំនួនរបស់ ក. ស. ភ. ដូចខាងក្រោម៖
  - ផ្ទេរភារកិច្ចឯកឧត្តម ណែម ធីម ពីអគ្គនាយករងអាជីវកម្ម/ប្រតិបត្តិការផែ មកជាអគ្គនាយករងរដ្ឋបាល/ហិរញ្ញវត្ថុ

- តែងតាំងលោកស្រី ហ៊ី ផានិន ជាអគ្គនាយករងអាជីវកម្ម/ប្រតិបត្តិការផែ ជំនួសឯកឧត្តម ណែម ធីម ដែលបានផ្ទេរភារកិច្ចទៅជាអគ្គនាយករងរដ្ឋបាល/ហិរញ្ញវត្ថុ បន្ទាប់ពីលោកជំទាវ គីម សែន ចូលនិវត្តន៍
- ផ្ទេរភារកិច្ច និងតែងតាំងថ្នាក់ប្រធាននាយកដ្ឋានមួយចំនួន ដែលនៅទំនេរ រួមមាន៖
  - តែងតាំង លោក តោ នី ជាប្រធាននាយកដ្ឋានសេវាកម្មនាវាចរណ៍
  - ប្រគល់ភារកិច្ចជូន លោក គង់ សុធា ជាប្រធាននាយកដ្ឋានបុគ្គលិក/ធនធានមនុស្សវិញ
  - ផ្ទេរភារកិច្ច លោក ជី វិចិត្រ ពីប្រធាននាយកដ្ឋានបុគ្គលិក/ធនធានមនុស្ស ទៅជាប្រធាននាយកដ្ឋានវិស្វកម្ម
  - តែងតាំង លោក ហ៊ុន សុខាល័យ ជាប្រធានស្តីទីនាយកដ្ឋានផែនការ/ទីផ្សារ

- បានពិនិត្យ និងសម្រេចយល់ព្រមជាគោលការណ៍បន្តកិច្ចសន្យាជូនទីប្រឹក្សាអម ក. ស. ភ. ចំនួន ៦រូប នាពេលបច្ចុប្បន្ន និងបានសម្រេចយល់ព្រមជាគោលការណ៍តែងតាំងអគ្គនាយករង ចំនួន ២ រូប គឺលោកជំទាវ គីម សែន និងឯកឧត្តម ណែម ធីម ជាទីប្រឹក្សាអម ក. ស. ភ. បន្ទាប់ពីចូលនិវត្តន៍ រហូតដល់បំណាច់ឆ្នាំ២០១៨
- បានពិនិត្យ និងសម្រេចយល់ព្រមជាគោលការណ៍ឱ្យ ក. ស. ភ. អនុវត្តតាមគោលការណ៍របស់រាជរដ្ឋាភិបាលដំឡើងប្រាក់ឧបត្ថម្ភប្រពន្ធ ១៥.០០០ រៀល និងកូន ១០.០០០ រៀល និងមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សចាប់ពី ១.០០០.០០១ រៀល
- បានពិនិត្យ និងសម្រេចឯកភាពឱ្យ ក. ស. ភ. បន្តជួលសេវា របស់ក្រុមហ៊ុនសវនកម្មឯករាជ្យKPMG សម្រាប់ការធ្វើសវនកម្ម និងសេវាត្រួតពិនិត្យលើរបាយការណ៍ប្រចាំ ត្រីមាសនីមួយៗ សម្រាប់ឆ្នាំ២០១៧ បន្តទៀត
- បានពិនិត្យ និងធ្វើការវាយតម្លៃខ្ពស់លើកិច្ចសហប្រតិបត្តិការរវាង ក. ស. ភ. និងក្រុមហ៊ុនយុនណាន សេងមៅ អ៊ិនវេសម៉ិន (ខេមបូឌា) ឯ.ក ដើម្បីវិនិយោគដីទីលានស្តុកសំបកកុងតឺន័រ (ICD) ឱ្យទៅជាមជ្ឈមណ្ឌលផ្គត់ផ្គង់គ្រឿងសំណង់ (CMSC)
- បានពិនិត្យ និងសម្រេចឱ្យ ក. ស. ភ. ពិគ្រោះយោបល់ជាមុនជាមួយគណៈកម្មការមូលបត្រកម្ពុជា (គ. ម. ក.) លើសេចក្តីព្រាងតារាងពេលវេលា និងកម្មវិធីការងារសម្រាប់បែងចែក ភាគលាភឆ្នាំ ២០១៦ និងដំណើរការរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី២ មុននឹងដាក់ជូនអង្គប្រជុំក្រុមប្រឹក្សាភិបាល (នៅដើមខែមីនា ឆ្នាំ២០១៧) នាពេលក្រោយដើម្បីធ្វើការសម្រេចជាផ្លូវការ។

### *៧. កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៥ អាណត្តិទី៦ ថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៧*

- បានពិនិត្យ និងអនុម័តលើរបាយការណ៍លទ្ធផលហិរញ្ញវត្ថុ សម្រាប់ការិយបរិច្ឆេទ២០១៦ ដែលបានធ្វើសវនកម្មដោយសវនករឯករាជ្យ KPMG

- បានពិនិត្យ និងសម្រេចលើការកំណត់បែងចែកប្រាក់ថ្លែងសរសើរជូនថ្នាក់ដឹកនាំ និងនិយោជិក ក. ស. ភ. ស្មើនឹងចំនួន ៣ខែ នៃប្រាក់បៀវត្សសរុបជាមធ្យមប្រចាំឆ្នាំ និង ការបែងចែកប្រាក់ចំណេញចូលមូលនិធិនានាប្រចាំឆ្នាំ២០១៦
- បានពិនិត្យ និងសម្រេច លើការបែងចែកភាគលាភជូនភាគហ៊ុនិក ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតប្រភេទ "ក" និងប្រភេទ "ខ" ឆ្នាំ២០១៦ និងភាគលាភបង្គរឆ្នាំ២០១៥
- បានពិនិត្យ និងសម្រេចលើកាលបរិច្ឆេទ របៀបវារៈ និងទីកន្លែង នៃការរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី២ របស់ ក. ស. ភ.
- បានពិនិត្យ និងសម្រេចអនុញ្ញាតឱ្យក្រុមហ៊ុន CHEAN CHHOENG THAI GROUP ធ្វើការសិក្សាលម្អិតអំពីគម្រោង, អំពីផលសេដ្ឋកិច្ចនៃគម្រោង, អំពីផលប៉ះពាល់ពាក់ព័ន្ធពីគម្រោង និងលើកគម្រោងដាក់ស្តែងដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេច ហើយក្នុងករណីចាំបាច់ នឹងអនុញ្ញាតឱ្យ ក. ស. ភ លើកសំណើជូនក្រសួងអាណាព្យាបាលទាំងពីរ ដើម្បីពិនិត្យ សម្រេច។

### *៣. កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៦ អាណត្តិទី៦ កាលពីថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៧*

- បានពិនិត្យ និងអនុម័តរបាយការណ៍សកម្មភាពការងាររយៈពេល ៦ខែ ឆ្នាំ២០១៧
- បានពិនិត្យ និងអនុម័តរបាយការណ៍របស់សវនករឯករាជ្យ KPMG ប្រចាំត្រីមាសទី២ ឆ្នាំ២០១៧
- បានពិនិត្យ និងអនុម័តរបាយការណ៍របស់សវនកម្មផ្ទៃក្នុងប្រចាំត្រីមាសទី២ ឆ្នាំ២០១៧
- បានពិនិត្យ និងសម្រេចលើការជ្រើសរើសយកក្រុមហ៊ុនសវនកម្មឯករាជ្យ BDO ដើម្បីធ្វើការត្រួតពិនិត្យលើរបាយការណ៍ប្រចាំត្រីមាសនីមួយៗ និងធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ សម្រាប់រយៈពេល ៣ ឆ្នាំ ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២០
- បានពិនិត្យ និងឯកភាពឱ្យ ក. ស. ភ. បន្តជួលសេវារបស់ក្រុមហ៊ុន Ernst & Young សម្រាប់គណនាប្រាក់សោធននិវត្តន៍របស់បុគ្គលិក ក. ស. ភ. រយៈពេល ៣ ឆ្នាំ ចាប់ពីឆ្នាំ២០១៧ រហូតដល់ឆ្នាំ២០១៩
- បានពិនិត្យ និងពិភាក្សាលើគម្រោងអភិវឌ្ឍន៍មជ្ឈមណ្ឌលពាណិជ្ជកម្មចំរុះ "THE CITY GATE" របស់ក្រុមហ៊ុនចៀន ឈឹង ថៃ គ្រុប នៅលើទីតាំងចំណតផែបណ្តែត TS១ និងចំណតផែថ្មTS៣
- បានពិនិត្យ និងសម្រេចលើការកែសម្រួលសមាសភាពគណៈកម្មាធិការតែងតាំង នៃក្រុមប្រឹក្សា-ភិបាល
- បានពិនិត្យ និងសម្រេចលើការស្នើសុំពន្យារពេលបង់ថ្លៃជួលដីនៅទីលានស្តុកទុកសំបកកុងតឺន័រ (ICD) របស់ក្រុមហ៊ុន យុនណាន សេងមៅ អ៊ិនវេសមិន ឯ.ក (ខេមបូឌា)
- បានពិនិត្យ និងសម្រេចដាក់នាយកដ្ឋានសវនកម្មផ្ទៃក្នុង ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការសវនកម្ម នៃក្រុមប្រឹក្សាភិបាល ក. ស. ភ.
- បានពិនិត្យ និងសម្រេចលើសំណើសុំជំរះបញ្ជីគ្រឿងចក្រ និងសម្ភារចាស់ៗ ចេញពីបញ្ជី ដោយអចលនទ្រព្យរបស់ ក. ស. ភ. ស្នើសុំការសម្រេចពីក្រសួងអាណាព្យាបាលទាំងពីរ និងអនុញ្ញាតឱ្យ

ក. ស. ភ. ធ្វើលិខិតស្នើសុំឧបត្ថម្ភរថយន្តរដ្ឋបាលចំនួន ៣ គ្រឿងជូនអតីតអគ្គនាយករង ក. ស. ភ. ចំនួន ៣ រូបទៅក្រសួងអាណាព្យាបាលទាំងពីរ

- បានពិនិត្យ និងសម្រេចអនុញ្ញាតឱ្យ ក. ស. ភ. អនុវត្តការងាររៀបចំពង្រីងទីលានផ្ទុកសំបកកុងតឺន័រ LM១៧ នៅលើទំហំ ១ ហិកតា បន្ថែម ប៉ែកខាងត្បូងនៃអគាររដ្ឋបាល ដោយធ្វើនិយ័តផលានទានថវិកាពីគម្រោងមិនទាន់ចាំបាច់ពាក់ព័ន្ធ សម្រាប់ការអនុវត្តគម្រោងនេះ
- បានពិនិត្យ និងសម្រេចអនុញ្ញាតឱ្យ ក. ស. ភ. ធ្វើការសិក្សាជាមួយក្រុមហ៊ុន Solar Partner Asia (Cambodia) Ltd. លើលទ្ធភាពធ្វើកិច្ចសហប្រតិបត្តិការ ដើម្បីបង្កើតប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ដោយពន្លឺព្រះអាទិត្យនៅចំណតផែកុងតឺន័រ LM១៧
- បានពិនិត្យ និងសម្រេចអនុញ្ញាតឱ្យ ក. ស. ភ. ធ្វើការសិក្សាជាមួយក្រុមហ៊ុនមកពីខេត្ត Anhui នៃសាធារណរដ្ឋប្រជាមានិតចិន លើលទ្ធភាពធ្វើកិច្ចសហប្រតិបត្តិការបង្កើតចំណតផែលើកដាក់ ផ្ទេរ ផ្ទុក ធ្យូងថ្ម ស៊ីម៉ង់ត៍ និងវត្ថុធាតុដើមគ្រឿងសំណង់ក្នុងស្រុក
- បានពិនិត្យ និងសម្រេចអនុញ្ញាតឱ្យ ក. ស. ភ. ធ្វើការសិក្សាជាមួយក្រុមហ៊ុន Mekong Oryza Trading Co., Ltd. លើលទ្ធភាពធ្វើកិច្ចសហប្រតិបត្តិការបង្កើតឃ្លាំងត្រជាក់ សម្រាប់ប្រមូល ផ្លែឈើវេចខ្ចប់នាំចេញ
- បានពិនិត្យ និងសម្រេចអនុញ្ញាតឱ្យ ក. ស. ភ. ធ្វើការសិក្សាជាមួយក្រុមហ៊ុន Green Trade លើលទ្ធភាពធ្វើកិច្ចសហប្រតិបត្តិការ ដើម្បីបង្កើតរោងចក្រកែច្នៃស្រូវ អង្ករ (Rice Processing Facility) តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP) សម្រាប់ការនាំចេញអង្ករ និង កសិផលផ្សេងៗ
- បានពិនិត្យ និងសម្រេចអនុញ្ញាតឱ្យ ក. ស. ភ. ធ្វើការសិក្សាលើករណីក្រុមហ៊ុន Mekong Sentosa Logistics (MSL) ដែលមានបំណងបញ្ឈប់អាជីវកម្ម ថាតើ ក. ស. ភ. គួរទទួលយកការងារនេះបន្ត ឬយ៉ាងណា។

## *៩.កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ជាវិសាមញ្ញលើកទី៧ អាណត្តិទី៦ នាថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧*

- បានពិនិត្យ និងអនុម័តលើរបាយការណ៍ស្ដីពីលទ្ធផលការងារបឋមរយៈពេល ៩ខែ ឆ្នាំ២០១៧ របស់ ក. ស. ភ.
- បានពិនិត្យ និងសម្រេចតែងតាំង លោក តោ នី ជាអគ្គនាយករងរដ្ឋបាល/ហិរញ្ញវត្ថុ ជំនួសឯកឧត្តម ណែម ធីម ដែលចូលនិវត្ត និងផ្ទេរភារកិច្ចលោក តុល សុខុម ពីប្រធាននាយកដ្ឋានប្រតិបត្តិការចំណតផែTS៣ មកជាប្រធាននាយកដ្ឋានសេវាកម្មនាវាចរណ៍ជំនួសលោក តោ នី
- បានពិនិត្យ និងគាំទ្រលទ្ធផលនៃកិច្ចប្រជុំរបស់គណៈកម្មការអន្តរក្រសួង លើការសិក្សាវាយតម្លៃទីតាំងចំណតផែថ្មTS៣ និងចំណតផែបណ្ដោតTS១ របស់ ក. ស. ភ. ដែលត្រូវជួលឱ្យក្រុមហ៊ុន ចៀន ឈឹង ថៃ គ្រុប

- បានពិនិត្យ និងសម្រេចពិចារណាលើការបង្កើនភាគលាភ ជូនភាគហ៊ុនិកមានសិទ្ធិបោះ-ឆ្នោត ប្រភេទ "ក" ក្នុងចំនួន ៦% សម្រាប់ឆ្នាំ២០១៧ បើលទ្ធផលអាជីវកម្ម/ហិរញ្ញវត្ថុប្រចាំឆ្នាំ២០១៧ សម្រេចបានតាមការប៉ាន់ស្មានទុក
- បានពិនិត្យ និងសម្រេចឱ្យក្រុមហ៊ុន យុនណាន សេងមៅ អ៊ិនវេសម៉ិន (ខេមបូឌា) ឯ.ក ប្តូរឈ្មោះគម្រោងពី "មជ្ឈមណ្ឌលផ្គត់ផ្គង់គ្រឿងសំណង់ (CMSC)" ទៅជា "មជ្ឈមណ្ឌលពាណិជ្ជកម្ម Triumph កម្ពុជា" ដោយត្រូវអនុវត្តតាមនីតិវិធីច្បាប់ជាធរមាន។

### ៥. កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៨ អាណត្តិទី៦ នាថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧

- បានពិភាក្សា និងអនុម័តផែនការអាជីវកម្ម សេវាកម្ម និងហិរញ្ញវត្ថុ ឆ្នាំ២០១៨ របស់ ក. ស. ភ.
- បានពិនិត្យ និងសម្រេចអនុញ្ញាតឱ្យ ក. ស. ភ. ធ្វើកិច្ចសហការជាមួយក្រុមហ៊ុន Infunde Development Pte. Ltd. លើការសិក្សាគម្រោងផ្គត់ផ្គង់ថាមពលអគ្គិសនី ដើរដោយពន្លឺ ព្រះអាទិត្យ (Solar Power) នៅចំណតផែកុងតឺន័រ LM១៧។

## ង-ការបណ្តុះបណ្តាលអភិបាល

សម្រាប់ឆ្នាំ២០១៧ ក. ស. ភ. បានចាត់បញ្ជូន **លោក ឌិត សុចល** អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ដើម្បីចូលរួមក្នុងកិច្ចប្រជុំលើកទី១០ នៃបណ្តាញអាស៊ី ដើម្បីអភិវឌ្ឍអភិបាលកិច្ចសាជីវកម្ម សម្រាប់សហគ្រាសសាធារណៈ (10th Meeting of the Asia Network on Corporate of State-owned Enterprise) ដែលរៀបចំឡើងដោយអង្គការសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច-អាស៊ីអាគ្នេយ៍ (OECD) ពីថ្ងៃទី១៩ ដល់ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៧ នៅប្រទេសម៉ាឡេស៊ី។

## ច-គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាភិបាល

សម្រាប់ឆ្នាំ២០១៧ ក. ស. ភ. បានបង្កើតគណៈកម្មាធិការតែងតាំង នៃក្រុមប្រឹក្សាភិបាល ដែលមានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| ១. អភិបាលតំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធាន |
| ២. អភិបាលតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣. អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន | សមាជិក។ |

## ៤- បុគ្គលិកជាន់ខ្ពស់

### ក- សមាសភាពបុគ្គលិកជាន់ខ្ពស់



ឯកឧត្តម **ហ៊ី បាវី**
**អគ្គនាយកកំពង់ផែស្វយ័តភ្នំពេញ**

- *ជនជាតិខ្មែរ* សញ្ជាតិខ្មែរ
- *ថ្ងៃខែឆ្នាំកំណើត* ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៥៥
- *ប្រវត្តិនៃការសិក្សា*
  - ឆ្នាំ១៩៧៤ បញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិនៅវិទ្យាល័យដូនពេញ
  - ឆ្នាំ២០០៨ បញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែករដ្ឋបាលធុរកិច្ចពីសកលវិទ្យាល័យ Charles Sturt ប្រទេសអូស្ត្រាលី
  - ឆ្នាំ២០០៩ បញ្ចប់ថ្នាក់បណ្ឌិតផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច ពីសកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យាកម្ពុជា។
- *បទពិសោធន៍ការងារ*
  - ឆ្នាំ១៩៧៩ បានចាប់បម្រើការងារនៅ ក.ស.ភ. រហូតមកដល់បច្ចុប្បន្ន
  - ពីឆ្នាំ២០០០ - បច្ចុប្បន្ន ជាអគ្គនាយក និងជាប្រធានក្រុមប្រឹក្សាភិបាល ក.ស.ភ.។



លោក **ម៉ម រិទ្ធី**
**មន្ត្រីត្រួតពិនិត្យរដ្ឋ**

- *ជនជាតិខ្មែរ* សញ្ជាតិខ្មែរ
- *ថ្ងៃខែឆ្នាំកំណើត* ថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៧២
- *ប្រវត្តិនៃការសិក្សា*
  - ឆ្នាំ១៩៨៥ បញ្ចប់ថ្នាក់មធ្យមសិក្សាកំរិត២ នៅសាលាដូនពេញ

- ឆ្នាំ១៩៩៦ បញ្ចប់ថ្នាក់បរិញ្ញាបត្រសេដ្ឋកិច្ចកសិកម្ម ពីសាកលវិទ្យាល័យកសិកម្ម និងព្រៃឈើ ទីក្រុងហូជីមិញ ប្រទេសវៀតណាម
- ឆ្នាំ២០០៧ ទទួលសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ពីសកលវិទ្យាល័យឯកទេសនៃកម្ពុជា។

- *បទពិសោធន៍ការងារ*
  - ឆ្នាំ១៩៩១ បានចូលបម្រើការងារជាមន្ត្រីនៅនាយកដ្ឋានរបបគណនេយ្យនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  - ពីឆ្នាំ២០១៣-បច្ចុប្បន្ន ជាអនុប្រធាននាយកដ្ឋានចំណូលពីទ្រព្យសម្បត្តិរដ្ឋ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  - ពីឆ្នាំ២០០១-បច្ចុប្បន្ន ជាមន្ត្រីត្រួតពិនិត្យរដ្ឋអម ក.ស.ភ.។



លោក **តោ នី**
**អគ្គនាយករងរដ្ឋបាល/ហិរញ្ញវត្ថុ**

- *ជនជាតិ* ខ្មែរ
- *សញ្ជាតិ* ខ្មែរ
- *ថ្ងៃ ខែ ឆ្នាំ កំណើត* ថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៥៨
- *ប្រវត្តិការសិក្សា*
  - ឆ្នាំ១៩៧៣ បានបញ្ចប់ថ្នាក់ មធ្យមសិក្សាទុតិយភូមិ ពីវិទ្យាល័យទួលទំពូង ភ្នំពេញ
  - ឆ្នាំ១៩៨៩ បានបញ្ចប់ថ្នាក់ Diploma Technical Navigator ពី Kherson Maritime Instituteសហភាពសូវៀត ( Union of Soviet Socialist Republics )

- *បទពិសោធន៍ការងារ*
  - ឆ្នាំ ១៩៧៩ ជាប៉ូលីសកងការពារ ក្រុងភ្នំពេញ
  - ឆ្នាំ ១៩៩០ ផ្ទេរចូលមកបំរើការងារជាបុគ្គលិក ក. ស. ភ. ជាកណ្ណធារ
  - ឆ្នាំ ២០០៧ ជាអនុប្រធានសេវាដ្ឋាននាវាចរណ៍ និងកណ្ណធារ
  - ឆ្នាំ ២០១១ ជាប្រធានអង្គភាពកណ្ណធារ
  - ឆ្នាំ ២០១៤ ជាប្រធានសេវាដ្ឋាននាវាចរណ៍
  - ឆ្នាំ ២០១៥ ជាប្រធានការិយាល័យកណ្ណធារ
  - ខែកុម្ភៈ ឆ្នាំ២០១៧ ជាប្រធាននាយកដ្ឋានសេវាកម្មនាវាចរណ៍ ក. ស. ភ.
  - ខែវិច្ឆិកា ឆ្នាំ២០១៧ ជាអគ្គនាយករងទទួលបន្ទុករដ្ឋបាល/ហិរញ្ញវត្ថុ។



លោក **ភុយ ម៉ិនធន**
**អគ្គនាយករងបច្ចេកទេស**

- *ជនជាតិ* ខ្មែរ
- *សញ្ជាតិ* ខ្មែរ
- *ថ្ងៃខែឆ្នាំកំណើត* ថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៦៤
- *ប្រវត្តិនៃការសិក្សា*
  - ឆ្នាំ១៩៨៨ បញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ
  - ឆ្នាំ១៩៩៤ បញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកវិទ្យាសាស្ត្រម៉ាស៊ីនពីសកលវិទ្យាល័យសំណង់ម៉ាស៊ីនលើកដាក់
  - ឆ្នាំ២០០០ បញ្ចប់ថ្នាក់បណ្ឌិតផ្នែកវិទ្យាសាស្ត្របច្ចេកទេស នៅសកលវិទ្យាល័យសាន់ពែទែ្សបួកនៃប្រទេសរុស្ស៊ី ។
- *បទពិសោធន៍ការងារ*
  - ឆ្នាំ១៩៨៥ ចូលបម្រើការងារ នៅ ក.ស.ភ.
  - ឆ្នាំ២០០៩-២០១៥ ជានាយកវិស្វកម្ម
  - ខែសីហា ឆ្នាំ២០១៥-កញ្ញា ឆ្នាំ២០១៦ ជាប្រធាននាយកដ្ឋានវិស្វកម្ម
  - ខែកញ្ញា ឆ្នាំ២០១៦ ដល់បច្ចុប្បន្ន ជាអគ្គនាយករងទទួលបន្ទុកបច្ចេកទេស។



លោក **ហៀក តិរុណា**
**អគ្គនាយករងកិច្ចការផែ**

- *ជនជាតិ* ខ្មែរ
- *សញ្ជាតិ* ខ្មែរ
- *ថ្ងៃខែឆ្នាំកំណើត* ថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៧២
- *ប្រវត្តិនៃការសិក្សា*
  - ឆ្នាំ១៩៩០ បញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ

- ឆ្នាំ១៩៩៧ បញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកវិទ្យាសាស្ត្របើកបរនាវាផ្លូវសមុទ្រ (Master of Science Degree in Engineering of Navigation on Sea Routes) ពីសកលវិទ្យាល័យ Murmansk State Technical នៃប្រទេសរុស្ស៊ី
- ឆ្នាំ២០០១ បញ្ចប់ថ្នាក់អនុបណ្ឌិត (MBA-Maritime Management) ពីសកលវិទ្យាល័យ Australian Maritime នៃប្រទេសអូស្ត្រាលី។

- *បទពិសោធន៍ការងារ*
  - ឆ្នាំ១៩៩៧ ចូលបម្រើការងារនៅ ក.ស.ភ.
  - ឆ្នាំ២០១១ ជានាយកផ្នែកជលធារាសាស្ត្រ
  - ឆ្នាំ២០១៩ - បច្ចុប្បន្ន ជាអគ្គនាយករងកិច្ចការផែ។
  -



លោកស្រី **ហ៊ឺ ផានិន**
**អគ្គនាយករងអាជីវកម្ម/ប្រតិបត្តិការផែ**

- *ជនជាតិ* ខ្មែរ
- *សញ្ជាតិ* ខ្មែរ
- *ថ្ងៃខែឆ្នាំកំណើត* ថ្ងៃទី៨ ខែតុលា ឆ្នាំ១៩៨៥

- *ប្រវត្តិនៃការសិក្សា*
  - ឆ្នាំ២០០៣ បញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ ពីវិទ្យាល័យ Killester
  - ឆ្នាំ២០០៨ បញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកភ័ស្តុភារ និងការគ្រប់គ្រងបណ្ដាញផ្គត់ផ្គង់នៅសកលវិទ្យាល័យ RMIT
  - ឆ្នាំ២០១២ បញ្ចប់ថ្នាក់អនុបណ្ឌិតជំនាញលើការគ្រប់គ្រង ពីសកលវិទ្យាល័យ Charles Sturt University ពីប្រទេសអូស្ត្រាលី
- *បទពិសោធន៍ការងារ*
  - ខែមិថុនា ឆ្នាំ២០០៨ បានចូលបម្រើការងារនៅ ក. ស. ភ.
  - ខែកញ្ញា ឆ្នាំ២០០៩ - ខែធ្នូ ឆ្នាំ២០១១ ជានាយកផែនការ/ទីផ្សារ
  - ខែសីហា ឆ្នាំ២០១៥ - ខែកុម្ភៈ ឆ្នាំ២០១៧ ជាប្រធាននាយកដ្ឋានផែនការ/ទីផ្សារ
  - ខែកុម្ភៈ ឆ្នាំ២០១៧ - បច្ចុប្បន្ន ជាអគ្គនាយករងទទួលបន្ទុកអាជីវកម្ម/ប្រតិបត្តិការផែ។



លោក **កែវ សុផាណ្ណារ៉ា**
**ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង**

- *ជនជាតិ* ខ្មែរ
- *សញ្ជាតិ* ខ្មែរ
- *ថ្ងៃខែឆ្នាំកំណើត* ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៣
- *ប្រវត្តិនៃការសិក្សា*
  - ឆ្នាំ១៩៩១ បញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ នៅវិទ្យាល័យព្រះស៊ីសុវត្ថិ
  - ឆ្នាំ២០០៥ បញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកវិស្វករ ពីវិទ្យាស្ថានពហុបច្ចេកវិទ្យាភ្នំពេញ និង ទទួលបានសញ្ញាបត្រអនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ពីសកលវិទ្យាល័យជាតិគ្រប់គ្រង។
- បទពិសោធន៍ការងារ
  - ពីខែមករា ឆ្នាំ១៩៩៧ បានចូលបម្រើការងារនៅ ក. ស. ភ.
  - ឆ្នាំ២០១០ ជាប្រធានការិយាល័យផែនការ
  - ឆ្នាំ២០១៤-២០១៥ ជាប្រធានអង្គភាពលទ្ធកម្ម
  - ឆ្នាំ២០១៥-បច្ចុប្បន្ន ជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង។



លោកស្រី **ជួន សុខេម**
**ប្រធាននាយកដ្ឋានរដ្ឋបាល**

- *ជនជាតិ* ខ្មែរ
- *សញ្ជាតិ* ខ្មែរ
- *ថ្ងៃខែឆ្នាំកំណើត* ថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៦៨
- *ប្រវត្តិនៃការសិក្សា*
  - ឆ្នាំ២០០៧ បញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកគណនេយ្យហិរញ្ញវត្ថុពីសកលវិទ្យាល័យធនធានមនុស្ស បន្ទាប់មកទទួលសញ្ញាបត្រអនុបណ្ឌិតផ្នែករដ្ឋបាលសាធារណៈនៅសកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា

- <u>បទពិសោធន៍ការងារ</u>
  - ឆ្នាំ១៩៨៦ បានចូលបម្រើការងារនៅ ក.ស.ភ.
  - ឆ្នាំ២០០៩ ជាអនុប្រធានការិយាល័យគណនេយ្យ/ហិរញ្ញវត្ថុ
  - ឆ្នាំ២០១០-២០១៥ ជាប្រធានការិយាល័យរដ្ឋបាល
  - ឆ្នាំ២០១៥-បច្ចុប្បន្ន ជាប្រធាននាយកដ្ឋានរដ្ឋបាល



លោក **គង់ សុធា**
**ប្រធាននាយកដ្ឋានបុគ្គលិក/ធនធានមនុស្ស**

- *<u>ជនជាតិ</u>* ខ្មែរ
- *<u>សញ្ជាតិ</u>* ខ្មែរ
- *<u>ថ្ងៃខែឆ្នាំកំណើត</u>* ថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៦៨
- *<u>ប្រវត្តិនៃការសិក្សា</u>*
  - ឆ្នាំ១៩៨៨ សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ នៅវិទ្យាល័យបឹងត្របែក
  - ឆ្នាំ២០០២ សញ្ញាបត្របរិញ្ញាបត្រផ្នែកគ្រប់គ្រងសហគ្រាស ពីសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាល័យសេដ្ឋកិច្ច
  - ឆ្នាំ២០០៦ សញ្ញាបត្រអនុបណ្ឌិតផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច ពីសាកលវិទ្យាល័យចំរើន ពហុបច្ចេកវិទ្យា។
- *<u>បទពិសោធន៍នៃការងារ</u>*
  - ឆ្នាំ១៩៨៩ បានចូលបម្រើការងារនៅ ក. ស. ភ.
  - ឆ្នាំ២០១០ ជាប្រធានការិយាល័យគណនេយ្យ/ហិរញ្ញវត្ថុ
  - ឆ្នាំ២០១៤ ជាប្រធានការិយាល័យបុគ្គលិក
  - ខែសីហា ឆ្នាំ២០១៥-បច្ចុប្បន្ន ជាប្រធាននាយកដ្ឋានបុគ្គលិក/ធនធានមនុស្ស



កញ្ញា **ឈាវ វណ្ណធា**
**ប្រធាននាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ**

- *ជនជាតិ* ខ្មែរ
- *សញ្ជាតិ* ខ្មែរ
- *ថ្ងៃខែឆ្នាំកំណើត* ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៨៣
- *ប្រវត្តិនៃការសិក្សា*
  - ឆ្នាំ២០០១ សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ នៅវិទ្យាល័យ ហ៊ុន សែន ខ្សាច់កណ្តាល
  - ឆ្នាំ ២០០៦ បរិញ្ញាបត្រផ្នែកគណនេយ្យ ពីសកលវិទ្យាល័យន័រតុន
- *បទពិសោធន៍នៃការងារ*
  - ឆ្នាំ២០០៨ បានចូលបម្រើការងារនៅ ក.ស.ភ.
  - ឆ្នាំ២០១០ ជាអនុប្រធានការិយាល័យគណនេយ្យ/ហិរញ្ញវត្ថុ
  - ឆ្នាំ២០១៤ ជាប្រធានការិយាល័យគណនេយ្យ/ហិរញ្ញវត្ថុ
  - ឆ្នាំ២០១៥ ជាប្រធាននាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ។



លោក **យឹម ឡឿន**
**ប្រធាននាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧**

- *ជនជាតិ* ខ្មែរ
- *សញ្ជាតិ* ខ្មែរ
- *ថ្ងៃខែឆ្នាំកំណើត* ថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៦២
- *ប្រវត្តិនៃការសិក្សា*
  - ឆ្នាំ១៩៨៦ បញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិពីសាលាបំពេញវិជ្ជាមជ្ឈឹម
  - ឆ្នាំ១៩៩៣ បញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកវិទ្យាសាស្ត្របើកបរនាវាផ្លូវសមុទ្រ (Master of Science Degree in Engineering of Navigation on Sea Routes) នៅសកលវិទ្យាល័យ Odessa State Maritime Academy នៃប្រទេសអ៊ុយក្រែន។

- *បទពិសោធន៍ការងារ*
  - ឆ្នាំ១៩៧៩ បានចូលបម្រើការងារ នៅ ក. ស. ភ.
  - ឆ្នាំ២០០៩ ជាប្រធានការិយាល័យនាវាចរណ៍
  - ឆ្នាំ២០១១ ជានាយកសេវាកម្ម នាវាចរណ៍
  - ឆ្នាំ២០១៥-ខែមិថុនា ឆ្នាំ២០១៦ ជាប្រធាននាយកដ្ឋានសេវាកម្មនាវាចរណ៍។
  - ខែមិថុនា ឆ្នាំ២០១៦-បច្ចុប្បន្ន ជាប្រធាននាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧។



លោក **ជៀប ទីរ៉ាយ៉ា**
**ប្រធាននាយកដ្ឋានជលធារសាស្ត្រ**

- *ជនជាតិ* ខ្មែរ
- *សញ្ជាតិ* ខ្មែរ
- *ថ្ងៃខែឆ្នាំកំណើត* ថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៨៧
- *ប្រវត្តិនៃការសិក្សា*
  - ឆ្នាំ២០០៤ បញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ នៅវិទ្យាល័យបាក់ទូក
  - ឆ្នាំ២០០៨ បញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ ពីសកលវិទ្យាល័យភូមិន្ទភ្នំពេញ។
- *បទពិសោធន៍ការងារ*
  - ពីខែកញ្ញា ឆ្នាំ២០០៩ បានចូលបម្រើការងារ នៅ ក. ស. ភ.
  - ឆ្នាំ២០១២ ជាអនុប្រធានសេវាដ្ឋាននាវាចរណ៍
  - ឆ្នាំ២០១៤ ជាប្រធានសេវាដ្ឋានថែទាំពោងសញ្ញា
  - ចាប់ពីខែសីហា ឆ្នាំ២០១៥-បច្ចុប្បន្ន ជាប្រធាននាយកដ្ឋានជលធារសាស្ត្រ



លោក **សយ សេរីសុខឧត្តម**
**ប្រធាននាយកដ្ឋានមណ្ឌលអាជីវកម្មផែ/ផែក្នុងស្រុក**

- *ជនជាតិ* ខ្មែរ
- *សញ្ជាតិ* ខ្មែរ
- *ថ្ងៃខែឆ្នាំកំណើត* ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៨៤
- *ប្រវត្តិនៃការសិក្សា*
  - ឆ្នាំ២០០០ បញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ ពីវិទ្យាល័យព្រះស៊ីសុវត្ថិ
  - ឆ្នាំ២០០៣ បញ្ចប់ថ្នាក់បរិញ្ញាបត្ររង ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង
  - ឆ្នាំ២០០៩ បញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រ ពីសកលវិទ្យាល័យកូឡូញ ប្រទេសអាល្លឺម៉ង់
  - ឆ្នាំ២០១២ បញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកហិរញ្ញវត្ថុ ពីសកលវិទ្យាល័យ Chales Sturt University of Australia ។
- *បទពិសោធន៍ការងារ*
  - ពីខែកញ្ញា ឆ្នាំ២០០៩ បានចូលបម្រើការងារនៅ ក.ស.ភ.
  - ឆ្នាំ២០១០ ជាអនុប្រធានការិយាល័យគណនេយ្យ/ហិរញ្ញវត្ថុ
  - ឆ្នាំ២០១៣ ជាប្រធានសេវាដ្ឋានផែក្នុងស្រុក
  - ចាប់ពីខែសីហា ឆ្នាំ២០១៥-បច្ចុប្បន្ន ជាប្រធានសេវាដ្ឋានមណ្ឌលអាជីវកម្មផែក្នុងស្រុករបស់ ក.ស.ភ។



លោក **ហ៊ុន សុខាល័យ**
**ប្រធាននាយកដ្ឋានផែនការ/ទីផ្សារ**

- *ជនជាតិ* ខ្មែរ
- *សញ្ជាតិ* ខ្មែរ
- *ថ្ងៃខែឆ្នាំកំណើត* ថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៨២
- *ប្រវត្តិនៃការសិក្សា*

- ឆ្នាំ១៩៩៩ បញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ ពីវិទ្យាល័យច្បារអំពៅ
- ឆ្នាំ២០០៤ បញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច ពីវិទ្យាស្ថានបច្ចេកវិទ្យា និងគ្រប់គ្រង
- ឆ្នាំ២០១០ បញ្ចប់ការសិក្សាអនុបណ្ឌិតផ្នែកវិទ្យាសាស្ត្រគ្រប់គ្រង និងដឹកជញ្ជូនតាមសមុទ្រពីសកលវិទ្យាល័យ Antwerp នៃប្រទេសប៊ែលហ្សិក
- ឆ្នាំ២០១៣ បញ្ចប់ការសិក្សាអនុបណ្ឌិតផ្នែកវិទ្យាសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចពីសាកលវិទ្យាល័យ យ៉ុង ណាំ (Yeungnam Univeristy) នៃប្រទេសកូរ៉េខាងត្បូង។

- *បទពិសោធន៍ការងារ*
  - ឆ្នាំ២០០៦ បានចូលបម្រើការងារនៅ ក.ស.ភ.
  - ឆ្នាំ២០១០ ជាអនុប្រធានការិយាល័យកិច្ចការជំនួញ
  - ឆ្នាំ២០១១ ជាប្រធានការិយាល័យស្រាវជ្រាវ និងអភិវឌ្ឍន៍ថ្មី
  - ឆ្នាំ២០១៣ ជាប្រធានអង្គភាពតម្លៃ/ទីផ្សារ
  - ឆ្នាំ២០១៣ ជាប្រធានអង្គភាពវិក័យបត្រ
  - ឆ្នាំ២០១៤ ជាប្រធានការិយាល័យតម្លៃ/ទីផ្សារ
  - ខែកុម្ភៈ ឆ្នាំ២០១៧ ជាប្រធានស្ដីទីនាយកដ្ឋានផែនការ/ទីផ្សារ
  - ខែវិច្ឆិកា ឆ្នាំ២០១៧ ជាប្រធាននាយកដ្ឋានផែនការ/ទីផ្សារ។



លោក **តុល សុខុម**

**ប្រធាននាយកដ្ឋានសេវាកម្មនាវាចរណ៍**

- *ជនជាតិ* ខ្មែរ
- *សញ្ជាតិ* ខ្មែរ
- *ថ្ងៃខែឆ្នាំកំណើត* ថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៦៦
- *ប្រវត្តិនៃការសិក្សា*
  - ឆ្នាំ១៩៨៧ បញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ នៅវិទ្យាល័យព្រះយុគន្ធរ
  - ឆ្នាំ១៩៩៥ បញ្ចប់ថ្នាក់អនុបណ្ឌិត ផ្នែកវិទ្យាសាស្ត្រវិស្វកម្មបើកបរនាវាផ្លូវសមុទ្រ (Master of Science Degree in Engineering of Navigation on Sea Routes) ពីសកលវិទ្យាល័យ Odessa State Maritime Academy នៃប្រទេសអ៊ុយក្រែន។
  - ឆ្នាំ២០០៩ បញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកអក្សរសាស្ត្រអង់គ្លេសពីសកលវិទ្យាល័យអាស៊ីអឺរ៉ុប។
- *បទពិសោធន៍ការងារ*

- ឆ្នាំ១៩៨០ បានចូលបម្រើការងារនៅ ក.ស.ភ.
- ឆ្នាំ២០០៩ ជាប្រធានសេវាដ្ឋាននាវាចរណ៍
- ឆ្នាំ២០១៤ ជានាយកប្រតិបត្តិការចំណតផែ TS៣
- ឆ្នាំ២០១៥ ជាប្រធាននាយកដ្ឋានប្រតិបត្តិការចំណតផែ TS៣
- ខែវិច្ឆិកា ឆ្នាំ២០១៧ ជាប្រធាននាយកដ្ឋានសេវាកម្មនាវាចរណ៍ និងជាប្រធានក្រុមការងារប្រតិបត្តិការចំណតផែTS៣។



លោក **ជី ទិចិត្រ**
**ប្រធាននាយកដ្ឋានវិស្វកម្ម**

- *ជនជាតិ* ខ្មែរ
- *សញ្ជាតិ* ខ្មែរ
- *ថ្ងៃខែឆ្នាំកំណើត* ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ១៩៧៧
- *ប្រវត្តិនៃការសិក្សា*
  - ឆ្នាំ១៩៩៥ បញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិពីវិទ្យាល័យទួលទំពូង
  - ឆ្នាំ២០០១ បញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកពាណិជ្ជកម្មពីសកលវិទ្យាល័យន័រតុន
  - ឆ្នាំ២០១០ បញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកវិទ្យាសាស្ត្រគ្រប់គ្រង និងដឹកជញ្ជូនតាមសមុទ្រ ពីសកលវិទ្យាល័យ Antwerp នៃប្រទេសប៊ែលហ្សិក។
- *បទពិសោធន៍ការងារ*
  - ឆ្នាំ១៩៩៧ បានចូលបម្រើការងារនៅ ក.ស.ភ.
  - ឆ្នាំ២០០៩ ជាប្រធានការិយាល័យផែនការ
  - ឆ្នាំ២០១៣ ជានាយកប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧
  - ឆ្នាំ២០១៥ ជាប្រធាននាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧
  - ខែមិថុនា ឆ្នាំ២០១៦ ជាប្រធាននាយកដ្ឋានបុគ្គលិក/ធនធានមនុស្ស
  - ខែកុម្ភៈ ២០១៧ ជាប្រធាននាយកដ្ឋានវិស្វកម្ម។



លោក **គង់ ចាន់នី**
**ប្រធានលេខាធិការដ្ឋាន**

- *ជនជាតិ* ខ្មែរ
- *សញ្ជាតិ* ខ្មែរ
- *ថ្ងៃខែឆ្នាំកំណើត* ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៨២
- *ប្រវត្តិនៃការសិក្សា*
  - ឆ្នាំ២០០៦ បញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញនីតិសាស្ត្រ ពីសកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
  - ឆ្នាំ២០០៨ បញ្ចប់ថ្នាក់អនុបណ្ឌិតជំនាញនីតិសាស្ត្រ ពីសកលវិទ្យាល័យហ្សង់មូឡាំង លីយ៉ុង៣ នៅទីក្រុងហាណូយ នៃប្រទេសវៀតណាម។
- *បទពិសោធន៍ការងារ*
  - ឆ្នាំ២០០៩ បានចូលបម្រើការងារនៅ ក. ស. ភ.
  - ឆ្នាំ២០១១ ជាអនុប្រធានការិយាល័យរដ្ឋបាល
  - ឆ្នាំ២០១៥ ជាប្រធានក្រុមលេខានៃក្រុមប្រឹក្សាភិបាល ក.ស.ភ. អាណត្តិទី៥
  - ឆ្នាំ២០១៥-បច្ចុប្បន្ន ជាប្រធានលេខាធិការដ្ឋាន។

## *ខ- តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់បុគ្គលិកជាន់ខ្ពស់*

តួនាទី និងការទទួលខុសត្រូវ របស់បុគ្គលិកជាន់ខ្ពស់ ក. ស. ភ. មានដូចខាងក្រោម៖

### *ខ.១ ឯកឧត្តម ហ៊ី បាវី (អគ្គនាយក) មានតួនាទី និងភារកិច្ចដូចខាងក្រោម៖*

- រៀបចំការប្រជុំនៃក្រុមប្រឹក្សាភិបាល
- ទទួលបន្ទុកប្រតិបត្តិនូវសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងការដាក់ឱ្យអនុវត្តនូវគោលនយោបាយ ដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ ក.ស.ភ. ហើយដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត
- រៀបចំរបាយការណ៍សកម្មភាពការងារប្រចាំឆ្នាំ និងរបាយការណ៍គណនេយ្យ/ហិរញ្ញវត្ថុប្រចាំឆ្នាំ ហើយដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត
- អនុវត្តតួនាទីជាអាជ្ញាធរ ដើម្បីគ្រប់គ្រងសណ្តាប់ធ្នាប់ទូទៅក្នុងមណ្ឌលអាជីវកម្មផែរបស់ ក.ស.ភ.
- កំណត់ចំនួនក្របខ័ណ្ឌបុគ្គលិក ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល និងគោរពទៅតាមលក្ខន្តិក:បុគ្គលិក

- អនុវត្តឋានានុក្រមរបស់ ក. ស. ភ. ចំពោះបុគ្គលិកទាំងអស់
- សម្រេច និងចុះហត្ថលេខាលើកិច្ចសន្យា ដោយអនុលោមតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាលស្ដីពីការបែងចែកអំណាច
- បំពេញកិច្ចការទូទៅក្នុងដំណើរការមុខងាររដ្ឋបាល និងការគ្រប់គ្រង ដែលចាំបាច់ក្នុងដំណើរការប្រក្រតីរបស់ ក. ស. ភ.។

## *ខ.២ តួនាទី និងការទទួលខុសត្រូវរបស់អគ្គនាយករង*

- លោក **តោ នី** អគ្គនាយករង ទទួលបន្ទុកការងាររដ្ឋបាល/ហិរញ្ញវត្ថុ
- លោក **ភុយ ម៉ុនធន** អគ្គនាយករង ទទួលបន្ទុកការងារបច្ចេកទេស
- លោក **ហៀក គិរុណា** អគ្គនាយករង ទទួលបន្ទុកការងារកិច្ចការផែ
- លោកស្រី **ហ៊ី ផានិន** អគ្គនាយករង ទទួលបន្ទុកការងារអាជីវកម្ម/ប្រតិបត្តិការផែ។

## *ខ.៣ តួនាទី និងការទទួលខុសត្រូវរបស់ប្រធាននាយកដ្ឋាន*

- លោក **កែវ សុផាណ្ណារ៉ា** (ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង)

- *ការងារគ្រប់គ្រង*
  - ជាសេនាធិការផ្ទាល់ឱ្យអគ្គនាយក លើការងារសវនកម្ម
  - ផ្ដល់ការណែនាំ និងកំណត់ទិសដៅការងារដល់អង្គភាពក្រោមឱវាទ។
- *ការងារជំនាញ*
  - រៀបចំផែនការកម្មវិធីចុះធ្វើសវនកម្មប្រចាំឆ្នាំ
  - ធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ឱ្យស្របតាមស្តង់ដារគណនេយ្យអន្តរជាតិ (CIFRS)
  - ធ្វើសវនកម្មលើកិច្ចប្រតិបត្តិការ
  - ធ្វើសវនកម្មលើការគ្រប់គ្រង និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង
  - ធ្វើរបាយការណ៍ប្រចាំឆ្នាំស្ដីអំពីការចុះធ្វើសវនកម្មជូនថ្នាក់ដឹកនាំជ្រាប និងមានវិធានការកែលំអចំណុចខ្វះខាត
  - ធ្វើអធិការកិច្ចលើករណីសង្ស័យ ឬវិវាទណាមួយដែលចង្អុលបង្ហាញដោយអគ្គនាយក
  - សម្របសម្រួលការងារសវនកម្មជាមួយនឹងសវនកម្មផ្ទៃក្រៅ។
- *ការងារវាយតម្លៃ*
  - ពិនិត្យ និងតាមដានផែនការដែលបានដាក់ចេញ
  - តាមដានការអនុវត្តសកម្មភាព ឬអនុសាសន៍កែលំអលើចំណុចខ្វះខាតរបស់អង្គភាពដែលរកឃើញដោយសវនកម្មផ្ទៃក្រៅ ឬសវនកម្មជំនាញ
  - តាមដានត្រួតពិនិត្យគោលការណ៍ណែនាំ ឬគោលនយោបាយ ដែលដាក់ចេញដោយអង្គភាព

- ពិនិត្យ និងវាយតម្លៃសមត្ថភាពការងាររបស់បុគ្គលិកក្រោមឱវាទដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការតម្លើងឋានៈ ការដាក់ពិន័យ ឬមានវិធានការដោះស្រាយ
- រៀបចំបូកសរុបរបាយការណ៍សកម្មភាពការងារប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំ ដើម្បីជូនថ្នាក់ដឹកនាំបានជ្រាប។

❖ លោកស្រី **ជួន សុខេម** (ប្រធាននាយកដ្ឋានរដ្ឋបាល)

- *ការងារគ្រប់គ្រង*
  - ជាសេនាធិការឱ្យអគ្គនាយករងរដ្ឋបាល/ហិរញ្ញវត្ថុ លើការងាររដ្ឋបាល ការងារសន្តិសុខ/សណ្តាប់ធ្នាប់ និងការងារព័ត៌មានវិទ្យា
  - អនុវត្ត និងតាមដានការគោរពនូវបទបញ្ជាផ្ទៃក្នុងរបស់ ក. ស. ភ.។
- *ការងារជំនាញ*
  - ត្រួតពិនិត្យ និងរៀបចំតាក់តែងឯកសាររដ្ឋបាល
  - គ្រប់គ្រងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ ក. ស. ភ.
  - រៀបចំសេវាផ្តល់ព័ត៌មានអំពីសេវាកម្មរបស់ ក. ស. ភ. ជូនអតិថិជន
  - ធ្វើទំនាក់ទំនង និងសហការជាមួយស្ថាប័នរដ្ឋ-ឯកជន ដែលពាក់ព័ន្ធនឹងវិស័យគ្រប់គ្រង ថែរក្សា និងការពារទ្រព្យសម្បត្តិទាំងឡាយ ព្រមទាំងការរៀបចំបញ្ជីសារពើភ័ណ្ឌរបស់ ក. ស. ភ.
  - ត្រួតពិនិត្យ និងរៀបចំសំណើសុំទិញ និងសំណើសុំដកសាច់ប្រាក់រាល់ការចំណាយការងាររដ្ឋបាល និងទិញសម្ភារការិយាល័យ សម្រាប់ប្រើប្រាស់ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
  - រៀបចំទីកន្លែងប្រជុំ និងការងារពិធីការសម្រាប់គ្រប់កម្មវិធីរបស់ ក. ស. ភ.
  - ត្រួតពិនិត្យគ្រប់គ្រង និងថែទាំប្រព័ន្ធទឹក និងប្រព័ន្ធអគ្គិសនី ព្រមទាំងអនាម័យ
  - គ្រប់គ្រង និងត្រួតពិនិត្យលើការប្រើប្រាស់ប្រេងឥន្ធនៈ
  - គ្រប់គ្រង និងចាត់ចែងការងារអន្តរាគមន៍សណ្តាប់ធ្នាប់រួម និងការពារសុវត្ថិភាពជូនថ្នាក់ដឹកនាំ និងបុគ្គលិករបស់ ក. ស. ភ.
  - រៀបចំបទបញ្ជាផ្ទៃកសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់របស់ ក. ស. ភ.
  - ដឹកនាំ ត្រួតពិនិត្យការរៀបចំយុទ្ធសាស្រ្តគ្រប់គ្រងកិច្ចដំណើរការប្រព័ន្ធព័ត៌មានវិទ្យា ការបែងចែកសិទ្ធិប្រើប្រាស់អ៊ីនធឺណែត និងបណ្តាញ Network សម្រាប់អង្គភាពនានា និងការតបណ្តាញប្រព័ន្ធត្រួតពិនិត្យសុវត្ថិភាព
  - សម្របសម្រួល និងដោះស្រាយវិវាទនានាពាក់ព័ន្ធការងាររដ្ឋបាល។

- *ការងារវាយតម្លៃ*
  - វាយតម្លៃនិងគ្រប់គ្រងការងារលើបុគ្គលិកក្រោមឱវាទ អនុលោមតាមច្បាប់ការងារ និងលក្ខន្តិកៈសហគ្រាស ព្រមទាំងលក្ខន្តិកៈបុគ្គលិករបស់ ក. ស. ភ.
  - ពិនិត្យ និងវាយតម្លៃសមត្ថភាពការងារបុគ្គលិកក្រោមឱវាទដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំ ក្នុងការលើកទឹកចិត្ត ការតម្លើងឋានៈ និងការដាក់ពិន័យ
  - ពិនិត្យ និងវាយតម្លៃដំណើរការប្រព្រឹត្តទៅនៃការងាររដ្ឋបាល ការងារសន្តិសុខ និងការងារព័ត៌មានវិទ្យា ជូនថ្នាក់ដឹកនាំដើម្បីជ្រាប និងមានវិធានការដោះស្រាយ
  - ពិនិត្យ និងវាយតម្លៃលើសំណើសុំផ្សេងៗពីគ្រប់អង្គភាព ដែលពាក់ព័ន្ធនឹងការចំណាយរដ្ឋបាលជូនថ្នាក់ដឹកនាំ ពិនិត្យ និងសម្រេច
  - ពិនិត្យ និងវាយតម្លៃលើគម្រោងរៀបចំកម្មវិធីជប់លៀងអាហារសាមគ្គី និងរង្វាន់លើកទឹកចិត្ត ប្រចាំឆ្នាំរបស់ ក. ស. ភ.
  - ពិនិត្យ និងវាយតម្លៃលើគម្រោងទិញសម្ភារការិយាល័យ ប្រើប្រាស់ក្នុងនាយកដ្ឋានចំណុះ និងគម្រោងរៀបចំឯកសណ្ឋានប្រចាំឆ្នាំ ជូនថ្នាក់ដឹកនាំ និងបុគ្គលិក ក. ស. ភ.
  - តាមដាន និងវាយតម្លៃ ព្រមទាំងបូកសរុបជារបាយការណ៍ការងាររដ្ឋបាល ជូនថ្នាក់ដឹកនាំជ្រាប និងមានវិធានការដោះស្រាយ។

❖ **លោក គង់ សុធា** (ប្រធាននាយកដ្ឋានបុគ្គលិក/ធនធានមនុស្ស)

- *ការងារគ្រប់គ្រង*
  - ជាសេនាធិការឱ្យអគ្គនាយករងរដ្ឋបាល/ហិរញ្ញវត្ថុ លើការងារគ្រប់គ្រងធនធានមនុស្ស និងការងារបណ្តុះបណ្តាល
  - ពិនិត្យ និងតាមដានការគោរពន្ធវបទបញ្ជាផ្ទៃក្នុង របស់ ក. ស. ភ.
  - គ្រប់គ្រងជីវប្រវត្តិ និងពិនិត្យរាល់សកម្មភាពការងាររបស់បុគ្គលិក ក. ស. ភ.។
- *ការងារជំនាញ*
  - ធានាដំណើរការនៃការគ្រប់គ្រងបុគ្គលិក ដោយអនុលោមទៅតាមលក្ខន្តិកៈ ក. ស. ភ. និងលក្ខន្តិកៈបុគ្គលិក ក. ស. ភ. ព្រមទាំងច្បាប់ការងារ
  - រៀបចំប្រាក់បេសកកម្មក្នុងនិងក្រៅប្រទេស ប្រាក់បៀវត្ស ប្រាក់បន្ថែមម៉ោង ប្រាក់រង្វាន់សរសើរប្រចាំឆ្នាំជូនបុគ្គលិក ក. ស. ភ.
  - គ្រប់គ្រងបញ្ជីវត្តមានរបស់បុគ្គលិក ក. ស. ភ.
  - រៀបចំសំណុំបែបបទនិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ គ្រោះថ្នាក់ការងារ មរណភាព
  - ពិនិត្យ និងធ្វើសំណើលើការងារតម្លើងកាំថ្នាក់ប្រចាំឆ្នាំជូនបុគ្គលិក ក. ស. ភ.
  - ពិនិត្យ ផ្តល់យោបល់ជូនថ្នាក់ដឹកនាំលើសំណើព្យួរការងារ ផ្ទេរការងារ ការដំឡើងតួនាទី
  - រៀបចំផែនការបណ្តុះបណ្តាលធនធានមនុស្សទាំងក្នុង និងក្រៅប្រទេស
  - រៀបចំជ្រើសរើសបុគ្គលិកតាមផែនការប្រចាំឆ្នាំរបស់ ក. ស. ភ.។

- *ការងារវាយតម្លៃ*
  - ពិនិត្យ និងវាយតម្លៃលើសមត្ថភាព និងសកម្មភាពការងាររបស់បុគ្គលិក ក. ស. ភ. ដើម្បី ផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ឬដំឡើងតួនាទី។

❖ កញ្ញា **ឈាវ ចណ្ណថា** (ប្រធាននាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ)

- *ការងារគ្រប់គ្រង*
  - ជាសេនាធិការឱ្យអគ្គនាយករងរដ្ឋបាល/ហិរញ្ញវត្ថុ លើការងារគណនេយ្យ និងហិរញ្ញវត្ថុ
  - ផ្តល់ការណែនាំ និងកំណត់ទិសដៅការងារដល់អង្គភាពក្រោមឱវាទ។
- *ការងារជំនាញ*
  - ត្រួតពិនិត្យលើផែនការអាជីវកម្ម សេវាកម្ម និងហិរញ្ញវត្ថុប្រចាំឆ្នាំ
  - ត្រួតពិនិត្យការព្យាករណ៍ហិរញ្ញវត្ថុ
  - ត្រួតពិនិត្យចំណុចដែលអាចកាត់បន្ថយចំណាយ និងធ្វើឱ្យមានភាពប្រសើរឡើង
  - អនុវត្តគោលនយោបាយ និងនីតិវិធីចុះបញ្ជីការគណនេយ្យរបស់អង្គភាព
  - អនុវត្តគោលការណ៍នៃការប្រមូលចំណូល និងបំណុលពីអតិថិជន
  - ធានាការបង់ពន្ធរបស់អង្គភាពឱ្យបានទាន់ពេលវេលាតាមការកំណត់របស់ច្បាប់ពន្ធដារ
  - គ្រប់គ្រង និងត្រួតពិនិត្យសាច់ប្រាក់ (ប្រចាំសប្តាហ៍, ប្រចាំខែ, និងប្រចាំឆ្នាំ)
  - ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់គណនីធនាគាររបស់អង្គភាព (ប្រចាំខែ)
  - រៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
  - វិភាគ និងផ្តល់យោបល់ជូនថ្នាក់ដឹកនាំលើលទ្ធផលហិរញ្ញវត្ថុ និងបម្រែបម្រួល ព្រមទាំងប្រតិបត្តិការអាជីវកម្មរបស់អង្គភាព។
- *ការងារវាយតម្លៃ*
  - តាមដានត្រួតពិនិត្យគោលការណ៍ណែនាំ ឬគោលនយោបាយគណនេយ្យ
  - ធ្វើបច្ចុប្បន្នភាពគោលនយោបាយ និងនីតិវិធីចុះបញ្ជីការគណនេយ្យប្រចាំឆ្នាំ
  - ពិនិត្យ និងវាយតម្លៃសមត្ថភាពការងាររបស់បុគ្គលិកក្រោមឱវាទ ដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការដំឡើងតួនាទី ការដាក់ពិន័យ ឬមានវិធានការដោះស្រាយ
  - រៀបចំបូកសរុបរបាយការណ៍សកម្មភាពការងារប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីជូនថ្នាក់ដឹកនាំបានជ្រាប។

❖ លោក **យឹម ឿន** (ប្រធាននាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧)

- *ការងារគ្រប់គ្រង*
  - ជាសេនាធិការឱ្យអគ្គនាយករងប្រតិបត្តិការលើការងារប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧
  - ផ្តល់ការណែនាំដល់អង្គភាពក្រោមឱវាទអំពីលំហូរប្រតិបត្តិការ។

- *ការងារជំនាញ*
  - រៀបចំកាលវិភាគនិងចាត់ចែងនាវាចូលចត និងចេញពីផែនៅតាមដងយោងនីមួយៗ
  - រៀបចំ និងចាត់ចែងប្លង់របស់កុងតឺន័រទាំងនាំចូល និងនាំចេញ
  - ធានាឱ្យការធ្វើប្រតិបត្តិការលើកដាក់នៅលើទីលាន និងនៅស្ពានផែឱ្យស្របតាមស្តង់ដារ អន្តរជាតិ និងលក្ខណៈបច្ចេកទេស
  - ណែនាំដល់កម្មករបម្រើការងារនៅលើចំណតអំពីគោលការណ៍សន្តិសុខ និងសុវត្ថិភាព
  - ធានាឱ្យមានបរិយាកាសការងារល្អជាមួយបុគ្គលិកក្រោមឱវាទ
  - រក្សាទំនាក់ទំនងល្អក្នុងចំណោមថ្នាក់ដឹកនាំ និងកម្មករក្រោមឱវាទ
  - ជំរុញការលើកទឹកចិត្តដល់បុគ្គលិកក្រោមឱវាទ
  - ជំរុញគុណភាពការងារតាមរយៈការផ្តល់ការណែនាំ និងការបណ្តុះបណ្តាល
  - ធានាឱ្យការផ្តល់សេវាកាន់តែល្អ ប្រកបដោយប្រសិទ្ធភាព និងផលិតភាពខ្ពស់
  - ធ្វើបញ្ជី Check List ផ្នែកប្រតិបត្តិការ
  - ល្បាត និងត្រួតពិនិត្យសកម្មភាពប្រតិបត្តិការដើម្បីធានាថា បុគ្គលិកផ្នែកប្រតិបត្តិការទាំងអស់ពាក់សម្ភារការពារខ្លួន (PPE) និងប្រើប្រាស់នូវសម្ភារគ្រឿងចក្រឱ្យបានត្រឹមត្រូវ
  - រៀបចំការប្រជុំប្រចាំខែជាមួយបុគ្គលិកក្រោមឱវាទ ដើម្បីពិភាក្សា និងដកពិសោធន៍ការងារកន្លងមក
  - ចូលរួមស៊ើបអង្កេតគ្រោះថ្នាក់ការងារដែលបានកើតឡើង
  - ត្រួតពិនិត្យមាត់ច្រកចេញ-ចូល។
- *ការងារវាយតម្លៃ*
  - គណនា និងវាយតម្លៃការប្រើប្រាស់ទីលាន ស្ពានផែ និងគ្រឿងចក្រលើកដាក់
  - ពិនិត្យ និងវាយតម្លៃសមត្ថភាពការងាររបស់បុគ្គលិកក្រោមឱវាទ ដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការតម្លើងឋានៈ និងការដាក់ពិន័យ
  - បូកសរុបរបាយការណ៍ប្រតិបត្តិការប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ។

❖ លោក **ឡៀម ទីរ៉ាយ៉ា** (ប្រធាននាយកដ្ឋានជលធារសាស្រ្ត)

- *ការងារគ្រប់គ្រង*
  - ជាសេនាធិការឱ្យអគ្គនាយករងបច្ចេកទេស លើការងារជលធារសាស្រ្ត រួមមានការងារវាស់ស្ទង់ ការងារបំពាក់ពោងសញ្ញា និងការងារបូមស្តារប្រឡាយ
  - ផ្តល់ការណែនាំ និងកំណត់ទិសដៅការងារដល់អង្គភាពក្រោមឱវាទ។
- *ការងារជំនាញ*
  - រៀបចំផែនការប្រចាំឆ្នាំលើការងារវាស់ស្ទង់ និងការងារបូមស្តារប្រឡាយនាវាចរណ៍

- រៀបចំគម្រោងផែនការប្រចាំឆ្នាំលើការបំពាក់ ការថែទាំ និងការជួសជុលពោងសញ្ញា និងបង្គោលសញ្ញាតាមផ្លូវនាវាចរណ៍ក្នុងដែនអាជីវកម្មរបស់ ក. ស. ភ.
- សិក្សានិងវាស់ស្ទង់ជម្រៅទឹកនៅក្នុងមណ្ឌលអាជីវកម្ម និងទីតាំងអភិវឌ្ឍន៍របស់ក.ស.ភ.
- អនុវត្តការងារបូមស្តារប្រឡាយនាវាចរណ៍ និងការងារបូមខ្សាច់ធ្វើអាជីវកម្ម
- គ្រប់គ្រងលើមធ្យោបាយបូមស្តារ និងមធ្យោបាយអូសទាញគ្រឿងចក្រ
- បំពាក់ពោងសញ្ញា និងបង្គោលសញ្ញាតាមផ្លូវនាវាចរណ៍ក្នុងមណ្ឌលអាជីវកម្ម
- គ្រប់គ្រង ថែរក្សា និងជួសជុលរាល់ពោងសញ្ញា បង្គោលសញ្ញា តាមផ្លូវនាវាចរណ៍ក្នុងមណ្ឌលអាជីវកម្មរបស់ ក. ស. ភ.។

• *ការងារវាយតម្លៃ*
  - ពិនិត្យ និងវាយតម្លៃសមត្ថភាពការងាររបស់បុគ្គលិកក្រោមឱវាទ ដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការដំឡើងតួនាទី ការដាក់វិន័យ
  - សិក្សាស្រាវជ្រាវបច្ចេកទេស និងឧបករណ៍វាស់ស្ទង់គ្រប់ប្រភេទ
  - ប្រមូលចងក្រងព័ត៌មាន និងឯកសារនានាពាក់ព័ន្ធនឹងផ្នែកជលធារសាស្ត្រ
  - រៀបចំបូកសរុបរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីរាយការណ៍ជូនអគ្គនាយក ក. ស. ភ.។

❖ លោក **សយ សេរីសុខឡុន:** (ប្រធាននាយកដ្ឋានមណ្ឌលអាជីវកម្មផែភ្នំពេញ/ផែក្នុងស្រុក)

• *ការងារគ្រប់គ្រង*
  - ជាសេនាធិការឱ្យអគ្គនាយករងកិច្ចការផែ លើការងារមណ្ឌលផែ/ផែក្នុងស្រុក ការងារផែទេសចរណ៍ ការងារចំណតផែទន្លេបិទ និងការងារផែប្រេង/ហ្គាស
  - ផ្តល់ការណែនាំ និងកំណត់ទិសដៅការងារដល់អង្គភាពក្រោមឱវាទ។

• *ការងារជំនាញ*
  - រៀបចំផែនការគ្រប់គ្រង និងរៀបចំសណ្តាប់ធ្នាប់ និងចំណតផែក្នុងមណ្ឌលអាជីវកម្មផែ
  - គ្រប់គ្រងចំណត សេវាកម្មផែក្នុងស្រុក និងមណ្ឌលផែរាល់ការចូលចត របស់នាវា សាឡង់ ទូក កាណូតផ្សេងៗ
  - គ្រប់គ្រងចំណតចេញ-ចូលនាវា នាវាទេសចរណ៍ជាតិ និងអន្តរជាតិ គ្រប់គ្រងចំណតរថយន្ត និងច្រកទ្វារចេញ-ចូល ប្រមូលថ្លៃឈ្នួល រៀបចំសណ្តាប់ធ្នាប់នាវាដឹកអ្នកដំណើរនៅផែបណ្តែត
  - គ្រប់គ្រងចំណតផែទន្លេបិទលើការងារប្រតិបត្តិការ និងដើរតួនាទីជាអាជ្ញាធរផែ រួមមានការងារលើកដាក់ ការងាររៀបចំចំណតផែ ការងារគ្រប់គ្រងនាវាចេញ-ចូល និងគ្រប់គ្រងចំណតផែប្រេង/ហ្គាសលើការងារសណ្តាប់ធ្នាប់ឱ្យមានសុវត្ថិភាព និងបរិស្ថានល្អ
  - គ្រប់គ្រងនាវាចេញ-ចូល និងប្រមូលស្ថិតិទំនិញឆ្លងកាត់

- ថែរក្សាបបនីយភណ្ឌផែ និងប្រឡាយនាវាចរណ៍នៅតាមចំណតផែទាំងនោះ ឱ្យមានរបៀប រៀបរយសម្រាប់នាវាធ្វើនាវាចរណ៍ ចងពួរនាវា បោះយុថ្កា ព្រមទាំង ផ្ទេរ និងផ្ទុកទំនិញ។

- *ការងារវាយតម្លៃ*
  - ពិនិត្យ និងវាយតម្លៃសមត្ថភាពការងាររបស់បុគ្គលិកក្រោមឱវាទ ដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការតម្លើងឋានៈ និងការដាក់ពិន័យ
  - វាយតម្លៃរាល់ផលប៉ះពាល់ដែលបណ្តាលឱ្យខូចខាតដល់ចំណតផែ ដែលស្ថិតនៅក្នុងព្រំប្រទល់ផ្ទៃទឹកកំពង់ផែ និងមណ្ឌលផែ ជូនថ្នាក់ដឹកនាំជ្រាប និងមានដំណោះស្រាយ
  - រៀបចំបូកសរុបរបាយការណ៍សកម្មភាពការងារប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីជូនថ្នាក់ដឹកនាំបានជ្រាប។

❖ លោក **ហ៊ុន សុខាល័យ** (ប្រធាននាយកដ្ឋានផែនការ/ទីផ្សារ)

- *ការងារគ្រប់គ្រង*
  - ជាសេនាធិការឱ្យអគ្គនាយករងអាជីវកម្ម/ប្រតិបត្តិការផែ លើការងារផែនការ/ស្ថិតិ ការងារតម្លៃ/ទីផ្សារ ការងារកិច្ចការជំនួញ និងការងារសិក្សាស្រាវជ្រាវ/អភិវឌ្ឍន៍ថ្មី
  - ផ្តល់ការណែនាំ និងកំណត់ទិសដៅការងារដល់អង្គភាពក្រោមឱវាទ។
- *ការងារជំនាញ*
  - រៀបចំផែនការអាជីវកម្ម សេវាកម្ម និងហិរញ្ញវត្ថុ រយៈពេលខ្លី មធ្យម និងវែង
  - តាមដានការងារអាជីវកម្ម ជាប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំសម្រាប់ ក. ស. ភ.
  - ចងក្រងទិន្នន័យ និងស្ថិតិរបស់ ក. ស. ភ. ដើម្បីធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ
  - រៀបចំផែនការយុទ្ធសាស្ត្រទីផ្សាររបស់ ក. ស. ភ. ដោយពឹងផ្អែកជាចម្បងទៅលើតម្លៃ គុណភាពសេវាកម្ម ការគ្រប់គ្រង និងបបនីយភណ្ឌផែ
  - រៀបចំកិច្ចសន្យា កិច្ចព្រមព្រៀង និង MOU ជាមួយដៃគូអាជីវកម្មរបស់ ក. ស. ភ.
  - រៀបចំ និងចងក្រងបណ្ណផ្សាយពាណិជ្ជកម្ម (Brochure) និងប្រតិទិន (Calendar)
  - ផ្សព្វផ្សាយអំពីតារាងតម្លៃសេវាកម្មរបស់ ក. ស. ភ. ជូនអតិថិជន
  - បម្រើសេវាកម្ម (Customer Service) ជូនអតិថិជន
  - ផលិតវិក្កយបត្រ។
- *ការងារវាយតម្លៃ*
  - ពិនិត្យ និងផ្តល់យោបល់លើគម្រោងសាងសង់ និងការចំណាយផ្សេងៗលើផ្នែកអាជីវកម្មរបស់ ក. ស. ភ. ជូនថ្នាក់ដឹកនាំ
  - វិភាគអំពីប្រសិទ្ធភាព និងផលប៉ះពាល់នៃគម្រោងអភិវឌ្ឍន៍នីមួយៗរបស់ ក. ស. ភ.
  - សិក្សាពីបរិយាកាសប្រកួតប្រជែង និងវិនិយោគក្នុងវិស័យដឹកជញ្ជូន វិស័យភ័ស្តុភារ និង វិស័យកំពង់ផែ

- សិក្សា និងវិភាគតម្លៃដឹកជញ្ជូនតាមផ្លូវទឹក ផ្លូវគោក ផ្លូវដែក និងផ្លូវអាកាស
- វិភាគលើផលប៉ះពាល់ ចំណុចខ្លាំង ចំណុចខ្សោយ និងឱកាស ដោយផ្អែកលើមជ្ឈដ្ឋានខាងក្នុង និងខាងក្រៅរបស់អង្គភាព
- តាមដានស្ថានការ និងនិន្នាការអភិវឌ្ឍសេដ្ឋកិច្ចទាំងក្នុង និងក្រៅប្រទេស
- តាមដានស្ថានការនៃការអភិវឌ្ឍ និងការប្រព្រឹត្តទៅរបស់កំពង់ផែនៅក្នុងប្រទេស និងកំពង់ផែនានានៅក្នុងប្រទេសជិតខាងក្នុងតំបន់ និងសកលលោក
- សិក្សាអំពីភាពប្រកួតប្រជែងនៃតម្លៃសេវាកម្មរបស់ ក. ស. ភ.
- សិក្សាលើគម្រោងស្រាវជ្រាវ និងការអភិវឌ្ឍថ្មីៗរបស់ ក. ស. ភ.
- ធ្វើការស្ទង់មតិអំពីការផ្តល់សេវាកម្មរបស់ ក. ស. ភ. ដើម្បីទទួលបានការវាយតម្លៃពីអ្នកប្រើប្រាស់លើចំណុចសកម្ម និងចំណុចអសកម្ម
- ពិនិត្យ និងវាយតម្លៃសមត្ថភាពការងាររបស់បុគ្គលិកក្រោមឱវាទ ដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការដំឡើងតួនាទី និងការដាក់វិន័យ
- រៀបចំបូកសរុបរបាយការណ៍សកម្មភាពការងារប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីជូនថ្នាក់ដឹកនាំបានជ្រាប។

❖ *តំណែងប្រធាននាយកដ្ឋានប្រតិបត្តិការចំណតផែ TS៣ ស្ថិតក្នុងភាពទំនេរ ពុំទាន់មានការតែងតាំងឡើយ*

• *ការងារគ្រប់គ្រង*

- ជាសេនាធិការឱ្យអគ្គនាយករងប្រតិបត្តិការ លើការងារប្រតិបត្តិការចំណតផែ TS៣
- ផ្តល់ការណែនាំដល់អង្គភាពក្រោមឱវាទអំពីលំហូរប្រតិបត្តិការ។

• *ការងារជំនាញ*

- រៀបចំកាលវិភាគ និងចាត់ចែងនាវាចូលចត និងចេញពីផែនៅតាមដងយោងនីមួយៗ
- រៀបចំ និងចាត់ចែងប្លង់របស់កុងតឺន័រទាំងនាំចូល និងនាំចេញ
- ធានាឱ្យការធ្វើប្រតិបត្តិការលើកដាក់នៅលើទីលាន និងនៅស្ពានផែឱ្យស្របតាមស្តង់ដារអន្តរជាតិ និងលក្ខណៈបច្ចេកទេស
- ផ្តល់ការណែនាំដល់កម្មករបម្រើការងារនៅលើចំណត អំពីគោលការណ៍សន្តិសុខ និងសុវត្ថិភាព
- ធានាឱ្យមានបរិយាកាសការងារល្អជាមួយបុគ្គលិកក្រោមឱវាទ
- រក្សាទំនាក់ទំនងល្អក្នុងចំណោមថ្នាក់ដឹកនាំ និងកម្មករក្រោមឱវាទ
- ជំរុញការលើកទឹកចិត្តដល់បុគ្គលិកក្រោមឱវាទ
- ជំរុញគុណភាពការងារតាមរយៈការផ្តល់ការណែនាំ និងការបណ្តុះបណ្តាល
- ធានាឱ្យការផ្តល់សេវាកាន់តែល្អ មានប្រសិទ្ធភាព និងផលិតភាពខ្ពស់

- ធ្វើបញ្ជី Check List ផ្នែកប្រតិបត្តិការ
- ល្បាតនិងត្រួតពិនិត្យសកម្មភាពប្រតិបត្តិការ ដើម្បីធានាថាបុគ្គលិកផ្នែកប្រតិបត្តិការទាំងអស់ពាក់សម្ភារការពារពលកម្ម (PPE) និងប្រើប្រាស់សម្ភារគ្រឿងចក្របានត្រឹមត្រូវ
- រៀបចំការប្រជុំប្រចាំខែជាមួយបុគ្គលិកក្រោមឱវាទ ដើម្បីពិភាក្សា និងដកពិសោធន៍ការងារកន្លងមក
- ចូលរួមស៊ើបអង្កេតគ្រោះថ្នាក់ការងារដែលបានកើតឡើង
- ត្រួតពិនិត្យមាត់ច្រកចេញ-ចូល។

• *ការងារវាយតម្លៃ*

- បូកសរុបរបាយការណ៍ប្រតិបត្តិការប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- គណនា និងវាយតម្លៃការប្រើប្រាស់ទីលាន ស្តានផែ និងគ្រឿងចក្រលើកដាក់
- ពិនិត្យ និងវាយតម្លៃសមត្ថភាពការងាររបស់កម្មករ និងនិយោជិតក្រោមឱវាទ ដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការដំឡើង និងការដាក់វិន័យ។

❖ លោក **ជី ទិចិត្រ** (ប្រធាននាយកដ្ឋានវិស្វកម្ម)

• *ការងារគ្រប់គ្រង*

- ជាសេនាធិការឱ្យអគ្គនាយករងបច្ចេកទេស លើការងារបច្ចេកទេស រួមមានការងារហេដ្ឋារចនាសម្ព័ន្ធ និងមធ្យោបាយគ្រឿងចក្រ
- ផ្តល់ការណែនាំ និងកំណត់ទិសដៅការងារដល់អង្គភាពក្រោមឱវាទ។

• *ការងារជំនាញ*

- រៀបចំកំណត់ស្តង់ដារបច្ចេកទេសសម្រាប់ហេដ្ឋារចនាសម្ព័ន្ធផែ និងមធ្យោបាយគ្រឿងចក្ររបស់ ក. ស. ភ.
- សិក្សា និងរៀបចំគម្រោងអភិវឌ្ឍន៍ផែលើផ្នែកបច្ចេកទេស
- ត្រួតពិនិត្យ ថែទាំ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធផែ និងមធ្យោបាយគ្រឿងចក្រ
- រៀបចំផែនការសម្ភារ និងគ្រឿងបន្លាស់សម្រាប់ការជួសជុលហេដ្ឋារចនាសម្ព័ន្ធផែ និងមធ្យោបាយគ្រឿងចក្រ។

• *ការងារវាយតម្លៃ*

- ពិនិត្យ និងវាយតម្លៃសមត្ថភាពការងារបុគ្គលិកក្រោមឱវាទ ដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការដំឡើងតួនាទី ការដាក់ពិន័យ ឬមានវិធានការដោះស្រាយ

ដឹកនាំការប្រជុំផ្ទៃរៀងរាល់ខែ ដើម្បីដកពិសោធន៍លើការងារជំនាញបច្ចេកទេសវិស្វកម្ម។

❖ លោក **តុល សុខុម** (ប្រធាននាយកដ្ឋានសេវាកម្មនាវាចរណ៍)

- *ការងារគ្រប់គ្រង*
  - ជាសេនាធិការឱ្យអគ្គនាយករងកិច្ចការផែ លើការងារនាវាចរណ៍ ការងារកណ្ដាធារ និងការងារ SHE
  - ផ្ដល់ការណែនាំ និងកំណត់ទិសដៅការងារដល់អង្គភាពក្រោមឱវាទ។
- *ការងារជំនាញ*
  - ធានាការពារសុវត្ថិភាពដែនទឹកកំពង់ផែ និងគ្រប់គ្រងចលនានាវា
  - តាមដានត្រួតពិនិត្យការបំពុលទឹក
  - អនុវត្តបទបញ្ជា និងផ្ដល់ការឯកភាពលើសកម្មភាពផ្សេងៗក្នុងតំបន់កំពង់ផែ
  - ធានាសុវត្ថិភាពប្រតិបត្តិការកំពង់ផែ និងនាវាទាំងឡាយនៅកំពង់ផែ
  - ដឹកនាំគណៈកម្មការធ្វើបែបបទចូល/ចេញកំពង់ផែរបស់នាវា
  - ធ្វើការណែនាំអំពីករណីនាវាដឹកជញ្ជូនទំនិញគ្រោះថ្នាក់
  - បដិសេធមិនឱ្យនាវាចាកចេញពីកំពង់ផែ ក្នុងករណីមិនទូទាត់ប្រាក់កម្រៃ ឬថ្លៃប្រើប្រាស់សេវាកម្មផ្សេងៗ
  - ផ្ដល់លិខិតអនុញ្ញាតចេញពីកំពង់ផែ (Port clearance) ដល់នាវា
  - បញ្ជូនវិញ្ញាបនបត្រ (Certificate Manifest) ដល់អង្គភាពពាក់ព័ន្ធ និងបញ្ជូនវិញ្ញាបនបត្រប៉ាន់ស្មានសេវាកម្មទៅការិយាល័យកិច្ចការជំនួញដើម្បីចេញវិក្កយបត្រផ្លូវការជូនអតិថិជន
  - បែងចែកកណ្ដាធារនាំផ្លូវនាវាចេញ-ចូល ក្នុងមណ្ឌលអាជីវកម្ម និងតាមបណ្ដាខេត្តផ្សេងៗ
  - គ្រប់គ្រង និងចាត់ចែងមធ្យោបាយនាវាសណ្ដោង និងមធ្យោបាយនាវាចម្លង
  - ពិនិត្យ និងបញ្ជូនព័ត៌មានមកដល់ និងចេញដំណើររបស់នាវា ដែលបានពីទីភ្នាក់ងារកម្ពុជានាវាចរណ៍កាំសាបឱ្យទៅអង្គភាពពាក់ព័ន្ធអនុវត្ត
  - រៀបចំ និងគ្រប់គ្រងសណ្ដាប់ធ្នាប់សាធារណៈ របៀបរៀបរយ សន្តិសុខ និងសុវត្ថិភាពរបស់នាវាចរណ៍ និងបរិស្ថានល្អក្នុងមណ្ឌលអាជីវកម្ម
  - ចាត់ចែងសកម្មភាពនាវាតាមផែក្នុងមណ្ឌលអាជីវកម្មផែភ្នំពេញ និងចំណតផែអ្នកដំណើរ
  - ណែនាំ និងត្រួតពិនិត្យការអនុវត្តគោលនយោបាយសុវត្ថិភាព សុខមាលភាព និងបរិស្ថានផែ ធានាឱ្យដំណើរការប្រតិបត្តិការផែ អនុលោមតាមស្តង់ដារអន្តរជាតិជាអាទិ៍ SHE (Safety, Health and Environment) ISPS Code IMDG Code
  - ប្រតិបត្តិច្បាប់ តាមបទប្បញ្ញត្តិជាតិ និង បទប្បញ្ញត្តិអន្តរជាតិលើនាវាជាតិអន្តរជាតិ និងចំណតផែ។
- *ការងារវាយតម្លៃ*
  - ពិនិត្យ និងវាយតម្លៃសមត្ថភាពការងាររបស់បុគ្គលិកក្រោមឱវាទ ដើម្បីផ្ដល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការតម្លើងឋានៈ ការដាក់ពិន័យ

- វាយតម្លៃរាល់ការប៉ះទង្គិចគ្រោះថ្នាក់ដែលបណ្តាលឱ្យខូចខាតនាវាសាឡង់ និងចំណតផែដែលស្ថិតនៅក្នុងព្រំប្រទល់ផ្ទៃទឹកកំពង់ផែ មណ្ឌលផែ ជូនថ្នាក់ដឹកនាំជ្រាប និងមានដំណោះស្រាយ
- តាមដានស្ថានភាពច្រាំងទន្លេ និងសកម្មភាពយកដីពីបាតទន្លេ និងផលប៉ះពាល់ក្នុងការកសាងផែ និងចំណតផែដែលមានស្រាប់
- តាមដានពិនិត្យកំពស់ទឹកឡើងចុះប្រចាំថ្ងៃ និងផ្តល់ជំរៅទឹកប្រចាំខែ ដល់ស្ថាប័នពាក់ព័ន្ធនានា តាមរយៈទីភ្នាក់ងារកម្ពុជានាវាចរណ៍កាំសាប សម្រាប់ការកំណត់ជម្រៅស៊ីទឹករបស់នាវាចេញ-ចូល ក. ស. ភ.
- រៀបចំបូកសរុបរបាយការណ៍សកម្មភាពការងារប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីជូនថ្នាក់ដឹកនាំបានជ្រាប។

### *ឃ- ការបណ្តុះបណ្តាលបន្តសម្រាប់បុគ្គលិកជាន់ខ្ពស់*

សម្រាប់ឆ្នាំ២០១៧ ក. ស. ភ. បានចាត់បញ្ជូនបុគ្គលិកជាន់ខ្ពស់ ដើម្បីទៅចូលរួមការបណ្តុះបណ្តាលដូចខាងក្រោម៖

- លោកស្រី **ហ៊ី ផានិន** អគ្គនាយករងអាជីវកម្ម/ប្រតិបត្តិការផែ ត្រូវបានចាត់បញ្ជូនឱ្យទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពី Port Management ចាប់ពីថ្ងៃទី១៤-២៨ ខែមករា ឆ្នាំ២០១៧ នៅប្រទេសប៊ែលហ្ស៊ិក
- លោក **ហ៊ុន សុខាល័យ** ប្រធាននាយកដ្ឋានផែនការ/ទីផ្សារ ត្រូវបានចាត់បញ្ជូនឱ្យទៅចូលរួមសិក្ខាសាលាស្តីពី Trade Facilitation by Integration and Innovation of Logistics (ASEAN - CHINA) ចាប់ពីថ្ងៃទី២០-២៤ ខែមីនា ឆ្នាំ២០១៧ នៅសាធារណរដ្ឋប្រជាមានិតចិន
- លោកស្រី **ហ៊ី ផានិន** អគ្គនាយករងអាជីវកម្ម/ប្រតិបត្តិការផែ ត្រូវបានចាត់បញ្ជូនឱ្យទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពី Port Management Program ចាប់ពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៧ នៅប្រទេសអៀកឡង់
- លោក **ជី វិចិត្រ** ប្រធាននាយកដ្ឋានវិស្វកម្ម ត្រូវបានចាត់បញ្ជូនឱ្យទៅចូលរួមសិក្ខាសាលា ស្តីពីគម្រោង និងការសាងសង់កំពង់ផែ និងដែសមុទ្រសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ចាប់ពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៧ នៅសាធារណរដ្ឋប្រជាមានិតចិន
- លោកស្រី **ហ៊ី ផានិន** អគ្គនាយករងអាជីវកម្ម/ប្រតិបត្តិការផែ និងលោក **យឹម ជឿន** ប្រធាននាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧ ត្រូវបានចាត់បញ្ជូនឱ្យទៅចូលរួមសន្និសីទស្តីពី "Port Cooperation and development of China-ASEAN Port Cities cooperation Network" ចាប់ពីថ្ងៃទី១២-១៥ ខែកញ្ញា ឆ្នាំ២០១៧ នៅសាធារណរដ្ឋប្រជាមានិតចិន

- លោក **គង់ ចាន់នី** ប្រធានលេខាធិការដ្ឋាន ត្រូវបានចាត់បញ្ជូនទៅចូលរួមក្នុងកិច្ចប្រជុំលើកទី ១០ នៃបណ្តាញអាស៊ី ដើម្បីអភិវឌ្ឍអភិបាលកិច្ចសាជីវកម្ម សម្រាប់សហគ្រាសសាធារណៈ (10th Meeting of the Asia Network on Corporate of State-owned Enterprise) ដែលរៀបចំឡើងដោយអង្គការសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច-អាស៊ីអាគ្នេយ៍ (OECD) ពីថ្ងៃទី១៩-២០ ខែកញ្ញា ឆ្នាំ២០១៧ នៅប្រទេសម៉ាឡេស៊ី។

## ៥- ការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់

គិតត្រឹមឆ្នាំ២០១៧ អភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ ក. ស. ភ. មិនមានការជាប់ពាក់ព័ន្ធក្នុងដំណើរការផ្លូវច្បាប់នោះទេ។

## ៦- លាភការ ឬប្រាក់បំណាច់របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់

*ក- ឈ្មោះ តំណែងអភិបាល និងបុគ្គលិកជាន់ខ្ពស់ និងប្រាក់បំណាច់ ឬលាភការ ដែលទទួលបានខ្ពស់បំផុត ៖*

(ឯកតា៖ពាន់រៀល)

| ល.រ | ឈ្មោះអភិបាល និងបុគ្គលិកជាន់ខ្ពស់ | មុខតំណែងក្នុងក.ស.ភ. | ប្រាក់បៀវត្សរ៍ និងលាភការ មធ្យមប្រចាំខែ | ចំនួនសរុប "ប្រាក់បៀវត្សរ៍ និងលាភការ" |
|---|---|---|---|---|
| | | | ឆ្នាំ២០១៧ | |
| ១ | ហ៊ី បារី | ប្រធានអគ្គនាយក | ២១.១៩១ | ២៥៤.៣០២ |
| ២ | ណែម ធីម | ទីប្រឹក្សា | ៧.២៦៨ | ៨៧.២២០ |
| ៣ | គីម សែន | ទីប្រឹក្សា | ៥.២៥៥ | ៦៣.០៦៨ |
| ៤ | តោ នី | អគ្គនាយករង | ៦.២៤៩ | ៧៤.៩៩៨ |
| ៥ | កុយ ប៊ុនធន | អគ្គនាយករង | ៨.០០២ | ៩៦.០២៩ |
| ៦ | ហៀក ភិរុណ | អគ្គនាយករង | ៧.២៨៤ | ៨៧.៤១៤ |
| ៧ | ហ៊ី ផានិន | អគ្គនាយករង | ៦.៩៦២ | ៨៣.៥៥៥ |
| ៨ | គង់ ចាន់នី | ប្រធានលេខាធិការដ្ឋាន | ៧.៤៩១ | ៨៩.៨៩៥ |
| ៩ | កែវ សុផាណ្ណារ៉ា | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | ៥.៩៨១ | ៧១.៧៧៥ |
| ១០ | ជួន សុខេម | ប្រធាននាយកដ្ឋានរដ្ឋបាល | ១៣.៩៤៦ | ១៦៧.៣៥៥ |
| ១១ | គង់ សុធា | ប្រធាននាយកដ្ឋានបុគ្គលិក/ធនធានមនុស្ស | ៦.០០១ | ៧២.០១៥ |
| ១២ | ឈាវ វណ្ណធា | ប្រធាននាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ | ៦.៩៤៦ | ៨៣.៣៥៥ |
| ១៣ | ជី វិចិត្រ | ប្រធាននាយកដ្ឋានវិស្វកម្ម | ៥.៩៧១ | ៧១.៦៥៥ |
| ១៤ | ជៀប វីរ៉ាយ៉ា | ប្រធាននាយកដ្ឋានជលធារសាស្ត្រ | ៥.៩៥៦ | ៧១.៤៧៥ |
| ១៥ | តុល សុខុម | ប្រធាននាយកដ្ឋានសេវាកម្មនាវាចរណ៍ | ៥.៩៩៦ | ៧១.៩៥៩ |
| ១៦ | សយ សេរីសុវឌ្ឍន: | ប្រធាននាយកដ្ឋានមណ្ឌលអាជីវកម្មផែ/ផែក្នុស្រុក | ៥.៩៤៦ | ៧១.៣៥៥ |
| ១៧ | ហ៊ុន សុខាល័យ | ប្រធាននាយកដ្ឋានផែនការ/ទីផ្សារ | ៤.៨២១ | ៥៧.៨៦១ |
| ១៨ | យឹម ជឿន | ប្រធាននាយកដ្ឋានប្រតិបត្តិការចំណតផែ | ៦.១៦១ | ៧៣.៩៣៧ |
| សរុប | | | ១៣៧.៤២៧ | ១.៦៤៩.២២៣ |

***សម្គាល់៖**

*- លោកស្រី ហ៊ី ផានិន ត្រូវបានតែងតាំងជាអគ្គនាយករង ចាប់ពីខែមីនា ឆ្នាំ២០១៧ និងលោក តោ នី ត្រូវបានតែងតាំងជាប្រធាននាយកដ្ឋានចាប់ពីខែកុម្ភៈ ឆ្នាំ២០១៧ ។*

*- លោក តោ នី ត្រូវបានតែងតាំងជាអគ្គនាយករង និងលោក ហ៊ុន សុខាល័យ ត្រូវបានតែងតាំងជាប្រធាននាយកដ្ឋានចាប់ពីខែ វិច្ឆិកា ឆ្នាំ២០១៧ ។*

## *ខ- ចំនួនប្រាក់បំណាច់ ឬលាភការសរុប ដែលបើកឱ្យអភិបាលមិនប្រតិបត្តិ*

(ឯកតា៖ ពាន់រៀល)

| ល.រ | ឈ្មោះអភិបាលមិនប្រតិបត្តិ | មុខតំណែងក្នុង ក.ស.ភ | ប្រាក់បៀវត្សរ៍ / ប្រាក់បំណាច់ |
|---|---|---|---|
| | | | ឆ្នាំ ២០១៧ |
| ១ | ឯកឧត្តម សួន រចនា | អភិបាល | ៩៦.០០០ |
| ២ | ឯកឧត្តម កែន សម្បត្តិ | អភិបាល | ៩៦.០០០ |
| ៣ | ឯកឧត្តម ប៉ែន សុវិជាតិ | អភិបាល | ៩៦.០០០ |
| ៤ | លោក ហ៊្គី អានវ៉ានិច | អភិបាលឯករាជ្យ | ៩៦.០០០ |
| ៥ | លោក ឱត សុចល | អភិបាលមិនប្រតិបត្តិ | ៩៦.០០០ |
| ៦ | លោក ម៉ម រិទ្ធី | មន្ត្រីត្រួតពិនិត្យរដ្ឋ | ៩៦.០០០ |
| សរុប | | | **៥៧៦.០០០** |

**សម្គាល់៖ លោក ហ៊្គី អានវ៉ានិច និង លោក ឱត សុចល ត្រូវបានតែងតាំងដោយអនុក្រឹត្យលេខ ៦៧៦ អនក្រ.តត ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៦*

## *គ- ចំនួនប្រាក់បៀវត្សរ៍សរុបសម្រាប់រយៈពេល ០១ (មួយ) ឆ្នាំខាងមុខ ដែលត្រូវផ្តល់ជូនអភិបាល ឬបុគ្គលិកជាន់ខ្ពស់*

(ឯកតា៖ពាន់រៀល)

| ល.រ | ឈ្មោះអភិបាល និង បុគ្គលិកជាន់ខ្ពស់ | មុខតំណែងក្នុងក.ស.ភ. | ប្រាក់បំណាច់ និងលាភការសរុបសម្រាប់រយៈពេល ០១ (មួយ) ឆ្នាំខាងមុខ |
|---|---|---|---|
| ១ | ឯកឧត្តម ហ៊ី បាវី | អភិបាល | ២៥៤.៥៥៦ |
| ២ | ឯកឧត្តម សួន រចនា | អភិបាល | ៩៦.០០០ |
| ៣ | ឯកឧត្តម កែន សម្បត្តិ | អភិបាល | ៩៦.០០០ |
| ៤ | ឯកឧត្តម ប៉ែន សុវិជាតិ | អភិបាល | ៩៦.០០០ |
| ៥ | លោក ហ៊្គី អានវ៉ានិច | អភិបាលឯករាជ្យ | ៩៦.០០០ |
| ៦ | លោក ឱត សុចល | អភិបាលមិនប្រតិបត្តិ | ៩៦.០០០ |
| ៧ | លោក ម៉ម រិទ្ធី | មន្ត្រីត្រួតពិនិត្យរដ្ឋ | ៩៦.០០០ |
| ៨ | ឯកឧត្តម ណែម ធីម | ទីប្រឹក្សា | ៥៨.៩១០ |
| ៩ | លោកជំទាវ គីម សែន | ទីប្រឹក្សា | ០ |
| ១០ | លោក តា នី | អគ្គនាយករង | ៥៨.៩៤០ |
| ១១ | លោក កុយ ប៊ុនធន | អគ្គនាយករង | ៩៦.១២៥ |

| | | | |
|---|---|---|---|
| ១២ | លោក ហៀក ភិរុណ | អគ្គនាយករង | ៩៦.១២៥ |
| ១៣ | លោកស្រី ហ៊ី ផានិន | អគ្គនាយករង | ៩៦.១២៥ |
| ១៤ | លោក គង់ ចាន់នី | ប្រធានលេខាធិការដ្ឋាន | ៨៩.៩៨៤ |
| ១៥ | លោក កែវ សុផាណ្ណារ៉ា | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | ៧១.៨៤៦ |
| ១៦ | លោកស្រី ជួន សុខេម | ប្រធាននាយកដ្ឋានរដ្ឋបាល | ១៦៧.៥២២ |
| ១៧ | លោក គង់ សុផា | ប្រធាននាយកដ្ឋានបុគ្គលិក/ធនធានមនុស្ស | ៧២.០៨៧ |
| ១៨ | កញ្ញា ឈាវ វណ្ណធា | ប្រធាននាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ | ៨៣.៤៣៨ |
| ១៩ | លោក ជី វិចិត្រ | ប្រធាននាយកដ្ឋានវិស្វកម្ម | ៧១.៧២៦ |
| ២០ | លោក ជៀប វីរ៉ាយ៉ា | ប្រធាននាយកដ្ឋានជលធារសាស្ត្រ | ៧១.៥៤៦ |
| ២១ | លោក គុល សុខុម | ប្រធាននាយកដ្ឋានសេវាកម្មនាវាចរណ៍ | ៧២.០៣០ |
| ២២ | លោក សយ សេរីសុវឌ្ឍនៈ | ប្រធាននាយកដ្ឋានមណ្ឌលអាជីវកម្មផែ/ផែក្នុងស្រុក | ៧១.៤២៦ |
| ២៣ | លោក ហ៊ុន សុខាល័យ | ប្រធាននាយកដ្ឋានផែនការ/ទីផ្សារ | ៧១.៥២០ |
| ២៤ | លោក យឹម ជឿន | ប្រធាននាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧ | ៧៤.០១០ |
| **សរុប** | | | **១.៥៧៦.៩២២** |

**សម្គាល់៖*

*- លោកជំទាវ គីម សែន ចូលនិវត្តន៍ចាប់ពីខែកក្កដា ឆ្នាំ២០១៧*

*- ឯកឧត្តម ណៃម ធីម ចូលនិវត្តន៍ចាប់ពីខែតុលា ឆ្នាំ ២០១៧*

*- ការប៉ាន់ស្មានប្រាក់បៀវត្សរ៍របស់បុគ្គលិកជាន់ខ្ពស់សម្រាប់រយៈពេល ០១ឆ្នាំ ទៅមុខ ផ្អែកលើកំណើន ប្រាក់TEUs ។*

### *ឃ- ការបង្កើនប្រាក់បំណាច់ ឬលាភការសេរុបក្នុងចំនួនច្រើន ដល់អភិបាល ឬបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុននៅក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន ឬអនាគត*

ប្រាក់បៀវត្សរ៍របស់ក្រុមប្រឹក្សាភិបាល មានការកើនឡើង លុះត្រាតែមានការស្នើសុំតាមរយៈការប្រជុំសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។ ទន្ទឹមនេះ ប្រាក់បៀវត្សរ៍ប្រចាំខែរបស់បុគ្គលិកជាន់ខ្ពស់ អាចនឹងមានការកើនឡើង ឬថយចុះ អាស្រ័យទៅតាមចំនួនកុងតឺន័រ TEUs ដែលឆ្លងការកំពង់ផែ ប្រចាំខែ។

## ៧. ក្រមសីលធម៌សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

### *ក- គោលការណ៍នៃក្រមសីលធម៌*

ក្រមសីលធម៌នេះ ជាក្រមប្រតិបត្តិ ដែលត្រូវអនុវត្តចំពោះក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ ក. ស. ភ.។

រាល់ការបំពានលើក្រមសីលធម៌នេះ អាចនឹងត្រូវទទួលទណ្ឌកម្មនានាទៅតាមនីតិវិធី ដែលប្រតិបត្តិដោយក្រុមប្រឹក្សាភិបាល។ គោលការណ៍ និងលក្ខខណ្ឌដែលមានចែងនៅក្នុងក្រមសីលធម៌នេះ ត្រូវបានតាក់តែងឡើង ដោយអនុលោមតាមច្បាប់ជាធរមាន ដើម្បីឱ្យអភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ ក. ស. ភ. គោរពប្រតិបត្តិតាម។ ក្រមសីលធម៌នេះ មិនត្រូវបានប្រើ ដើម្បីជំនួសការដោះស្រាយវិវាទតាមផ្លូវតុលាការនោះទេ។

យន្តការតាមដាន និងរក្សាតុល្យភាព (Checks and Balances) ដែលមានក្នុងក្រមសីលធម៌នេះ ត្រូវបានរៀបចំឡើង ដើម្បីធានាតុល្យភាពក្នុងការគ្រប់គ្រង និងការគោរពកាតព្វកិច្ចកំណត់ដោយច្បាប់ ព្រមទាំងការពារក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់ពីការចោទប្រកាន់មិនត្រឹមត្រូវ ឬគ្មានហេតុផលណា មួយ។ ការចោទប្រកាន់បែបនេះ នឹងអាចមានផលប៉ះពាល់ដល់អាជីវកម្មរបស់ ក. ស. ភ. ឬប៉ះពាល់ផលប្រយោជន៍ដល់បុគ្គលណាម្នាក់។ សមាជិកក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់ ក. ស. ភ. អះអាង និងប្តេជ្ញាថានឹងគោរពតាមគោលការណ៍ និងកាតព្វកិច្ច ដូចមានចែងនៅក្នុងក្រមសីលធម៌នេះ។

- **និយមន័យ**

**ក្រុមប្រឹក្សាភិបាល** ៖ សំដៅដល់ក្រុមប្រឹក្សាភិបាលនៃកំពង់ផែស្វយ័តភ្នំពេញ។

**អភិបាល** ៖ សំដៅដល់សមាជិកនៃក្រុមប្រឹក្សាភិបាល ហើយអាចជាអភិបាលប្រតិបត្តិ អភិបាលមិនប្រតិបត្តិ ឬ អភិបាលឯករាជ្យ។

**អភិបាលឯករាជ្យ** ៖ សំដៅដល់សមាជិកឯករាជ្យ ដែលបំពេញតាមលក្ខខណ្ឌនៃជំពូកទី៥ នៃប្រកាសស្តីពី អភិបាលកិច្ចអាជីវកម្ម សម្រាប់សហគ្រាសសាធារណៈបោះផ្សាយលក់មូលបត្រជាសាធារណៈ និងដែលជាទូទៅសំដៅដល់អភិបាល ដែលអាចមានភារកិច្ចដោយមិនមានទំនាស់ផលប្រយោជន៍ដែលកើតឡើងពាក់ព័ន្ធជាមួយ ក.ស.ភ.។

**អភិបាលប្រតិបត្តិ** ៖ សំដៅដល់អភិបាលដែលកាន់តំណែងជាបុគ្គលិកជាន់ខ្ពស់នៅក្នុង ក.ស.ភ.។

**អភិបាលមិនប្រតិបត្តិ** ៖ សំដៅដល់អភិបាលដែលមិនអនុវត្តនូវប្រតិបត្តិការប្រចាំថ្ងៃក្នុង ក. ស. ភ. ឬក៏ជាអភិបាលមិនប្រតិបត្តិជាតំណាងភាគហ៊ុនិកឯកជននិងសាធារណៈ។

**បុគ្គលិកជាន់ខ្ពស់** ៖ សំដៅដល់បុគ្គលទាំងឡាយណាដែលមានមុខតំណែងចាប់ពីប្រធាននាយកដ្ឋាន រហូតដល់អគ្គនាយក រួមទាំងលេខាធិការរបស់ ក. ស. ភ. និងប្រធានសវនកម្មផ្ទៃក្នុង និងអ្នកដែលមានមុខតំណែងសំខាន់ផ្សេងទៀតក្នុងក្រុមហ៊ុន។

❖ **ការបំពេញកាតព្វកិច្ចតាមច្បាប់ និងតាមក្រមសីលធម៌**

អភិបាល និងបុគ្គលិកជាន់ខ្ពស់ទាំងអស់ ត្រូវតែប្រតិបត្តិតាមក្រមសីលធម៌ និងគោរពតាមច្បាប់ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តទាំងឡាយជាធរមានក្នុងព្រះរាជាណាចក្រកម្ពុជា។

❖ **ការធ្វើអាជីវកម្ម**

អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវបំពេញការងារក្នុងអាជីវកម្មរបស់ ក. ស. ភ. ដោយស្មោះត្រង់ គោរពតាមច្បាប់។

ភាពស្មោះត្រង់ និងការបំពេញកាតព្វកិច្ចតាមច្បាប់ មានន័យថា អភិបាល ឬបុគ្គលិកជាន់ខ្ពស់ត្រូវ៖

- បំពេញតួនាទីជាមួយនឹងព័ត៌មានពេញលេញទាក់ទងនឹងកម្មវត្ថុពាក់ព័ន្ធ នឹងសេចក្តីសម្រេចណាមួយ
- បំពេញតួនាទីប្រកបដោយសុចរិត និងក្នុងគោលបំណងត្រឹមត្រូវ
- បំពេញតួនាទីដោយមិនគិតពីផលប្រយោជន៍ផ្ទាល់ខ្លួន ដែលនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍អង្គភាព
- អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវមានគោលជំហរច្បាស់លាស់ ក្នុងការបម្រើផលប្រយោជន៍ របស់ភាគហ៊ុនិកទាំងអស់ ជាពិសេស ក្នុងពេលធ្វើការសម្រេចចិត្ត។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ មិនត្រូវជាប់ពាក់ព័ន្ធ ទោះបីដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ជាមួយនឹងការជួញដូរផ្ទៃក្នុង ឬស៊ែហ្វ៍ដៀលីង (Self-Dealing) ដែលមិនត្រឹមត្រូវ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវធ្វើសេចក្តីប្រកាសជាសាធារណៈមួយអំពីទំនាស់ផលប្រយោជន៍របស់ខ្លួន ដែលកើតមានឡើងពាក់ព័ន្ធនឹង ក. ស. ភ.។ អភិបាល និងបុគ្គលិកជាន់ខ្ពស់នៃ ក.ស.ភ. ពុំត្រូវបានអនុញ្ញាតឱ្យធ្វើការជួញដូរមូលបត្រកម្មសិទ្ធិរបស់ ក.ស.ភ. ឡើយ ក្នុងកំឡុងពេលដូចខាងក្រោម៖

- ១០ថ្ងៃ នៃថ្ងៃធ្វើការ មុនការចេញផ្សាយព័ត៌មានហិរញ្ញវត្ថុ រហូតដល់១ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីការចេញផ្សាយព័ត៌មានហិរញ្ញវត្ថុ
- ៧ថ្ងៃ នៃថ្ងៃធ្វើការ មុនកិច្ចប្រជុំនៃក្រុមប្រឹក្សាភិបាល រហូតដល់១ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយកិច្ចប្រជុំនៃក្រុមប្រឹក្សាភិបាល។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ អាចចូលរួមក្នុងកិច្ចការជំនួញក្នុងនាម ក. ស. ភ. ដែលពួកគេមានផលប្រយោជន៍ លុះត្រាតែអភិបាល ឬបុគ្គលិកជាន់ខ្ពស់ទាំងនោះ អនុវត្តតាមគោលការណ៍ និងបែបបទទាំងអស់ ដែលបានអនុម័ត ព្រមទាំងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយ ក្នុងព្រះរាជាណាចក្រកម្ពុជា។

❖ **ការរក្សាការសម្ងាត់**

គ្មានអភិបាល ឬបុគ្គលិកជាន់ខ្ពស់ណាម្នាក់ មានសិទ្ធិចែកចាយ ថតចម្លង ផលិតជាថ្មី បញ្ជូន បង្ហាញ ឬលាតត្រដាង រាល់ព័ត៌មានសម្ងាត់ណាមួយ ដែលពាក់ព័ន្ធនឹងកិច្ចការរបស់ ក. ស. ភ.។ អភិបាល ឬបុគ្គលិកជាន់ខ្ពស់ ត្រូវរក្សាយ៉ាងម៉ឺងម៉ាត់ នូវការសម្ងាត់នៃកិច្ចប្រជុំទាំងអស់ និងការពិភាក្សាផ្សេងៗ ព្រមទាំងការទំនាក់ទំនងនៃក្រុមប្រឹក្សាភិបាល លើកលែងតែក្រុមប្រឹក្សាភិបាល ឬច្បាប់តម្រូវផ្សេងពីនេះ ។

គ្មានអភិបាល ឬបុគ្គលិកជាន់ខ្ពស់ណាម្នាក់ ប្រើប្រាស់នូវរាល់ព័ត៌មានណាមួយ ដែលផ្តល់ដោយ ក. ស. ភ. ឬទទួលបានតាមរយៈការបំពេញការងារជាអភិបាលទៅឱ្យ ក. ស. ភ. ទោះបីក្រោមរូបភាពណា ក៏ដោយលើកលែងតែក្នុងគោលបំណងជួយសម្រួលដល់កាតព្វកិច្ចរបស់ខ្លួន នៅក្នុងក្រុមប្រឹក្សាភិបាល។ អភិបាល ឬបុគ្គលិកជាន់ខ្ពស់ ត្រូវយកចិត្តទុកដាក់ជាពិសេស ក្នុងពេលបំពេញការងារទាក់ទងនឹង លទ្ធផលរបស់ក្រុមហ៊ុន ការប៉ាន់ស្មានព័ត៌មានហិរញ្ញវត្ថុផ្សេងទៀត ចំណេះដឹង និងបច្ចេកវិទ្យា ព្រមទាំងព័ត៌មានធនធានមនុស្ស។ អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវគោរពកាតព្វកិច្ចរក្សាការសម្ងាត់ ទោះបីក្រោយពីបានបញ្ចប់ការងាររបស់ខ្លួននៅ ក. ស. ភ. ក៏ដោយ។

❖ **ការគោរពសិទ្ធិចំពោះបុគ្គលិក ក. ស. ភ.**

អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវអនុវត្តអំណាចរបស់ខ្លួនឱ្យបានត្រឹមត្រូវ និងធ្វើការវិនិច្ឆ័យឱ្យបានល្អ ចំពោះបុគ្គលិករបស់ ក. ស. ភ. ព្រមទាំងត្រូវឆ្លើយតបទៅតាមតម្រូវការនៃសមាជិករបស់ ក. ស. ភ. ដោយភាពទទួលខុសត្រូវ ការគោរព និងដោយមានវិជ្ជាជីវៈខ្ពស់។

ទំនាក់ទំនងរវាងមន្រ្តី និយោជិត និងអភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវធ្វើឡើយដោយឈរលើគោលការណ៍នៃការជឿទុកចិត្ត ការគោរពគ្នាទៅវិញទៅមក និងស្មារតីគោរពសេចក្តីថ្លៃថ្នូររបស់បុគ្គលិកម្នាក់ៗ។

ក. ស. ភ. ត្រូវគោរពតាមគោលនយោបាយធនធានមនុស្សរបស់ខ្លួនដោយឥតលម្អៀង និងគោរពតាមច្បាប់ ដោយមិនត្រូវបង្កាច់បង្ខូច ឬមានការរើសអើងឡើយ។ រាល់ការគាបសង្កត់ ការរំខាន ការធ្វើទុក្ខ បុកម្នេញ ឬការធ្វើទារុណកម្មខាងផ្លូវចិត្ត ឬផ្លូវកាយ ត្រូវបានហាមឃាត់។

គោលការណ៍ទាំងនេះ អនុវត្តលើអភិបាល និងបុគ្គលិកជាន់ខ្ពស់ ទាក់ទងនឹងការប្រព្រឹត្តរបស់ខ្លួន ចំពោះបុគ្គលិករបស់ ក. ស. ភ. និងបុគ្គលដែលមិនមែនជាបុគ្គលិកក្នុង ក. ស. ភ. ផងដែរ ។

❖ **ការការពារទ្រព្យសម្បត្តិ**

អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវការពារទ្រព្យសម្បត្តិទាំងអស់របស់ ក. ស. ភ.។ ទ្រព្យសម្បត្តិទាំងនោះ រួមមាន ទ្រព្យរូបី និងទ្រព្យអរូបី ដូចជាគំនិត ជំនាញ ចំណេះដឹង ចំណេះធ្វើ ដែលបង្កើតឡើងដោយ ក. ស. ភ.។

អភិបាល ឬបុគ្គលិកជាន់ខ្ពស់ មិនត្រូវប្រើប្រាស់ទ្រព្យសម្បត្តិ ឬធនធានរបស់ ក. ស. ភ សម្រាប់ហេតុផលផ្ទាល់ខ្លួន ឬដើម្បីផលប្រយោជន៍ដល់តតិយជនឡើយ។ អភិបាល ឬបុគ្គលិកជាន់ខ្ពស់ ត្រូវរក្សាទ្រព្យសម្បត្តិរបស់ ក. ស. ភ. ឱ្យបានល្អគង់វង្ស គ្រប់ពេលវេលា និងមិនត្រូវឱ្យបុគ្គលណាម្នាក់ ដែលមិនទទួលបានការអនុញ្ញាតពីក្រុមប្រឹក្សាភិបាល មានសិទ្ធិប្រើប្រាស់ អាស្រ័យផល និងចាត់ចែងទ្រព្យសម្បត្តិរបស់ ក. ស. ភ. ឡើយ។

❖ សវនកម្មផ្ទៃក្នុង

អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវធានានូវតម្លាភាព និងភាពស្មោះត្រង់ នៅពេលបំពេញការងារទាក់ទងជាមួយនឹងសវនកម្មផ្ទៃក្នុង និងអធិការកិច្ច ដើម្បីធានាថាភាពទន់ខ្សោយ និងគុណវិបត្តិចម្បងៗ អាចត្រូវបានកំណត់ និងកែតម្រូវបាន។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ មិនត្រូវធ្វើទង្វើណាមួយ ដែលនាំឱ្យរាំងស្ទះ ឬ លាក់បាំងព័ត៌មានណាមួយ ដល់ការធ្វើសវនកម្ម ឬការធ្វើអធិការកិច្ចណាមួយឡើយ ទោះបីជាការធ្វើឡើងនោះជាលក្ខណៈផ្ទៃក្នុង ដោយសវនករនៃ ក. ស. ភ. ក៏ដោយ។ រាល់ការប្រព្រឹត្តទង្វើទាំងនេះ គឺជាការបំពានយ៉ាងធ្ងន់ធ្ងរទៅលើក្រមសីលធម៌នេះ ហើយត្រូវបានហាមឃាត់ ។

❖ សកម្មភាពអភិវឌ្ឍន៍

អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវចូលរួមឱ្យអស់ពីលទ្ធភាពរបស់ខ្លួនជាប្រចាំ នៅក្នុងសកម្មភាពអភិវឌ្ឍន៍វិជ្ជាជីវៈ ព្រមទាំងបំពេញភារកិច្ចរបស់ខ្លួនឱ្យមានលក្ខណៈវិជ្ជាជីវៈ និងឱ្យបានទាន់ពេលវេលាទៅតាមការណែនាំ និងការគ្រប់គ្រងរបស់ក្រុមប្រឹក្សាភិបាល។

❖ ផលប្រយោជន៍របស់ ក. ស. ភ.

អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវធ្វើការលះបង់ ដើម្បីបំពេញតាមតម្រូវការរបស់ ក. ស. ភ.។

អភិបាល ត្រូវបំពេញតួនាទីគ្រប់ពេលទាំងអស់ ដើម្បីជាឧត្តមប្រយោជន៍របស់ ក. ស. ភ. ហើយមិនមែនដើម្បីផលចំណេញ ឬការបង្កើនប្រយោជន៍ហិរញ្ញវត្ថុផ្ទាល់ខ្លួន ឬតតិយជនណាមួយឡើយ។ បុគ្គលិកទាំងអស់របស់ ក. ស. ភ. ដោយរាប់បញ្ចូលទាំងអភិបាល និងបុគ្គលិកជាន់ខ្ពស់ផង ត្រូវបំពេញនូវតួនាទី ដោយស្មោះត្រង់ និងដើម្បីផលប្រយោជន៍របស់ ក. ស. ភ. គ្រប់កាលៈទេសៈទាំងអស់។ បុគ្គលិកទាំងអស់ មិនត្រូវបរិហារជាសាធារណៈ និងវាយប្រហារណាមួយមកលើកិត្តិនាម និងភាពស្មោះត្រង់របស់ ក. ស. ភ. និងការវាយប្រហារមកលើវិជ្ជាជីវៈការងាររបស់បុគ្គលិក ក. ស. ភ.។

❖ ទំនាស់ផលប្រយោជន៍

អភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ ក. ស. ភ. ត្រូវធានាថាសកម្មភាពខាងក្រៅ និងផលប្រយោជន៍ផ្ទាល់ខ្លួនត្រូវបានចែកឱ្យដាច់ពីតួនាទីនៅក្នុង ក. ស. ភ. និងមិនត្រូវប្រើឥទ្ធិពលទៅលើការសម្រេចអាជីវកម្មក្នុងនាម ក. ស. ភ. ឡើយ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់ ចាំបាច់ត្រូវប្រើនូវសុភវិនិច្ឆ័យ និងរក្សាផលប្រយោជន៍ ក. ស. ភ. ជាធំ។ ដើម្បីកុំឱ្យមានទំនាស់ផលប្រយោជន៍ អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវជៀសវាងចេញពីស្ថានភាពណាមួយ ដែលអាចបណ្តាលឲ្យកើតមានទំនាស់ផលប្រយោជន៍។

នៅពេលដែលទំនាស់ផលប្រយោជន៍អាចនឹងកើតមានឡើង នោះអភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ ក. ស. ភ. ត្រូវកំណត់ទំនាស់ផលប្រយោជន៍នោះ ហើយធ្វើការប្រកាសជាសាធារណៈ អំពីទំនាស់ផលប្រយោជន៍ និងធ្វើការដកខ្លួនចេញពីការពិភាក្សា និងការបោះឆ្នោតលើបញ្ហាទាំងនោះ (បើអនុវត្តបាន)។

### ❖ អំពើពុករលួយ

អភិបាល និងបុគ្គលិកជាន់ខ្ពស់ មិនត្រូវផ្តល់ប្រាក់ឧបត្ថម្ភ ឬអំណោយដោយផ្ទាល់ ឬដោយប្រយោល មិនត្រូវធ្វើការសន្យា ឬផ្តល់ផលប្រយោជន៍ណាមួយទៅកាន់មន្រ្តីសាធារណៈ ឬប្រជាពលរដ្ឋដែលទទួលការទុកចិត្តក្នុងអាណត្តិសាធារណៈ តាមរយៈការបោះឆ្នោតដើម្បីឲ្យមន្រ្តីសាធារណៈនោះ ឬមន្ត្រីដែលជាប់ឆ្នោតនោះ (១)អនុវត្តសកម្មភាពណាមួយក្នុងតួនាទីរបស់គេ ឬក៏សម្របសម្រួលការងារណាមួយក្នុងតួនាទីរបស់ពួកគេ ឬ (២)មិនអនុវត្តកាតព្វកិច្ច ឬសម្របសម្រួលការងារណាមួយក្នុងតួនាទីរបស់ពួកគេ ។

អភិបាល ឬបុគ្គលិកជាន់ខ្ពស់ មិនត្រូវទទួលយកអំណោយ ដែលត្រូវបានផ្តល់ឱ្យ ឬនឹងត្រូវផ្តល់ឱ្យ ដោយសារតែតួនាទីរបស់ខ្លួននៅក្នុង ក. ស. ភ.។

### ❖ សកម្មភាពនយោបាយ

ក. ស. ភ. គោរពតាមការប្តេជ្ញាចិត្តរបស់ក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់ ដែលចង់ចូលរួមក្នុងកិច្ចការសាធារណៈ ប៉ុន្តែ ក. ស. ភ. ត្រូវប្រកាន់គោលការណ៍អព្យាក្រឹតចំពោះវិស័យនយោបាយ។ ដូចនេះ អភិបាល ឬបុគ្គលិកជាន់ខ្ពស់របស់ ក. ស. ភ. អាចអនុវត្តសេរីភាពបញ្ចេញមតិ និងធ្វើសកម្មភាពនយោបាយបាននៅក្រៅពីម៉ោងធ្វើការ ដោយចំណាយផ្ទាល់ខ្លួន និងផ្អែកលើគំនិតផ្ទាល់ខ្លួនប៉ុណ្ណោះ។

អភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ ក. ស. ភ. មិនត្រូវភ្ជាប់ ក. ស. ភ. ទៅនឹងសកម្មភាពផ្ទាល់ខ្លួនរបស់ពួកគេទេ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់ ពុំត្រូវពិភាក្សាពីសមាជិកភាពរបស់ ក. ស. ភ. ទៅក្នុងបរិបទនយោបាយណាមួយឡើយ។

### ❖ ការបញ្ចប់អាណត្តិ

ក្រោយពីបញ្ចប់ភារកិច្ចរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ ដែលចូលនិវត្តត្រូវប្រគល់ភ្លាមទៅឱ្យ ក. ស. ភ. វិញនូវឯកសារអេឡិចត្រូនិច និងឯកសារ ជាក្រដាស ឯកសារយោង និងឯកសារផ្សេងៗ ទៀត ដែលត្រូវបានផ្តល់ជូនក្នុងគោលបំណងបំពេញការងារ។ ការប្រគល់ជូនទៅវិញនូវឯកសារទាំងនេះ មិនបានលុបចោលនូវកាតព្វកិច្ចរក្សាការសម្ងាត់នូវព័ត៌មាន ដែលទទួលបានក្នុងរយៈពេលនៃការកាន់ មុខតំណែងនៅក្នុងក្រុមប្រឹក្សាភិបាល ឬតួនាទីជាន់ខ្ពស់នៅក្នុង ក. ស. ភ. នោះទេ។

### ❖ ការបកស្រាយ

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមស្មារតី និងខ្លឹមសារនៃក្រមសីលធម៌នេះ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់ មានភារកិច្ចយល់ដឹងអំពីក្រមសីលធម៌នេះ។ អភិបាល ឬបុគ្គលិកជាន់ខ្ពស់ណាម្នាក់ ដែលមានភាពស្រពិចស្រពិល ឬយល់មិនច្បាស់លើបទប្បញ្ញត្តិណាមួយ ត្រូវទាក់ទងទៅផ្នែកច្បាប់ ដោយផ្តល់ពេលវេលាគ្រប់គ្រាន់ឱ្យផ្នែកច្បាប់អាចផ្តល់យោបល់ ឬធ្វើការសម្រេចចិត្តសមស្របមួយ។

❖ **ការកែប្រែ**

ក្រមសីលធម៌នេះ អាចត្រូវបានធ្វើការកែប្រែ ដោយក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ដោយគោរព តាមលក្ខខណ្ឌតម្រូវក្នុងការផ្តល់ព័ត៌មាន ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយជាធរមាន។

**ខ- ការអនុវត្តក្រមសីលធម៌**

ក្រមសីលធម៌នេះ ត្រូវបានអនុម័ត ដោយក្រុមប្រឹក្សាភិបាលនៃកំពង់ផែស្វយ័តភ្នំពេញ នៅថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០១៥ និងមានអានុភាពចាប់ពីពេលក្រុមហ៊ុនទទួលបានការយល់ព្រមឱ្យធ្វើការ បោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ដោយគណៈកម្មការមូលបត្រកម្ពុជា និងត្រូវបានចុះ បញ្ជីលក់មូលបត្រនៅផ្សារមូលបត្រកម្ពុជា។ ក្រុមប្រឹក្សាភិបាល ត្រូវចាត់វិធានការសមស្រប ក្នុងករណី មានការបំពារបំពានក្រមសីលធម៌នេះ។

## ៨. សិទ្ធិភាគីពាក់ព័ន្ធ

សម្រាប់ឆ្នាំ២០១៧ សិទ្ធិភាគីពាក់ព័ន្ធមិនទាន់បានអនុវត្តនោះទេ។

# ផ្នែកទី៤

# បញ្ជីរាយនាមភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ និងភាគហ៊ុនិកកាន់កាប់ភាគហ៊ុន មានសិទ្ធិបោះឆ្នោតចំនួនច្រើន

## ១. ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុន មានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់

| ល.រ | ឈ្មោះ | សញ្ញាតិ | អាសយដ្ឋាន | លេខអត្តសញ្ញាណវិនិយោគិន (ប្រសិនបើមាន) | បរិមាណ | ភាគរយ |
|---|---|---|---|---|---|---|
| ១ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ខ្មែរ | ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ | គ្មាន | ១៦.៥៤៧.៩៩២ | ៨០% |
| សរុប | | | | | **១៦.៥៤៧.៩៩២** | **៨០%** |

## ២. ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន

| ល.រ | ឈ្មោះ | សញ្ញាតិ | អាសយដ្ឋាន | លេខអត្តសញ្ញាណវិនិយោគិន (ប្រសិនបើមាន) | បរិមាណ | ភាគរយ |
|---|---|---|---|---|---|---|
| ១ | Mekong Strategic Infrastructure | បរទេស | Craigmor Chambers. Road Town. Tortola. Vg១១១០. Virgin Islands, British | F៤១៨៧៦៧៨៤៧៨៦ | ១.២៣០.៩២៧ | ៥,៩៥% |
| សរុប | | | | | **១.២៣០.៩២៧** | **៥,៩៥%** |

# ផ្នែកទី ៥
# ព័ត៌មានអំពីការជួញដូរមូលបត្ររបស់កំពង់ផែស្វយ័តភ្នំពេញ

## ១. ព័ត៌មានអំពីមូលបត្រកម្មសិទ្ធិ

ឈ្មោះមូលបត្រកម្មសិទ្ធិ : មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតប្រភេទ "ក"

អក្សរកូដមូលបត្រកម្មសិទ្ធិ : **KH1000040001**

ចំណាត់ថ្នាក់នៃមូលបត្រកម្មសិទ្ធិ : មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតប្រភេទ "ក"

តម្លៃចារឹកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ : ៤.០០០រៀល

ថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ : ៥.១២០រៀល

បរិមាណមូលបត្រកម្មសិទ្ធិសរុបទាំងអស់ដែលកំពុងធ្វើចរាចរលើទីផ្សារ : ៤.១៣៦.៨៧៣ មូលបត្រ

មូលធនូបនីយកម្មទីផ្សារ : ១០៥.៩០៣.៩៤៨.៨០០ រៀល

ឈ្មោះទីផ្សារមូលបត្រប្រតិស្រុត : ផ្សារមូលបត្រកម្ពុជា

កាលបរិច្ឆេទនៃការចុះបញ្ជីលក់មូលបត្រ : ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥

## ២. ថ្លៃនិងបរិមាណជួញដូរ

| មូលបត្រកម្មសិទ្ធ | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ថ្លៃជួញដូរ | អតិបរមា | ៥.២០០ | ៥.៣០០ | ៥.២០០ | ៥.២២០ | ៥.៣៤០ | ៥.២០០ | ៥.១៦០ | ៥.១៨០ | ៥.០៤០ | ៥.៤០០ | ៥.១០០ | ៥.១៤០ |
| | អប្បបរមា | ៥.០៦០ | ៥.១៨០ | ៥.០២០ | ៤.៦០០ | ៤.៩០០ | ៤.៩០០ | ៤.៨២០ | ៤.៨៦០ | ៤.៩០០ | ៤.៩៨០ | ៤.៩០០ | ៤.៩០០ |
| | មធ្យម | ៥.១៣០ | ៥.២៤០ | ៥.១១០ | ៤.១៩០ | ៥.១២០ | ៥.០៥០ | ៤.៩៩០ | ៥.០២០ | ៤.៩៧០ | ៥.១៩០ | ៥.០០០ | ៥.០២០ |
| បរិមាណជួញដូរ | អតិបរមា | ៨០.០២០ | ១៧០ | ១៥.៧៥៦ | ៣២.៤៩២ | ២១.៣៦១ | ១២.១៩២ | ៧៧.៩៨២ | ៨.៧៧០ | ២.៨៧៧ | ៥.៧៧៩ | ៧.៤២២ | ៧.៨៥៥ |
| | អប្បបរមា | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ៣០ | ០ |
| | មធ្យម | ៣.៩៩១ | ២៤ | ២.៧២៧ | ៥.០៥៦ | ៧.៣៦៨ | ៤.៨៥៧ | ៤.៤៦៥ | ១.៥២៦ | ៥៨៩ | ១.៥៥៥ | ១.១៥៣ | ៨៣៣ |

# ផ្នែកទី ៦

# របាយការណ៍សវនកម្មរបស់សវនករ ផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

កំពង់ផែស្វយ័តភ្នំពេញ

គណៈកម្មាធិការសវនកម្ម

នាយកដ្ឋានសវនកម្មផ្ទៃក្នុង

លេខ...០១៣..... នសផក-ក. ស. ភ.

**របាយការណ៍សវនកម្ម**

**ស្តីពីការអនុវត្តការត្រួតពិនិត្យផ្ទៃក្នុងប្រចាំឆ្នាំ ២០១៧**

កំពង់ផែស្វយ័តភ្នំពេញ ជាសហគ្រាសសាធារណៈមានការអភិវឌ្ឍន៍ជាបន្តបន្ទាប់ ដែលអនុលោមតាមច្បាប់លិខិតបទដ្ឋានគតិយុត្តជាធរមាន ដើម្បីសម្រេចបានតាមផែនការសកម្មភាពហិរញ្ញវត្ថុ នាពេលបច្ចុប្បន្ននេះក៏នៅតែបន្តពង្រីកសក្តានុពលរបស់ខ្លួនឥតឈប់ឈរ ដោយបោះផ្សាយលក់មូលបត្រជាសាធារណៈផងដែរ។ ទន្ទឹមនឹងនេះ ក៏នៅមានចំនុចអវិជ្ជមានមួយចំនួនទៀតដែលត្រូវកែលម្អ។

ដូចនេះ ការងារត្រួតពិនិត្យផ្ទៃក្នុង គឺជាកត្តាចម្បងដ៏មានសារៈសំខាន់បំផុត ដែលជួយដល់ ក. ស. ភ. ធ្វើប្រតិបត្តិការប្រចាំថ្ងៃរបស់អង្គភាពប្រកបដោយជោគជ័យ និងសម្រេចបាននូវគោលដៅជាអាទិភាពក្នុងសកម្មភាពអាជីវកម្ម ដើម្បីបំពេញចិត្តអតិថិជន និងកែលម្អឥតឈប់ឈរនៅសមត្ថភាពបុគ្គលិក កម្មករជំនាញសម្រួលបែបបទឯកសារ ភាពទន់ភ្លន់នៃតម្លៃ សេវាកម្មសមស្រប នឹងទីផ្សារ ដែលប្រកបដោយគណនេយ្យភាព។

យោងតាមផែនការសវនកម្មប្រចាំឆ្នាំ ២០១៧ នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានចុះត្រួតពិនិត្យ÷

១.សេវាដ្ឋានបួមស្តារ/ផែទាំប្រឡាយ

២.អង្គភាពថែទាំ/ជួសជុល

៣.អង្គភាពផែស្ងួត ICD

៤.នាយកដ្ឋានមណ្ឌលអាជីវកម្ម/ផែក្នុងស្រុក

៥.សេវាដ្ឋានផែក្នុងស្រុក/មណ្ឌលផែ

៦.អង្គភាពផែននេ្លបិទ

៧.អង្គភាពផែប្រេង/ហ្គាស

៨.នាយកដ្ឋានវិស្វកម្ម

៩.សេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ

១០. សេវាដ្ឋានថែទាំពោងសញ្ញា/GPS

១១. អង្គភាពវាស់ស្ទង់

១២. ការិយាល័យផែនការ/ ស្ថិតិ

១៣. ការិយាល័យតម្លៃ/ទីផ្សារ

**១. សេវាដ្ឋានបូមស្ដារ/ថែទាំច្រកឡាយ, អង្គភាពថែទាំ/ជួសជុល និងអង្គភាពផែស្ងួត ICD (ត្រីមាសទី១)**

**១.១. សេវាដ្ឋានបូមស្ដារ/ថែទាំច្រកឡាយ**

- សវនករផ្ទៃក្នុងសង្កេតឃើញថា ចំពោះតារាងទទួលប្រេងឥន្ធនៈការដ្ឋានប្រឡាយនាវាចរណ៍ស្ពោ គួរតែបន្ថែមតារាងសម្រាប់ចុះហត្ថលេខាទទួលស្គាល់ពីប្រធានផែនប្រតិបត្តិការនីមួយៗ ដែលបានធ្វើការប្រគល់-ទទួលប្រេងឥន្ធនៈពីក្រុមហ៊ុនផ្គត់ផ្គង់ប្រេងដើម្បីឱ្យមានភាពត្រឹមត្រូវ និងច្បាស់លាស់ ។
- សេវាដ្ឋានគួរតែបន្តជម្រុញធ្វើសំណើសុំរៀនវគ្គបណ្តុះបណ្តាលមេកានិចជួសជុលបឋមដល់ បុគ្គលិក កម្មករជំនាញ ដើម្បីបង្កើនជំនាញរបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ងាយស្រួលក្នុងការជួសជុលម៉ាស៊ីនមួយចំនួនពេលមានបញ្ហាកើតឡើងជាយថាហេតុពេលកំពុងបូមស្ដារ និងរាំងស្ទះការងារ (តាមអនុសាសន៍របស់ថ្នាក់ដឹកនាំ ក. ស. ភ.) ។
- សេវាដ្ឋានគួរតែរៀបចំធ្វើបញ្ជីឧបករណ៍បូមស្ដារមានដូចជា: ទុយោបែកធ្លាយ និងបណ្តាសម្ភារដទៃទៀតដែលខូចប្រើការលែងបាន ហើយត្រូវធ្វើរបាយការណ៍ជូនដំណឹងដល់នាយកដ្ឋានពាក់ព័ន្ធ ដើម្បីធ្វើវិលោះសម្ភារទាំងនោះ ។
- សេវាដ្ឋានគួរតែធ្វើគម្រោងជួសជុលថែទាំលាបថ្នាំផ្ទះទឹកជម្រកកម្មករ ឱ្យបានល្អប្រសើរជាងសព្វថ្ងៃ ដើម្បីរក្សាសុវត្ថិភាព និងសុខភាពជូនដល់បុគ្គលិក កម្មករ ដែលនៅបម្រើការងារ ។
- សេវាដ្ឋានគួរតែធ្វើរបាយការណ៍ជូននាយកដ្ឋានពាក់ព័ន្ធពីកង្វះខាតអ្នកជំនាញបូមស្ដារ ជាពិសេសផ្តល់ដំណឹងដល់នាយកដ្ឋានធនធានមនុស្ស/បុគ្គលិក អំពីទំហំការងារតួនាទី ភារកិច្ច មន្ត្រី បុគ្គលិក កម្មករ នឹងអ្នកបច្ចេកទេសឡើងវិញពីចំនួនដែលកំពុងបំពេញការងារទាំងអ្នកបានចូលនិវត្តន៍ និងអ្នកត្រៀមចូលនិវត្តន៍នៅក្នុងឆ្នាំ២០១៧នេះ។ សវនករបានពិនិត្យឃើញថា សេវាដ្ឋាននៅខ្វះអ្នកមានជំនាញផ្នែកបូមស្ដារនៅពេលអ្នកជំនាញទាំងនោះចូលនិវត្តន៍។

**១.២. អង្គភាពថែទាំ/ជួសជុល**

- សវនករសង្កេតឃើញថា ចំពោះរបាយការណ៍ស្ដីពីវឌ្ឍនភាពការងារប្រចាំខែ មានដូចខាងក្រោម÷
  - គិតចាប់ពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ ដល់ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៧ និង
  - គិតចាប់ពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៧ ដល់ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៧ កំឡុងពេលដែលមិនទាន់មានប្រធានាយកដ្ឋានវិស្វកម្ម អង្គភាពថែទាំ/ជួសជុល គួរតែផ្តល់ជូនរបាយការណ៍នេះទៅ

ប្រធានសេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ ដើម្បីចុះហត្ថលេខាទទួលស្គាល់ឱ្យបានត្រឹមត្រូវទៅតាមទម្រង់ច្បាប់រដ្ឋបាល ។

- អង្គភាពផែចាំផ្ទុសផុល នៅមិនទាន់បានបំពេញបន្ថែមឱ្យត្រឹមត្រូវនូវវត្តមាន ភារកិច្ចនៅឡើយ ពីព្រោះក្នុងរបាយការណ៍វឌ្ឍនភាពការងារប្រចាំខែស្តីអំពីស្ថានភាព នៅតាមមុខងាររថយន្ត គ្រឿងចក្រ និងការងារផ្ទុសផុលអចិន្ត្រៃយ៍ផ្សេងទៀត អង្គភាពគួរតែមានការចុះហត្ថលេខាទទួលស្គាល់ពីលោកអគ្គនាយករងទទួលបន្ទុកបច្ចេកទេស ដើម្បីឱ្យរបាយការណ៍មានទម្រង់ត្រឹមត្រូវតាមច្បាប់រដ្ឋបាល ។

**១.៣. អង្គភាពផែស្ងួត ICD**

- អង្គភាព គួរតែមានកិច្ចសហការជាមួយក្រុមហ៊ុនដែលកំពុងជួលឃ្លាំងស្តុកទំនិញនៅ ICD ក្នុងការបញ្ចេញ-បញ្ចូល ទំនិញដើម្បីទទួលបាននូវព័ត៌មានសម្រាប់រក្សាសុវត្ថិភាពជូនអង្គភាព និងអតិថិជន ។
- អង្គភាពគួរតែបន្តជម្រុញផ្នែកពាក់ព័ន្ធ ក. ស. ភ. និងមានកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋានក្នុងការកសាងរបង ដើម្បីកំណត់ព្រំប្រទល់ដី ក. ស. ភ. (ICD) ព្រោះព្រំដីផ្នែកខាងជើងឃ្លាំងពុំទាន់មានរបងព្រំប្រទល់នៅឡើយ ។

**២. នាយកដ្ឋានមណ្ឌលអាជីវកម្មផែ/ផែក្នុងស្រុក, សេវាដ្ឋានផែក្នុងស្រុក/មណ្ឌលផែ, អង្គភាពផែនាគ, អង្គភាពផែរម្យូង/ម្លាស (ត្រីមាសទី២)**

**២.១ នាយកដ្ឋានមណ្ឌលអាជីវកម្មផែ/ផែក្នុងស្រុក**

- សវនករពិនិត្យឃើញថា នាយកដ្ឋានមានផែនការឆ្នាំ២០១៦ ប៉ុន្តែដើម្បីអោយមន្ត្រីមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការចុះអនុវត្តនូវកិច្ចការរបស់ខ្លួនក្នុងឆ្នាំ២០១៧ ប្រកបដោយប្រសិទ្ធភាព នាយកដ្ឋានគួរតែធ្វើផែនការប្រចាំឆ្នាំ២០១៧ បន្ថែមទៀត។
- ក្នុងឆ្នាំ២០១៧ សវនករពិនិត្យឃើញថានាយកដ្ឋានបានធ្វើរបាយការណ៍សរុប៥ខែ ដើមឆ្នាំ ប៉ុន្តែចំពោះការធ្វើរបាយការណ៍ប្រចាំខែ ជូនថ្នាក់ដឹកនាំពិនិត្យ និងជ្រាប នៅពុំទាន់បានសមស្របទៅតាមសេចក្តីណែនាំស្តីពីរបៀបធ្វើរបាយការណ៍ប្រចាំខែ យោងលិខិតលេខ១២២៥ ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ ដែលចុះហត្ថលេខាដោយប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាប្រធានអគ្គនាយក ក. ស. ភ. ។

**២.២ សេវាដ្ឋានផែក្នុងស្រុក/មណ្ឌលផែ**

- ក្រោយពីបានធ្វើសវនកម្មនៅទីតាំងផែក្នុងស្រុក ឃើញថាមន្ត្រីនៅសេវាដ្ឋានមានភាពសហការគ្នា និងណែនាំទៅប្រជាពលរដ្ឋដែលស្នាក់នៅក្នុងទីតាំងផែក្នុងស្រុកកុំឱ្យមានសំណង់ថ្មី ឬសាងសង់បន្ថែមទៀត។ ទន្ទឹមនឹងនេះក៏មានប្រជាពលរដ្ឋមួយចំនួនតូចបានលួចសាងសង់រោង និងតូបបន្ថែម តែត្រូវបានមន្ត្រីផែក្នុងស្រុក និងសន្តិសុខ ក. ស. ភ. ព្រមទាំងសមត្ថកិច្ចពាក់ព័ន្ធធ្វើការហាមឃាត់មិនឱ្យ

សាងសង់បន្ត និងធ្វើការរុះរើភ្លាមៗផងដែរ។ ដូចនេះសេវាដ្ឋានគួរតែរៀបចំវេនចុះត្រួតពិនិត្យបន្ថែមទៀត ដើម្បីសង្កេត និងមានវិធានការទប់ស្កាត់ប្រជាពលរដ្ឋនិលខ្វចម្ខយចំនួននិទ្យាន់ពេលវេលា ។

- ក្រោយពីបានចុះទៅពិនិត្យផ្ទាល់នៅផែក្នុងស្រុក (ចាប់ពីចំណុចស្ថានីយ៍ប្រេងឥន្ធនៈ PTT ដល់ទីស្នាក់ការផែក្នុងស្រុក/មណ្ឌលផែ) សវនករសង្កេតឃើញថា សេវាដ្ឋានគួរតែធ្វើបង្គោលរបងសងខាងច្រកចេញ-ចូលទាំង០៤ច្រក និងលើកស្លាកឈ្មោះមកវិញ (សេវាដ្ឋានផែក្នុងស្រុក/មណ្ឌលផែ) ដើម្បី÷
    - បញ្ជាក់ពីទីតាំងឱ្យអតិថិជនបានស្គាល់
    - កំណត់សម្គាល់ពីព្រំប្រទល់ច្រកចេញ-ចូលទាំង០៤ច្រក (កុំឱ្យប្រជាពលរដ្ឋធ្វើការសាងសង់បន្ថែមទៀត នៅលើច្រកចេញ-ចូល)
    - ជម្រុញឱ្យផែក្នុងស្រុកមានសកម្មភាពអាជីវកម្មឡើងវិញ ។
- សេវាដ្ឋានគួរតែសហការជាមួយអង្គភាពពាក់ព័ន្ធ និងក្រុមហ៊ុនផ្គត់ផ្គង់ និងលក់កាណូត ធ្វើការរុះរើ ឬផ្លាស់ប្តូរទីតាំងតូបវិញ ព្រោះសាងសង់នៅលើច្រកផ្លូវចេញ-ចូល នៅជិតទីស្នាក់ការផែក្នុងស្រុក/មណ្ឌលផែ ។
- សេវាដ្ឋានគួរតែបន្តធ្វើការស្នើសុំ ដល់ថ្នាក់ដឹកនាំដើម្បីផ្តល់ជាអនុសាសន៍ និងសម្របសម្រួល ជាមួយអាជ្ញាធរពាក់ព័ន្ធនានា អនុញ្ញាតអោយសេវាដ្ឋានផែក្នុងស្រុក/មណ្ឌលផែ អាចទទួលថ្លៃថែទាំមណ្ឌលអាជីវកម្មពីស្ថង់អាជីវកម្មទាំងនោះ ដើម្បីអោយស្របទៅតាមអនុក្រឹត្យលេខ ០១អនក្រ.បក ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៩ និងប្រកាសអន្តរក្រសួងលេខ ៥៦៦ សហវ.ប្រក. ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០២ ស្តីពីការប្រមូលថ្លៃឈ្នួលឱ្យមានប្រសិទ្ធភាព ។
- សវនករសង្កេតឃើញថា នៅក្នុងបរិវេណទីតាំងផែក្នុងស្រុកមានដីមួយកន្លែងដែលព័ទ្ធរបងសំណាញ់លួស (នៅជិតស្ថានីយ៍ប្រេងឥន្ធនៈPTT) ដោយបច្ចុប្បន្នមានការខូចខាតដាច់រហែកមួយចំនួន ដូចនេះសេវាដ្ឋានផែក្នុងស្រុក គួរតែធ្វើការជួសជុលរបងសំណាញ់ឱ្យបានរឹងមាំឡើងវិញ ដើម្បីការពារការទន្ទ្រានយកដីពីសំណាក់ប្រជាជន។

**២.៣ អង្គភាពផែទន្លេបិទ**

- ក្រោយពីសវនករចុះធ្វើសវនកម្មនៅអង្គភាពផែទន្លេបិទឃើញថា អង្គភាពគួរតែបន្តជម្រុញសហការជាមួយអ្នកបច្ចេកទេសគ្រឿងចក្រ ដើម្បីរៀបវេនចុះត្រួតពិនិត្យ និងថែទាំគ្រឿងចក្រនៅក្នុងផែទន្លេបិទ ឱ្យស្របទៅតាមបទដ្ឋានបច្ចេកទេស ។
- នៅអង្គភាពផែទន្លេបិទ (UM២) មិនមានកន្លែងរក្សាប្រេងសម្រាប់ដំណើរការប្រតិបត្តិការនៅឡើយទេ គឺដាក់នៅខាងក្រោមមុខទីស្នាក់ការ ជាហេតុអាចធ្វើអោយបាត់បង់ ឬក៏អាចកើតមានហានិភ័យខ្ពស់ ដោយប្រការផ្សេងៗ ដូចនេះអង្គភាពគួរតែធ្វើការស្នើសុំដល់ថ្នាក់ដឹកនាំដើម្បីធ្វើកន្លែងរក្សាប្រេងអោយស្របតាមបទដ្ឋានបច្ចេកទេសដើម្បីធានាសុវត្ថិភាព ។

### ២.៤ អង្គភាពនាវាចរណ៍/ឡានស

- សវនករសង្កេតឃើញថា អង្គភាពបានខិតខំប្រឹងប្រែងប្រមូល រៀបចំធ្វើស្ថិតិនាវា បរិមាណប្រេង និងហ្គាស។ ប៉ុន្តែអង្គភាពនៅខ្វះព័ត៌មានអំពីការប្រើប្រាស់លើមធ្យោបាយអូសទាញដូចជា នាវាសណ្តោង ដែលត្រូវចេញទៅជួយរុញនាវាប្រេង ហ្គាសរែមបផែ នៅផែ Da Long Gas ដូច្នេះអង្គភាពគួរតែសហការជាមួយសេវាដ្ឋាននាវាចរណ៍ ដើម្បីពិនិត្យមើលចំនួនម៉ោងចាប់ពីនាវាសណ្តោងចេញដំណើរពីផែ LM១៧ រហូតបញ្ចប់ការងារនៅផែ Da Long Gas និងពេលវិលត្រឡប់មកចំណតផែ LM១៧វិញ មានរយៈពេលប៉ុន្មានម៉ោង ប្រើប្រេងអស់ប៉ុន្មានលីត្រ ដើម្បីសម្គាល់ថានាវាសណ្តោង បានបំពេញការងារប្រាកដមែន។

## ៣. នាយកដ្ឋានវិស្វកម្ម,សេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ, សេវាដ្ឋាន ថែទាំពោងសញ្ញា/(GPS) (ភ្ជាប់ឧបសម្ព័ន្ធ៣)

### ៣.១ នាយកដ្ឋានវិស្វកម្ម

- នាយកដ្ឋានវិស្វកម្ម គួរតែធ្វើរបាយការណ៍បូកសរុបការងារប្រចាំខែ តាមបណ្តាសេវាដ្ឋាន ដែលនៅក្រោមនាយកដ្ឋាន ដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងជ្រាបដើម្បីស្របតាមសេចក្តីណែនាំលិខិតលេខ ១២២៥ ចុះនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីរបៀបធ្វើរបាយការណ៍ប្រចាំខែ ។
- ដោយពិនិត្យទៅលើ រចនាសម្ព័ន្ធនាយកដ្ឋានវិស្វកម្ម ឃើញថាបានបង្កើតផ្នែកថ្មីមួយទៀតគឺ ផ្នែកសិក្សាស្រាវជ្រាវ/គម្រោង ប៉ុន្តែចំពោះការអនុវត្តគឺនៅមិនទាន់បានបែងចែកការងារអោយបានច្បាស់នៅឡើយទេ ដោយអ្នកគូសប្លង់ និងអ្នកសិក្សាស្រាវជ្រាវ/គម្រោងគឺមន្ត្រីជំនាញតែម្នាក់ជាអ្នកធ្វើ។ ដូចនេះដើម្បីឱ្យការងាររលូនទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់ នាយកដ្ឋានគួរតែធ្វើការបែងចែកតួនាទីអោយបានច្បាស់លាស់ ។

### ៣.២ សេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ

- សេវាដ្ឋានគួរតែធ្វើរបាយការណ៍ការងាររៀងរាល់មួយខែម្តង ដាក់ជូនប្រធាននាយកដ្ឋាន របស់សាម៉ីសេវាដ្ឋាន ដើម្បីឱ្យប្រធាននាយកដ្ឋានធ្វើការបូកសរុបការងារប្រចាំខែ ជូនថ្នាក់ដឹកនាំពិនិត្យ និងជ្រាបដើម្បីឱ្យស្របតាមសេចក្តីណែនាំលិខិតលេខ ១២២៥ ចុះនៅថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីរបៀបធ្វើរបាយការណ៍ប្រចាំខែ ។
- សេវាដ្ឋានបច្ចេកទេសគ្រឿងចក្រ គួរតែបន្តជំរុញ អង្គភាពពាក់ព័ន្ធ ធ្វើការងារជួសជុលតូច និងធំឱ្យស្របទៅតាមបទដ្ឋានបច្ចេកទេសគ្រឿងចក្រ និងទាន់ពេលវេលាដើម្បីកុំអោយរាំងស្ទះការងារអាជីវកម្ម ក. ស. ក ។
- ចំពោះតារាងបទដ្ឋានការកំណត់ប្រើប្រាស់ប្រេង និងតម្រងប្រេងគ្រឿងចក្រ ដែលកំពុងប្រើប្រាស់នៅ ក. ស. ក. សេវាដ្ឋាន គួរតែសហការជាមួយអង្គភាពពាក់ព័ន្ធចងក្រងជាសៀវភៅដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងជ្រាប ដើម្បីអោយមានលក្ខណៈគតិយុត្ត ។

### ៣.៣ សេវាដ្ឋានថែទាំពោងសញ្ញា/GPS

- សេវាដ្ឋានថែទាំពោងសញ្ញា/GPS ត្រូវតែធ្វើរបាយការណ៍ការងាររៀងរាល់មួយខែម្តង ដាក់ជូនប្រធាននាយកដ្ឋាន របស់សាមីដើម្បីឱ្យប្រធាននាយកដ្ឋានធ្វើការបូកសរុបការងារប្រចាំខែ ជូនថ្នាក់ដឹកនាំពិនិត្យ និងជ្រាប ដើម្បីឱ្យស្របសេចក្តីណែនាំលិខិតលេខ ១២២៥ ចុះនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីរបៀបធ្វើរបាយការណ៍ប្រចាំខែ ។
- ចំពោះតំរោងផែនការអនុវត្តការងារប្រចាំត្រីមាស របស់សេវាដ្ឋានថែទាំពោងសញ្ញា/GPS ប្រចាំឆ្នាំ ២០១៧ ដែលបានគ្រោងឡើង ត្រូវតែមានការចុះហត្ថលេខាពីប្រធាននាយកដ្ឋាន និងដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងជ្រាប ដើម្បីអោយឯកសារមានលក្ខណៈគតិយុត្ត ។
- សេវាដ្ឋានត្រូវតែសហការជាមួយនាយកដ្ឋានផែនការ/ទីផ្សារ ដើម្បីរៀបចំធ្វើគម្រោងផែនការប្រចាំឆ្នាំ និងឆ្នាំបន្តបន្ទាប់ឱ្យបានសមស្របនៅតាមទំហំការងារដែលត្រូវអនុវត្តជាក់ស្តែង ព្រោះគម្រោងទឹកប្រាក់ដែលមានក្នុងផែនការពិតត្រឹម ខែកញ្ញា ឆ្នាំ២០១៧ មានទឹកប្រាក់នៅសល់ជាក់ស្តែងច្រើនជាងការចំណាយ កត្តានេះជាហេតុធ្វើឱ្យសេវាដ្ឋានជាប់ស្ទាក់ក្នុងគម្រោងការងារ និងការអនុវត្តមិនទាន់អស់សក្តានុពល ។
- សេវាដ្ឋានត្រូវតែប្រមូលពោងសញ្ញានៅក្នុងអង្គភាពផែស្វយ័តដើម្បីធ្វើគម្រោងជួសជុលប្រើប្រាស់ឡើងវិញ ចំពោះពោងសញ្ញាណាដែលនៅប្រើប្រាស់បាន ។ ចំពោះពោងសញ្ញាណាដែលបានជួសជុលរួចហើយ និងមិនទាន់ប្រើប្រាស់ត្រូវយកទៅរក្សាទុកក្នុងឃ្លាំងសម្ភារ ជៀសវាងទុកចោលហាលភ្លៀង ត្រូវកំដៅថ្ងៃខ្យល់ធ្វើ ឱ្យច្រេះស៊ី និងឆាប់ពុកផុយខូចកាន់តែច្រើន ។
- សវនករបានពិនិត្យឃើញថា÷គម្រោងជួសជុលថែទាំពោងបង្គោលសញ្ញា និងបញ្ជីប៉ាន់តម្លៃ ផ្លូវទន្លេសាប (ភ្នំពេញ-ឆ្នុកត្រូ) ឆ្នាំ២០១៧ សេវាដ្ឋានបានចុះទៅធ្វើការជួសជុលរួចរាល់ហើយ ។ ក៏ប៉ុន្តែមានគម្រោងចំនួន០២ ដែលមិនទាន់បានអនុវត្តបញ្ចប់នៅឡើយ ÷
    - គម្រោងជួសជុលថែទាំពោង បង្គោលសញ្ញា និងបញ្ជីប៉ាន់តម្លៃ ផ្លូវនាវាចរណ៍ទន្លេមេគង្គក្រោម (ភ្នំពេញ-ក្អមសំណរ) ឆ្នាំ២០១៧ លេខ០៦៤ ក. ស. ក. ស. ភ. ចុះថ្ងៃទី១៩ ខែ មិថុនា ឆ្នាំ២០១៧
    - គម្រោងជួសជុលថែទាំពោង បង្គោលសញ្ញា និងបញ្ជីប៉ាន់តម្លៃផ្លូវនាវាចរណ៍ទន្លេមេគង្គលើ (ភ្នំពេញ-កំពង់ចាម) ឆ្នាំ២០១៧ លេខ០៩១ ក. ស. ក. ស. ភ. ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ២០១៧

មានភាពយឺតយ៉ាវក្នុងការចុះអនុវត្តន៍គម្រោង ទៅតាមកាលបរិច្ឆេទអនុវត្តការងារនៃឆ្នាំ២០១៧។ ករណីខ្វះមធ្យោបាយអូសទាញ ឬប៉ុងតុង និងមធ្យោបាយផ្សេងទៀត សេវាដ្ឋានត្រូវតែធ្វើសំណើសុំទៅអង្គភាពពាក់ព័ន្ធ ដើម្បីជម្រុញការងារជួសជុល ថែទាំពោងសញ្ញាឱ្យបានចប់សព្វគ្រប់នាពេលខាងមុខ។ នៅឆ្នាំ២០១៨ខាងមុខនេះ សេវាដ្ឋានគួរប្រញាប់លើកគម្រោងជួសជុល ថែទាំ និងជម្រុញផ្នែកជំនាញពាក់ព័ន្ធសហការការងារឱ្យបានរហ័ស ដើម្បីបញ្ចប់ការធ្វើឯកសារយ៉ាងយូរត្រឹមថ្ងៃទី១៥ ខែមករា នៃឆ្នាំនីមួយៗ ។

- សេវាដ្ឋានគួរតែសហការជាមួយនាយកដ្ឋានបុគ្គលិក/ធនធានមនុស្សធ្វើសំណើសុំបញ្ជូនមន្ត្រី បុគ្គលិករៀនវគ្គបណ្តុះបណ្តាលខ្លីៗ ដើម្បីបំពេញចំណេះ និងជំនាញបន្ថែម ឱ្យស្របទៅតាមមុខងារភារកិច្ច និងប្រសិទ្ធភាពការងារ ។
- ដើម្បីបង្កើនការងារថែទាំពោងសញ្ញាតាមដងទន្លេអោយមានប្រសិទ្ធភាពខ្ពស់ ទាន់ពេលវេលា និងស្របទៅតាមផែនការប្រចាំឆ្នាំដែលបានលើកឡើង សេវាដ្ឋានថែទាំពោងសញ្ញា / GPS គួរតែមានមធ្យោបាយផ្ទាល់របស់សាម៉ីសេវាដ្ឋាន ។

**៣.៤ អង្គភាពវាស់ស្ទង់**

- ចំពោះគំរោងផែនការអនុវត្តការងារប្រចាំត្រីមាស របស់អង្គភាពវាស់ស្ទង់ ប្រចាំឆ្នាំ២០១៧ ដែលបានព្រាងឡើងបន្ទាប់ពីប្រធាននាយកដ្ឋាន ចុះហត្ថលេខាហើយ ត្រូវដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងជ្រាបដើម្បីឱ្យឯកសារមានលក្ខណៈគតិយុត្ត ។
- អង្គភាពវាស់ស្ទង់គួរតែធ្វើរបាយការណ៍ការងាររៀងរាល់មួយខែម្តង ដាក់ជូនប្រធាននាយកដ្ឋានរបស់សាម៉ីដើម្បីឱ្យប្រធាននាយកដ្ឋានធ្វើការបូកសរុបការងារប្រចាំខែ ជូនថ្នាក់ដឹកនាំពិនិត្យ និងជ្រាបដើម្បីឱ្យស្របតាមសេចក្តីណែនាំលិខិតលេខ១២២៥ ចុះនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីរបៀបធ្វើរបាយការណ៍ប្រចាំខែ ។

**៤.ការិយាល័យផែនការ /ស្ថិតិ និងការិយាល័យគណនេយ្យ/ហិរញ្ញវត្ថុ (ត្រីមាសទី៤)**

**៤.១ ការិយាល័យផែនការ/ស្ថិតិ**

- ***ការរៀបចំសៀវភៅចុះលេខចូល-ចេញ***
  - មានតែសៀវភៅចុះលេខចេញ
  - ចុះលេខស្ទួន
  - មិនបានធ្វើការបិទបញ្ជីដំណាច់ឆ្នាំក្នុងការកត់ត្រាសៀវភៅចូល-ចេញ

កត្តានេះ ធ្វើឱ្យការគ្រប់គ្រងសៀវភៅចូល-ចេញ ពុំមានភាពច្បាស់លាស់។

**សំណូមពររបស់សវនករ÷** ដើម្បីឱ្យការគ្រប់គ្រងលិខិតចូល-ចេញមានភាពច្បាស់លាស់ និងត្រឹមត្រូវតាមបែបបទរដ្ឋបាលការិយាល័យផែនការ /ស្ថិតិ គួរតែយកចិត្តទុកដាក់ក្នុងការកត់ត្រាលិខិតចូល-ចេញ និងធ្វើការ បិទបញ្ជីដំណាច់ឆ្នាំ ដោយមានការចុះហត្ថលេខាពីប្រធានការិយាល័យ និងប្រធាននាយកដ្ឋានសាម៉ី ។

**មតិឆ្លើយតបសវនដ្ឋាន÷** *តាមការស្រាយបំភ្លឺរបស់សវនដ្ឋាននឹងធ្វើការកែសម្រួលនូវចំណុចខ្វះខាតខាងលើឱ្យបានល្អប្រសើរ ។*

- ***ការធ្វើផែនការប្រចាំឆ្នាំ***

សវនករពិនិត្យឃើញថា ការធ្វើផែនការប្រចាំឆ្នាំរបស់ការិយាល័យផែនការ/ស្ថិតិមានភាពយឺតយ៉ាវ។

កត្តានេះ ធ្វើឱ្យមានភាពយឺតយ៉ាវក្នុងការអនុវត្តគម្រោងដែលចាំបាច់មួយចំនួនដល់អង្គភាព និងស្ថាប័នពាក់ព័ន្ធ។

**សំណូមពររបស់សវនករ÷** ដូចនេះ ដើម្បីឱ្យការធ្វើផែនការប្រចាំឆ្នាំទាន់ពេលវេលា សវនដ្ឋានគួរសហការជំរុញជាមួយអង្គភាព ដែលពាក់ព័ន្ធក្នុងការផ្តល់ទិន្នន័យដែលត្រឹមត្រូវ និងតាមការកំណត់ ។

**មតិឆ្លើយតបសវនដ្ឋាន÷** *តាមការបកស្រាយបំភ្លឺរបស់សវនដ្ឋានដោយសារផ្នែកពាក់ព័ន្ធមិនបានពិនិត្យឯកសារមុន និងបញ្ជូនមកការិយាល័យផែនការ / ស្ថិតិ គឺនៅមានចន្លោះខ្វះខាតជាហេតុតម្រូវឱ្យការិយាល័យធ្វើការត្រួតពិនិត្យសារជាថ្មីម្តងទៀត ដូចនេះទើបធ្វើឱ្យមានភាពយឺតយ៉ាវ ។*

- ***ការធ្វើផែនការរយៈពេលមធ្យម និងវែង***

ជាការអង្កេតរបស់សវនករឃើញថា សវនដ្ឋានមិនបានធ្វើផែនការរយៈពេលមធ្យម និងវែងតិតចាប់ពីការិយបរិច្ឆេទឆ្នាំ២០១៣ រហូតដល់បច្ចុប្បន្ន។

កត្តានេះ ធ្វើឱ្យការរៀបចំគម្រោងចំណាយ និងអភិវឌ្ឍន៍មិនមានភាពច្បាស់លាស់ ។

**សំណូមពររបស់សវនករ÷** ដើម្បីឱ្យការធ្វើផែនការរយៈពេលមធ្យម និងវែងមានសកម្មភាពផែនការឡើងវិញ សវនដ្ឋានគួរសហការជំរុញជាមួយអង្គភាពដែលពាក់ព័ន្ធក្នុងការផ្តល់ទិន្នន័យដែលត្រឹមត្រូវ និងតាមការកំណត់។

**មតិឆ្លើយតបសវនដ្ឋាន÷** *តាមការស្រាយបំភ្លឺរបស់សវនដ្ឋាន មូលហេតុដែលមិនបានធ្វើដោយសារមិនមានការសហការពីផ្នែកពាក់ព័ន្ធ ក្នុងការផ្តល់ទិន្នន័យ។*

- ***កំណត់បង្ហាញ (សំណើសុំប្រេង, សម្ភារផ្គត់ផ្គង់ និងផ្លាស់ប្តូរ)***

តាមការពិនិត្យឃើញរបស់សវនករ លើកំណត់បង្ហាញមួយចំនួន សំណើសុំប្រេង សម្ភារផ្គត់ផ្គង់ និងផ្លាស់ប្តូរមានភាពយឺតយូរ។

កត្តានេះ ធ្វើឱ្យដំណើរការសេវាកម្មមានភាពយឺតយ៉ាវ ។

**សំណូមពររបស់សវនករ÷** ដូចនេះ ដើម្បីឱ្យដំណើរការសេវាកម្មប្រកបទៅដោយភាពរលូន និងទាន់ពេលវេលា ឱ្យគ្រប់ផ្នែកពាក់ព័ន្ធត្រូវពិនិត្យលើឯកសារមុន និងបញ្ជូនមកការិយាល័យផែនការ/ស្ថិតិ ។

**មតិឆ្លើយតបសវនដ្ឋាន÷** *តាមការស្រាយបំភ្លឺរបស់សវនដ្ឋាន បណ្តាមកពីកត្តាមួយចំនួនដូចជា ការបញ្ជូនឯកសារមកខុសត្រូវធ្វើការកែសម្រួលឡើងវិញ ការសាកសួរព័ត៌មានពីផ្នែកពាក់ព័ន្ធ និងសិក្សាតម្លៃ។*

- ***ឯកសារតម្កល់ទុក***

សវនករពិនិត្យឃើញថា ការផ្តិតកម្ពស់ឯកសារតម្កល់ទុកក្នុងសវនដ្ឋាន ដែលទាក់ទងនឹងគម្រោង ឯកសារពាក់ព័ន្ធផ្សេងៗ មិនឃើញមានហត្ថលេខាចុងក្រោយចេញដោយអគ្គនាយករង និង ឯកឧត្តមប្រតិភូ។

កត្តានេះ ធ្វើឱ្យការគ្រប់គ្រងឯកសារនៅមានភាពខ្វះចន្លោះ។

**សំណូមពររបស់សវនករ÷** ដូចនេះ ការិយាល័យផែនការ / ស្ថិតិ គួរតែសហការជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីផ្តល់ឯកសារ ដែលស្របតាមនីតិវិធីច្បាស់លាស់ហើយប្រគល់ជូនសវនដ្ឋានក្នុងការងាយស្រួលតាមដានការអនុវត្តន៍បន្តទៀត។

**មតិឆ្លើយតបសវនដ្ឋាន÷** *តាមការស្រាយបំភ្លឺរបស់សវនដ្ឋាននឹងធ្វើការកែសម្រួលនូវចំណុចខ្វះខាតខាងលើឱ្យបានល្អប្រសើរ។*

- ***សន្និធិប្រេង***

ចំពោះប័ណ្ណសន្និធិប្រេង សវនករពិនិត្យឃើញថា ការិយាល័យផែនការ /ស្ថិតិ បានធ្វើការបូកសរុបបញ្ចូលគ្នាក្នុងតារាងតែមួយ ដោយមិនបានធ្វើការបែងចែងទៅតាមគោលដៅស្តុកប្រេងនីមួយៗ។

កត្តានេះអាចប៉ះពាល់ដល់ការតាមដានប្រេងបញ្ចូលស្តុក។

**សំណូមពររបស់សវនករ÷**ដើម្បីងាយស្រួលក្នុងការតាមដានប្រេងនៅសល់ និងប្រេងចូលស្តុកថ្មី សវនដ្ឋានគួរបង្កើតទម្រង់របាយការណ៍សន្និធិចូលស្តុក ដោយបំបែកទៅតាមស្ថានីយ៍ដាច់ដោយឡែកពីគ្នា។

**មតិឆ្លើយតបសវនដ្ឋាន÷** *តាមការស្រាយបំភ្លឺរបស់សវនដ្ឋាននិងធ្វើការកែសម្រួលនូវចំណុចខ្វះខាតខាងលើឱ្យបានល្អប្រសើរ។*

- ***របាយការណ៍ប្រើប្រាស់ប្រេងឥន្ធនៈប្រចាំខែ***

សវនករពិនិត្យឃើញថា ប្រេងរំអិលប្រភេទ (Rotella លេខ៤០) ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៧ បានចូលស្តុកក្នុងឃ្លាំងរួចហើយ ប៉ុន្តែការិយាល័យផែនការ/ស្ថិតិមិនបានធ្វើការកត់ត្រាបញ្ចូលទៅក្នុងរបាយការណ៍ប្រើប្រាស់ប្រេងឥន្ធនៈប្រចាំខែនៅឡើយទេ។

កត្តានេះ ធ្វើឱ្យការសរុបរបាយការណ៍ប្រចាំឆ្នាំមិនត្រឹមត្រូវ ។

**សំណូមពររបស់សវនករ÷** ដូចនេះដើម្បីឱ្យមានភាពត្រឹមត្រូវ និងច្បាស់លាស់សវនដ្ឋានគួរតែយកចិត្តទុកដាក់បន្ថែមទៀតក្នុងការតាមដានប្រេងបញ្ចូលស្តុក ។

**មតិឆ្លើយតបសវនដ្ឋាន÷** *តាមការស្រាយបំភ្លឺរបស់សវនដ្ឋាន បច្ចុប្បន្នខាងសវនដ្ឋានបានធ្វើការសម្រួលរួចហើយ។*

- ***របាយការណ៍ប្រចាំខែ លើបរិមាណធីអ៊ីយូ (TEU)***

ចំពោះរបាយការណ៍ប្រចាំខែ ក្នុងឆ្នាំ២០១៧ លើបរិមាណធីអ៊ីយូ (TEU) កុងតឺន័រឆ្លងកាត់ សម្រាប់រៀបចំប្រាក់ឧបត្ថម្ភជូនមន្ត្រីនិយោជិត-កម្មករ ទម្រង់ឯកសារពុំទាន់មានលក្ខណគតិយុត្ត ។

កត្តានេះធ្វើអោយឯកសារមិនមានលក្ខណគតិយុត្ត ។

**សំណូមពររបស់សវនករ÷**ដូចនេះគួរតែមានការចុះហត្ថលេខាពីផ្នែកសេវាដ្ឋាននាវាចរណ៍ និងអង្គភាពរៀបចំវេនប្រតិបត្តិការចំណតផែ LM១៧ និងកំណត់កាលបរិច្ឆេទយ៉ាងយូរបំផុតត្រឹមថ្ងៃទី២៤ ដើម្បីឱ្យឯកសារមានលក្ខណគតិយុត្ត។

**មតិឆ្លើយតបសវនដ្ឋាន÷** *តាមការស្រាយបំភ្លឺរបស់សវនដ្ឋាន នឹងធ្វើការកែសម្រួលនូវចំណុចខ្វះខាតខាងលើឱ្យបានល្អប្រសើរ។*

**៤.២.ការិយាល័យគយតាំម៉ូ /ចិនជួរ**

- ***ការរៀបចំសៀវភៅចុះលេខចូល-ចេញ***
    - ចុះលេខរៀងស្ទួន
    - មិនបានធ្វើការបិទបញ្ជីដំណាច់ឆ្នាំក្នុងការកត់ត្រាសៀវភៅ ចូល-ចេញ ។

កត្តានេះ ធ្វើអោយការគ្រប់គ្រងលិខិតចូល-ចេញពុំមានភាពច្បាស់លាស់ ។

**សំណូមពររបស់សវនករ÷**ដូចនេះដើម្បីឱ្យការគ្រប់គ្រងលិខិតចូល-ចេញ មានភាពច្បាស់លាស់ និងត្រឹមត្រូវតាមបែបបទរដ្ឋបាល ការិយាល័យតម្លៃ /ទីផ្សារ គួរតែយកចិត្តទុកដាក់ក្នុងការកត់ត្រាលិខិតចូល-ចេញ និងធ្វើការបិទបញ្ជីបិណាច់ឆ្នាំ ដោយមានការចុះហត្ថលេខាពីប្រធានការិយាល័យ និងប្រធាននាយកដ្ឋាន ។

**មតិឆ្លើយតបសវនដ្ឋាន÷***តាមការបកស្រាយបំភ្លឺរបស់សវនដ្ឋាន នឹងធ្វើការកែសម្រួលនូវចំណុចខ្វះខាតខាងលើឱ្យបានល្អប្រសើរ ។*

– ***ការបណ្តុះបណ្តាលសមត្ថភាពមន្ត្រីក្នុងការិយាល័យអោយស្របទៅតាមជំនាញ***

យោងតាមការពិនិត្យ និងសាកសួរសវនករសង្កេតឃើញថា សវនដ្ឋានមានមន្ត្រីមួយចំនួននៅមានកម្រិតជំនាញ ទីផ្សារ និងការធ្វើកិច្ចសន្យានៅឡើយ ។

**សំណូមពររបស់សវនករ÷**សវនករយល់ឃើញថា ការិយាល័យគួរតែធ្វើការស្នើសុំវគ្គបណ្តុះបណ្តាលបន្ថែមទៀតលើជំនាញនីមួយៗ ស្តីពីការធ្វើកិច្ចសន្យា និងជំនាញទីផ្សារដល់មន្ត្រីខ្លួន ដើម្បីជំរុញការងារឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

**មតិឆ្លើយតបសវនដ្ឋាន÷***តាមការបកស្រាយបំភ្លឺរបស់សវនដ្ឋាន ឯកភាពតាមអនុសាសន៍របស់សវនករ និងនឹងបន្តជំរុញសមត្ថភាពមន្ត្រីសាមុី។*

– ***កង្វះខាតក្នុងការចុះហត្ថលេខាលើសំណើសុំផ្ទុកដាក់ផ្ទេរ លើកដាក់លើយកកុងតឺន័រ*** *(LOLO)*

កត្តានេះធ្វើអោយឯកសារមិនមានភាពពេញលេញ ស្របតាមលិខិតគតិយុត្ត ។

**សំណូមពររបស់សវនករ÷**ដូចនេះដើម្បីឱ្យឯកសារខាងលើមានលក្ខណៈពេញលេញ ស្របតាមលិខិតគតិយុត្ត គួរតែមានការចូលរួមចុះហត្ថលេខាឱ្យបានគ្រប់ផ្នែកជំនាញដែលពាក់ព័ន្ធ ។

**មតិឆ្លើយតបសវនដ្ឋាន÷***តាមការបកស្រាយបំភ្លឺរបស់សវនដ្ឋាន ដោយសារភាពចាំបាច់ ដើម្បីបំពេញសេវាកម្មឱ្យ អតិថិជនទាន់ពេលវេលា ការិយាល័យតម្លៃ /ទីផ្សារ នឹងបន្តការសហការជាមួយគ្រប់បណ្តាអង្គភាពពាក់ព័ន្ធដើម្បីអោយឯកសារមានលក្ខណៈពេញលេញ និងស្របតាមគតិយុត្ត។*

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៨

**ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង**

**វ៉ែន សុផាណ្ណារ៉ា**

**បានឃើញ និងឯកភាព**

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៨

**ប្រធានគណៈកម្មាធិការសវនកម្ម**

Anuwith Cui

**ហ៊ី អានវ៉ាលិថ**

# ផ្នែកទី ៧

# របាយការណ៍ហិរញ្ញវត្ថុ
# ដែលធ្វើសវនកម្មដោយសវនករឯករាជ្យ

# កំពង់ផែស្វយ័តភ្នំពេញ

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល មានក្តីសោមនស្សរីករាយ សូមដាក់ជូនពិនិត្យនូវរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុរបស់ **កំពង់ផែស្វយ័តភ្នំពេញ** ហៅកាត់ថា ("ក.ស.ភ" ឬ "ក្រុមហ៊ុន") ដែលបានធ្វើសវនកម្មរួច សម្រាប់ការិយបរិច្ឆេទ ដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ ។

### សកម្មភាពចម្បងៗ

**កំពង់ផែស្វយ័តភ្នំពេញ** ជាកំពង់ផែអន្តរជាតិ ដែលស្ថិតនៅក្រោមអាណាព្យាបាលផ្នែកបច្ចេកទេសរបស់ក្រសួង សាធារណការ និងដឹកជញ្ជូន និងអាណាព្យាបាលផ្នែកហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សិទ្ធិ និងភារកិច្ចជូន **កំពង់ផែស្វយ័តភ្នំពេញ** ដើម្បីបំពេញបេសកកម្មស្របតាមកម្មវត្ថុរបស់ខ្លួន ។ ក. ស. ភ. មានគោលដៅទទួលខុសត្រូវក្នុងការគ្រប់គ្រង ថែទាំ និងធ្វើអាជីវកម្មសេវាកំពង់ផែ ព្រមទាំងអនិស្សរវត្ថុនៃកំពង់ផែ ដើម្បីប្រតិបត្តិការពង្រីក និងអភិវឌ្ឍ សម្រាប់តម្រូវការខាងពាណិជ្ជកម្ម ឧស្សាហកម្ម សេវាកម្មទេសចរណ៍ និងអ្នកដំណើរ និងចាត់វិធានការចាំបាច់គ្រប់បែបយ៉ាងឲ្យ ក.ស.ភ. រីកចម្រើនល្អតលាស់ទៅមុខ ។

ក. ស. ភ. មានភារកិច្ចជារោងជាងនិងប្រតិបត្តិករផែរួមមាន៖

- ផ្តល់កណ្ណធារកិច្ច នាំនាវាចេញ-ចូលកំពង់ផែ
- ផ្តល់ចំណតនាវា
- ផ្តល់ទីតាំងសម្រាប់នាវាធ្វើការជួសជុល និងចាក់ប្រេង
- ធ្វើអាជីវកម្មបូមស្តារ និងថែទាំប្រឡាយនាវាចរណ៍
- ត្រួតពិនិត្យឯកសារសម្គាល់នាវា ដើម្បីបំពេញបែបបទនាវាចេញ-ចូលផែ
- បណ្តុះបណ្តាលធនធានមនុស្សផ្នែកនាវាចរណ៍ និងផ្នែកកំពង់ផែតាមរយៈវិទ្យាស្ថាននាវាចរណ៍កម្ពុជា
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផែ តាមរយៈសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ក្នុង និងក្រៅប្រទេស ដើម្បីពង្រីកចំណតផែកុងតឺន័រ ផែទំនិញរាយ-ទំនិញចាក់ធារ ចំណតផែរណប ចំណតផែអ្នកដំណើរ និងទេសចរណ៍
- បង្កើតតំបន់គាំទ្រកំពង់ផែ រួមមាន តំបន់សេដ្ឋកិច្ចពិសេស តំបន់ឧស្សាហកម្ម តំបន់កែច្នៃផលិតផលកសិកម្ម និងតំបន់ភស្តុភារកម្ម
- ចាត់វិធានការនានា ដើម្បីធានាការអនុវត្តច្បាប់ និងលិខិតបទដ្ឋានជាធរមាន ពាក់ព័ន្ធនឹងកំពង់ផែ និងមធ្យោបាយដឹកជញ្ជូននានាតាមផ្លូវទឹក
- លើកដាក់ ផ្ទេរផ្ទុក រក្សាស្តុកទំនិញ
- ដឹកជញ្ជូនទំនិញក្នុងទីលានផែ និងរវាងកំពង់ផែនិងតំបន់ផលិតកម្មរោងចក្រ
- ផ្តល់សេវាកម្មភណ្ឌាគារគយមានដែនកំណត់ ភណ្ឌាគារគយបណ្តោះអាសន្ន និងទីលានស្តុកកុងតឺន័រ
- ផ្តល់សេវាកម្មអូសទាញនាវាពាក់ និងដោះឰរ
- ផ្តល់សេវាកម្មផ្គត់ផ្គង់ភស្តុភារ ទឹកស្អាត អនាម័យដល់នាវា
- ផ្តល់សេវាកម្មវេរ និងច្រកទំនិញដាក់កុងតឺន័រ

## កំពង់ផែស្វយ័តភ្នំពេញ

### សកម្មភាពចម្បងៗ (ត)

- ផ្តល់សេវាកម្មផ្គត់ផ្គង់ទំនិញ និងថែទាំសំបកកុងតឺន័រ
- ផ្តល់សេវាកម្មចំណតផែទេសចរណ៍ និងអ្នកដំណើរ និងមណ្ឌលសេវាកម្មផែក្នុងស្រុក
- ធ្វើប្រតិបត្តិការអាជីវកម្មបន្ថែមផ្សេងទៀត ដែលអនុញ្ញាតដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដើម្បីបម្រើដល់ការរីកចម្រើនរបស់ ក.ស.ភ.។

នាថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០១៥ ក.ស.ភ. បានចុះបញ្ជីនៅលើផ្សារមូលបត្រកម្ពុជា ("ផ.ម.ក") ។

ពុំមានការផ្លាស់ប្តូរជាសារវន្ត លើសកម្មភាពចម្បងរបស់ ក.ស.ភ. នៅក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះទេ ។

### លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ ក.ស.ភ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ ត្រូវបានបង្ហាញក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗនៅទំព័រទី ១៨ ។

### ភាគលាភ

នាថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០១៧ ក្រុមប្រឹក្សាភិបាលរបស់ ក.ស.ភ. បានសម្រេចបែងចែកភាគលាភ ពីប្រាក់ចំណេញសុទ្ធប្រចាំឆ្នាំ ២០១៦ ទៅឲ្យភាគហ៊ុនិក តាមប្រភេទភាគហ៊ុនដូចខាងក្រោម៖

- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "ក" មានសិទ្ធិទទួលបានភាគលាភដែលបានធានាសរុបចំនួន ២៦១.២៥៨ ដុល្លារអាមេរិក (សមមូលទៅនឹង ១.០៥៩.០៣៥.៨៤៨ រៀល) ហើយត្រូវបានទូទាត់រួចរាល់នៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៧ ។ ភាគលាភដែលបានធានាដែលបានបែងចែកកាលពីឆ្នាំ ២០១៦ ទៅភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "ក" ចំនួន ២៦.៣២៥ ដុល្លារអាមេរិក ក៏ត្រូវបានទូទាត់នៅកាលបរិច្ឆេទដូចគ្នានេះដែរ ។
- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "ខ" មានសិទ្ធិទទួលបានភាគលាភសរុបចំនួន ៥៣៨.០៣៨ ដុល្លារអាមេរិក (សមមូលទៅនឹង ២.១៥០.០០០ ពាន់រៀល) ហើយត្រូវបានទូទាត់រួចរាល់នៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៧ ។

យោងទៅតាម កិច្ចប្រជុំក្រុមប្រឹក្សាភិបាលនៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៧ និង សេចក្តីប្រកាសព័ត៌មានរបស់ ក.ស.ភ. នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៧ ក.ស.ភ. អាចនឹងពិចារណាបង្កើនលទ្ធភាពបែងចែកភាគលាភបន្ថែម ១% (ដែលស្មើទៅនឹង ៥២.៨៦៧ ដុល្លារអាមេរិក) បន្ថែមទៅលើការធានាទិន្នផលភាគលាភស្មើនឹង ៥% នៃថ្លៃ IPO ដែលមានស្រាប់ទៅឲ្យ ភាគហ៊ុនិកប្រភេទ "ក" សម្រាប់ឆ្នាំ ២០១៧ ក្នុងករណីដែលលទ្ធផលអាជីវកម្មហិរញ្ញវត្ថុ ប្រចាំឆ្នាំ ២០១៧ សម្រេចបានតាមការប៉ាន់ស្មានទុក ។ នៅក្នុងឆ្នាំ ២០១៨ ក្រុមប្រឹក្សាភិបាល បានសម្រេចបែងចែក និង កត់ត្រាភាគលាភបន្ថែមនេះដែលស្មើទៅនឹង ៥២.៨៦៧ ដុល្លារអាមេរិក នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំ ដែលបានបញ្ចប់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ ។

# គំពង់ផែស្វយ័តភ្នំពេញ

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តនៃទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ ។

## បំណុលពិបាកទារ និងបំណុលជាប់សង្ស័យ

នៅមុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ភ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមស្រប ដើម្បីបញ្ជាក់ថា វិធានការទាក់ទងទៅនឹងការលុបបំបាត់ចោលពីឥណទាន និងការធ្វើសំវិធានធនលើបំណុលពិបាកទារ និងបំណុលជាប់សង្ស័យត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថាកល់បំណុលពិបាកទារទាំងអស់ត្រូវបានលុបចោល និងសំវិធានធនគ្រប់គ្រាន់ត្រូវបានកំណត់ឡើងសម្រាប់បំណុលពិបាកទារ និងបំណុលជាប់សង្ស័យ ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានពិនិត្យឃើញមានស្ថានភាពណាមួយដែលអាចនឹងបណ្តាលឲ្យចំនួនដែលត្រូវលុបចោលសម្រាប់បំណុលពិបាកទារ ឬចំនួននៃសំវិធានធនលើបំណុលជាប់សង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ មានចំនួនខ្វះខាតជាសារវន្តនោះឡើយ ។

## ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ភ ត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមស្រប ដើម្បីបញ្ជាក់ថា បណ្តាទ្រព្យសកម្មចរន្តដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ ក.ស.ភ. ហើយដែលមានតម្លៃមិនអាចប្រមូលបាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ត្រូវ បានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលគិតថានឹងអាចប្រមូលបានជាក់ស្តែង ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្តនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ភ ថាមានភាពមិនត្រឹមត្រូវនោះទេ ។

## វិធីសាស្ត្រកំណត់តម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើងធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រដែលមានកន្លងមក ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ភ ថាមានភាពមិនត្រឹមត្រូវ និងមិនសមស្របនោះទេ ។

## បំណុលយថាហេតុ និងបំណុលផ្សេងៗទៀត

នាថ្ងៃចេញរបាយការណ៍នេះ ពុំមាន៖

(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ ក.ស.ភ ដែលកើតមានឡើងចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទមកក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាមួយឡើយ ឬ

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះ ក.ស.ភ ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទមកក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ ក.ស.ភ ។

## អំពាន់ផែស្វយ័តភ្នំពេញ

### បំណុលយថាហេតុ និងបំណុលផ្សេងៗទៀត (ត)

ក្រុមប្រឹក្សាភិបាលយល់ឃើញថា ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ ក.ស.ភ ដែល ក.ស.ភ ត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងរយៈពេល ១២ ខែ បន្ទាប់ពីថ្ងៃបញ្ចប់នៃការិយបរិច្ឆេទដែលនឹងមាន ផលប៉ះពាល់ ឬអាចនឹងប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ ក.ស.ភ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលដល់ថ្ងៃកំណត់ឡើយ ។

### ការប្រែប្រួលសភាពការណ៍

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានពិនិត្យឃើញសភាពការណ៍ណាមួយ ដែលមិនបានបង្ហាញ នៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ភ ដែលអាចនឹងបណ្តាលឲ្យមានតួលេខនៃចំនួនណាមួយ ដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវនោះទេ ។

### ប្រតិបត្តិការមិនប្រក្រតី

តាមមតិរបស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃប្រតិបត្តិការរបស់ ក.ស.ភ ក្នុងការិយបរិច្ឆេទមិនទទួលរងផលប៉ះពាល់ជាសារវន្តដោយសារកត្តាណាមួយ ឬប្រតិបត្តិការណាមួយ ឬព្រឹត្តិការណ៍ណាមួយ ដែលមានលក្ខណៈមិនប្រក្រតីនោះទេ ។

ក្រុមប្រឹក្សាភិបាល កំមានមតិដែរថានៅក្នុងចន្លោះពេលចាប់ពីថ្ងៃបញ្ចប់ការិយបរិច្ឆេទ ដល់ថ្ងៃចេញរបាយការណ៍នេះ ពុំមានកត្តាណាមួយ ឬប្រតិបត្តិការណាមួយ ឬព្រឹត្តិការណ៍ណាមួយ ដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតី បានកើតឡើងនោះឡើយ ដែលនាំឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការអាជីវកម្មរបស់ ក.ស.ភ. ក្នុងការិយបរិច្ឆេទនៃការរៀបចំរបាយការណ៍នេះ ។

### ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលបានបម្រើការនៅក្នុងការិយបរិច្ឆេទ និងថ្ងៃចេញរបាយការណ៍ចុងក្រោយរួមមាន៖

| | |
|---|---|
| ឯកឧត្តម ហ៊ី បាវី | (ប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយក) |
| ឯកឧត្តម សួន រចនា | (សមាជិកក្រុមប្រឹក្សាភិបាលតំណាងក្រសួងសាធារណការ និងដឹកជញ្ជូន) |
| ឯកឧត្តម កែន សម្បត្តិ | (សមាជិកក្រុមប្រឹក្សាភិបាលតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) |
| ឯកឧត្តម ប៉ែន សុវិជាតិ | (សមាជិកក្រុមប្រឹក្សាភិបាលតំណាងក្រសួងពាណិជ្ជកម្ម) |
| លោក ឃ្លី អានក់និថ | (សមាជិកក្រុមប្រឹក្សាភិបាល តំណាងអភិបាលឯករាជ្យ) |
| លោកស្រី ជួន សុខេម | (សមាជិកក្រុមប្រឹក្សាភិបាល តំណាងនិយោជិត ក.ស.ភ.) |
| លោក ឌិត សុចល | (សមាជិកក្រុមប្រឹក្សាភិបាល តំណាងអភិបាលមិនប្រតិបត្តិ តំណាងភាគហ៊ុនិកឯកជន ) |

# កំពង់ផែស្វយ័តភ្នំពេញ

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងការិយបរិច្ឆេទហិរញ្ញវត្ថុ និងថ្ងៃបញ្ចប់ការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានកិច្ចព្រមព្រៀងណាមួយដែល ក.ស.ភ. ជាគូភាគីម្ខាង ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះ អាចផ្តល់លទ្ធភាពដល់អភិបាលណាម្នាក់ ទទួលបាននូវអត្ថប្រយោជន៍ តាមមធ្យោបាយផ្សេងៗដូចជា ការទិញយកភាគហ៊ុន ឬប័ណ្ណបំណុលរបស់ ក.ស.ភ ឬរបស់សាជីវកម្មដទៃ នោះទេ ។

ចាប់តាំងពីថ្ងៃបញ្ចប់ការិយបរិច្ឆេទនៃឆ្នាំកន្លងទៅ ពុំមានអភិបាលរបស់ ក.ស.ភ ណាម្នាក់បានទទួល ឬមានសិទ្ធិ ទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលរួមបញ្ចូលនៅក្នុងចំនួនលាភការសរុបដែលទទួលបាន ដូចបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយ ក.ស.ភ ឬដោយក្រុមហ៊ុនពាក់ព័ន្ធជាមួយនឹង ក.ស.ភ ដែលអភិបាលគឺជាសមាជិក ឬក៏ជាមួយក្រុមហ៊ុន ដែលអភិបាលនោះ មានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុជាសារវន្តនោះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុបានរៀបចំឡើងយ៉ាងត្រឹមត្រូវ ដើម្បីចង្អុលបង្ហាញពីភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ ក.ស.ភ គិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ និង លទ្ធផលហិរញ្ញវត្ថុ និងស្ថានភាពលំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវ៖

(ក) អនុម័តគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព។

(ខ) គោរពទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ឬបើមានការផ្លាស់ប្តូរផ្សេងពីនេះ ដើម្បីបង្ហាញនូវភាពត្រឹមត្រូវ គឺត្រូវបង្ហាញ ពន្យល់ និងកំណត់បរិមាណឲ្យបានច្បាស់លាស់ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

(គ) ត្រួតពិនិត្យប្រព័ន្ធដំណើរការនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ភ. និងការរក្សាទុកបញ្ជីគណនេយ្យឲ្យបានសមរម្យ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព ។

(ឃ) វាយតម្លៃនូវលទ្ធភាពរបស់ ក.ស.ភ ក្នុងការបន្តនិរន្តរភាពនៃដំណើរការអាជីវកម្ម និងការបង្ហាញពីបញ្ហាដែលពាក់ព័ន្ធទៅលើការបន្តនិរន្តរភាពនៃដំណើរការអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃបញ្ជីគណនេយ្យ លុះត្រាតែអ្នកគ្រប់គ្រងមានបំណងជម្រះបញ្ជី ផ្អាកដំណើរការ ក.ស.ភ ឬគ្មានជម្រើសសមរម្យដទៃទៀត ក្រៅពីការធ្វើបែបនេះ ។

(ង) ត្រួតពិនិត្យ និងដឹកនាំ ក.ស.ភ ឲ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេចសំខាន់ៗទាំងអស់ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ ក.ស.ភ ហើយត្រូវធ្វើឲ្យប្រាកដថា កិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា បានអនុវត្តនូវរាល់លក្ខខណ្ឌតម្រូវដូចមានរាយការណ៍ខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ របស់ ក. ស.ភ ។

# កំពង់ផែស្វយ័តភ្នំពេញ

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំ សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងកំណត់សម្គាល់ទាំងឡាយពីទំព័រទី ១២ ដល់ទី ៦៤ បានបង្ហាញពីភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ ក.ស.ភ គិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ។

***តាងនាមឱ្យក្រុមប្រឹក្សាភិបាល*** :

**ឯកឧត្តម ហ៊ី ប៊ាវី**
ប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយក

**កញ្ញា ឈាង ចណ្ណធា**
ប្រធាននាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី: 7 MAR 2018

KPMG

KPMG Cambodia Ltd
4th Floor, Delano Center
No. 144, Street 169, Sangkat Veal Vong
Khan 7 Makara, Phnom Penh
Kingdom of Cambodia
+855 23 216 899 | kpmg.com.kh

# របាយការណ៍របស់សវនករឯករាជ្យ
# ជូនចំពោះភាគហ៊ុនិក
# កំពង់ផែស្វយ័តភ្នំពេញ

## មតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ **កំពង់ផែស្វយ័តភ្នំពេញ** ហៅកាត់ថា ("ក.ស.ភ" ឬ "ក្រុមហ៊ុន") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ របាយការណ៍ចំណេញ ឬ ខាត និងលទ្ធផលលម្អិតផ្សេងៗ របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និង របាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និង កំណត់សម្គាល់ដែលរួមមាន គោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗទៀតដែលបានបង្ហាញនៅទំព័រទី ១២ ដល់ ៦៤ ។

តាមមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុជាសារវន្ត បានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១៧ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ។

## មូលដ្ឋាននៃមតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ។ ការទទួលខុសត្រូវរបស់យើងខ្ញុំស្របតាមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងកថាខណ្ឌស្តីពីការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ ។ យើងខ្ញុំ មានភាពឯករាជ្យពីក្រុមហ៊ុន ដោយស្របទៅតាមលក្ខខណ្ឌតម្រូវនៃក្រមសីលធម៌វិជ្ជាជីវៈ ដែលពាក់ព័ន្ធនឹងសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញនូវទំនួលខុសត្រូវក្រមសីលធម៌វិជ្ជាជីវៈស្របតាមលក្ខខណ្ឌតម្រូវរបស់ស្តង់ដារទាំងនោះ ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប សម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ ។

## បញ្ហាសំខាន់ក្នុងការធ្វើសវនកម្ម

បញ្ហាសំខាន់ក្នុងការធ្វើសវនកម្ម គឺជាបញ្ហាមួយដែលតាមការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈរបស់យើងខ្ញុំ គឺជាបញ្ហាដ៏សំខាន់បំផុតក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ។ បញ្ហានេះត្រូវបានដោះស្រាយក្នុងបរិបទនៃការធ្វើសវនកម្ម និងជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុទាំងមូល និងមិនមានការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំដាច់ដោយឡែកសម្រាប់បញ្ហានេះទេ ។

| បញ្ហាសំខាន់ក្នុងការធ្វើសវនកម្ម | វិធីដែលបញ្ហានេះត្រូវបានដោះស្រាយក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំ |
|---|---|
| ហានិភ័យ នៃការក្លែងបន្លំលើការទទួលស្គាល់ចំណូល<br><br>ការរំពឹងទុកពីទីផ្សារ និងការកំណត់គោលដៅនៃប្រាក់ចំណេញ អាចជាកត្តាដែលដាក់សម្ពាធឲ្យអ្នកគ្រប់គ្រង ធ្វើការបំភាន់លើការទទួលស្គាល់ចំណូល ហើយការធ្វើដូចនេះ អាចនឹងបង្កើនឲ្យមាន ហានិភ័យនៃការបង្ហាញខុសជាសារវន្តលើការវាស់វែងចំណូល និងការកើតឡើងនៃចំណូល ។ ការធ្វើដូចនេះអាចនឹង បណ្តាលឲ្យមាន ការកត់ត្រាលើស ឬការពន្យារការទទួលស្គាល់ចំណូល ដើម្បីសម្រេចឲ្យបាននូវគោលដៅ ឬការរំពឹងទុក នៅពេលបច្ចុប្បន្ន ឬពេលអនាគត ។ | នីតិវិធីក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំ ក្នុងចំណោមនីតិវិធីផ្សេងៗទៀតរួមមាន ការស្វែងយល់លើគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុន ក្នុងការទទួលស្គាល់ចំណូល ។ យើងខ្ញុំ បានវាយតម្លៃលើប្រព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុនទាំងមូល និងបានពិនិត្យមើលលើប្រសិទ្ធភាពនៃដំណើរការនៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងទៅលើភាពពេញលេញ ភាពត្រឹមត្រូវ និងអត្ថិភាព និងពេលវេលានៃការទទួលស្គាល់ចំណូល ។ យើងខ្ញុំបានពិនិត្យមើលលើ ទិនានុប្បវត្តិដែលបានកត់ត្រា លើគណនីចំណូល ដើម្បីរកមើលសមាសធាតុ ដែលមានភាពមិនប្រក្រតី និងមិនទៀងទាត់ ។<br><br>យើងខ្ញុំក៏បានអនុវត្តនូវនីតិវិធីវិភាគជាក់លាក់ និងការធ្វើតេស្តលម្អិតលើគណនីចំណូលសំខាន់ៗមួយចំនួន ។ |

## ព័ត៌មានផ្សេងៗ

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំព័ត៌មានផ្សេងៗ ។ ព័ត៌មានផ្សេងៗដែលរួមមាន ព័ត៌មានដែលបានដាក់បញ្ចូលក្នុងរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល ដែលយើងខ្ញុំបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ និងរបាយការណ៍ប្រចាំឆ្នាំ ដែលរំពឹងថានឹងផ្តល់ជូនបន្ទាប់ពីកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ ។

KPMG

## ព័ត៌មានផ្សេងៗ (ត)

មតិសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់លើព័ត៌មានផ្សេងៗឡើយ ហើយយើងខ្ញុំនឹងមិនបញ្ចេញមតិសន្និដ្ឋានអះអាងក្រោមទម្រង់ណាមួយទៅលើព័ត៌មានផ្សេងៗនេះទេ ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗដែលបានបញ្ជាក់ខាងលើ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានអសង្គតិភាពជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានបង្ហាញនូវកំហុសឆ្គងជាសារវន្ត ។ ប្រសិនបើការធ្វើសវនកម្មរបស់យើងខ្ញុំ អាចឲ្យយើងខ្ញុំសន្និដ្ឋានថា មានកំហុសឆ្គងជាសារវន្តកើតឡើង យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង ។ យើងខ្ញុំ ពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ ។

## ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ច

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ហើយនិងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់ សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឲ្យជៀសផុតពីការបង្ហាញខុសជាសារវន្តដោយសារ ការក្លែងបន្លំ ឬ កំហុសឆ្គង ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមស្របផ្សេងទៀតក្រៅពីធ្វើបែបនេះ ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ច មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ។

KPMG

## ការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលដៅរបស់យើងខ្ញុំ គឺផ្តល់នូវអំណះអំណាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានការបង្ហាញខុសជាសារវន្តដោយសារ ការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍សវនកម្ម ដែលរួមបញ្ចូលទាំងមតិសវនកម្មរបស់យើងខ្ញុំ ។ អំណះអំណាងសមហេតុផល គឺជាអំណះអំណាងដែលមានការធានាកម្រិតខ្ពស់មួយ ប៉ុន្តែវាមិនអាចធានាថា គ្រប់ពេលនៃការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា អាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ ។ ការបង្ហាញខុសជាសារវន្ត អាចកើតឡើងដោយសារការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានចាត់ទុកថាជាសារវន្ត នៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងតែមួយ ឬក៏រួមបញ្ចូលគ្នា មានផលប៉ះពាល់ដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវអប្បធាតុនិយម ក្នុងអំឡុងពេលសវនកម្ម ។ យើងខ្ញុំក៏៖

- ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុដោយសារតែ ការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការរៀបចំ និងការអនុវត្តនូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ ។ ហានិភ័យដែលមិនអាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលកើតឡើងដោយសារតែការក្លែងបន្លំ មានលក្ខណៈខ្ពស់ជាងការបង្ហាញខុសកើតឡើងពី កំហុសឆ្គង ដោយសារតែការក្លែងបន្លំអាចរួមបញ្ចូលទាំង ការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា ការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីគ្រប់គ្រងផ្ទៃក្នុង ។

- ទទួលបាននូវការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ក្នុងគោលបំណងដើម្បីរៀបចំនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ ។

- ការវាយតម្លៃលើភាពសមស្របនៃគោលនយោបាយគណនេយ្យដែលក្រុមហ៊ុនបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង ។

- ធ្វើការសន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ របស់អ្នកគ្រប់គ្រង ហើយដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ធ្វើការសន្និដ្ឋានថាតើភាពមិនច្បាស់លាស់ជាសារវន្តពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចធ្វើឲ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់ក្រុមហ៊ុន ដើម្បីបន្តនិរន្តរភាពអាជីវកម្ម ។ ប្រសិនបើយើងខ្ញុំ ធ្វើការសន្និដ្ឋានថាមានអត្ថិភាពនៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវបញ្ចូលនៅក្នុងរបាយការណ៍របស់យើងខ្ញុំ ដើម្បីទាញចំណាប់អារម្មណ៍លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាង ព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ ។ យ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចធ្វើឲ្យក្រុមហ៊ុនបញ្ឈប់និរន្តរភាពនៃអាជីវកម្ម ។

KPMG

## ការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ (ត)

- វាយតម្លៃលើការបង្ហាញនៃទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដែលរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យ ដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។

យើងខ្ញុំ ផ្តល់ព័ត៌មានជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ច ស្តីពីបញ្ហាផ្សេងទៀតវិសាលភាព និងពេលវេលាដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្តផ្សេងទៀត ដែលមានរួមបញ្ចូលទាំងចំនុចខ្វះខាតនៃការគ្រប់គ្រងផ្ទៃក្នុងដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម ។

យើងខ្ញុំក៏បានផ្តល់សេចក្តីបញ្ជាក់ជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ចថា យើងខ្ញុំបានអនុលោមតាមលក្ខខណ្ឌតម្រូវនៃក្រមសីលធម៌វិជ្ជាជីវៈដែលពាក់ព័ន្ធលើឯករាជ្យភាពរបស់យើងខ្ញុំ និងបានជម្រាបជូនពួកគាត់នូវរាល់ទំនាក់ទំនង និងបញ្ហាផ្សេងៗទៀតដែលអាចត្រូវបានយកមកពិចារណាយ៉ាងសមហេតុផលថាអាចមានទំនាក់ទំនងទៅនឹងការការពារឯករាជ្យភាពរបស់យើងខ្ញុំ ។

បញ្ហាដែលយើងខ្ញុំបានជម្រាបជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ច គឺជាបញ្ហាដែលយើងខ្ញុំកំណត់ថា មានសារៈសំខាន់បំផុត នៅក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ហើយបញ្ហានេះគឺជាបញ្ហាសំខាន់ក្នុងការធ្វើសវនកម្ម ។ យើងខ្ញុំបង្ហាញបញ្ហានេះ នៅក្នុងរបាយការណ៍សវនកម្ម លើកលែងតែច្បាប់ ឬបទប្បញ្ញត្តិ ហាមឃាត់នូវការលាតត្រដាងជាសាធារណៈអំពីបញ្ហានេះក្នុងការធ្វើសវនកម្ម ឬក៏ក្នុងកាលៈទេសៈដ៏កម្របំផុត នៅពេលដែលយើងខ្ញុំរកឃើញថាបញ្ហានោះ មិនគួរត្រូវបានបង្ហាញក្នុងរបាយការណ៍របស់យើងខ្ញុំ ដោយសារតែផលវិបាក អាចមានច្រើនជាងអត្ថប្រយោជន៍ជាសាធារណៈ ដែលកើតចេញពីការជូនដំណឹងនេះ។

តំណាងក្រុមហ៊ុន **ខេភីអឹមជី ខេមបូឌា ចំកាត់**

**ខែ ហ៊ុយ**

*Engagement Partner*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១៨

# កំពង់ផែស្វយ័តភ្នំពេញ

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
## នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧

| | កំណត់សម្គាល់ | នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ ដុល្លារអាមេរិក | នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ ពាន់រៀល (កំណត់សម្គាល់ ៤) | នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦ ដុល្លារអាមេរិក | នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦ ពាន់រៀល (កំណត់សម្គាល់ ៤) |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | | | |
| ទ្រព្យ រោងចក្រ និងបរិក្ខារ | ៥ | ១៤៥.៣៥៥.០១៧ | ៥៨៦.៧៩៨.២០៤ | ១៤៥.១៥៦.៣៩២ | ៥៨៥.៩៩៦.៣៥៥ |
| ទ្រព្យវិនិយោគ | ៦ | ៨.៤៧៣.៧០៣ | ៣៤.២០៨.៣៣៩ | ៨.៥៣៥.៣២០ | ៣៤.៤៥៧.០៨៧ |
| | | ១៥៣.៨២៨.៧២០ | ៦២១.០០៦.៥៤៣ | ១៥៣.៦៩១.៧១២ | ៦២០.៤៥៣.៤៤២ |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | | | |
| គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ | ៧ | ៣.០០៩.៣០៨ | ១២.១៤៨.៥៧៦ | ២.៩៣៤.៧៨១ | ១១.៨៤៧.៧១១ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ៨ | ១១.៧១៧.៩៤៤ | ៤៧.៣០៥.៣៤០ | ៦.៧៥១.៤៨៩ | ២៧.២៥៥.៧៦១ |
| | | ១៤.៧២៧.២៥២ | ៥៩.៤៥៣.៩១៦ | ៩.៦៨៦.២៧០ | ៣៩.១០៣.៤៧២ |
| **ទ្រព្យសកម្មសរុប** | | ១៦៨.៥៥៥.៩៧២ | ៦៨០.៤៦០.៤៥៩ | ១៦៣.៣៧៧.៩៨២ | ៦៥៩.៥៥៦.៩១៤ |
| **មូលធន និងបំណុល** | | | | | |
| **មូលធន** | | | | | |
| ដើមទុន | ៩ | ១១៤.៤៥៣.៤៨៥ | ៤៥៧.៨១៣.៩៤០ | ១១៤.៤៥៣.៤៨៥ | ៤៥៧.៨១៣.៩៤០ |
| បុព្វលាភភាគហ៊ុន/មូលធនផ្សេងៗ | ៩ | ១៥៥.៥០២ | ៦២២.០០៨ | ១៥៥.៥០២ | ៦២២.០០៨ |
| ទុនបម្រុងតាមច្បាប់ | | ៧៩៥.៣១១ | ៣.២១០.៦៧១ | ៥៩០.៩៤១ | ២.៣៨៥.៦២៩ |
| ទុនបម្រុងទូទៅ | | ៧៩៥.៣១១ | ៣.២១០.៦៧១ | ៥៩០.៩៤១ | ២.៣៨៥.៦២៩ |
| មូលនិធិអភិវឌ្ឍន៍សហគ្រាស | | ១២.៣៥៥.៦៦១ | ៤៩.៨៧៩.៨០៣ | ១០.១២៦.៧៦៨ | ៤០.៨៨១.៧៦២ |
| ចំណេញរក្សាទុក | | ៥.២៨២.០៦២ | ២១.៣២៣.៦៨៤ | ៣.១៧៥.៦៧១ | ១២.៨២០.១៨៤ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | ៤.២៤០.៥៣២ | - | ៤.២៤០.៥៣២ |
| **មូលធនសរុប** | | ១៣៣.៨៣៧.៣៣២ | ៥៤០.៣០១.៣០៩ | ១២៩.០៩៣.៣០៨ | ៥២១.១៤៩.៦៨៤ |

# គំពង់ផែស្វយ័តភ្នំពេញ

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (ត)
## នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧

| | កំណត់សម្គាល់ | នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧<br>ដុល្លារអាមេរិក | <br>ពាន់រៀល<br>(កំណត់សម្គាល់ ៤) | នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦<br>ដុល្លារអាមេរិក | <br>ពាន់រៀល<br>(កំណត់សម្គាល់ ៤) |
|---|---|---|---|---|---|
| **បំណុល** | | | | | |
| **បំណុលរយៈពេលវែង** | | | | | |
| បំណុលការធានាបង់ភាគលាភ | ៩ | ៦៣០.០៨០ | ២.៥៤៣.៦៣៣ | ៧៩៣.៦៥៣ | ៣.២០៣.៩៧៧ |
| ប្រាក់កម្ចី | ១០ | ២៦.៩០៩.៦៦៣ | ១០៨.៦៣៤.៣១០ | ២៨.៩៧៩.៦៣៧ | ១១៦.៩៩០.៧៩៥ |
| សំវិធានធនលើមូលនិធិសោធននិវត្តន៍ | ១១ | ៦១៩.២៧៩ | ២.៥០០.០២៩ | ៥៣៣.៩៥៩ | ២.១៥៥.៥៩២ |
| បំណុលពន្ធពន្យារសុទ្ធ | ១២ | ១.៤១៤.២៩៦ | ៥.៧០៩.៥១៣ | ១.១៨៣.៧០១ | ៤.៧៧៨.៦០១ |
| | | ២៩.៥៧៣.៣១៨ | ១១៩.៣៨៧.៤៨៥ | ៣១.៤៩០.៩៥០ | ១២៧.១២៨.៩៦៥ |
| **បំណុលរយៈពេលខ្លី** | | | | | |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីបំណុលផ្សេងៗ | ១៣ | ២.៥១០.៨៨៥ | ១០.១៣៦.៤៤៣ | ២.៣០៤.៤៦៣ | ៩.៣០៣.១១៨ |
| សំវិធានធនសម្រាប់ពន្ធលើប្រាក់ចំណេញ | ១២ | ៥៦៤.៤៦៣ | ២.២៧៨.៧៣៧ | ៤៨៩.២៦១ | ១.៩៧៥.១៤៧ |
| ប្រាក់កម្ចីរយៈពេលខ្លី | ១០ | ២.០៦៩.៩៧៤ | ៨.៣៥៦.៤៨៥ | - | - |
| | | ៥.១៤៥.៣២២ | ២០.៧៧១.៦៦៥ | ២.៧៩៣.៧២៤ | ១១.២៧៨.២៦៥ |
| **បំណុលសរុប** | | ៣៤.៧១៨.៦៤០ | ១៤០.១៥៩.១៥០ | ៣៤.២៨៤.៦៧៤ | ១៣៨.៤០៧.២៣០ |
| **មូលធន និងបំណុលសរុប** | | ១៦៨.៥៥៥.៩៧២ | ៦៨០.៤៦០.៤៥៩ | ១៦៣.៣៧៧.៩៨២ | ៦៥៩.៥៥៦.៩១៨ |

កំណត់សម្គាល់ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# អំពាធ់ផែស្វយ័តភ្នំពេញ

## របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧

| | | ការិយបរិច្ឆេទប្រចាំឆ្នាំ ដែលបានបញ្ចប់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ | | ការិយបរិច្ឆេទប្រចាំឆ្នាំ ដែលបានបញ្ចប់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦ | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) |
| ចំណូល | ១៤ | ១៨.៨៥៦.២៨៦ | ៧៦.២៧៣.៧១៧ | ១៦.៣០០.៤២២ | ៦៦.០៦៥.៦១០ |
| ថ្លៃដើមនៃការលក់ និងសេវាកម្ម | ១៥ | (៦.៤៦០.៧៨៤) | (២៦.១៣៣.៩១២) | (៥.៦១៩.៦៤៥) | (២២.៧៧៦.៤២១) |
| **ប្រាក់ចំណេញដុល** | | ១២.៣៩៥.៥០២ | ៥០.១៣៩.៨០៥ | ១០.៦៨០.៧៧៧ | ៤៣.២៨៩.១៨៩ |
| ចំណូលផ្សេងៗ | ១៦ | ៦០៣.៩៦៤ | ២.៤៤៣.០៥១ | ៩៦៧.៩០៤ | ៣.៩២២.៩១៥ |
| ចំណាយរដ្ឋបាលទូទៅ និងការលក់ | ១៧ | (៥.៥៦១.២១៥) | (២២.៤៩៥.១៣១) | (៥.៦១៩.៧៣០) | (២២.៧៧៦.៧៦៦) |
| **ចំណេញសុទ្ធពីប្រតិបត្តិការ** | | ៧.៤៣៨.២៥១ | ៣០.០៨៧.៧២៥ | ៦.០២៨.៩៥១ | ២៤.៤៣៥.៣៣៨ |
| ចំណាយហិរញ្ញប្បទាន | | (១.២៥៤.៧៦៧) | (៥.០៧៥.៥៣៣) | (១.២៧២.៣៨៥) | (៥.១៥៦.៩៧៦) |
| **ប្រាក់ចំណេញមុនដកពន្ធ** | | ៦.១៨៣.៤៨៤ | ២៥.០១២.១៩២ | ៤.៧៥៦.៥៦៦ | ១៩.២៧៨.៣៦២ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ១២ | (៨២១.៦៥១) | (៣.៣២៣.៥៧៨) | (៦៦៩.១៧៦) | (២.៧១២.១៧០) |
| **ប្រាក់ចំណេញសុទ្ធ សម្រាប់ការិយបរិច្ឆេទ** | | ៥.៣៦១.៨៣៣ | ២១.៦៨៨.៦១៤ | ៤.០៨៧.៣៩០ | ១៦.៥៦៦.១៩២ |
| **លទ្ធផលលម្អិតផ្សេងៗ** | | | | | |
| ការកំណត់ឡើងវិញនូវសំវិធានធន លើមូលនិធិសោធននិវត្តន៍ | | (២៧.៣០៤) | (១១០.៤៤៥) | ៤៧.៦២៦ | ១៩៣.០២៨ |
| | | ៥.៣៣៤.៥២៩ | ២១.៥៧៨.១៦៩ | ៤.១៣៥.០១៦ | ១៦.៧៥៩.២២០ |
| **ប្រាក់ចំណេញ ក្នុងមួយភាគហ៊ុន** | ២២ | | | | |
| ចំណេញមូលដ្ឋានក្នុងមួយភាគហ៊ុន (ពីប្រតិបត្តិការកំពុងបន្ត) | | ០.២៦ | ១.០៥ | ០.២០ | ០.៨០ |

កំណត់សម្គាល់ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

## កំពង់ផែស្វយ័តភ្នំពេញ

### របាយការណ៍ស្តីពីបម្រែបម្រួលមូលធន
### សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧

| | ដើមទុន ដុល្លារអាមេរិក | បុព្វលាភភាគហ៊ុន/ មូលធនផ្សេងៗ ដុល្លារអាមេរិក | ទុនបម្រុង តាមច្បាប់ ដុល្លារអាមេរិក | ទុនបម្រុង ទូទៅ ដុល្លារអាមេរិក | មូលនិធិអភិវឌ្ឍន៍ សហគ្រាស ដុល្លារអាមេរិក | ចំណេញ រក្សាទុក ដុល្លារអាមេរិក | លម្អៀងពីការ ប្តូររូបិយប័ណ្ណ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|---|---|---|
| **នាថ្ងៃទី ១ខែមករាឆ្នាំ ២០១៧** | ១១៨.៥៧៣.៨៨៥ | ១៥៥.៥០២ | ៥៤០.៩៤១ | ៥៤០.៩៤១ | ១០.១២៦.៧២៨ | ៣.១៧៥.៦៧១ | - | ១២៩.០៩៣.៣០៨ |
| *ប្រតិបត្តិការជាមួយភាគហ៊ុនិករបស់ក.ស.ភ.* | | | | | | | | |
| ភាគលាភសម្រាប់ភាគហ៊ុនិកប្រភេទ 'ខ' | - | - | - | - | - | (៥៣៨.០៣៨) | - | (៥៣៨.០៣៨) |
| ភាគលាភសម្រាប់ភាគហ៊ុនិកប្រភេទ 'ក' (កំណត់សម្គាល់ ៨) | - | - | - | - | - | (៥២.៤៦៧) | - | (៥២.៤៦៧) |
| | - | - | - | - | - | (៥៩០.៥០៥) | - | (៥៩០.៥០៥) |
| *លទ្ធផលលម្អិតសរុប* | | | | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - | - | ៥.៣៦១.៨៣៣ | - | ៥.៣៦១.៨៣៣ |
| លទ្ធផលលម្អិតផ្សេងៗ | - | - | - | - | - | (២៧.៣០៤) | - | (២៧.៣០៤) |
| ការផ្ទេរ | - | - | ២០៤.៣៧០ | ២០៤.៣៧០ | ២.២២៨.៨៩៣ | (២.៦៣៧.៦៣៣) | - | - |
| | - | - | ២០៤.៣៧០ | ២០៤.៣៧០ | ២.២២៨.៨៩៣ | ២.៦៩៥.៨៩៦ | - | ៥.៣៣៤.៥២៩ |
| នាថ្ងៃទី ៣១ខែធ្នូ ឆ្នាំ ២០១៧ | ១១៨.៥៧៣.៨៨៥ | ១៥៥.៥០២ | ៧៤៥.៣១១ | ៧៤៥.៣១១ | ១២.៣៥៥.៦៦១ | ៥.២៦២.០៦២ | - | ១៣៣.៤៣៧.៧៣២ |
| **នាថ្ងៃទី ៣១ខែធ្នូឆ្នាំ ២០១៧ (គិតជាពាន់រៀល-កំណត់សម្គាល់ ៤)** | ៤៥៧.៤១៣.៩៩០ | ៦២២.០០៨ | ៣.២១០.៦៧១ | ៣.២១០.៦៧១ | ៤៩.៩៧៩.៩០៣ | ២១.៣២៣.៦៩៩ | ៨.២៩០.៩៣២ | ៥៩០.៣០១.៣០៨ |

កំណត់សម្គាល់ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# កំពង់ផែស្វយ័តភ្នំពេញ

## របាយការណ៍ស្តីពីបម្រែបម្រួលមូលធន (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧

| | ដើមទុន ដុល្លារអាមេរិក | បុព្វលាភភាគហ៊ុន/ មូលធនផ្សេងៗ ដុល្លារអាមេរិក | ទុនបម្រុង តាមច្បាប់ ដុល្លារអាមេរិក | ទុនបម្រុង ទូទៅ ដុល្លារអាមេរិក | មូលនិធិអភិវឌ្ឍន៍ សហគ្រាស ដុល្លារអាមេរិក | ចំណេញ រក្សាទុក ដុល្លារអាមេរិក | លម្អៀងពីការ ប្តូររូបិយប័ណ្ណ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|---|---|---|
| **នាថ្ងៃទី ១ខែមករាឆ្នាំ ២០១៦** | ១១០.៣១៦.៦១២ | ៤.២៩២.៣៧៨ | ៨៣២.៧៨០ | ៨៣២.៧៨០ | ៧.៨២២.៦១៧ | ៣.១៦០.០២៥ | - | ១២៦.៩៥៥.១៨៩ |
| *ប្រតិបត្តិការជាមួយភាគហ៊ុនិករបស់ក.ស.ភ.* | | | | | | | | |
| ប់ណ្ណុលលើភាគលាភដែលបានធានា | - | - | - | - | - | (៩៣៦.១៩៥) | - | (៩៣៦.១៩៥) |
| ភាគលាភសម្រាប់ភាគហ៊ុនិកប្រភេទ 'ខ' | - | - | - | - | - | (៥៥០.៧៥២) | - | (៥៥០.៧៥២) |
| | - | - | - | - | - | (១.៤៨៦.៩៤៧) | - | (១.៤៨៦.៩៤៧) |
| *លទ្ធផលលម្អិតសរុប* | | | | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - | | ៤.០៨៧.៣៩០ | - | ៤.០៨៧.៣៩០ |
| លទ្ធផលលម្អិតផ្សេងៗ | - | - | - | - | | ៨៧.៦២៦ | - | ៨៧.៦២៦ |
| ការផ្ទេរ | ៤.១៣៦.៨៧៣ | (៤.១៣៦.៨៧៣) | ១៥៨.១៦១ | ១៥៨.១៦១ | ២.៣០៤.១៥១ | (២.៦២០.៤៧៣) | - | - |
| | ៤.១៣៦.៨៧៣ | (៤.១៣៦.៨៧៣) | ១៥៨.១៦១ | ១៥៨.១៦១ | ២.៣០៤.១៥១ | ១.៥៥៤.៥៤៣ | - | ៤.១៧៥.០១៦ |
| **នាថ្ងៃទី ៣១ខែធ្នូ ឆ្នាំ ២០១៦** | ១១៤.៤៥៣.៤៨៥ | ១៥៥.៥០៥ | ៩៩០.៩៤១ | ៩៩០.៩៤១ | ១០.១២៦.៧៦៨ | ៣.១៧៥.៦៧១ | - | ១២៩.០៩៣.៣០៨ |
| **នាថ្ងៃទី ៣១ខែធ្នូ ឆ្នាំ ២០១៦ (គិតជាពាន់រៀល-កំណត់សម្គាល់ ៥)** | ៤៥៧.៩១៣.៩៤០ | ៦២២.០០៤ | ២.៣៨៥.៦២៩ | ២.៣៨៥.៦២៩ | ៤០.៩៨១.៧៦២ | ១២.៩២០.១៨៩ | ៥.២៥០.៥៣២ | ៥២១.១៩៩.៦៨៩ |

កំណត់សម្គាល់ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# កំពង់ផែស្វយ័តភ្នំពេញ

## របាយការណ៍លំហូរសាច់ប្រាក់
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧

| | ការិយបរិច្ឆេទប្រចាំឆ្នាំ ដែលបានបញ្ចប់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ | | ការិយបរិច្ឆេទប្រចាំឆ្នាំ ដែលបានបញ្ចប់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៧) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៧) |
| **សកម្មភាពប្រតិបត្តិការ** | | | | |
| ប្រាក់ចំណេញសុទ្ធ សម្រាប់ការិយបរិច្ឆេទ | ៥.៣៦១.៨៣៣ | ២១.៦៤៨.៦១៤ | ៤.០៤៧.៣៩០ | ១៦.៥៦៦.១៩២ |
| និយ័តភាពលើ: | | | | |
| ចំណាយពន្ធលើប្រាក់ចំណេញ | ៨២១.៦៥១ | ៣.៣២៣.៥៧៨ | ៦៦៥.១៧៦ | ២.៧១២.១៧០ |
| រំលស់ | ២.៨៩៤.១៧៥ | ១១.៧០៦.៩៣៨ | ២.៣៧៨.១៣១ | ៩.៦៣៨.៥៦៥ |
| ការលុបចោលទ្រព្យរោងចក្រនិងបរិក្ខារ | - | - | ១៩.០៩០ | ៥៧.១០៧ |
| លម្អៀងលើអត្រាប្តូរប្រាក់ | ៣.៧៩៥ | ១៥.៣៥១ | ៥.៦០៧ | ២២.៧២៥ |
| សំវិធានធនលើមូលនិធិសោធននិវត្តន៍ | ៩០.៩៨២ | ៣៦៨.០២២ | ៩៥.៦៨៨ | ៣៨៧.៨២៣ |
| ចំណាយហិរញ្ញប្បទាន | ១.២៥៤.៧៦៧ | ៥.០៧៥.៩៣៣ | ១.២៧២.៣៨៥ | ៥.១៥៦.៩៧៦ |
| | ១០.៤២៧.២០៣ | ៤២.១៧៨.០៣៦ | ៨.៥២២.៨៦៧ | ៣៤.៥៤១.៥៥៨ |
| ការប្រែប្រួលនូវ: | | | | |
| គណនីអតិថិជន និងគណនី ត្រូវទទួលផ្សេងៗ | (៧៤.៥២៧) | (៣០១.៨៦២) | (២១.៦០១) | (៨៧.៥៤៩) |
| គណនីអ្នកផ្គត់ផ្គង់ និងគណនី បំណុលផ្សេងៗ | ១៧៨.៦២៩ | ៧២២.៥៥៨ | ១១៦.៧៤៩ | ៤៧៣.១៨៧ |
| | ១០.៥៣១.៣០៥ | ៤២.៥៩៩.១២៨ | ៨.៦១៧.៦១៥ | ៣៤.៩២៧.១៩៦ |
| ការប្រាក់ដែលបានបង់ | (១.១៥៩.១៨៦) | (៤.៦៨៨.៩០៧) | (១.១៥៩.១៨៦) | (៤.៦៩៨.១៨១) |
| ពន្ធលើប្រាក់ចំណេញដែលបានបង់ | (៤៨៦.៥២៦) | (២.០០៨.៨៨៨) | (៧០៩.៩២៦) | (២.៨៧៧.៣៣១) |
| គណទានពន្ធកាត់ទុក | (១៩.៣២៨) | (៧៨.១៨២) | (៩.៧៨៦) | (៣៩.៦៦៣) |
| មូលនិធិសោធននិវត្តន៍ដែលបានបង់ | (៣២.៩៦៦) | (១៣៣.៣៨៨) | (៣៩.២៨៥) | (១៥៩.២៦៣) |
| សាច់ប្រាក់សុទ្ធទទួលបាន ពីសកម្មភាពប្រតិបត្តិការ | ៨.៨២៣.២៩៩ | ៣៥.៦៩០.២៧៣ | ៦.៦៩៩.៨២២ | ២៧.១៥២.៧៥៨ |

# កំពង់ផែស្វយ័តភ្នំពេញ

## របាយការណ៍លំហូរសាច់ប្រាក់ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧

| | ការិយបរិច្ឆេទប្រចាំឆ្នាំ ដែលបានបញ្ចប់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ | | ការិយបរិច្ឆេទប្រចាំឆ្នាំ ដែលបានបញ្ចប់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៧) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៧) |
| **សកម្មភាពវិនិយោគ** | | | | |
| ការទិញទ្រព្យ រោងចក្រ និងបរិក្ខារ | (៣.០២៩.២៩០) | (១២.២៥៣.៤៧៨) | (៧.៦១១.០៥១) | (៣០.៨៤៧.៥៩០) |
| ការទិញទ្រព្យវិនិយោគ | (១.៨៩៣) | (៧.៦៥៧) | (៥៥១.៦៧៦) | (២.២៣៥.៩៤៣) |
| សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ | (៣.០៣១.១៨៣) | (១២.២៦១.១៣៥) | (៨.១៦២.៧២៧) | (៣៣.០៨៣.៥៣៣) |
| **សកម្មភាពហិរញ្ញប្បទាន** | | | | |
| ភាគលាភបានបង់ | (៨២៥.៦៦១) | (៣.៣៣៩.៧៩៩) | (៥៣៤.៤២៧) | (២.១៦៦.០៣៣) |
| សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពហិរញ្ញប្បទាន | (៨២៥.៦៦១) | (៣.៣៣៩.៧៩៩) | (៥៣៤.៤២៧) | (២.១៦៦.០៣៣) |
| **ការកើនឡើង/(ថយចុះ)សុទ្ធនូវសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | ៤.៩៦៥.៩៥៥ | ២០.០៨៩.៣០៩ | (១.៩៩៦.៣៧២) | (៨.០៩១.៤០៨) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាថ្ងៃទី ១ ខែមករា** | ៦.៧៥១.៨៨៩ | ២៧.២៥៥.៧៦១ | ៨.៧៤៨.២៦១ | ៣៥.៤២៨.៩៤៥ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (៣៩.៧៣០) | - | (៨១.៧៧៦) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាថ្ងៃទី ៣១ ខែធ្នូ** (កំណត់សម្គាល់ ៨) | ១១.៧១៧.៨៤៤ | ៤៧.៣០៥.៣៤០ | ៦.៧៥១.៨៨៩ | ២៧.២៥៥.៧៦១ |

កំណត់សម្គាល់ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# កំពង់ផែស្វយ័តភ្នំពេញ

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧

### ១. អំពីក្រុមហ៊ុន

កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ. ឬ ក្រុមហ៊ុន) ជាសហគ្រាសសាធារណៈដែលមានទម្រង់ជាក្រុមហ៊ុនរដ្ឋ ត្រូវបានបង្កើតឡើងតាមអនុក្រឹតលេខ ៥១ អនក្រ.បក នៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៨ ដែលស្ថិតនៅក្រោម អាណាព្យាបាលផ្នែកបច្ចេកទេសរបស់ ក្រសួងសាធារណការ និងដឹកជញ្ជូន និងអាណាព្យាបាលផ្នែកហិរញ្ញវត្ថុ របស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ក.ស.ភ. បាន ចុះបញ្ជីលក់មូលបត្រនៅលើផ្សារមូលបត្រកម្ពុជា (ផ.ម.ក) នៅថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០១៥ ដែលមានលេខចុះបញ្ជី ០០៣ CSX/SC និងប្រែក្លាយជាសហគ្រាសសាធារណៈដែលមានទម្រង់ជាក្រុមហ៊ុនរដ្ឋ ដែលបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ ។

ក.ស.ភ. គឺជានីតិបុគ្គល មានស្វ័យភាពផ្នែកបច្ចេកទេស ផ្នែករដ្ឋបាល និងផ្នែកហិរញ្ញវត្ថុ ហើយមានបេសកកម្មចម្បងផ្នែកសេវាកំពង់ផែ និងសេវាអនិស្សរវត្ថុនៃកំពង់ផែ ។

ការរៀបចំ និងការប្រព្រឹត្តទៅលើគ្រប់ផ្នែករបស់ ក.ស.ភ. ត្រូវអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានដែលពាក់ព័ន្ធ ។

ក. ស. ភ. មានគោលដៅទទួលរ៉ាប់រងក្នុងការគ្រប់គ្រង ថែទាំ និងធ្វើអាជីវកម្មសេវាកំពង់ផែ ព្រមទាំងអនិស្សរវត្ថុនៃកំពង់ផែ ដើម្បីប្រតិបត្តិការពង្រីក និងអភិវឌ្ឍ សម្រាប់តម្រូវការខាងពាណិជ្ជកម្ម ឧស្សាហកម្ម សេវាកម្មទេសចរណ៍ និងអ្នកដំណើរ និងចាត់វិធានការចាំបាច់គ្រប់បែបយ៉ាងឲ្យ ក.ស.ភ. រីកចម្រើនល្អតលាស់ទៅមុខ ។

ក. ស. ភ. មានភារកិច្ចជាអាជ្ញាធរ និងប្រតិបត្តិករផែរួមមាន៖

- ផ្តល់កណ្តាធារកិច្ច នាំនាវាចេញ-ចូលកំពង់ផែ
- ផ្តល់ចំណតនាវា
- ផ្តល់ទីតាំងសម្រាប់នាវាធ្វើការជួសជុល និងចាក់ប្រេង
- ធ្វើអាជីវកម្មឃ្លាំងស្តុក និងថែទាំប្រឡាយនាវាចរណ៍
- ត្រួតពិនិត្យការប្រតិបត្តិតាមលក្ខណៈបច្ចេកទេស និងជំរុញកិច្ចការពារសុវត្ថិភាព បរិស្ថាន សណ្តាប់ធ្នាប់ក្នុងបណ្តាលអាជីវកម្មរបស់កំពង់ផែ
- ត្រួតពិនិត្យឯកសារសម្គាល់នាវា ដើម្បីបំពេញបែបបទនាវាចេញ-ចូលផែ
- បណ្តុះបណ្តាលធនធានមនុស្សផ្នែកនាវាចរណ៍ និងផ្នែកកំពង់ផែតាមរយៈវិទ្យាស្ថាននាវាចរណ៍កម្ពុជា
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផែ តាមរយៈសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ក្នុង និងក្រៅប្រទេស ដើម្បីពង្រីកចំណតផែកុងតឺន័រ ផែទំនិញរាយ-ទំនិញចាក់ធារ ចំណតផែរណប ចំណតផែអ្នកដំណើរ និងទេសចរណ៍
- បង្កើតតំបន់គាំទ្រកំពង់ផែរួមមានតំបន់សេដ្ឋកិច្ចពិសេសតំបន់ឧស្សាហកម្ម តំបន់កែច្នៃផលិតផលកសិកម្ម និងតំបន់ភស្តុភារកម្ម
- ចាត់វិធានការនានា ដើម្បីធានាការអនុវត្តច្បាប់ និងលិខិតបទដ្ឋានជាធរមាន ពាក់ព័ន្ធនឹងកំពង់ផែ និងអធ្យាបាយដឹកជញ្ជូននានាតាមផ្លូវទឹក

# កំពង់ផែស្វយ័តភ្នំពេញ

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧

### ១. អំពីក្រុមហ៊ុន (ត)

- លើកដាក់ ផ្ទេរ ផ្ទុក រក្សាស្តុកទំនិញ
- ដឹកជញ្ជូនទំនិញក្នុងទីលានផែ និងរោងកំពង់ផែ និងតំបន់ផលិតកម្មរោងចក្រ
- ផ្តល់សេវាកម្មភណ្ឌាគារគយមានដែនកំណត់ ភណ្ឌាគារគយបណ្តោះអាសន្ន និងទីលានស្តុកកុងតឺន័រ
- ផ្តល់សេវាកម្មអូសទាញនាវា ពាក់ និងដោះពួរ
- ផ្តល់សេវាកម្មផ្គត់ផ្គង់ភស្តុភារ ទឹកស្អាត អនាម័យដល់នាវា
- ផ្តល់សេវាកម្មរើ និងប្រាកទំនិញដាក់កុងតឺន័រ
- ផ្តល់សេវាកម្មជួសជុល និងថែទាំសំបកកុងតឺន័រ
- ផ្តល់សេវាកម្មចំណតផែទេសចរណ៍ និងអ្នកដំណើរ និងមណ្ឌលសេវាកម្មផែក្នុងស្រុក
- ធ្វើប្រតិបត្តិការអាជីវកម្មបន្ថែមផ្សេងទៀត ដែលអនុញ្ញាតដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដើម្បីបម្រើដល់ការរីកចម្រើនរបស់ ក.ស.ភ.។

គិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ ក.ស.ភ. មានបុគ្គលិកសរុបចំនួន ៨៦០ នាក់ (និងគិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦ បុគ្គលិកសរុបមានចំនួន ៨៧៥ នាក់ )។

### ២. មូលដ្ឋាននៃការរៀបចំ

#### (ក) របាយការណ៍អនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានរៀបចំឡើង ស្របតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ។ របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល និងផ្តល់សិទ្ធិផ្សាយនៅថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១៨ ។

#### (ខ) មូលដ្ឋាននៃការវាស់វែង

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងផ្អែកលើមូលដ្ឋានថ្លៃដើមដំបូង លើកលែងតែសវិធានធនលើមូលនិធិសោធននិវត្តន៍ ដែលត្រូវបានវាស់វែងតាមតម្លៃសមស្រប ។

## អំពាច់ផែសួយ័តភ្នំពេញ

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧**

### ២. មូលដ្ឋាននៃការរៀបចំ (ត)

### (គ) រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់ការកំណត់បង្ហាញ

រូបិយប័ណ្ណជាតិនៃព្រះរាជាណាចក្រកម្ពុជា គឺប្រាក់រៀល ។ ដោយសារក្រុមហ៊ុនធ្វើប្រតិបត្តិការអាជីវកម្ម និងកត់ត្រាកាល់បញ្ជីគណនេយ្យរបស់ខ្លួនផ្អែកលើមូលដ្ឋានប្រាក់ដុល្លារអាមេរិក អ្នកគ្រប់គ្រងក៏បានកំណត់ថាប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណមុខងារ និងជារូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ ព្រោះវាបានឆ្លុះបញ្ចាំងពីសារជាតុសេដ្ឋកិច្ចនៃប្រភពព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ក្រុមហ៊ុន ។

របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិកដែលជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន ។ តួលេខទាំងអស់ត្រូវបានកាត់ខ្ទង់ចំនួនមួយដុល្លារអាមេរិក ដែលជិតបំផុត ឬលុះត្រាមានការបង្ហាញផ្សេងពីនោះ ។

### (ឃ) ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ អ្នកគ្រប់គ្រងបានធ្វើការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មតដែលមានផលប៉ះពាល់ដល់ការអនុវត្តនូវគោលនយោបាយគណនេយ្យ និងចំនួននៃទ្រព្យសកម្ម បំណុល ចំណូល និងចំណាយដែលបានរាយការណ៍ ។ លទ្ធផលជាក់ស្តែងអាចខុសពីការប៉ាន់ស្មានទាំងនោះ ។

ការប៉ាន់ស្មាន និងការសន្មត ដែលពាក់ព័ន្ធត្រូវបានត្រួតពិនិត្យជាប្រចាំ ។ ការកែប្រែទៅលើការប៉ាន់ស្មានត្រូវបានទទួលស្គាល់តាមមូលដ្ឋានទស្សនវិស័យ ។

ព័ត៌មានស្តីពីការសន្មត និងការប៉ាន់ស្មានដែលមិនមានភាពប្រាកដប្រជា ដែលអាចបណ្តាលឲ្យមានហានិភ័យជាសារវន្តដែលធ្វើឲ្យមាននិយ័តភាពជាសារវន្ត នៅក្នុងការិយបរិច្ឆេទក្រោយ ហើយត្រូវបានដាក់បញ្ចូលនៅក្នុងកំណត់សម្គាល់ដូចខាងក្រោម៖

កំណត់សម្គាល់ ១១ - សំវិធានធនលើមូលនិធិសោធននិវត្តន៍ ។

កំណត់សម្គាល់ ២១ - យថាភាពលើពន្ធ ។

**ការវាស់វែងតម្លៃសមស្រប**

គោលនយោបាយគណនេយ្យ និងការលាតត្រដាងព័ត៌មានមួយចំនួនរបស់ក្រុមហ៊ុន តម្រូវឲ្យមានការវាស់វែងតាមតម្លៃសមស្របទាំងទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ និង មិនមែនទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ ។

# អំពាន់ផែស្វយ័តភ្នំពេញ

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧**

## ២. មូលដ្ឋាននៃការរៀបចំ (ត)

### (ឃ) ការប៉ាន់ស្មាន និងការវិនិច្ឆ័យ (ត)

#### ការវាស់វែងតម្លៃសមស្រប (ត)

ក្រុមការងារផ្នែកហិរញ្ញវត្ថុ ធ្វើការត្រួតពិនិត្យលើការបញ្ចូលទិន្នន័យសំខាន់ៗដែលមិនអាចអង្កេតបាន និងនិយ័តភាពលើការវាស់វែងតម្លៃ ។ ប្រសិនបើព័ត៌មានពីអ្នកទីបី ដូចជាសម្រង់តម្លៃពីឈ្មួញកណ្តាល ឬសេវាកម្មផ្តល់តម្លៃត្រូវប្រើសម្រាប់ការវាស់វែងតម្លៃសមស្រប នោះអ្នកគ្រប់គ្រងនឹងវាយតម្លៃលើភស្តុតាងដែលបានមកពីភាគីទីបី ដើម្បីផ្តល់អំណះអំណាងដល់ការសន្និដ្ឋានថាតើការវាយតម្លៃនោះត្រឹមត្រូវតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ដោយរួមបញ្ចូលទាំងឋានានុក្រមនៃតម្លៃសមស្រប ដែលការវាយតម្លៃទាំងនោះត្រូវបានចាត់ថ្នាក់ ។

ក្នុងពេលវាស់វែងតម្លៃសមស្របនៃទ្រព្យ និងបំណុល ក្រុមហ៊ុនបានប្រើព័ត៌មានទីផ្សារកាន់តែច្រើនកាន់តែល្អ ។ តម្លៃសមស្រប ត្រូវបានចាត់ថ្នាក់ក្នុងកម្រិតខុសៗគ្នាតាមឋានានុក្រមនៃតម្លៃសមស្រប ដោយយោងទៅលើទិន្នន័យដែលប្រើប្រាស់នៅក្នុងវិធីសាស្ត្រវាយតម្លៃ ដូចខាងក្រោម៖

- កម្រិតទី ១: តម្លៃដកស្រង់ (មិនទាន់មាននិយ័តភាព) នៅក្នុងទីផ្សារសកម្ម សម្រាប់ទ្រព្យសកម្ម បំណុលស្រដៀងគ្នា ។
- កម្រិតទី ២: ទិន្នន័យដែលមិនមែនជាតម្លៃដកស្រង់ដែលមាននៅក្នុងកម្រិតទី ១ ដែលអាចធ្វើការអង្កេតបានសម្រាប់ទ្រព្យសកម្ម ឬបំណុល ទោះបីដោយផ្ទាល់ (ឧទាហរណ៍ដូចជាតម្លៃ) ឬមិនផ្ទាល់ (ឧទាហរណ៍កើតចេញពីតម្លៃ) ។
- កម្រិតទី ៣: ទិន្នន័យសម្រាប់ទ្រព្យសកម្ម ឬបំណុល ដែលមិនអាស្រ័យទៅលើទិន្នន័យអង្កេតទីផ្សារ (ធាតុចូលមិនអាចអង្កេតបាន) ។

ប្រសិនបើការបញ្ចូលទិន្នន័យ ដើម្បីវាយតម្លៃនូវតម្លៃសមស្រប ទ្រព្យ និងបំណុល ត្រូវបានចាត់ថ្នាក់ក្នុងកម្រិតខុសៗគ្នាតាមឋានានុក្រមតម្លៃសមស្រប នោះការវាស់វែងតម្លៃសមស្របត្រូវបានចាត់ថ្នាក់ស្ថិតនៅក្នុងកម្រិតដូចគ្នានៃឋានានុក្រមតម្លៃសមស្របទាំងមូល ក៏ដូចជាការបញ្ចូលទិន្នន័យកម្រិតទាបបំផុតសំខាន់ៗសម្រាប់ការវាស់វែងទាំងមូលដែរ ។

ក្រុមហ៊ុន ទទួលស្គាល់ការផ្ទេររវាងកម្រិតនៃឋានានុក្រមតម្លៃសមស្របនៅចុងការិយបរិច្ឆេទរបាយការណ៍ក្នុងអំឡុងពេលកែប្រែដែលបានកើតឡើង ។

ព័ត៌មានអំពីការសន្មតធ្វើឡើងសម្រាប់ការវាស់វែងនូវតម្លៃសមស្រប ត្រូវបានបង្ហាញក្នុងកំណត់សម្គាល់ ១៩ - ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ ។

# អំពាង់ផែស្វយ័តភ្នំពេញ

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧

### ៣. គោលនយោបាយគណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យសំខាន់ៗខាងក្រោមនេះ ត្រូវបានយកមកអនុវត្ត ប្រកបដោយសង្គតិភាព នៅគ្រប់ការិយបរិច្ឆេទ និងក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ។

### (ក) រូបិយប័ណ្ណសម្រាប់ការកំណត់បង្ហាញ

សកម្មភាពប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗទៀតក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ដោយប្រើប្រាស់អត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការនោះ ។

សមតុល្យនៃទ្រព្យសកម្មរូបិយវត្ថុ និងបំណុលរូបិយវត្ថុនាកាលបរិច្ឆេទរាយការណ៍ដែលជារូបិយប័ណ្ណក្រៅពីប្រាក់ដុល្លារអាមេរិក ក៏ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិកដោយប្រើអត្រានាកាលបរិច្ឆេទរាយការណ៍ ។ ភាពលំអៀងពីការប្តូររូបិយប័ណ្ណបរទេស ដែលកើតមកពីការប្តូរនោះត្រូវបានទទួលស្គាល់ជាចំណេញ ឬខាតនៅក្នុងរបាយការណ៍លទ្ធផល ។ ទ្រព្យដែលមិនមែនរូបិយវត្ថុដែលបានវាស់វែងផ្អែកតាមថ្លៃដើមដំបូងជារូបិយប័ណ្ណបរទេសមិនបានប្តូរឡើយ ។ ភាពលំអៀងពីការប្តូររូបិយប័ណ្ណ ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាតនៅក្នុងរបាយការណ៍លទ្ធផល ។

### (ខ) ឧបករណ៍ហិរញ្ញវត្ថុ

ក្រុមហ៊ុន បែងចែកអនិស្សន្ទទ្រព្យសកម្មហិរញ្ញវត្ថុជាឥណទាន និងគណនីត្រូវទទួល ។

ក្រុមហ៊ុន បែងចែកអនិស្សន្ទបំណុលហិរញ្ញវត្ថុជាបំណុលហិរញ្ញវត្ថុផ្សេងៗ ។

#### (i) អនិស្សន្ទទ្រព្យសកម្មហិរញ្ញវត្ថុ និងអនិស្សន្ទបំណុលហិរញ្ញវត្ថុ - ការទទួលស្គាល់ និងការឈប់ទទួលស្គាល់

ក្រុមហ៊ុន ទទួលស្គាល់ដំបូងនូវឥណទាន និងគណនីត្រូវទទួលនៅកាលបរិច្ឆេទប្រតិបត្តិការបានចាប់ផ្តើម ។ រាល់ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុដទៃទៀត ត្រូវបានទទួលស្គាល់ដំបូងនៅកាលបរិច្ឆេទជួញដូរ ។

ក្រុមហ៊ុនឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែលសិទ្ធិទទួលបានសាច់ប្រាក់តាមកិច្ចសន្យានៃទ្រព្យសកម្មនោះផុតកំណត់ ឬក្រុមហ៊ុនបានផ្ទេរសិទ្ធិក្នុងការទទួលបានសាច់ប្រាក់តាមកិច្ចសន្យា ក្នុងប្រតិបត្តិការដែលហានិភ័យ និងតម្លៃតបស្នងពីកម្មសិទ្ធិភាពសារវន្តនៃទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានផ្ទេរចេញ ឬមិនបានផ្ទេរ ឬមិនរក្សានូវហានិភ័យ និងតម្លៃតបស្នងពីកម្មសិទ្ធិភាពសារវន្ត និងមិនរក្សានូវការគ្រប់គ្រងទ្រព្យសកម្មដែលបានផ្ទេរ ។ រាល់អត្ថប្រយោជន៍ដែលបានកើតឡើង ឬរក្សាទុកដោយក្រុមហ៊ុនតាមរយៈទ្រព្យសកម្មហិរញ្ញវត្ថុដែលបានផ្ទេរចេញ ត្រូវបានទទួលស្គាល់ជាទ្រព្យសកម្ម ឬបំណុលដាច់ដោយឡែក ។

ក្រុមហ៊ុនឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលភាតព្វកិច្ចកិច្ចសន្យាបានបញ្ចប់ លុបចោល ឬផុតកាលកំណត់ ។

## អគ្គិសនីកម្ពុជាភ្នំពេញ

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧**

### ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ខ) ឧបករណ៍ហិរញ្ញវត្ថុ (ត)

**(i) អនិស្សន្ទទ្រព្យសកម្មហិរញ្ញវត្ថុ និងអនិស្សន្ទបំណុលហិរញ្ញវត្ថុ - ការទទួលស្គាល់ និងការឈប់ទទួលស្គាល់ (ត)**

ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុត្រូវបានកាត់កង ហើយចំនួននៅសល់សុទ្ធ ត្រូវបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលក្រុមហ៊ុនមានសិទ្ធិតាមផ្លូវច្បាប់ដើម្បីទូទាត់ និងមានបំណងធ្វើការទូទាត់លើមូលដ្ឋានកាត់កង ឬពេលទ្រព្យសកម្មទទួលបាន និងទូទាត់បំណុលកើតឡើងដំណាលគ្នា ។

**(ii) អនិស្សន្ទទ្រព្យសកម្មហិរញ្ញវត្ថុ និងអនិស្សន្ទបំណុលហិរញ្ញវត្ថុ - ការវាស់វែង**

*ឥណទាន និងគណនីត្រូវទទួល*

ទ្រព្យសកម្មទាំងនោះ ត្រូវបានទទួលស្គាល់ជាដំបូងតាមតម្លៃសមស្របបូកចំណាយប្រតិបត្តិការពាក់ព័ន្ធ ។ បន្ទាប់ពីការទទួលស្គាល់លើកដំបូង វាត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព ។

*សាច់ប្រាក់ និងសាច់ប្រាក់សមមូល*

នៅក្នុងរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមានសមតុល្យសាច់ប្រាក់ និងប្រាក់បញ្ញើតាមតម្រូវការដែលមាន កាលកំណត់ ៣ ខែ ឬតិចជាង គិតចាប់ពីថ្ងៃដែលបានទទួល ហើយដែលអាចប្តូរជាសាច់ប្រាក់ ដោយមានហានិភ័យតិចតួចចំពោះការផ្លាស់ប្តូរតម្លៃ ហើយវាគឺជាផ្នែកមួយដ៏សំខាន់នៅក្នុងការគ្រប់គ្រងសាច់ប្រាក់របស់ក្រុមហ៊ុន ។

*បំណុលហិរញ្ញវត្ថុផ្សេងៗ*

បំណុលហិរញ្ញវត្ថុទាំងនោះ ត្រូវបានទទួលស្គាល់ដំបូងតាមតម្លៃសមស្របដកថ្លៃដើមប្រតិបត្តិការដែលពាក់ព័ន្ធ ។ បន្ទាប់ពីការទទួលស្គាល់លើកដំបូងបំណុលហិរញ្ញវត្ថុទាំងនេះ ត្រូវបានវាស់វែងតាមរំលស់ថ្លៃដើមដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព ។

**(iii) ដើមទុន - ភាគហ៊ុនធម្មតា**

តម្លៃបន្ថែមផ្ទាល់ដែលទាក់ទងនឹងការបោះផ្សាយ ភាគហ៊ុនត្រូវបានទទួលស្គាល់ដោយការដកចេញពីមូលធន ហើយកាត់កងនឹងពន្ធដែលពាក់ព័ន្ធនានា ។

# កំពង់ផែស្វយ័តភ្នំពេញ

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧

### ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (គ) ទ្រព្យ រោងចក្រ និងបរិក្ខារ

#### (i) ការទទួលស្គាល់ និងការវាស់វែង

ផ្នែកនៃទ្រព្យ រោងចក្រ និងបរិក្ខារ ត្រូវបានកត់ត្រាតាមតម្លៃដើមដករំលស់បង្គរ និងការខាតបង់លើឱនភាពនៃតម្លៃបង្គរ ប្រសិនបើមាន ។

ថ្លៃដើមមានរួមបញ្ចូលនូវរាល់ចំណាយទាំងឡាយ ដែលទាក់ទងដោយផ្ទាល់ទៅនឹងការទិញទ្រព្យ ។ ទ្រព្យកំពុងបង្កើត រួមបញ្ចូលទាំងថ្លៃនៃការសាងសង់ បរិក្ខារ និងថ្លៃផ្សេងៗទៀត ត្រូវបានបញ្ចូលជាថ្លៃដើម ។

នៅពេលដែលធាតុនៃទ្រព្យ រោងចក្រ និងបរិក្ខារ មានអាយុកាលប្រើប្រាស់ខុសៗគ្នា ធាតុទាំងនោះ ត្រូវបានចាត់ទុកជាផ្នែកផ្សេងគ្នា (សមាសធាតុចម្បង) នៃទ្រព្យ រោងចក្រ និងបរិក្ខារ ។

ចំណេញ ឬខាតការលក់ចេញផ្នែកនៃទ្រព្យ រោងចក្រ និងបរិក្ខារ ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាតនៅក្នុងរបាយការណ៍លទ្ធផល ។

#### (ii) ចំណាយបន្ទាប់

ចំណាយបន្ទាប់ដែលពាក់ព័ន្ធទៅនឹងធាតុមួយនៃផ្នែកនៃទ្រព្យ រោងចក្រ និងបរិក្ខារដែលបានទទួលស្គាល់រួចមកហើយ ត្រូវបានបូកបញ្ចូលនៅក្នុងតម្លៃយោងនៃផ្នែកនោះ ប្រសិនបើវាអាចមានលទ្ធភាពផ្តល់នូវអត្ថប្រយោជន៍ សេដ្ឋកិច្ចនាពេលអនាគតដល់ក្រុមហ៊ុន ។

#### (iii) រំលស់

ទ្រព្យ រោងចក្រ និងបរិក្ខារត្រូវបានដករំលស់ចាប់ពីថ្ងៃដែលបានដំឡើង និងអាចប្រើប្រាស់បាន ។ ទ្រព្យសកម្ម កំពុងសាងសង់ មិនត្រូវបានធ្វើរំលស់នោះទេ រហូតដល់ការសាងសង់ទ្រព្យសកម្មនោះបានបញ្ចប់ និងដាក់ឲ្យប្រើប្រាស់ ។

រំលស់ត្រូវបានគណនាដើម្បីកាត់បន្ថយថ្លៃដើមនៃទ្រព្យ រោងចក្រ និងបរិក្ខារ ដកតម្លៃកាកសំណល់របស់ទ្រព្យ រោងចក្រ និងបរិក្ខារ ដោយប្រើប្រាស់វិធីសាស្ត្ររំលស់ថេរ ទៅតាមអាយុកាលប្រើប្រាស់ប៉ាន់ស្មាន ។ រំលស់ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាតនៅក្នុងរបាយការណ៍លទ្ធផល ។ ដីធ្លីកម្មសិទ្ធិមិនត្រូវបានគិតរំលស់ទេ ។

ការប៉ាន់ស្មាន់អាយុកាលប្រើប្រាស់នៃទ្រព្យ រោងចក្រ និងបរិក្ខារសំខាន់ៗក្នុងការិយបរិច្ឆេទបច្ចុប្បន្ន និងការិយបរិច្ឆេទប្រៀបធៀបមានដូចខាងក្រោម៖

# កំពង់ផែស្វយ័តភ្នំពេញ

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧

### ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (គ) ទ្រព្យ រោងចក្រ និងបរិក្ខារ (ត)

#### (iii) រំលស់ (ត)

| | |
|---|---|
| ចំណតនាវា (ស្ពាន ផែ) និងអាគារ | ១០-៥០ ឆ្នាំ |
| គ្រឿងចក្រ និងគ្រឿងម៉ាស៊ីន | ១០-១៥ ឆ្នាំ |
| គ្រឿងសង្ហារឹមនិងគ្រឿងបំពាក់ | ៥ ឆ្នាំ |
| កុំព្យូទ័រ | ៥-១៥ ឆ្នាំ |
| សម្ភារការិយាល័យ និងផ្សេងៗ | ៥-១៥ ឆ្នាំ |
| យានយន្ត | ៨-១៥ ឆ្នាំ |

វិធីសាស្ត្ររំលស់ អាយុកាលប្រើប្រាស់ និងតម្លៃកាកសំណល់ ត្រូវបានពិនិត្យនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ ហើយត្រូវកែសម្រួលប្រសិនបើសមស្រប ។

### (ឃ) ទ្រព្យវិនិយោគ

ទ្រព្យវិនិយោគ គឺជាទ្រព្យកាន់កាប់សម្រាប់រកចំណូលពីការជួល ឬកំណើនមូលធន ឬទាំងពីរប៉ុន្តែមិនមែនសម្រាប់លក់ជាដំណើរការអាជីវកម្មប្រចាំថ្ងៃ ការផលិត ឬផ្គត់ផ្គង់ ទំនិញ ឬសេវាកម្ម ឬសម្រាប់ការងាររដ្ឋបាលនោះទេ ។

ទ្រព្យវិនិយោគ ត្រូវបានកត់ត្រាតាមតម្លៃដើម ដករំលស់បង្គរ និងការខាតបង់លើឱនភាពនៃតម្លៃ ។

ទ្រព្យវិនិយោគ ត្រូវបានរំលស់ដោយប្រើប្រាស់វិធីសាស្ត្ររំលស់ថេរ រយៈពេលពី១០-៥០ ឆ្នាំ ។

វិធីសាស្ត្ររំលស់ អាយុកាលប្រើប្រាស់ និងតម្លៃកាកសំណល់ ត្រូវបានពិនិត្យនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ ហើយត្រូវកែសម្រួលប្រសិនបើសមស្រប ។

### (ង) ឱនភាពនៃតម្លៃ

#### (i) អនិស្សន្ទទ្រព្យសកម្មហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាយតម្លៃនាកាលបរិច្ឆេទរាយការណ៍នីមួយៗ ដើម្បីកំណត់សញ្ញាណឱនភាពនៃតម្លៃ ។

## ក្រុមហ៊ុនផលិតអគ្គិសនីវារីអគ្គិសនីពេញ

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧**

### ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ង) ឱនភាពនៃតម្លៃ (ត)

#### (i) អនិស្សន្ទទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

សញ្ញាណដែលថាទ្រព្យសកម្មហិរញ្ញវត្ថុកេនឱនភាពនៃតម្លៃរួមមាន៖

- ការខកខាន ឬយឺតយ៉ាវក្នុងការទូទាត់សងរបស់កូនបំណុល
- ការរៀបចំឡើងវិញនូវលក្ខខណ្ឌទូទាត់សង ដែលក្រុមហ៊ុនមិនបានរំពឹងទុក
- សញ្ញាណបង្ហាញថាកូនបំណុល នឹងជួបប្រទះការក្ស័យធន
- ការប្រែប្រួលជាអវិជ្ជមានស្ថានភាពទូទាត់របស់កូនបំណុល
- ការបាត់បង់ទីផ្សារសកម្ម សម្រាប់មូលបត្រ ឬ
- ស្ថិតិអង្កេត ដែលបង្ហាញថាមាន នឹងមានការថយចុះសាច់ប្រាក់ដែលអាចវាស់វែងបានពីក្រុមទ្រព្យសកម្មហិរញ្ញវត្ថុ ។

*ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមរំលស់ថ្លៃដើម*

ក្រុមហ៊ុន ពិចារណាភស្តុតាងនៃឱនភាពតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុទាំងលើទ្រព្យសកម្មទោល និងជាក្រុម ។ រាល់ទ្រព្យសកម្មទោលសារវន្ត ត្រូវបានវាយតម្លៃឱនភាពដាច់ដោយឡែក ។ ទ្រព្យសកម្មហិរញ្ញវត្ថុទោលដែលមិនរកឃើញថា មានឱនភាពនៃតម្លៃក្នុងទម្រង់ ជាក់លាក់មួយនោះទេត្រូវបានវាយតម្លៃជាក្រុមសម្រាប់ឱនភាពនៃតម្លៃដែលបានកើតឡើង ប៉ុន្តែមិនទាន់កំណត់នៅឡើយ ។ គណនីមិនសារវន្ត ត្រូវបានវាយតម្លៃជាក្រុម ។ ការវាយតម្លៃជាក្រុម ត្រូវបានធ្វើឡើងដោយបញ្ចូលនូវទ្រព្យដែលមានចរិកលក្ខណៈហានិភ័យស្រដៀងគ្នា ។

ក្នុងការវាយតម្លៃឱនភាពនៃតម្លៃជាក្រុម ក្រុមហ៊ុនប្រើប្រាស់ព័ត៌មានពីមុន លើថេរវេលានៃការប្រមូលបាន និងចំនួននៃការខាតបង់កើតឡើង និងធ្វើការវិនិច្ឆ័យលើសេដ្ឋកិច្ចបច្ចុប្បន្ន និងលក្ខខណ្ឌឥណទានបច្ចុប្បន្ន ដើម្បីប៉ាន់ស្មានពីការខាតបង់ជាក់ស្តែងអាចច្រើនជាង ឬតិចជាងចំនួនដែលបានកើតឡើងដោយយោងតាមនិន្នាការពីមុន ។

ការខាតបង់លើឱនភាពនៃតម្លៃលើទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានគណនាដោយផ្អែកលើភាពខុសគ្នារវាងសមតុល្យយោង និងតម្លៃបច្ចុប្បន្ននៃលំហូរទឹកប្រាក់នាអនាគត ដែលធ្វើអប្បហារតាមអត្រាការប្រាក់ប្រសិទ្ធភាព ដំបូង ។ ការខាតបង់ត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬខាតក្នុងគណនីសំវិធានធន ។ នៅពេលដែលក្រុមហ៊ុនគិតថាមិនមានសង្ឃឹមក្នុងការទទួលបាននូវការទូទាត់សង ចំនួនដែលពាក់ព័ន្ធនឹងត្រូវបានលុបចោល ។ ប្រសិនបើការខាតបង់លើឱនភាពនៃតម្លៃមានការថយចុះនៅពេលបន្ទាប់ ហើយការថយចុះអាចពាក់ព័ន្ធនឹងព្រឹត្តការណ៍កើតឡើងបន្ទាប់ពីឱនភាពនៃតម្លៃបានទទួលស្គាល់នោះ ការខាតលើឱនភាពនៃតម្លៃដែលបានទទួលស្គាល់ពីមុន ត្រូវបានធ្វើនិយ័តកម្មក្នុងរបាយការណ៍លទ្ធផល ។

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧

### ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ង) ឱនភាពនៃតម្លៃ (ត)

### (ii) ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

នាកាលបរិច្ឆេទរាយការណ៍នីមួយៗ ក្រុមហ៊ុនពិនិត្យសមតុល្យយោងនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ដើម្បីកំណត់សញ្ញាណនៃឱនភាពនៃតម្លៃ ។ ក្នុងករណីដែលមានកត្តាទាំងនោះកើតឡើងចំនួននៃទ្រព្យសកម្មដែលអាចប្រមូលបានវិញ នឹងត្រូវបានប៉ាន់ស្មាន ។

សម្រាប់ការធ្វើតេស្តឱនភាពនៃតម្លៃ ទ្រព្យសកម្មត្រូវបានដាក់បញ្ចូលគ្នាជាក្រុម ដែលអាចបង្កើតសាច់ប្រាក់តូចបំផុតពីការបន្តការប្រើប្រាស់ ដោយមិនពឹងផ្អែកខ្លាំងលើលំហូរទឹកប្រាក់នៃទ្រព្យសកម្មដទៃទៀត ឬក្រុមទ្រព្យសកម្មដទៃទៀត ហៅកាត់ថា ("ឯកតាបង្កើតសាច់ប្រាក់") ។

តម្លៃដែលអាចប្រមូលមកវិញបាននៃ ទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ គឺផ្អែកលើតម្លៃដែលធំជាងរវាងតម្លៃប្រើប្រាស់ និងតម្លៃសមស្រប ដកចំណាយការលក់ចេញ ។ តម្លៃប្រើប្រាស់ គឺអាស្រ័យលើការប៉ាន់ស្មាន នូវលំហូរទឹកប្រាក់នាពេលអនាគតអប្បហារទៅតម្លៃបច្ចុប្បន្ន ដោយប្រើប្រាស់អត្រាអប្បហាមុនដកពន្ធ ដែលឆ្លុះបញ្ចាំងពីការប៉ាន់ប្រមាណទីផ្សារបច្ចុប្បន្ននៃតម្លៃពេលវេលា និងហានិភ័យជាក់លាក់ សម្រាប់ទ្រព្យសកម្មទាំងនោះ ឬឯកតាបង្កើតសាច់ប្រាក់ ។

ការខាតបង់លើឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់ ប្រសិនបើសមតុល្យយោងនៃទ្រព្យសកម្ម ឬ ឯកតាបង្កើតសាច់ប្រាក់ មានតម្លៃលើសតម្លៃដែលអាចប្រមូលមកវិញបាន ។

ការខាតបង់លើឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល ។ ការខាតបង់លើឱនភាព នៃតម្លៃ ត្រូវបានបែងចែក ដើម្បីកាត់បន្ថយសមតុល្យយោងនៃទ្រព្យសកម្មក្នុងឯកតាបង្កើតសាច់ប្រាក់ តាមមូលដ្ឋានសមាមាត្រ ។

### (ច) អត្ថប្រយោជន៍របស់និយោជិត

### (i) អត្ថប្រយោជន៍របស់និយោជិតរយៈពេលខ្លី

អត្ថប្រយោជន៍របស់និយោជិតរយៈពេលខ្លី គឺជាចំណាយនៅពេលសេវាកម្មពាក់ពន្ធត្រូវបានផ្តល់ ។ បំណុលត្រូវបានទទួលស្គាល់លើចំនួនដែលរំពឹងថានឹងត្រូវទូទាត់ប្រសិនបើក្រុមហ៊ុន មានកាតព្វកិច្ចផ្លូវច្បាប់ ឬប្រយោលក្នុងការទូទាត់ចំនួននេះ ដែលជាលទ្ធផលនៃសេវាកម្ម ដែលបានផ្តល់ដោយនិយោជិតរួចហើយ ហើយកាតព្វកិច្ចអាចប៉ាន់ស្មានដោយភាពជាក់លាក់ ។

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧

### ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ច) អត្ថប្រយោជន៍របស់និយោជិត (ត)

#### (ii) គម្រោងអត្ថប្រយោជន៍ដែលបានកំណត់

កាតព្វកិច្ចរបស់ក្រុមហ៊ុនសម្រាប់អត្ថប្រយោជន៍និយោជិតនេះ ត្រូវបានគណនាដាច់ដោយឡែកសម្រាប់គម្រោងនីមួយៗ ដោយធ្វើការប៉ាន់ស្មានលើចំនួនអត្ថប្រយោជន៍អនាគតដែលនិយោជិត ត្រូវទទួលសម្រាប់ការបម្រើការងារនៅក្នុងឆ្នាំបច្ចុប្បន្ន និងឆ្នាំកន្លងទៅរបស់ពួកគេ នូវចំនួននោះ និងដកតម្លៃទៅតាមគម្រោងទ្រព្យសកម្ម ។

ការគណនាកំណត់ពីកាតព្វកិច្ចនៃអត្ថប្រយោជន៍ ត្រូវបានធ្វើឡើងដោយកំណត់នូវភាពជាក់ស្តែងដោយប្រើរបៀបនៃការប៉ាន់ប្រមាណ ។ នៅពេលលទ្ធផលនៃការគណនា បង្ហាញថាជាទ្រព្យសកម្មរបស់ក្រុមហ៊ុន ការទទួលស្គាល់ទ្រព្យសកម្ម ត្រូវបានកំណត់ទៅតាមតម្លៃបច្ចុប្បន្ននៃអត្ថប្រយោជន៍សេដ្ឋកិច្ច ដែលមានក្នុងទម្រង់ប្រាក់បង្វិល គម្រោងនាពេលអនាគត ឬដកពីគម្រោងការចូលរួមចំណែកនាពេលអនាគត ។ ការគណនាតម្លៃបច្ចុប្បន្ននៃអត្ថប្រយោជន៍សេដ្ឋកិច្ច សាច់ប្រាក់ត្រូវបានផ្តល់ឲ្យទៅមូលនិធិអតិបរមា តាមតម្រូវការណាមួយដែលអនុវត្តបាន ។

កាកំណត់នៃការវាស់វែងបំណុល អត្ថប្រយោជន៍សុទ្ធឡើងវិញ ដោយរួមបញ្ចូលទាំងការចំណេញ ឬខាតជាក់ស្តែង ផែនការវិលត្រលប់មកលើទ្រព្យសកម្ម (មិនរួមបញ្ចូលការប្រាក់) និងផលប៉ះពាល់នៃកម្រិតទ្រព្យសកម្ម (ប្រសិនបើមាន មិនរួមបញ្ចូលការប្រាក់) ត្រូវទទួលស្គាល់ភ្លាមៗ ក្នុងលទ្ធផលលម្អិតផ្សេងៗ ។ ក្រុមហ៊ុនបានកំណត់ចំណូល ចំណាយការប្រាក់សុទ្ធលើការកំណត់បំណុល (ទ្រព្យសកម្ម) អត្ថប្រយោជន៍សុទ្ធសម្រាប់ការិយបរិច្ឆេទ ដោយអនុវត្តតាមអត្រាអប្បហារសម្រាប់ការវាស់វែងនូវការកំណត់ កាតព្វកិច្ចនៃអត្ថប្រយោជន៍នាដើមការិយបរិច្ឆេទប្រចាំឆ្នាំ បន្ទាប់មកកំណត់បម្រែបម្រួលនៅក្នុងការិយបរិច្ឆេទ ដែលជាលទ្ធផលបានមកពីការរួមចំណែកវិភាគទាននិងការបង់ប្រាក់ ។ ចំណាយការប្រាក់សុទ្ធ និងចំណាយទាំងអស់ដែលពាក់ព័ន្ធនឹងគម្រោងអត្ថប្រយោជន៍នេះ ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាតនៅក្នុងរបាយការណ៍លទ្ធផល ។

ក្រុមហ៊ុនទទួលស្គាល់ចំណេញ ឬខាតពី Curtailment ឬការទូទាត់ នៅពេលប្រតិបត្តិនោះកើតឡើង ។ ចំណេញ ឬខាតពី Curtailment ឬការទូទាត់រួមមានការប្រែប្រួលនូវតម្លៃបច្ចុប្បន្ន ឬចំណេញ ឬខាតពី Actuarial និងចំណាយនៃការបម្រើការរួចដែលមិនទាន់ទទួលស្គាល់ពីមុន ។

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧**

### ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ឆ) សំវិធានធន

សំវិធានធន ត្រូវបានកំណត់ដោយអប្បហារលំហូរទឹកប្រាក់ដែលរំពឹងថានឹងទទួលបាន នាពេលអនាគត ដោយប្រើអត្រាមុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងពីការប៉ាន់ប្រមាណនៃតម្លៃពេលវេលាក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់ចំពោះបំណុលទាំងនោះ ។ តម្លៃនៃអប្បហារ ត្រូវបានទទួលស្គាល់ជាចំណាយហិរញ្ញប្បទាន ។

### (ជ) ទុនបម្រុងតាមច្បាប់ ទុនបម្រុងសេរី និងមូលនិធិអភិវឌ្ឍន៍សហគ្រាស

យោងតាមលក្ខន្តិកថ្មីក្រោយពីក.ស.ភ.បានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ ក.ស.ភ ត្រូវផ្ទេរពីប្រាក់ចំណេញសុទ្ធនៃការិយបរិច្ឆេទចុងក្រោយដូចខាងក្រោម៖

- ៥% ទៅទុនបម្រុងតាមច្បាប់
- ៥% ទៅទុនបម្រុងសេរី
- ប្រាក់ចំណេញដែលសល់ក្រោយការបែងចែកខាងលើ ត្រូវបែងចែកជា ភាគលាភ ឲ្យភាគហ៊ុនិក ទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- ប្រាក់ចំណេញនៅសល់ចុងក្រោយ ត្រូវបង្វិលចូលមូលនិធិអភិវឌ្ឍន៍សហគ្រាស ។

### (ឈ) ការទទួលស្គាល់ចំណូល

ចំណូល ត្រូវបានទទួលស្គាល់នៅពេលទទួលបាននូវតម្លៃសមស្រប ឬការលក់ទំនិញ និងសេវាកម្មដែលត្រូវទទួល ពីសកម្មភាពប្រចាំថ្ងៃរបស់ក្រុមហ៊ុន ។ ប្រាក់ចំណូល ត្រូវទទួលស្គាល់បន្ទាប់ពីដកពន្ធ ការបង្វិលឲ្យវិញ និងការបញ្ចុះតម្លៃ ។

ចំណូលត្រូវបានទទួលស្គាល់ដូចខាងក្រោម៖

*(i)* ***កិច្ចការផែ***

ចំណូលកិច្ចការផែ ត្រូវបានទទួលស្គាល់នៅពេលដែលសេវាកម្មដែលទាក់ទងបានផ្តល់សេវាកម្ម ។ នាកាលបរិច្ឆេទរាយការណ៍ ប្រសិនជាសេវាកម្មនៅកំពុងដំណើរការ ដូច្នេះចំណែកសេវាកម្មដែលបានផ្តល់រួចរាល់ត្រូវបានទទួលស្គាល់នៅក្នុងការិយបរិច្ឆេទ ។

## កំពង់ផែស្វយ័តភ្នំពេញ

### កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
### សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧

### ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

#### (ឈ) ការទទួលស្គាល់ចំណូល (ត)

*(ii) សេវាលើកដាក់ក្រោមដងយោង (Stevedoring) សេវាលើកដាក់លើទីលាន (LoLo) សេវាស្តុកទំនិញ/កុងតឺន័រ*

ចំណូលលើកដាក់ក្រោមដងយោង (Stevedoring) ចំណូលលើកដាក់លើទីលាន (LoLo) ចំណូលពីថ្លៃឈ្នួលស្តុកទំនិញ/កុងតឺន័រ ត្រូវបានទទួលស្គាល់នៅពេលដែលផ្តល់សេវាកម្ម ។ នាកាលបរិច្ឆេទរាយការណ៍ ប្រសិន ជាសេវាកម្មនៅកំពុងដំណើរការ ដូច្នេះចំណែកសេវាកម្មដែលបានផ្តល់រួចរាល់ ត្រូវបានទទួលស្គាល់នៅក្នុងការិយបរិច្ឆេទ។

*(iii) ការគ្រប់គ្រងអាជីវកម្មឧទ្យាន*

ចំណូលពីថ្លៃឈ្នួលគ្រប់គ្រងអាជីវកម្មឧទ្យាន ត្រូវបានទទួលស្គាល់នៅពេលដែលផ្តល់សេវាកម្ម ។ នាកាលបរិច្ឆេទរាយការណ៍ ប្រសិនជាសេវាកម្មនៅកំពុងដំណើរការ ដូច្នេះចំណែកសេវាកម្មដែលបានផ្តល់រួចរាល់ ត្រូវបានទទួលស្គាល់នៅក្នុងការិយបរិច្ឆេទ ។

*(iv) ច្រកទ្វារ*

ចំណូលពីច្រកទ្វារត្រូវបានទទួលស្គាល់នៅពេលដែលផ្តល់សេវាកម្ម ។ នាកាលបរិច្ឆេទរាយការណ៍ ប្រសិនជាសេវាកម្មនៅកំពុងដំណើរការ ដូច្នេះចំណែកសេវាកម្មដែលបានផ្តល់រួចរាល់ ត្រូវបានទទួលស្គាល់នៅក្នុងការិយបរិច្ឆេទ ។

*(v) សេវាកម្មវាស់ស្ទង់ សេវាដឹកជញ្ជូននិងសេវាថ្លឹងកុងតឺន័រ*

ចំណូលពីការវាស់ស្ទង់ ចំណូលពីការដឹកជញ្ជូន និងចំណូលពីថ្លៃឈ្នួលថ្លឹងកុងតឺន័រ ត្រូវបានទទួលស្គាល់នៅពេលដែលផ្តល់សេវាកម្ម ។ នាកាលបរិច្ឆេទរាយការណ៍ ប្រសិនជាសេវាកម្មនៅកំពុងដំណើរការ ដូច្នេះចំណែកសេវាកម្មដែលបានផ្តល់រួចរាល់ ត្រូវបានទទួលស្គាល់នៅក្នុងការិយបរិច្ឆេទ ។

#### (ញ) ចំណូលពីការជួល

ចំណូលពីការជួលទ្រព្យវិនិយោគស្ថិតក្រោមភតិសន្យាប្រតិបត្តិការ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលដោយផ្អែកលើមូលដ្ឋានរំលស់ថេរទៅតាមថេរវេលានៃភតិសន្យា ។ ប្រាក់លើកទឹកចិត្តភតិសន្យាដែលបានទទួល ត្រូវទទួលស្គាល់ជាផ្នែកមួយនៃចំណូលភតិសន្យាសរុបទៅតាមថេរវេលានៃភតិសន្យា ។

# គំពង់ផែស្វយ័តភ្នំពេញ

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧

### ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ដ) ចំណាយហិរញ្ញប្បទាន

ចំណាយហិរញ្ញប្បទានរួមមានចំណាយការប្រាក់លើប្រាក់កម្ចី និងអប្បហារលើសំវិធានធន ។

ចំណាយហិរញ្ញប្បទាន ដែលមិនពាក់ព័ន្ធដោយផ្ទាល់លើការទិញ ការសាងសង់ ឬការផលិតទ្រព្យសកម្មដែលមានលក្ខណៈសម្បត្តិត្រូវបានទទួលស្គាល់ជាចំណេញ ឬខាតដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព ។

### (ឋ) ភតិសន្យាប្រតិបត្តិការ

ការទូទាត់ក្រោមភតិសន្យាប្រតិបត្តិការ ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាតក្នុងរបាយការណ៍លទ្ធផលតាមវិធីសាស្ត្ររំលស់ថេរទៅតាមថេរវេលានៃភតិសន្យា ។ ការលើកទឹកចិត្តភតិសន្យាដែលទទួលបាន ត្រូវបានទទួលស្គាល់ជាផ្នែកនៃចំណាយភតិសន្យាតាមថេរវេលានៃភតិសន្យា ។

### (ឌ) ពន្ធលើប្រាក់ចំណេញ

ពន្ធលើប្រាក់ចំណេញរួមមានពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ ។ ពន្ធប្រចាំឆ្នាំ និងពន្ធពន្យារត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាតនៅក្នុងរបាយការណ៍លទ្ធផល លើកលែងតែធាតុណាបានទទួលស្គាល់ដោយផ្ទាល់ក្នុងមូលធន ឬនៅក្នុងរបាយការណ៍លម្អិតផ្សេងៗទៀត ។

#### ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ

ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ គឺជាពន្ធដែលរំពឹងថា ត្រូវបង់ទៅលើប្រាក់ចំណេញជាប់ពន្ធប្រចាំឆ្នាំដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តជាគោលនៅកាលបរិច្ឆេទរបាយការណ៍ និងនិយ័តភាពទាំងឡាយទៅលើពន្ធត្រូវបង់ពីឆ្នាំមុនៗ ។

#### ពន្ធពន្យារ

ពន្ធពន្យារ ត្រូវបានកំណត់ទៅលើភាពលំអៀងជាបណ្តោះអាសន្ន រវាងសមតុល្យយោងនៃទ្រព្យសកម្ម និងបំណុល ក្នុងគោលបំណងនៃការធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងសមតុល្យយោងសម្រាប់ការគិតពន្ធ ។ ពន្ធពន្យារមិនត្រូវបានកំណត់សម្រាប់៖

- ពន្ធពន្យារខុសគ្នាទទួលស្គាល់ដំបូងជាទ្រព្យសកម្ម ឬបំណុល ក្នុងប្រតិបត្តិការវាមិនមែនរួមបញ្ចូលពាណិជ្ជកម្ម និងមិនមានផលប៉ះពាល់ទាំងគណនេយ្យ ឬពន្ធលើប្រាក់ចំណេញ ឬខាតនោះឡើយ ។

# អំពៅផែស្វយ័តភ្នំពេញ

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧**

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ឌ) ពន្ធលើប្រាក់ចំណេញ (ត)

**ពន្ធពន្យារ (ត)**

- ភាពខុសគ្នាជាបណ្តោះអាសន្នទាក់ទងជាមួយការវិនិយោគក្នុងបុត្រសម្ព័ន្ធ ក្រុមហ៊ុនសហគម ការរៀបចំរួមគ្នា ក្នុងលក្ខខណ្ឌឲ្យក្រុមហ៊ុនអាចគ្រប់គ្រងទាំងពេលវេលានៃការចម្រាសមកវិញនៃភាពខុសគ្នាជាបណ្តោះអាសន្ន និងទំនងជាមិនអាចចម្រាសមកវិញ នាពេលអនាគត និង
- ភាពខុសគ្នាជាបណ្តោះអាសន្នកើតឡើងពីការទទួលស្គាល់ជាលើកដំបូងលើកេរ្តិ៍ឈ្មោះ ។

ពន្ធពន្យារជា ទ្រព្យសកម្ម ត្រូវបានទទួលស្គាល់សម្រាប់ការខាតលើពន្ធ និងភាពលំអៀងជាបណ្តោះអាសន្នដែលអាចកាត់ កងបានតែក្នុងករណីអាចនឹងកើតមានឡើងទៅលើប្រាក់ចំណេញជាប់ពន្ធ នាពេលអនាគតដែលអាចប្រើប្រាស់បាន ។ ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យនៅរាល់កាលបរិច្ឆេទរាយការណ៍ ហើយត្រូវបានកាត់បន្ថយ ក្នុងករណីដែលវាមិនអាចកើតឡើងនូវអត្ថប្រយោជន៍ពន្ធដែលពាក់ព័ន្ធដែលអាចនឹងប្រើប្រាស់បាន ។

ពន្ធពន្យារ ត្រូវបានកំណត់ដោយប្រើអត្រាពន្ធដែលរំពឹងថានឹងប្រើទៅលើភាពលំអៀងជាបណ្តោះអាសន្នដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តជាអាទិ៍នៅកាលបរិច្ឆេទរាយការណ៍ ។

ការវាស់វែងពន្ធពន្យារ ឆ្លុះបញ្ចាំងពីលទ្ធផលដែលក្រុមហ៊ុនរំពឹងថា (នាកាលបរិច្ឆេទរាយការណ៍) នឹងមានទទួលមកវិញ ឬការកាត់កងសមតុល្យយោងនៃទ្រព្យសកម្ម និងបំណុល ។

ពន្ធពន្យារជាទ្រព្យសកម្ម និងបំណុល ត្រូវកាត់កងក្នុងករណីដែលបានបំពេញនូវលក្ខណៈវិនិច្ឆ័យមួយចំនួន ។

### (ឍ) ស្តង់ដារថ្មី និងការបកស្រាយថ្មីមិនទាន់អនុវត្ត

ស្តង់ដារ ការបកស្រាយ និង ការកែប្រែ ខាងក្រោមត្រូវបានបោះផ្សាយ ប៉ុន្តែមិនទាន់បានចូលជា ធរមានសម្រាប់ឆ្នាំ ២០១៧ និងមិនទាន់បានអនុវត្តមុនកាលកំណត់នៅឡើយ។ បញ្ជីស្តង់ដារខាងក្រោមនេះមិនបានរួមបញ្ចូលគ្រប់ស្តង់ដារទាំងអស់នោះទេពីព្រោះវាមានតែស្តង់ដារ ការបកស្រាយ និង ការកែប្រែ ដែលអាចនឹងមានផលប៉ះពាល់ទៅលើ របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានពិភាក្សា។ អ្នកគ្រប់គ្រងកំពុងធ្វើការវិភាគលើសក្តានុពលនៃ ផលប៉ះពាល់លើរបាយការណ៍ហិរញ្ញវត្ថុ ដែលកើតឡើងពីការអនុវត្តនៃស្តង់ដាររបាយការណ៍ទាក់ទងនឹង ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ហ.អ.ក") ដែលមានដូចខាងក្រោម ៖

# កំពង់ផែស្វយ័តភ្នំពេញ

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧**

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ឈ) ស្តង់ដារថ្មី និងការស្រាយបំភ្លឺមិនទាន់អនុវត្ត (ត)

#### ស.រ.ហ.អ.ក ១៥ ចំណូលពីកិច្ចសន្យាជាមួយអតិថិជន

ស.រ.ហ.អ.ក ១៥ បង្កើតនូវបរិបទលម្អិតសម្រាប់កំណត់ថាតើចំណូលចំនួនប៉ុន្មាន និងពេលវេលា ត្រូវទទួលស្គាល់ ។ ស.រ.ហ.អ.ក ១៥ ជំនួសការណែនាំអំពីការទទួលស្គាល់ចំណូលដែលមានស្រាប់ ដែលរួមបញ្ចូល ស.គ.អ.ក ១៨ ចំណូល ស.គ.អ.ក ១១ កិច្ចសន្យាសាងសង់ និងគណៈកម្មការបកស្រាយលើរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ("គ.ប.រ.ហ.អ") ១៣ កម្មវិធីសម្រាប់អតិថិជនស្មោះត្រង់ ។

ស.រ.ហ.អ.ក ១៥ មានប្រសិទ្ធភាពអនុវត្តសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំដែលចាប់ផ្តើម ឬបន្ទាប់ពី ថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨ ជាមួយនឹងការអនុញ្ញាតក្នុងការអនុវត្តមុន ។

#### ស.រ.ហ.អ.ក ៩ ឧបករណ៍ហិរញ្ញវត្ថុ

ស.រ.ហ.អ.ក ៩ ឧបករណ៍ហិរញ្ញវត្ថុ ដាក់ចេញនូវតម្រូវការសម្រាប់ការទទួលស្គាល់ និងការវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុ បំណុលហិរញ្ញវត្ថុ និង កិច្ចសន្យាមួយចំនួន ដើម្បីទិញ ឬ លក់ ឧបករណ៍មិនមែនហិរញ្ញវត្ថុ ។ ស.រ.ហ.អ.ក ៩ ឧបករណ៍ហិរញ្ញវត្ថុ ជំនួសឲ្យការណែនាំ ស.គ.អ.ក ៣៩ ឧបករណ៍ហិរញ្ញវត្ថុ - ការទទួលស្គាល់ និងការវាស់វែង ។

ស.រ.ហ.អ.ក ៩ រួមមានការធ្វើចំណាត់ថ្នាក់ និង វិធីសាស្ត្រនៃការវាស់វែងថ្មី សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលឆ្លុះបញ្ចាំងពីទម្រង់ពាណិជ្ជកម្ម ដែលទ្រព្យសកម្មត្រូវបានគ្រប់គ្រង និង ចរិកលក្ខណៈរបស់លំហូរសាច់ប្រាក់។ ស.រ.ហ.អ.ក ៩ រួមមាន ចំណាត់ថ្នាក់ចំបងៗ ចំនួន ៣ បែងចែកសម្រាប់ ទ្រព្យសកម្មហិរញ្ញវត្ថុ៖ វាស់វែង ដោយរំលស់តម្លៃដើម, តម្លៃសមស្រប ដោយភាពលំអៀងត្រូវបានបញ្ចូលទៅក្នុងលទ្ធផលលម្អិតផ្សេងៗ និង តម្លៃសមស្រប ដោយភាពលំអៀងត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍ចំណេញ ឬ ខាត ។ ស្តង់ដារនេះលុបចោលនូវចំណាត់ថ្នាក់ដែលមាននៅក្នុង ស.គ.អ.ក ៣៩ ដូចជាការកាន់កាប់រហូតដល់កាលកំណត់ ឥណទាន និង គណនីត្រូវទទួលសម្រាប់លក់ដែលមានស្រាប់ ។

# អគ្គិសនីកម្ពុជា (sic)

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧

### ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ឈ) ស្តង់ដារថ្មី និងការស្រាយបំភ្លឺមិនទាន់អនុវត្ត (ត)

#### ស.រ.ហ.អ.ក ៩ ឧបករណ៍ហិរញ្ញវត្ថុ (ត)

ស.រ.ហ.អ.ក ៩ ជំនួសឲ្យទម្រង់ "ការខាតបង់កើតឡើង" នៅក្នុង ស.គ.អ.ក ៣៩ ជាមួយនឹងការបន្តឃ្លាំមើល 'ឥណទានដែលរំពឹងថានឹងបាត់បង់' ដែលតម្រូវឲ្យមានការវិនិច្ឆ័យដ៏សំខាន់អំពីការផ្លាស់ប្តូរនៃកត្តាសេដ្ឋកិច្ច ដែលមានផលប៉ះពាល់ 'ឥណទានដែលរំពឹងថានឹងបាត់បង់', ហើយដែលនឹងត្រូវបានកំណត់ដោយមូលដ្ឋានទម្ងន់ប្រហាក់ប្រហែល ។

ទម្រង់ឱនភាពនៃតម្លៃថ្មី នឹង អនុវត្តទៅលើទ្រព្យសកម្មហិរញ្ញវត្ថុ វាស់វែងដោយរំលស់តម្លៃដើម ឬ តម្លៃសមស្រប ដោយភាពលំអៀងត្រូវបានបញ្ចូលទៅក្នុងលទ្ធផលលម្អិតផ្សេងៗ លើកលែងតែការវិនិយោគក្នុងឧបករណ៍មូលធន, និង ទៅលើទ្រព្យសកម្មជាប់កិច្ចសន្យា ។

នៅក្នុង ស.រ.ហ.អ.ក ៩ សំវិធានធនខាតនឹងត្រូវបានវាស់វែងដោយវិធីមួយក្នុងចំណោមវិធីខាងក្រោម៖

- ឥណទានដែលរំពឹងថានឹងបាត់បង់ ក្នុងរយៈពេល ១២ ខែ៖ គឺជាឥណទានដែលលទ្ធផលបានមកពីហេតុការណ៍ឱនភាពដែលអាចកើតឡើងនៅក្នុងរយៈពេល ១២ ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ និង
- ឥណទានដែលរំពឹងថានឹងបាត់បង់ ដែលមិនកំណត់ពេលវេលា៖ គឺជាឥណទានដែលលទ្ធផលបានមកពីហេតុការណ៍ឱនភាពទាំងអស់ដែលអាចកើតមានឡើងហើយ មិនកំណត់ពេលវេលានៃឧបករណ៍ហិរញ្ញវត្ថុ ។

ការវាស់វែងឥណទានដែលរំពឹងថានឹងបាត់បង់ ដែលមិនកំណត់ពេលវេលា ត្រូវបានយកមកអនុវត្ត ប្រសិនបើហានិភ័យឥណទានរបស់ទ្រព្យសកម្មហិរញ្ញវត្ថុដែលនាថ្ងៃកាលបរិច្ឆេទរាយការណ៍បានកើនឡើងខ្លាំងចាប់តាំងពីការទទួលស្គាល់ លើកដំបូង ប្រសិនបើផ្ទុយពីនេះ ការវាស់វែងឥណទានដែលរំពឹងថានឹងបាត់បង់ ក្នុងរយៈពេល ១២ ខែត្រូវបានយកមកអនុវត្ត ។ អង្គភាពមួយ អាចកំណត់ ហានិភ័យឥណទានទៅលើទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនកើនឡើងខ្លាំង ប្រសិនបើទ្រព្យសកម្មហិរញ្ញវត្ថុមានហានិភ័យឥណទានទាបនាថ្ងៃកាលបរិច្ឆេទរាយការណ៍ ។ ទោះបីជាយ៉ាងណាក៏ដោយ ការវាស់វែងឥណទានដែលរំពឹងថានឹងបាត់បង់ដែលមិនកំណត់ពេលវេលា តែងតែត្រូវបានយកមកអនុវត្តសំរាប់គណនីអតិថិជន និង គណនីត្រូវទទួលផ្សេងៗដោយគ្មានសមាសភាគហិរញ្ញវត្ថុធំបង ។

ស.រ.ហ.អ.ក ៩ មានប្រសិទ្ធភាពអនុវត្តសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំដែលចាប់ផ្តើម ឬបន្ទាប់ពី ថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨ ជាមួយនឹងការអនុញ្ញាតក្នុងការអនុវត្តមុន ។

# អំពាន់វៃផស្វយ័តភ្នំពេញ

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧**

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ឍ) ស្តង់ដារថ្មី និងការស្រាយបំភ្លឺមិនទាន់អនុវត្ត (ត)

**ស.រ.ហ.អ.ក ១៦ ភតិសន្យា**

ស.រ.ហ.អ.ក ១៦ ណែនាំតែមួយគត់ លើទម្រង់ក្នុងការកត់ត្រាលើរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនៃភតិសន្យាសម្រាប់អ្នកជួល ។ អ្នកជួល ទទួលស្គាល់សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ដែលតំណាងដោយសិទ្ធិរបស់ខ្លួនក្នុងការប្រើប្រាស់ទ្រព្យសកម្ម និងបំណុលភតិសន្យា ដែលតំណាងដោយកាតព្វកិច្ចរបស់ខ្លួនដើម្បីទូទាត់ភតិសន្យានោះ ។ មានជម្រើសលើកលែងមួយចំនួនសម្រាប់ ភតិសន្យារយៈពេលខ្លី និងភតិសន្យាលើវត្ថុដែលមានតម្លៃទាប ។ បញ្ជីគណនេយ្យរបស់ភតិបតី នៅក្បែរស្រដៀងគ្នាទៅនឹងស្តង់ដារនាពេលបច្ចុប្បន្ន គឺភតិបតីបន្តចាត់ថ្នាក់ភតិសន្យា ជាភតិសន្យាហិរញ្ញវត្ថុ ឬភតិសន្យាប្រតិបត្តិការ ។

ស.រ.ហ.អ.ក ១៦ ជំនួសឲ្យការណែនាំដែលមានស្រាប់លើភតិសន្យា ដោយរួមបញ្ចូល ស.គ.អ.ក ១៧ ភតិសន្យា និងគ.ប.រ.ហ.អ ៤ លើការកំណត់សមាសភាពនៃកិច្ចព្រមព្រៀង និងគណៈកម្មការបកស្រាយស្តង់ដារ (គ.ប.ស) ១៥ លើភតិសន្យាប្រតិបត្តិការ ស្តីពីការលើកទឹកចិត្ត និងគ.ប.ស ២៧ លើការវាយតម្លៃលើខ្លឹមសាររបស់ប្រតិបត្តិការដែលទាក់ទងទៅនឹងទម្រង់គតិយុត្តិរបស់ភតិសន្យា ។

ស.រ.ហ.អ.ក នេះមានប្រសិទ្ធភាពអនុវត្តសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំដែលចាប់ផ្តើម ឬបន្ទាប់ពី ថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៩ ។ ការអនុវត្តមុនត្រូវបានអនុញ្ញាត សម្រាប់អង្គភាពដែលអនុវត្ត ស.រ.ហ.អ.ក ១៥ ចំណូលពីកិច្ចសន្យាជាមួយអតិថិជន នៅពេល ឬមុនពេលកាលបរិច្ឆេទនៃការអនុវត្តជាលើកដំបូងនៃ ស.រ.ហ.អ.ក ១៦ ។

### (ណ) ការរាយការណ៍តាមចំណែក

ចំណែកប្រតិបត្តិការ ត្រូវបានរាយការណ៍ ឲ្យស្របទៅនឹងរបាយការណ៍ផ្ទៃក្នុង ដែលដាក់ជូនអ្នកសម្រេចចិត្តរបស់ក្រុមហ៊ុន ។ អ្នកគ្រប់គ្រងសំខាន់ៗ គឺជាអ្នកទទួលខុសត្រូវលើការបែងចែកធនធាន និងវាយតម្លៃការអនុវត្តប្រតិបត្តិការរបស់ក្រុមហ៊ុន ។ ក្រុមហ៊ុនធ្វើប្រតិបត្តិការលើចំណែកប្រតិបត្តិការតែមួយតែមួយគឺអាជីវកម្មដែលពាក់ព័ន្ធនឹងកំពង់ផែ ។

## កំពង់ផែស្វយ័តភ្នំពេញ

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧**

### ៤. ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិកទៅជាប្រាក់រៀល

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាដុល្លារអាមេរិក ។ ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិកទៅជាប្រាក់រៀល ត្រូវបានធ្វើឡើងដើម្បីឲ្យស្របទៅតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ។

ទ្រព្យសកម្ម និងបំណុល ត្រូវបានប្រែសម្រួលដោយប្រើអត្រាប្តូរប្រាក់នៅចុងការិយបរិច្ឆេទ ហើយគណនីដើមទុន បុព្វលាភភាគហ៊ុន និងមូលធនផ្សេងៗ ត្រូវបានប្រែសម្រួលដោយប្រើអត្រាប្តូរប្រាក់ប្រវត្តិសាស្ត្រដំបូង ។ របាយការណ៍លទ្ធផល និងរបាយការណ៍លំហូរទឹកប្រាក់ ត្រូវបានប្រែសម្រួលទៅជាប្រាក់រៀលដោយប្រើប្រាស់អត្រាប្តូរប្រាក់មធ្យមប្រចាំឆ្នាំ ។ លម្អៀងលើអត្រាប្តូរប្រាក់ ពីការប្រែសម្រួល ត្រូវបានទទួលស្គាល់ជា "លម្អៀងពីការប្តូររូបិយប័ណ្ណ" នៅក្នុងលទ្ធផលលម្អិតផ្សេងៗ ។

ក្រុមហ៊ុនប្រើអត្រាប្តូរប្រាក់ផ្លូវការនៅចុងការិយបរិច្ឆេទ និងអត្រាប្តូរប្រាក់មធ្យមផ្លូវការ ដូចខាងក្រោម ៖

| ឆ្នាំសារពើពន្ធដែលបានបញ្ចប់ | | | អត្រាប្តូរប្រាក់ចុងការិយបរិច្ឆេទ | អត្រាប្តូរប្រាក់មធ្យម |
|---|---|---|---|---|
| ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ | ១ដុល្លារអាមេរិក | = | ៤.០៣៧ | ៤.០៤៥ |
| ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦ | ១ដុល្លារអាមេរិក | = | ៤.០៣៧ | ៤.០៥៣ |

ការប្រែសម្រួលនេះ មិនគួរត្រូវបានយកមកបកស្រាយថាតួលេខ ប្រាក់ដុល្លារអាមេរិកនេះ ត្រូវបានប្តូរទៅជាប្រាក់រៀល ឬគួរតែត្រូវបានប្តូរជាប្រាក់រៀល ឬនឹងត្រូវបានប្តូរជាប្រាក់រៀល នាពេលអនាគតតាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតនោះឡើយ ។

## កំពង់ផែស្វយ័តភ្នំពេញ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧

### ៥. ទ្រព្យ ពេទចក្រ និងបរិក្ខារ

| ២០១៧ | ដីធ្លី<br>ដុល្លារអាមេរិក | ចំណតនាវា<br>និងអគារ<br>ដុល្លារអាមេរិក | គ្រឿងចក្រ<br>និងម៉ាស៊ីន<br>ដុល្លារអាមេរិក | គ្រឿងសង្ហារឹម<br>និងគ្រឿងបំពាក់<br>ដុល្លារអាមេរិក | កុំព្យូទ័រ<br>ដុល្លារអាមេរិក | សម្ភារការិយាល័យ<br>និងផ្សេងៗ<br>ដុល្លារអាមេរិក | យានយន្ត<br>ដុល្លារអាមេរិក | ទ្រព្យកំពុងបង្កើត<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|---|---|---|---|---|---|
| **ថ្លៃដើម** | | | | | | | | | |
| នាថ្ងៃទី ១ ខែមករា ឆ្នាំ ២០១៧ | ៩៦.២៧៦.៦៨១ | ៣៨.៧៧៦.១០១ | ១១.៩៣២.៥២៥ | ៥៦.៨៨២ | ៥៩២.១៥៥ | ៥៤៧.០០៧ | ១.៣១៨.១៤៧ | ៦.០៥៤.៣៨០ | ១៥៥.៥៥៤.៨៦៨ |
| ការទិញបន្ថែម | - | ៤៧.៤៣១ | ១៣០.០៧១ | - | ៦.២៨៦ | ១០.៧៤០ | ៤៨.៦០១ | ២.៧៨៦.០១១ | ៣.០២៩.២៨០ |
| ផ្ទេរទៅទ្រព្យវិនិយោគ | ៨៦០.៦៦៦ | ២៥៨.៦០០ | ៧.៣៧១.១៤៤ | ៧.៩៧៥ | ៣៩.១៣៨ | ៤០.២១៨ | - | (៨.៥៧២.៦១១) | - |
| នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៧ | ៩៧.១៣៧.៣៤៧ | ៣៩.០៨២.១៣២ | ១៩.៤៣៣.៧៤០ | ៦៤.៨១៧ | ៦៣៧.៦១៩ | ៥៩៨.០០៥ | ១.៣៦៦.៧៤៨ | ២៦៧.៧៨០ | ១៥៨.៥៨៤.១៥៨ |
| **ដក: រំលស់បង្គរ** | | | | | | | | | |
| នាថ្ងៃទី ១ ខែមករា ឆ្នាំ ២០១៧ | - | ៦.២៨៧.៨១១ | ៣.១៣៤.២៨៦ | ៤២.៣៧៦ | ៤៤២.៦៩៤ | ១៦៧.៨១៩ | ៣២៣.៨៤០ | - | ១០.៩០២.៩៧៦ |
| រំលស់ក្នុងឆ្នាំ | - | ១.២៩៤.១២៦ | ១.៣០០.៣៩៣ | ៦.៤០៨ | ៨៤.១០៦ | ៤៩.៥៤៨ | ៩៦.០៨៥ | - | ២.៤៣០.៦៦៥ |
| នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៧ | - | ៧.៥៨១.៩៣៧ | ៤.៤៣៤.៦៧៩ | ៤៨.៧៨៤ | ៥២៦.៨០០ | ២១៧.៣៦៧ | ៤១៩.៩២៥ | - | ១៣.៣៣៣.៦៤១ |
| **សមតុល្យយោង** | | | | | | | | | |
| នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៧ | ៩៧.១៣៧.៣៤៧ | ៣១.៥០០.១៩៥ | ១៤.៩៩៥.០៥១ | ១៦.០៣៣ | ១១០.៨១៩ | ៣៨០.៦៣៨ | ៩៤៦.៧៨៣ | ២៦៧.៧៨០ | ១៤៥.៣៥០.០១៧ |
| សរុបជាប់រៀល(កំណត់សម្គាល់ ៤) | ៣៩២.១៥៣.៨៧០ | ១២៧.១៦៧.៨០២ | ៦០.៥៣៥.០២១ | ៦៤.៧២៥ | ៤៤៧.៣៧៦ | ១.៥៣៦.៦៣៦ | ៣.៨២២.១៦៧ | ១.០៨០.៩០៧ | ៥៨៦.៧៩៤.២០៨ |

# គំពង់ផែស្វយ័តភ្នំពេញ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧

## ៥. ទ្រព្យ រោងចក្រ និងបរិក្ខារ (ត)

| ២០១៦ | ដីធ្លី | ចំណតនាគារ និងអាគារ | គ្រឿងចក្រ និងម៉ាស៊ីន | គ្រឿងសង្ហារឹម និងគ្រឿងបំពាក់ | កុំព្យូទ័រ | សម្ភារការិយាល័យ និងផ្សេងៗ | យានយន្ត | ទ្រព្យកំពុងបង្កើត | សរុប |
|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **ថ្លៃដើម** | | | | | | | | | |
| នាថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៦ | ៨៥.៧៦២.៨២៧ | ៣៤.៩៣១.៣៥៦ | ១១.២៥៥.៦០៧ | ៥៦.៨៩២ | ៥៣៩.១១៧ | ៥០៥.៨៩១ | ១.៣១៧.៨០៩ | ២៣៩.៧៤២ | ១៣៤.៦០៩.២៤១ |
| ការទិញបន្ថែម | ៥១៣.៨២២ | ៣១៣.៦៦៧ | ៣៥.៨០៥ | - | ២៥.៩៤០ | ៣០.៥០៩ | - | ៦.៥៨១.២៧៦ | ៧.៥០០.០១៩ |
| ផ្ទេរទៅទ្រព្យវិនិយោគ | - | ៣១.៩១៨ | ៦៣២.៨៥៥ | - | ៤៣.៥២៩ | ១៩.២០០ | - | (៧៦៧.៦៣៨) | (៤០.១៣៦) |
| ការលុបចោល | - | - | (១.០០០) | - | (១៧.១០០) | (៨.១១៤) | - | - | (២៦.២១៤) |
| ការធ្វើចំណាត់ថ្នាក់ជាថ្មី | - | ១៦០ | ៩.២១៧ | - | ៦៩៩ | ៥៧១ | ៣៣៨ | - | ១០.៩៨៥ |
| នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦ | ៨៦.២៧៦.៦៤៩ | ៣៥.២៧៧.១០១ | ១១.៩៣២.៤៨៤ | ៥៦.៨៩២ | ៥៩២.១៨៥ | ៥៤៨.០៥៧ | ១.៣១៨.១៤៧ | ៦.០៥៤.៣៨០ | ១៤២.០៥៥.៨៩៥ |
| **ដក: រំលស់បង្គរ** | | | | | | | | | |
| នាថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៦ | - | ៥.០០៣.២៦៧ | ២.៣៤៧.៩៩២ | ៣៤.៩៧៨ | ៣៨៨.៥៥៩ | ១២៧.០៣៨ | ២២៨.៨០៧ | - | ៨.១៣០.៦៤១ |
| រំលស់ក្នុងឆ្នាំ | - | ១.២៨៣.៣៨៣ | ៧៨៩.៨២៩ | ៧.៤០២ | ១០២.៨៥៦ | ៨៨.១៦៣ | ៩៤.៧៣៨ | - | ២.៣៦៦.៣៧១ |
| ការលុបចោល | - | - | (៩៥០) | - | (៩.០២០) | (៣.៩៨៧) | - | - | (១៣.៩៥៧) |
| ការធ្វើចំណាត់ថ្នាក់ជាថ្មី | - | ៨០១ | ១.០៧៥ | - | ៦៩៩ | ៥៧១ | ៣៣៨ | - | ៣.៤៨៤ |
| នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦ | - | ៦.២៨៧.៤៥១ | ៣.១៣៧.៩៤៦ | ៤២.៣៨០ | ៤៨៣.០៩៤ | ២១១.៧៨៥ | ៣២៣.៨៨៣ | - | ១០.៤៨៦.៥៣៩ |
| **តម្លៃសុទ្ធចុះបញ្ជី** | | | | | | | | | |
| នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦ | ៨៦.២៧៦.៦៤៩ | ២៨.៩៨៩.៦៥០ | ៨.៧៩៤.៥៣៨ | ១៤.៥១២ | ១០៩.០៩១ | ៣៣៦.២៧២ | ៩៩៤.២៦៤ | ៦.០៥៤.៣៨០ | ១៣១.៥៦៩.៣៥៦ |
| សរុបពាន់រៀល (កំណត់សម្គាល់ ៤) | ៣៤៨.៦៦៨.៦៦១ | ១១៧.១៦០.៦៧៨ | ៣៥.៥០២.៣០២ | ៥៨.៣៨៨ | ៤៤០.៤៤៥ | ១.៣៥៧.៤៧៦ | ៤.០១៣.៨៥៦ | ២៤.៤៣៧.៦៨០ | ៥៣១.១៨៦.៣៥៥ |

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧

### ៥. ទ្រព្យ រោងចក្រ និងបរិក្ខារ (ត)

រំលស់ទ្រព្យ រោងចក្រ និងបរិក្ខារ ត្រូវបានបែងចែកដូចខាងក្រោម៖

| | ការិយបរិច្ឆេទប្រចាំឆ្នាំ ដែលបានបញ្ចប់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ | | ការិយបរិច្ឆេទប្រចាំឆ្នាំ ដែលបានបញ្ចប់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) |
| ថ្លៃដើមនៃការលក់ និងសេវាកម្ម (កំណត់សម្គាល់ ១៥) | ២.៥០៨.៨៥៨ | ១០.១៤៨.៣៣១ | ១.៩៩៦.៩៤៩ | ៨.០៧៧.៤៤៣ |
| ចំណាយរដ្ឋបាលទូទៅ និងការលក់ | ៣២១.៨០៧ | ១.៣០១.៧០៩ | ៣២៤.៥៧៩ | ១.៣៣១.៧១០ |
| | ២.៨៣០.៦៦៥ | ១១.៤៥០.០៤០ | ២.៣២១.៥២៨ | ៩.៤០៩.១៥៣ |

### ៦. ទ្រព្យវិនិយោគ

| | នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ | | នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) |
| **ថ្លៃដើម** | | | | |
| នាថ្ងៃទី ១ ខែ មករា | ៤.៨១១.៧០៦ | ៣៥.៥៧២.៨៥៧ | ៤.១២៩.៣១២ | ៣២.៨១៤.០៣៣ |
| ការទិញបន្ថែម | ១.៨៩៣ | ៧.៥៥៧ | ៥៥១.៦៧៥ | ២.២៣៥.៩៤២ |
| ផ្ទេរពីទ្រព្យ រោងចក្រ និងបរិក្ខារ | - | - | ១៤០.០៩៥ | ៥៦៧.៤០៥ |
| ការធ្វើចំណាត់ថ្នាក់ជាថ្មី | - | - | (៩.៣៧៦) | (៣៤.០០៥) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (១៥) | - | (១០.៥១៨) |
| នាថ្ងៃទី ៣១ ខែ ធ្នូ | ៤.៨១៣.៥៩៩ | ៣៥.៥៨០.៣៩៩ | ៤.៨១១.៧០៦ | ៣៥.៥៧២.៨៥៧ |
| **ដក: រំលស់បង្គរ** | | | | |
| នាថ្ងៃទី ១ ខែ មករា | ២៧៦.៣៨៦ | ១.១១៥.៧៨០ | ២២១.៦៥៩ | ៨៩៤.៨៤៧ |
| រំលស់ក្នុងឆ្នាំ | ៦៣.៥១០ | ២៥៦.៧៨៤ | ៥៦.៦០៣ | ២២៩.០១២ |
| ការធ្វើចំណាត់ថ្នាក់ជាថ្មី | - | - | (១.៨៧៦) | (៧.៦០៣) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (៥០៤) | - | (៤៧៦) |
| នាថ្ងៃទី ៣១ ខែ ធ្នូ | ៣៣៩.៨៩៦ | ១.៣៧២.០៦០ | ២៧៦.៣៨៦ | ១.១១៥.៧៨០ |
| **សមតុល្យយោង** | | | | |
| នាថ្ងៃទី ៣១ ខែ ធ្នូ | ៤.៤៧៣.៧០៣ | ៣៤.២០៨.៣៣៩ | ៤.៥៣៥.៣២០ | ៣៤.៤៥៧.០៧៧ |

## កំពង់ផែស្វយ័តភ្នំពេញ

### កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
### សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧

### ៧. គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ

| | នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ | | នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) |
| គណនីអតិថិជន | ២.៥១១.៧៥៩ | ១០.១៣៩.៩៧១ | ២.០៦៨.៩៤២ | ៨.៣៥២.៣១៩ |
| ប្រាក់កក់ ប្រាក់បង់មុន និងផ្សេងៗ | ៤៩៧.៥៤៩ | ២.០០៤.៦០៥ | ៦៨៨.៨១២ | ២.៧៨០.៧៣៨ |
| ឥណទានផ្តល់ដល់បុគ្គលិក(*) | - | - | ១៧៧.០២៧ | ៧១៤.៦៥៤ |
| | ៣.០០៩.៣០៨ | ១២.១៤៤.៥៧៦ | ២.៩៣៤.៧៨១ | ១១.៨៤៧.៧១១ |

(*) នេះគឺជាឥណទានផ្តល់ដល់បុគ្គលិកដើម្បីទិញភាគហ៊ុនរបស់ក្រុមហ៊ុនក្នុងអំឡុងពេល សំណើរលក់មូលបត្រជាសាធារណៈជាបឋម។ ឥណទានដែលផ្តល់ដល់បុគ្គលិកនេះ គឺពុំមានគិតការប្រាក់ឡើយ និងត្រូវសងត្រឡប់មកវិញតាមចំនួនស្មើគ្នារៀងរាល់ខែក្នុងរយៈពេល ២៤ ខែ។

តម្លៃសមស្របនៃឥណទានផ្តល់ដល់បុគ្គលិក គឺផ្អែកទៅលើលំហូរសាច់ប្រាក់ដែលត្រូវបានធ្វើការអប្បហារ ដោយប្រើប្រាស់អត្រាការប្រាក់ជាក់ស្តែង ១២% ក្នុង ១ ឆ្នាំ។ អ្នកគ្រប់គ្រងបានធ្វើការវាយតម្លៃថា អត្រាការប្រាក់ ១២% គឺជាអត្រាសមស្របមួយដែលសមមូលនឹងអត្រាការប្រាក់នៃឥណទានប្រាក់រៀលរយៈពេល ២ ឆ្នាំ ដែលបុគ្គលិកអាចទទួលបានពីធនាគារពាណិជ្ជ។

### ៨. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

| | នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ | | នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) |
| សាច់ប្រាក់ក្នុងធនាគារ | ១១.៧១៤.១២៩ | ៤៧.២៨៩.៩៣៩ | ៦.៧៤៦.៥៨៦ | ២៧.២៣៥.៩៦៨ |
| សាច់ប្រាក់ក្នុងដៃ | ៣.៨១៥ | ១៥.៤០១ | ៤.៩០៣ | ១៩.៧៩៣ |
| | ១១.៧១៧.៩៤៤ | ៤៧.៣០៥.៣៤០ | ៦.៧៥១.៤៨៩ | ២៧.២៥៥.៧៦១ |

## កំពង់ផែស្វយ័តភ្នំពេញ

### កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
### សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧

### ៩. ដើមទុន និងបុព្វលាភភាគហ៊ុន

| | នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ | | នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) |
| ចុះបញ្ជី បែងចែក និងបានបង់ | ១១៤.៤៥៣.៤៨៥ | ៤៥៧.៨១៣.៩៤០ | ១១៤.៤៥៣.៤៨៥ | ៤៥៧.៨១៣.៩៤០ |

ដើមទុនរបស់ក្រុមហ៊ុនចំនួន ១១៤.៤៥៣.៤៨៥ ដុល្លារអាមេរិក ចែកជា ១១៤.៤៥៣.៤៨៥ ហ៊ុន ដោយមានតម្លៃ ៤.០០០ រៀល ក្នុងមួយហ៊ុន (សមមូលទៅនឹង ១ ដុល្លារអាមេរិក) ហើយត្រូវបានបែងចែកជា ៣ ថ្នាក់ ដូចខាងក្រោម៖

- ភាគហ៊ុនប្រភេទ "ក" (ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត) ចំនួន ៤.១៣៦.៨៧៣ (ស្មើនឹង ៣.៦១% នៃចំនួនហ៊ុនសរុប) ដែលមានតម្លៃ ៤.១៣៦.៨៧៣ ដុល្លារអាមេរិក (សមមូលទៅនឹង ១៦.៥៤៧.៤៩២ ពាន់រៀល) ។
- ភាគហ៊ុនប្រភេទ "ខ" (ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត) ចំនួន ១៦.៥៤៧.៤៩២ (ស្មើនឹង ១៤.៤៦% នៃចំនួន ហ៊ុនសរុប) ដែលមានតម្លៃ ១៦.៥៤៧.៤៩២ ដុល្លារអាមេរិក (សមមូលទៅនឹង ៦៦.១៨៩.៩៦៨ ពាន់រៀល) ។
- ភាគហ៊ុនប្រភេទ "គ" (ភាគហ៊ុនដែលគ្មានសិទ្ធិបោះឆ្នោត) ចំនួន ៩៣.៧៦៩.១២០ (ស្មើនឹង ៨១.៩៣% នៃចំនួនហ៊ុនសរុប) ដែលមានតម្លៃ ៩៣.៧៦៩.១២០ ដុល្លារអាមេរិក (សមមូលទៅនឹង ៣៧៥.០៧៦.៤៨០ ពាន់រៀល) ។

|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | % | ពាន់រៀល | % |
| ចំណូលលើកដាក់ក្រោមដងយោង (Stevedoring) | ៧.៧៣៧.៤៦៩ | ៣១.២៩៨.០៦២ | ៦.៧១០.០៣៧ | ២៧.១៩៥.៧៨០ | ១.០២៧.៤៣២ | ១៥,៣១% | ៤.១០២.២៨២ | ១៥,០៨% |
| ចំណូលលើកដាក់លើទីលាន(LOLO) | ៦.៥៩៨.១០៩ | ២៦.៦៨៩.៣៥១ | ៥.៣៥៣.៩២៩ | ២១.៦៩៩.៤៧៤ | ១.២៤៤.១៨០ | ២៣,២៤% | ៤.៩៨៩.៨៧៧ | ២៣,០០% |
| ចំណូលពីកិច្ចការផែ | ៣.១៦៥.៦១៩ | ១២.៨០៤.៩២៩ | ២.៨៧៤.៣០០ | ១១.៦៤៩.៥៣៨ | ២៩១.៣១៩ | ១០,១៤% | ១.១៥៥.៣៩១ | ៩,៩២% |
| ចំណូលពីថ្លៃឈ្នួលស្តុកទំនិញ/កុងតឺន័រ | ៤២៦.០៧៣ | ១.៧២៣.៤៦៥ | ៤៧៨.៤៥៨ | ១.៩៣៩.១៩០ | (៥២.៣៨៥) | -១០,៩៥% | (២១៥.៧២៥) | -១១,១២% |

- ចំណូលលើកដាក់ក្រោមដងយោង (Stevedoring) : បានកើនឡើងចំនួន ៤.១០២.២៨២ ពាន់រៀល (១.០២៧.៤៣២ដុល្លារអាមេរិក) ឬស្មើនឹង ១៥,០៨% ពី២៧.១៩៥.៧៨០ពាន់រៀល (៦.៧១០.០៣៧ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៦ ដល់ ៣១.២៩៨.០៦២ពាន់រៀល (៧.៧៣៧.៤៦៩ ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៧។ ការកើនឡើង ចំណូលនេះដោយសារតែកំណើនកុងតឺន័រឆ្លងកាត់ដែលមានចំនួន ៣៣.០២៤TEUs ឬស្មើនឹង ២១,៧៦% និងកំណើនទំនិញរាយដែលមានចំនួន ៥៣.៨០៦តោន ឬស្មើនឹង ១២% សម្រាប់ឆ្នាំ២០១៧។ អត្រាកើនឡើងនៃចំណូលលើកដាក់ក្រោមដងយោង មានអត្រាទាបជាងកំណើនចំនួនកុងតឺន័រឆ្លងកាត់(TEUs) ដោយសារតែ ក.ស.ភ. ផ្តល់ជូននូវអត្រាតម្លៃពិសេសជូនក្រុមហ៊ុនដឹកជញ្ជូន នៅពេលដែលចំនួនកុងតឺន័រឆ្លងកាត់(TEUs) របស់ក្រុមហ៊ុននីមួយៗកើនទៅដល់កម្រិតមួយដែលបានកំណត់ទុកដោយ ក.ស.ភ.។

- ចំណូលលើកដាក់នៅទីលាន(LOLO): បានកើនឡើងចំនួន ៤.៩៨៩.៨៧៧ពាន់រៀល (១.២៤៤.១៨០ដុល្លារអាមេរិក) ឬស្មើនឹង ២៣% ពី ២១.៦៩៩.៤៧៤ពាន់រៀល (៥.៣៥៣.៩២៩ ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៦ ដល់ ២៦.៦៨៩.៣៥១ពាន់រៀល (៦.៥៩៨.១០៩ ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៧។ ការកើនឡើងចំណូលនេះបណ្តាលមកពីកំណើនកុងតឺន័រឆ្លងកាត់ដែលមានចំនួន ៣៣.០២៤TEUs ឬស្មើនឹង ២១,៧៦% បើធៀបនឹងឆ្នាំ២០១៦។ លើសពីនេះ ក.ស.ភ. បានផ្តល់នូវសេវាកម្មថ្មីមួយកាលពីដើមខែសីហា ឆ្នាំ២០១៦ គឺ ***សេវាកម្មលើកដាក់ស្កេនកុងតឺន័រ*** ដើម្បីត្រួតពិនិត្យទំនិញនៅទីលានកុងតឺន័រ។ សេវាកម្មថ្មីនេះ

ទទួលបានចំណូលសរុបចំនួន ៥០៥.៦០០ដុល្លារអាមេរិក ដែលបានបូកបញ្ចូលនៅក្នុងចំណូលលើកដាក់លើទីលាន សម្រាប់ឆ្នាំ២០១៧។

- ចំណូលពីកិច្ចការផែ (Port dues &charge): គឺអាស្រ័យលើចំនួននាវា និងចំណុះផ្ទុកនាវាដែលឆ្លងកាត់ ក.ស.ភ.។ ចំណូលពីកិច្ចការផែ បានកើនឡើងចំនួន ១.១៥៥.៣៩១ពាន់រៀល (២៩១.៣១៩ដុល្លារអាមេរិក) ឬស្មើនឹង៩,៩២% ពី ១១.៦៤៩.៥៣៨ (២.៨៧៤.៣០០ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៦ ដល់ ១២.៨០៤.៩២៩ពាន់រៀល (៣.១៦៥.៦១៩ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៧។ កត្តាចំបងនៃការកើនឡើងចំណូលនេះ គឺដោយសារតែការផ្លាស់ប្តូររបៀបនៃការគណនាចំណុះផ្ទុកនាវា (GRT) គឺក.ស.ភ. បានគណនាដោយផ្អែកទៅតាមចំណុះនាវា (GRT) ណាដែលមានចំនួនខ្ពស់ជាងគេរវាងវិញ្ញាបនបត្របញ្ជាក់ទម្ងន់អន្តរជាតិ និងវិញ្ញាបនបត្រចុះបញ្ជីរបស់នាវាដែលក្រុមហ៊ុនបានផ្ញើមក ក.ស.ភ. ។ ជាមួយគ្នានេះដែរ ក្នុងឆ្នាំ២០១៧ ចំនួននាវាឆ្លងកាត់មានការធ្លាក់ចុះចំនួន ០៣ជើង ឬស្មើនឹង ០,១៨% ដោយសារតែក្រុមហ៊ុនដឹកជញ្ជូនកុងតឺន័រខ្លះបានកាត់បន្ថយជើងនាវា ប៉ុន្តែចំណុះផ្ទុកនាវា(GRT) មានទំហំធំជាងមុន ដូចជាករណីក្រុមហ៊ុនដឹកជញ្ជូនកុងតឺន័រថ្មីមួយ ដែលមានចំណុះផ្ទុកនាវារហូតដល់ ១.៩២៥ ដែលមានចំនួន ៥០ជើង។

- ចំណូលពីថ្លៃឈ្នួលស្តុកទំនិញ/កុងតឺន័រមានការថយចុះចំនួន ២១៥.៧២៥ ពាន់រៀល (៥២.៣៨៥ដុល្លារអាមេរិក) ឬស្មើនឹង១១,១២% ពី ១.៩៣៩.១៩០ ពាន់រៀល (៤៧៨.៤៥៨ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៦ ទៅ ១.៧២៣.៤៦៥ ពាន់រៀល (៤២៦.០៧៣ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៧។ ជាមួយគ្នានេះដែរ គឺដោយសារមានការជួយសម្រួលដល់អតិថិជនលើការលើកដាក់ ដើម្បីយកកុងតឺន័រទៅស្តែន ដោយក.ស.ភ. គិតលើសេវាកម្មលើកដាក់ស្តែនកុងតឺន័រ។ បន្ទាប់មកយកកុងតឺន័រដែលស្តែនរួចទៅស្តុកទុកនៅទីតាំងផ្សេងពីទីលានស្តុកដែល ក.ស.ភ. គិតលើថ្លៃស្តុកឃ្លាំង។ ដូចនេះទើបបណ្តាលឲ្យ ចំណូលដែលបានមកពីស្តុកឃ្លាំងរបស់ ក.ស.ភ. មានការថយចុះ តែមានការកើនឡើងចំណូលលើកដាក់នៅទីលាន ដែលក្នុងនោះមានចំណូលលើសេវាកម្មលើកដាក់ស្តែនកុងតឺន័រ ។

## ខ.ការវិភាគតំលាតប្រាក់ចំណេញដុល

ប្រាក់ចំណេញដុលត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាត របស់ ក.ស.ភ. ដែលបានមកពីចំណូលសរុបនៃផលអាជីវកម្ម និងសេវាកម្ម ដកនឹងចំណាយថ្លៃដើមនៃសេវាកម្ម (ចំណាយប្រតិបត្តិការ)។ ក.ស.ភ.សូមលើកយកចំណាយថ្លៃដើមនៃសេវាកម្មដែលសំខាន់ៗ ដើម្បីយកមកវិភាគដូចខាងក្រោម÷

ដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ប្រៀបធៀបនឹងដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

| បរិយាយ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៧ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៦ | | បំរែបំរួល | | បំរែបំរួល | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | % | ពាន់រៀល | % |
| **ចំណូល** | **១៨.៨៥៦.២៩៦** | **៧៦.២៧៣.៧១៧** | **១៦.៣០០.៤២២** | **៦៦.០៦៥.៦១០** | **២.៥៥៥.៨៧៤** | **១៥,៦៨%** | **១០.២០៨.១០៧** | **១៥,៤៥%** |
| **ថ្លៃដើមនៃសេវាកម្ម** | | | | | | | | |
| វំលស់ទ្រព្យពោងចក្រ បរិក្ខារ | ២.៥០៨.៨៥៨ | ១០.១៤៨.៣៣១ | ១.៩៩២.៩៥៤ | ៨.០៧៧.៤៤៣ | ៥១៥.៩០៤ | ២៥,៨៩% | ២.០៧០.៨៨៨ | ២៥,៦៤% |
| ថ្លៃដងយោង | ១.៥១៥.៩៣៨ | ៦.១៣១.៩៦៩ | ១.៣៧០.៨១៤ | ៥.៥៥៥.៩០៩ | ១៤៥.១២៤ | ១០,៥៩% | ៥៧៦.០៦០ | ១០,៣៧% |
| ប្រាក់បៀវត្ស និងប្រាក់ឈ្នួល | ១.១៩៨.០០១ | ៤.៨៤៥.៩១៤ | ១.០៦០.៩១១ | ៤.២៩៩.៨៧២ | ១៣៧.០៩០ | ១២,៩២% | ៥៤៦.០៤២ | ១២,៧០% |
| ប្រេងឥន្ទនៈ(ប្រតិបត្តិការ និងបូមស្ការ ប្រឡាយនាវាចរណ៍) | ៦០៨.៤៧៨ | ២.៤៦១.២៩៤ | ៣០៩.៩៧៥ | ១.២៥៦.៣២៩ | ២៩៨.៥០៣ | ៩៦,៣០% | ១.២០៤.៩៦៥ | ៩៥,៩១% |
| ការជួសជុល និងថែទាំ | ៣៨៤.២៩៤ | ១.៥៥៤.៤៦៩ | ៥៣៦.៧៤៦ | ២.១៧៥.៤៣២ | (១៥២.៤៥២) | -២៨,៤០% | (៦២០.៩៦៣) | -២៨,៥៤% |
| ចំណាយលើការគ្រប់គ្រងអាជីវកម្មខ្សាច់ | ៣៨.៥០៧ | ១៥៥.៧៦១ | ១៨៣.៧១៣ | ៧៤៤.៥៨៩ | (១៤៥.២០៦) | -៧៩,០៤% | (៥៨៨.៨២៨) | -៧៩,០៨% |
| ការវាស់ស្ទង់ | ៧.៤៧២ | ៣០.២២៤ | ៧.០២១ | ២៨.៤៥៦ | ៤៥១ | ៦,៤២% | ១.៧៦៨ | ៦,២១% |
| ចំណាយលើសេវាកម្មជួសជុល និងសេវាកម្ម | ១៨៧ | ៧៥៦ | - | - | ១៨៧ | 0,00% | ៧៥៦ | 0,00% |
| ផ្សេងៗ | ១៩៩.០៥៩ | ៨០៥.១៩៤ | ១៥៧.៥១១ | ៦៣៨.៣៩១ | ៤១.៥៤៨ | ២៦,៣៨% | ១៦៦.៨០៣ | ២៦,១៣% |
| **សរុបថ្លៃដើមនៃសេវាកម្ម** | **៦.៤៦០.៧៩៤** | **២៦.១៣៣.៩១២** | **៥.៦១៩.៦៤៥** | **២២.៧៧៦.៤២១** | **៨៤១.១៤៩** | **១៤,៩៧%** | **៣.៣៥៧.៤៩១** | **១៤,៧៤%** |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ប្រាក់ចំណេញដុល | ១២.៣៩៥.៥០២ | ៥០.១៣៩.៨០៥ | ១០.៦៨០.៧៧៧ | ៤៣.២៨៩.១៨៩ | ១.៧១៤.៧២៥ | ១៦,០៥% | ៦.៨៥០.៦១៦ | ១៥,៨៣% |
| អត្រាគំលាតប្រាក់ចំណេញដុល | ៦៥,៧៤% | ៦៥,៧៤% | ៦៥,៥២% | ៦៥,៥២% | | | | |

-ថ្លៃដើមនៃសេវាកម្ម:

- ចំណាយរំលស់ទ្រព្យរោងចក្រ បរិក្ខារ : បានកើនឡើងចំនួន ២.០៧០.៨៨៨ពាន់រៀល(៥១៩.៩០៤ដុល្លារអាមេរិក) ឬស្មើនឹង ២៥,៦៤% ពី ៨.០៧៧.៤៤៣ ពាន់រៀល (១.៩៩២.៩៥៤ ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៦ ដល់ ១០.១៤៨.៣៣១ពាន់រៀល (២.៥០៨.៨៥៨ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៧។ ការកើន ឡើងនេះ គឺដោយសារតែ ក.ស.ភ. បានទទួលស្គាល់ជាចលនទ្រព្យ និងអចលនទ្រព្យលើការបំពាក់គ្រឿងចក្រមួយចំនួនដូចជា គ្រឿងចក្រលើកដាក់លើទីលាន (RTG) ចំនួន ៤គ្រឿង, ក្បាលរថយន្ត KAMAZ ចំនួន ១២គ្រឿង, រ៉ូឡូ២៥តោនចំនួន ១គ្រឿង, កន្ទុយសណ្តោងរ៉ឺម៉កដឹកកុងតឺន័រចំនួន ២៤គ្រឿង, ការសាងសង់ទីលានសំបកកុងតឺន័រស្ថិតនៅប្លង់ B, ទិញប៉ុងតុងចំនួន ១គ្រឿង និងបំពាក់គ្រឿងចក្រមួយចំនួនបន្ថែមទៀតក្នុងឆ្នាំ២០១៧ នេះ។

- ចំណាយលើថ្លៃដងយោង: បានកើនឡើងចំនួន ៥៧៦.០៦០ពាន់រៀល (១៤៥.១២៤ដុល្លារអាមេរិក) ឬស្មើនឹង១០,៣៧% ពី ៥.៥៥៥.៩០៩ពាន់រៀល (១.៣៧០.៨១៤ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៦ ដល់ ៦.១៣១.៩៦៩ពាន់រៀល (១.៥១៥.៩៣៨ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៧។ ការកើនឡើងនេះបណ្តាលមកពីកំណើនកុងតឺន័រឆ្លងកាត់ដែលមានចំនួន៣៣.០២៤TEUs ឬស្មើនឹង ២១,៧៦% និងកំណើនទំនិញរាយដែលមានចំនួន ៥៣.៨០៦តោន ឬស្មើនឹង ១២% សម្រាប់ឆ្នាំ២០១៧។

- ចំណាយប្រាក់បៀវត្ស និងប្រាក់ឈ្នួល (បុគ្គលិកប្រតិបត្តិការ): បានកើនឡើងចំនួន ៥៤៦.០៤២ពាន់រៀល (១៣៧.០៩០ដុល្លារអាមេរិក) ឬស្មើនឹង ១២,៧០% ពី៤.២៩៩.៨៧២ពាន់រៀល (១.០៦០.៩១១ ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៦ ដល់៤.៨៤៥.៩១៤ពាន់រៀល (១.១៩៨.០០១ ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៧។ ការ កើនឡើងនេះ គឺបណ្តាលមកពីកំណើនកុងតឺន័រឆ្លងកាត់ជាប្រចាំខែ និងមានការកែប្រែដូចជា ការដំឡើងប្រាក់វិភាជន៍គ្រួសារ ការកែប្រែសន្ទស្សន៍ប្រាក់បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិលដែលបានអនុវត្តចាប់ពីដើមឆ្នាំ២០១៧ ការជ្រើសរើសបុគ្គលិកបន្ថែម ព្រមទាំងការផ្តល់ប្រាក់បៀវត្សបន្ថែមដែលបានមកពីសេវាកម្មលើកដាក់ស្អែនកុងតឺន័រជូនដល់បុគ្គលិកពាក់ព័ន្ធទៅលើប្រតិបត្តិការលើកដាក់កុងតឺន័រស្អែន។

- ចំណាយប្រេងឥន្ធនៈ (កិច្ចការប្រតិបត្តិការ និងបូមស្តារ/ថែទាំប្រឡាយនាវាចរណ៍): បានកើនឡើងចំនួន ១.២០៤.៩៦៥ពាន់រៀល (២៩៨.៥០៣ដុល្លារអាមេរិក) ឬស្មើនឹង ៩៥,៩១% ពី ១.២៥៦.៣២៩ ពាន់រៀល (៣០៩.៩៧៥ ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៦ ទៅ ២.៤៦១.២៩៤ពាន់រៀល (៦០៨.៤៧៨ ដុល្លារអាមេរិក)

ក្នុងឆ្នាំ២០១៧។ ក្នុងនោះ ចំណាយប្រេងឥន្ធនៈលើការបូមស្តារ/ថែទាំប្រឡាយនាវាចរណ៍មានចំនួន ៧៩៤.៩៨៣ពាន់រៀល (១៨៩.៥៣៩ ដុល្លារអាមេរិក)។ ការកើនឡើងចំណាយប្រេងឥន្ធនៈសម្រាប់ប្រើប្រាស់ទៅលើកិច្ចការប្រតិបត្តិការជាប្រចាំថ្ងៃស្មើនឹង៣១,៤៦% ធៀបនឹងឆ្នាំ២០១៦។ ដោយសារ ការកើនឡើងថ្លៃប្រេងឥន្ធនៈ ដែលជាក់ស្តែងតម្លៃប្រេងឥន្ធនៈក្នុងមួយលីត្រ ដែល ក.ស.ភ. បានទិញយកមកប្រើប្រាស់ជាមធ្យមកើនឡើងពី ០,៥៥ដុល្លារអាមេរិក/លីត្រក្នុងឆ្នាំ២០១៦ ទៅ០,៦៥ដុល្លារអាមេរិក/លីត្រក្នុងឆ្នាំ២០១៧។ ជាមួយគ្នានេះដែរ សម្រាប់ឆ្នាំ២០១៧នេះ គឺប្រតិបត្តិការនៃការលើកដាក់កុងតឺន័រមានការកើនឡើងផងដែរ។

- ចំណាយលើការជួសជុល និងថែទាំ(គ្រឿងចក្រ និងប្រឡាយនាវាចរណ៍): បានថយចុះចំនួន ៦២០.៩៦៣ពាន់រៀល (១៥២.៥៥២ដុល្លារអាមេរិក) ឬស្មើនឹង ២៨,៥៤% ធៀបនឹងឆ្នាំ២០១៦ ការធ្លាក់ចុះនេះដោយសារពុំមានចំណាយជួសជុលធំទៅលើការថែទាំ/ជួសជុលគ្រឿងចក្រ និងហេដ្ឋារចនាសម្ព័ន្ធផែ ដូចនឹងឆ្នាំ២០១៦ ព្រមទាំងចំណាយលើការថែទាំប្រឡាយនាវាចរណ៍ ក៏មានការធ្លាក់ចុះផងដែរ ។

- ចំណាយលើការគ្រប់គ្រងអាជីវកម្មខ្សាច់: បានធ្លាក់ចុះចំនួន ៥៨៨.៨២៨ពាន់រៀល (១៤៥.២០៦ដុល្លារអាមេរិក) ឬស្មើនឹង៧៩,០៨%ធៀបនឹងឆ្នាំ២០១៦។ មូលហេតុនៃការធ្លាក់ចុះ ដោយសារពុំមានការទូទាត់លើការសិក្សាអំពីផលប៉ះពាល់លើបរិស្ថាន (EIA) និងចំណាយលើការរៀបចំវេទិកាសាធារណៈ តាមបណ្តាទីតាំងដែល ក.ស.ភ. ទទួលបានអាជ្ញាប័ណ្ណពីក្រសួងរ៉ែ និងថាមពល ។ ម្យ៉ាងវិញទៀតប្រតិបត្តិការបូមខ្សាច់នៅប្រឡាយស្ពានតាឯក ត្រូវផ្អាកជាបណ្តោះអាសន្នចាប់ពីខែកុម្ភៈ ឆ្នាំ២០១៧ រហូតមកដល់បច្ចុប្បន្ន។

- ចំណាយផ្សេងៗ: បានកើនឡើងចំនួន ១៦៦.៨០៣ពាន់រៀល (៤១.៥៨៨ដុល្លារអាមេរិក) ឬស្មើនឹង ២៦,១៣% ធៀបនឹងឆ្នាំ២០១៦។ ដោយសារ ក.ស.ភ. មានការសហការប្រើប្រាស់សេវាកម្មដឹកជញ្ជូនកុងតឺន័រក្នុងបរិវេណចំណតផែកុងតឺន័រLM១៧ ពីក្រុមហ៊ុនប្រាយឡៃថ៍អ៊ីមផត-អិចផត បន្ថែមទៀត, ចំណាយលើថ្លៃឈ្នួលដឹកជញ្ជូនរថស្ទូច និងអេស្កាវ៉ាទ័រពីចំណតផែLM១៧ ទៅចំណតផែរណបទន្លេបិទ និងពីផែរណបទន្លេបិទមកចំណតផែLM១៧ វិញ ព្រមទាំងមានចំណាយលើការរៀបចំទីលានសម្រាប់ការលើកដាក់ទំនិញរាយនៅផែទន្លេបិទ។

- អត្រាគំលាតប្រាក់ចំណេញដុល

អត្រាគំលាតប្រាក់ចំណេញដុលបានកើនឡើងចំនួន ០,២២% ពីអត្រា៦៥,៥២% ក្នុងឆ្នាំ២០១៦ ទៅ ៦៥,៧៤ % ក្នុងឆ្នាំ២០១៧។ ការកើនឡើងនៃអត្រាគំលាតប្រាក់ចំណេញដុលដោយសារតែចំណូលសរុបពីផលអាជីវកម្ម និងសេវាកម្មមានការកើនឡើងចំនួន ១០.២០៨.១០៧ពាន់រៀល (២.៥៥៥.៨៧៤ដុល្លារអាមេរិក) ឬស្មើនឹង១៥,៤៥% ពី៦៦.០៦៥.៦១០ពាន់រៀល (១៦.៣០០.៤២២ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៦ ដល់ ៧៦.២៧៣.៧១៧ពាន់រៀល (១៨.៨៥៦.២៩៦ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៧។ ចំណែកឯ ចំណាយថ្លៃដើមនៃសេវាកម្មមានការកើនឡើងចំនួន ៣.៣៥៧.៤៩១ពាន់រៀល (៨៤១.១៩៩ដុល្លារអាមេរិក) ឬស្មើនឹង១៤,៧៤% ពី ២២.៧៧៦.៤២១ពាន់រៀល (៥.៦១៩.៦៤៥ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៦ ដល់ ២៦.១៣៣.៩១២ពាន់រៀល (៦.៤៦០.៧៩៤ ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៧ គឺដោយសារមានការកើនឡើងទៅលើចំណាយថ្លៃដើមនៃសេវាកម្មមួយចំនួនដូចជា ចំណាយទៅលើការប្រើប្រាស់ប្រេងឥន្ទនៈ,ចំណាយរំលស់ទ្រព្យរោងចក្រ បរិក្ខារ និងចំណាយផ្សេងៗជាដើម។

*គ. ការវិភាគប្រាក់ចំណេញមុនបង់ពន្ធ*

ប្រាក់ចំណេញមុនបង់ពន្ធ គឺបានមកពីប្រាក់ចំណេញដុល បូកចំណូលផ្សេងៗ ដកនឹងចំណាយរដ្ឋបាលទូទៅ និងចំណាយហិរញ្ញប្បទាន។ ដូចនេះ ក.ស.ភ. សូមលើកយកចំណាយដែលសំខាន់ៗនៅក្នុងចំណាយរដ្ឋបាលទូទៅ ដើម្បីយកមកវិភាគដូចខាងក្រោម÷

ដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ប្រៀបធៀបនឹងដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

| បរិយាយ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | | បំរែបំរួល | | បំរែបំរួល | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | % | ពាន់រៀល | % |
| **ប្រាក់ចំណេញដុល** | **១២.៣៩៥.៥០២** | **៥០.១៣៩.៨០៥** | **១០.៦៨០.៧៧៧** | **៤៣.២៨៩.១៨៩** | **១.៧១៤.៧២៥** | **១៦,០៥%** | **៦.៨៥០.៦១៦** | **១៥,៨៣%** |
| **ចំណូលផ្សេងៗ** | **៦០៣.៩៦៨** | **២.៤៤៣.០៥១** | **៩៦៧.៩០៤** | **៣.៩២២.៩១៥** | **(៣៦៣.៩៣៦)** | **-៣៧,៦០%** | **(១.៤៧៩.៨៦៤)** | **-៣៧,៧២%** |
| **ចំណាយរដ្ឋបាលទូទៅនិងការលក់** | | | | | | | | |
| ចំណាយប្រាក់បៀវត្ស និងអត្ថប្រយោជន៍ផ្សេងៗ | ៣.១៤៦.១៧១ | ១២.៧២៦.២៦២ | ៣.០៣២.១៤៩ | ១២.២៨៩.៣០០ | ១១៤.០២២ | ៣,៧៦% | ៤៣៦.៩៦២ | ៣,៥៦% |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| អំណោយសទ្ធារទាន | ៣៨៦.៦១៣ | ១.៥៦៣.៨៥០ | ៤០០.៥៤២ | ១.៦២៣.៣៩៧ | (១៣.៩២៩) | -៣,៤៨% | (៥៩.៥៤៧) | -៣,៦៧% |
| ចំណាយទឹក-ភ្លើង និងប្រេងឥន្ធនៈ | ៤៤០.៥០០ | ១.៧៨១.៨២៣ | ៤០៩.៦៨៣ | ១.៦៦០.៤៤៥ | ៣០.៨១៧ | ៧,៥២% | ១២១.៣៧៨ | ៧,៣១% |
| ចំណាយរំលស់លើទ្រព្យវិនិយោគនិងទ្រព្យរោងចក្របរិក្ខារ | ៣៨៥.៣១៧ | ១.៥៥៨.៦០៧ | ៣៨៥.១៧៧ | ១.៥៦១.១២២ | ១៤០ | ០,០៤% | (២.៥១៥) | -០,១៦% |
| ចំណាយជួសជុលនិង ថែទាំ | ១៣៧.១៨១ | ៥៥៤.៨៩៧ | ១៩៨.០៦៩ | ៨០២.៧៧៤ | (៦០.៨៨៨) | -៣០,៧៤% | (២៤៧.៨៧៧) | -៣០,៨៨% |
| ចំណាយលើការកំសាន្ត | ១៩២.០២៣ | ៧៧៦.៧៣៣ | ១៦៣.១៨២ | ៦៦១.៣៧៧ | ២៨.៨៤១ | ១៧,៦៧% | ១១៥.៣៥៦ | ១៧,៤៤% |
| ចំណាយការធ្វើដំណើរ | ១០៩.៧២៥ | ៤៤៣.៨៣៨ | ១៣២.៨៣៨ | ៥៣៨.៣៩២ | (២៣.១១៣) | -១៧,៤០% | (៩៤.៥៥៤) | -១៧,៥៦% |
| ចំណាយជំនាញវិជ្ជាជីវៈ | ៥១.២១៨ | ២០៧.១៧៧ | ៥៩.៧៤២ | ២៤២.១៣៤ | (៨.៥២៤) | -១៤,២៧% | (៣៤.៩៥៧) | -១៤,៤៤% |
| ចំណាយកម្រៃក្រុមប្រឹក្សាភិបាល | ២០៩.២២០ | ៨៤៦.២៩៥ | ២០៨.៨១៨ | ៨៤៦.៣៣៩ | ៤០២ | ០,១៩% | (៤៤) | -០,០១% |
| ចំណាយសម្ភារផ្គត់ផ្គង់ការិយាល័យ | ១០២.៥៧១ | ៤១៤.៩០០ | ១២៩.១៩៧ | ៥២៣.៦៣៥ | (២៦.៦២៦) | -២០,៦១% | (១០៨.៧៣៥) | -២០,៧៧% |
| ចំណាយទំនាក់ទំនងផ្សេងៗ | ៥៣.៨៤៦ | ២១៧.៨០៧ | ៥៧.៣៤៩ | ២៣២.៤៣៥ | (៣.៥០៣) | -៦,១១% | (១៤.៦២៨) | -៦,២៩% |
| ចំណាយពន្ធផ្សេងៗ | ៣០.៧១០ | ១២៤.២២២ | ១០៨.៦៤៦ | ៤៤០.៣៤២ | (៧៧.៩៣៦) | -៧១,៧៣% | (៣១៦.១២០) | -៧១,៧៩% |
| ផ្សេងៗ | ៣១៦.១២៤ | ១.២៧៨.៧២០ | ៣៣៤.៣៣៨ | ១.៣៥៥.០៧៤ | (១៨.២១៤) | -៥,៤៥% | (៧៦.៣៥៤) | -៥,៦៣% |
| **សរុបចំណាយរដ្ឋបាលទូទៅនិងការលក់** | **៥.៥៦១.២១៩** | **២២.៤៩៥.១៣១** | **៥.៦១៩.៧៣០** | **២២.៧៧៦.៧៦៦** | **(៥៨.៥១១)** | **-១,០៤%** | **(២៨១.៦៣៥)** | **-១,២៤%** |
| **ចំណាយហិរញ្ញប្បទាន** | **(១.២៥៤.៧៦៧)** | **(៥.០៧៥.៥៣៣)** | **(១.២៧២.៣៨៥)** | **(៥.១៥៦.៩៧៦)** | **១៧.៦១៨** | **-១,៣៨%** | **៨១.៤៤៣** | **-១,៥៨%** |
| **ប្រាក់ចំណេញមុនបង់ពន្ធ** | **៦.១៨៣.៤៨៤** | **២៥.០១២.១៩២** | **៤.៧៥៦.៥៦៦** | **១៩.២៧៨.៣៦២** | **១.៤២៦.៩១៨** | **៣០,០០%** | **៥.៧៣៣.៨៣០** | **២៩,៧៤%** |

- ចំណាយលើប្រាក់បៀវត្ស និងអត្ថប្រយោជន៍ផ្សេងៗ: បានកើនឡើងចំនួន ៤៣៦.៩៦២ពាន់រៀល (១១៤.០២២ដុល្លារអាមេរិក) ឬស្មើនឹង៣,៥៦% បើធៀបនឹងឆ្នាំ២០១៦។ ក្នុងនោះការកើនឡើងចំណាយលើប្រាក់បៀវត្សសុទ្ធស្មើនឹង៥,២៨% បើធៀបនឹងឆ្នាំ២០១៦ ដោយសារកំណើនកុងតឺន័រឆ្លងកាត់ដែលមាន

ចំនួន ៣៣.០២៤TEUsឬស្មើនឹង ២១,៧៦% និងមានការកែប្រែដូចជា ការដំឡើងប្រាក់វិភាជន៍គ្រួសារ ការកែប្រែសន្ទស្សន៍ប្រាក់បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជ-ការស៊ីវិលដែលបានអនុវត្តចាប់ពីដើម ឆ្នាំ២០១៧ ព្រមទាំងមានការតម្លើងតួនាទីដល់បុគ្គលិក ។

- ចំណាយបដិសណ្ឋារកិច្ច និងការកំសាន្ត : មានការកើនឡើងចំនួន១១៥.៣៥៦ ពាន់រៀល (២៨.៨៩១ដុល្លារអាមេរិក) ឬស្មើនឹង ១៧,៩៤%បើធៀបនឹងឆ្នាំ២០១៦។ ការកើនឡើងដោយសារ ក.ស.ភ. មានការទទួលភ្ញៀវក្នុងកម្មវិធីសម្ពោធដាក់ឲ្យប្រើប្រាស់ឧបករណ៍ស្រាវជ្រាវសារធាតុវិទ្យុសកម្មនៅចំណតផែ-កុងតឺន័រLM១៧ និងការទទួលគណៈប្រតិភូ ព្រមទាំងភ្ញៀវជាតិ និងអន្តរជាតិដែលមកទស្សនកិច្ច ក.ស.ភ.។

- ចំណាយការជួសជុល និងថែទាំ : មានការថយចុះចំនួន ២៩៧.៨៧៧ពាន់រៀល(៦០.៨៨៨ ដុល្លារអាមេរិក) ឬស្មើនឹង៣០,៨៨% បើធៀបនឹងឆ្នាំ២០១៦។ ការថយចុះនេះដោយសារ ក.ស.ភ. ពុំសូវមានចំណាយជួសជុលថែទាំជាប្រចាំទៅលើអគារ, របង និងហេដ្ឋារចនាសម្ព័ន្ធមួយចំនួន និងសេវាថែទាំលើប្រព័ន្ធ AIS ជាដើម។

ជាមួយគ្នានេះដែរ ចំណាយមួយចំនួនមានការធ្លាក់ចុះបើធៀបនឹងការអនុវត្តឆ្នាំ២០១៦ ដូចជា ចំណាយលើការធ្វើដំណើរ ,ចំណាយសម្ភារផ្គត់ផ្គង់ការិយាល័យ និងចំណាយទំនាក់ទំនងផ្សេងៗ ជាដើម ។

### *ឃ.ការវិភាគប្រាក់ចំណេញក្រោយបង់ពន្ធ*

ក.ស.ភ. ស្ថិតនៅក្រោមច្បាប់នៃក្រុមហ៊ុនពាណិជ្ជកម្មក្នុងវិស័យពន្ធដារ និងអាករ ដូចនេះ ក.ស.ភ. មានកាតព្វកិច្ចក្នុងការបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំក្នុងអត្រា២០% ប៉ុន្តែក្រោយពី ក.ស.ភ. បានបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈកាលពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥ គឺ ក.ស.ភ. ទទួលបានការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ។

ដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ប្រៀបធៀបនឹងដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

| បរិយាយ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | | បំរែបំរួល | | បំរែបំរួល | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | % | ពាន់រៀល | % |
| ប្រាក់ចំណេញមុនបង់ពន្ធ (ក) | ៦.១៨៣.៨៨៩ | ២៥.០១២.១៩២ | ៤.៧៥៦.៥៦៦ | ១៩.២៧៨.៣៦២ | ១.៤២៦.៩១៨ | ៣០,០០% | ៥.៧៣៣.៨៣០ | ២៩,៧៤% |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ចំណាយពន្ធលើប្រាក់ចំណេញ(ខ) | ៨២១.៦៥១ | ៣.៣២៣.៥៧៨ | ៦៦៩.១៧៦ | ២.៧១២.១៧០ | ១៥២.៤៧៥ | ២២,៧៩% | ៦១១.៤០៨ | ២២,៥៤% |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | ៥.៣៦១.៨៣៣ | ២១.៦៨៨.៦១៤ | ៤.០៨៧.៣៩០ | ១៦.៥៦៦.១៩២ | ១.២៧៤.៤៤៣ | ៣១,១៨% | ៥.១២២.៤២២ | ៣០,៩២% |
| **អត្រាពន្ធមធ្យម(ខ)/(ក)** | **១៣,២៩%** | **១៣,២៩%** | **១៤,០៧%** | **១៤,០៧%** | | | | |

ក.ស.ភ.ទទួលបានប្រាក់ចំណេញសុទ្ធក្នុងឆ្នាំ២០១៧ ចំនួន ២១.៦៨៨.៦១៤ពាន់រៀល (៥.៣៦១.៨៣៣ ដុល្លារអាមេរិក) និងក្នុងឆ្នាំ២០១៦ ចំនួន ១៦.៥៦៦.១៩២ពាន់រៀល (៤.០៨៧.៣៩០ ដុល្លារអាមេរិក) ដែលបង្ហាញឱ្យឃើញនូវការកើនឡើងនូវប្រាក់ចំណេញសុទ្ធចំនួន ៥.១២២.៤២២ពាន់រៀល (១.២៧៤.៤៤៣ដុល្លារអាមេរិក) ឬស្មើនឹង៣០,៩២%។ ការកើនឡើងនេះដោយសារចំណូលសរុបពីផលអាជីវកម្ម និងសេវាកម្មស្មើនឹង ១៥,៤៥% បើធៀបនឹងឆ្នាំ២០១៦។ ចំណាយរដ្ឋបាលទូទៅមានការធ្លាក់ចុះ ២៤១.៦៣៥ពាន់រៀល (៥៨.៥១១ ដុល្លារអាមេរិក) ឬស្មើនឹង១,២៤% បើធៀបនឹងឆ្នាំ២០១៦។

ការថយចុះនៃអត្រាពន្ធមធ្យមចំនួន ០,៧៨ %ពី ១៤,០៧% ក្នុងឆ្នាំ២០១៦ ទៅ ១៣,២៩% ក្នុងឆ្នាំ២០១៧ ដោយសារចំណាយពន្ធលើប្រាក់ចំណេញមានការកើនឡើងចំនួន ៦១១.៤០៨ពាន់រៀល (១៥២.៤៧៥ដុល្លារអាមេរិក) ឬស្មើនឹង២២,៥៤% ដែលបណ្តាលមកពីការប្រែប្រួលនៃចំណាយដែលមិនអាចកាត់កងបាន ការកើនឡើងចំណូលសរុបពីផលអាជីវកម្ម និងសេវាកម្ម ស្មើនឹង១៥,៤៥% បើធៀបនឹងឆ្នាំ២០១៦ និងមានការកត់ត្រាពន្ធពន្យារបំណុល (Deferred tax liability)បន្ថែម។

## ង.ការវិភាគពីកត្តានិងនិន្នាការដែលប៉ះពាល់ដល់ស្ថានភាពនិងលទ្ធផលហិរញ្ញវត្ថុ

### ង.១. កំរិតនៃការជួញដូរក្នុងតំបន់និងជាសកលនិងសកលភាវូបនីយកម្ម

ស្ថានភាពហិរញ្ញវត្ថុនិងលទ្ធផលប្រតិបត្តិការរបស់ ក.ស.ភ. អាស្រ័យលើបរិមាណកុងតឺន័រឆ្លងកាត់និងសកម្មភាពដឹកជញ្ជូនឆ្លងកាត់កំពង់ផែដែលពឹងផ្អែកលើទំហំពាណិជ្ជកម្មក្នុងស្រុកនិងទូទាំងពិភពលោកព្រមទាំងបរិមាណនៃការនាំចេញនិងការនាំចូលក្នុងតំបន់ដែលត្រូវបានធ្វើប្រតិបត្តិការ។ បរិមាណនៃការជួញដូរក្នុងស្រុកនិងទូទាំងពិភពលោកនិងបរិមាណនៃការនាំចេញនិងនាំចូលក្នុងស្រុកដែលបានធ្វើប្រតិបត្តិការនេះទទួលរងផលប៉ះពាល់ដោយសារការផ្លាស់ប្តូរលក្ខខណ្ឌសេដ្ឋកិច្ចហិរញ្ញវត្ថុនិងនយោបាយក្នុងតំបន់និងសកលដែលហួសពីការគ្រប់គ្រងរបស់ ក.ស.ភ.។

### ង.២. សមត្ថភាពទទួលកុងតឺន័រនៅចំណតផែកុងតឺន័រLM១៧

ការលើកដាក់ចំបងៗត្រូវបានធ្វើឡើងនៅចំណតផែកុងតឺន័រLM១៧។ ក.ស.ភ. មានសមត្ថភាពលើកដាក់ទំនិញជាកុងតឺន័រប្រមាណ ១៨៤.៨០៥TEUs ក្នុងមួយឆ្នាំគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧។ ក.ស.ភ. ដើម្បីឆ្លើយតបនឹងកំណើននាឆ្នាំបន្ទាប់ ក.ស.ភ. មានគម្រោងនឹងបញ្ចប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផែដំណាក់កាលទី២ដែលនឹងបង្កើនសមត្ថភាពលើកដាក់កុងតឺន័រនៅចំណតផែកុងតឺន័រLM១៧ ដល់ចំនួន ៣០០.០០០TEUs ក្នុងមួយឆ្នាំនៅបំណាច់ ឆ្នាំ២០១៨។

| បរិយាយ | ឆ្នាំ២០១៥ | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ |
|---|---|---|---|---|
| | សមត្ថភាពលើកដាក់ | សមត្ថភាពលើកដាក់ | សមត្ថភាពលើកដាក់ | សមត្ថភាពលើកដាក់ (ប៉ាន់ស្មាន) |
| ចំណតផែកុងតឺន័រ LM១៧ (TEUs) | ១៥០.០០០ | ១៥១.៧៨១ | ១៨៤.៨០៥ | ៣០០.០០០ |

### ង.៣.ប្រសិទ្ធភាពនៃប្រតិបត្តិការ

ដើម្បីបង្កើនប្រសិទ្ធភាពខ្ពស់ក្នុងប្រតិបត្តិការ ក.ស.ភ. មានគោលការណ៍កាត់បន្ថយចំណាយថ្លៃដើមដោយប្រើធនធានដែលមានស្រាប់ និងការបំពាក់គ្រឿងចក្រលើកដាក់ទំនើបៗសម្រាប់បំរើឱ្យប្រតិបត្តិការ។ ជាក់ស្តែង ក.ស.ភ. បានអនុវត្តនូវវិធានការដូចខាងក្រោម ដើម្បីបង្កើនប្រសិទ្ធភាពប្រតិបត្តិការះ

- បន្តបំពាក់គ្រឿងចក្រលើកដាក់ទំនើបៗដើម្បីបង្កើនល្បឿននៃការលើកដាក់ទំនិញនិងកាត់បន្ថយការរង់ចាំដោយសារការខូចខាតគ្រឿងចក្រ
- បន្តជម្រុញសមត្ថភាពផ្នែកប្រតិបត្តិការតាមរយៈការបណ្តុះបណ្តាល
- ពង្រីកចំណតផែដើម្បីធានាថានាវាដឹកកុងតឺន័រអាចដឹកជញ្ជូនចេញចូលបានលឿននិងប្រកបដោយប្រសិទ្ធភាព

- ការប្រើទីលានស្តុកទុកទំនិញខាងក្រៅដើម្បីបង្កើនសមត្ថភាពផ្ទុកកុងតឺន័រដូចជានៅអង្គភាពផែស្ងួត ICDនៅចំណតផែគីឡូម៉ែត្រលេខ៦នៅចំណតផែពហុបំណងTS៣នៅ MSL សម្រាប់LM១៧
- គ្រប់គ្រងទីលានស្តុកកុងតឺន័រឱ្យមានប្រសិទ្ធភាពដោយកាត់បន្ថយការរក្សាទុកកុងតឺន័រនៅលើទីលានក្នុងរយៈពេលយូរ
- ប្រើប្រាស់ចំណតផែឲ្យមានប្រសិទ្ធភាពដោយការរៀបចំទីតាំងចូលចតនាវាទៅតាមផែនការច្បាស់លាស់។

### ង.៤. *តម្លៃ*

បន្ថែមពីសមត្ថភាពគ្រប់គ្រាន់និងប្រសិទ្ធភាពប្រតិបត្តិការខ្ពស់លទ្ធភាពរបស់ ក.ស.ភ. ក្នុងការទាក់ទាញ និងរក្សាអតិថិជន អាស្រ័យលើតារាងតម្លៃ ការលើកទឹកចិត្តនិងការសន្សំសំចៃផ្តល់ជូនអតិថិជន។ ក.ស.ភ. អាចសម្របតាមតម្លៃដែលផ្តល់ជូនទៅអតិថិជនដូចជាការបញ្ចុះតម្លៃសរុបសម្រាប់នាវាទេសចរណ៍ចេញចូលបញ្ចុះតម្លៃលើកដាក់សម្រាប់ការដឹកជញ្ជូនទំនិញរាយនិងផ្តល់ជូនកញ្ចប់លើកទឹកចិត្តទៅកាន់ក្រុមហ៊ុនសេវាកម្មដឹកជញ្ជូនតាមនាវា អាស្រ័យលើបរិមាណនៃការដឹកជញ្ជូន។ជាក់ស្តែងនៅថ្ងៃ ទី១៦ ខែឧសភា ឆ្នាំ២០១៦ក.ស.ភ. បានបញ្ចុះ តម្លៃ (LOLO) ចំនួន៥% ។

### ង.៥. *ការតភ្ជាប់រវាងផែរណប*

ការតភ្ជាប់រវាងផែរណបដើរតួនាទីយ៉ាងសំខាន់ ដែលក្រុមហ៊ុនដឹកជញ្ជូនធ្វើការជ្រើសរើសកំពង់ផែសម្រាប់ការដឹកជញ្ជូនទំនិញ។ ការតភ្ជាប់រវាងផែរណបដែលមានប្រសិទ្ធភាពអាចជម្រុញឱ្យអ្នកដឹកជញ្ជូនកាត់បន្ថយពេលវេលាដឹកជញ្ជូន។ ប្រសិទ្ធភាពចរាចរណ៍រវាងផែរណប អាស្រ័យទៅលើសេវាកម្ម ផែរណបផ្សេងទៀតដែលគ្រប់គ្រងលើចរាចរណ៍នៃការដឹកជញ្ជូនទំនិញព្រោះថាទីតាំងរបស់ ក.ស.ភ. មានអំណោយផលសម្រាប់ការប្រមូលទំនិញដើម្បីដឹកជញ្ជូនតាមផ្លូវទឹក។

### ង.៦. *ការរំលស់*

ការរំលស់កើតឡើងពីការរំលស់ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារកំពង់ផែរួមទាំងចំណតនាវាអគារឃ្លាំង និងគ្រឿងចក្រលើកដាក់។ការប៉ាន់ស្មានអាយុកាលប្រើប្រាស់ទ្រព្យសំខាន់ៗ មានដូចជាចំណតនាវាអគារ (១០-៥០ឆ្នាំ) គ្រឿងចក្រគ្រឿងម៉ាស៊ីន (១០-១៥ឆ្នាំ) គ្រឿងសង្ហារឹមនិងគ្រឿងបំពាក់ (៥ឆ្នាំ) កុំព្យូទ័រ (៥-១៥ឆ្នាំ) សម្ភារការិយាល័យនិងផ្សេងៗ (៥-១៥ឆ្នាំ) និងយានយន្ត(៨-១៥ឆ្នាំ)។ វិធីសាស្រ្តរំលស់អាយុកាលប្រើប្រាស់ និងតម្លៃកាកសំណល់ត្រូវបានពិនិត្យនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ ហើយត្រូវកែសម្រួលប្រសិនបើសមស្រប។

## ២.កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### *ក.កត្តាសេដ្ឋកិច្ចជាតិ តំបន់ និងសកល*

បរិមាណទំនិញឆ្លងកាត់ ក.ស.ភ. ទាក់ទងដោយផ្ទាល់ទៅនឹង កត្តាសេដ្ឋកិច្ចជាតិតំបន់ ឬសកល។ ជាការចាំបាច់ដែល ក.ស.ភ. ត្រូវធ្វើការវិភាគសេដ្ឋកិច្ច និងពាណិជ្ជកម្ម ដើម្បីបានដឹងនូវនិន្នាការកំណើន ឬការធ្លាក់ចុះនៃតម្រូវការដឹកជញ្ជូន។ នេះជាមូលដ្ឋាន ដើម្បីរៀបចំឆ្លើយតបបានទាន់ពេលវេលា ក៏ដូចជាធ្វើផែនការវិនិយោគហេដ្ឋារចនាសម្ព័ន្ធ ឬក៏បំពាក់គ្រឿងចក្របានសមស្រប។ នេះក៏អាចជួយឲ្យ ក.ស.ភ. ជៀសបានពីការវិនិយោគហួសតម្រូវការ ដែលធ្វើឲ្យខាតប្រយោជន៍ពីការប្រើប្រាស់ទុន ឬកប់ទុន ក្នុងករណីដែលតម្រូវការដឹកជញ្ជូនអាចធ្លាក់ចុះ។

### *ខ.ការគ្រប់គ្រងថ្លៃដើមនៃសេវាកម្ម*

ការរក្សាបាននូវភាពប្រកួតប្រជែងខ្ពស់ក្នុងទីផ្សារ ជាកត្តាសំខាន់សម្រាប់និរន្តភាពនៃការរីកលូតលាស់របស់ ក.ស.ភ. ក្នុងនោះគឺគុណភាពសេវាកម្ម និងតម្លៃសេវាកម្មសមរម្យ។ ដើម្បីធានាបាននូវតម្លៃថ្លៃដើមនៃសេវាកម្មប្រកួតប្រជែង ក.ស.ភ. យកចិត្តទុកដាក់លើការគ្រប់គ្រងចំណាយប្រតិបត្តិការមួយចំនួនដូចខាងក្រោម៖

#### ខ.១. *ចំណាយបៀវត្ស និងអត្ថប្រយោជន៍ផ្សេងៗទៀតលើបុគ្គលិក*

ផ្នែកមួយនៃការចំណាយច្រើនគឺទៅលើបៀវត្សបុគ្គលិក និងអត្ថប្រយោជន៍ផ្សេងៗដែលស្មើនឹងអត្រា **២៣,០៣%** (អត្រា៦,៣៥%ជាបៀវត្សបុគ្គលិកផ្នែកប្រតិបត្តិការ និងអត្រា១៦,៦៨% ជាបៀវត្សបុគ្គលិកផ្នែករដ្ឋបាល និងអត្ថប្រយោជន៍ផ្សេងៗ) ធៀបនឹងចំណូលសរុបពីផលអាជីវកម្ម និងសេវាកម្មក្នុងឆ្នាំ២០១៧ ដែលបានកត់ត្រាជាចំណាយថ្លៃដើមនៃសេវាកម្ម និងចំណាយរដ្ឋបាលទូទៅ។ ទោះជាយ៉ាងណា ក.ស.ភ. បានរៀបចំផែនការធនធានមនុស្សត្រឹមត្រូវតាមទំហំការងារ និងការរៀបចំប្រាក់បៀវត្សយោងតាមបរិមាណកុងតឺន័រឆ្លងកាត់(TEU)ដែលជួយឲ្យការចំណាយលើបុគ្គលិកមិនមានការប៉ះពាល់ខ្លាំងលើ ប្រាក់ចំណេញ ។

#### ខ.២.*ចំណាយថ្លៃដងយោង*

ចំណាយថ្លៃដើមនៃសេវាកម្មដ៏ធំមួយផ្នែកទៀតគឺចំណាយថ្លៃដងយោងដែលស្មើនឹង **៨,០៤%** បើធៀបទៅនឹងចំណូលសរុបពីផលអាជីវកម្ម និងសេវាកម្មក្នុងឆ្នាំ២០១៧។ ក.ស.ភ. បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនជាដៃគូអាជីវកម្មចំនួនបីក្នុងការប្រើប្រាស់ដងយោងសម្រាប់សេវាកម្មលើកដាក់លើស្ពានផែ។ យោងតាមកិច្ចសន្យាភាគរយនៃការបែងចែកប្រាក់ចំណូលទៅកាន់ក្រុមហ៊ុនជាដៃគូនៅត្រឹម៨០% បន្ទាប់ពីការធ្វើប្រតិបត្តិការបានរយៈពេល៣ ទៅ៤ឆ្នាំ។ ក.ស.ភ. រំពឹងថាចំណាយថ្លៃដងយោងនឹងបន្តកើនឡើង ព្រោះកំណើនបរិមាណទំនិញឆ្លងកាត់ត្រូវបានព្យាករណ៍ថាបន្តឡើងខ្ពស់ក្នុងពេលខាងមុខ។ យ៉ាងណាមិញការចំណាយនេះ គឺប៉ះពាល់ដល់ផលចំណេញតិចតួចប៉ុណ្ណោះ ពីព្រោះការកើនឡើងនៃ

បរិមាណកុងតឺន័របានធ្វើឲ្យចំណូលរបស់ក.ស.ភ.មានការកើនឡើងដូចគ្នា។ តារាងខាងក្រោមនេះបង្ហាញពីភាគរយនៃការ បែងចែកប្រាក់ចំណូលៈ

| ម្ចាស់ដងយោង | ឈ្មោះដងយោង | ចំនួន | សមត្ថភាព (តោន) | ចំណែកប្រាក់ចំណូលរបស់ម្ចាស់ដងយោង | ចំណែកប្រាក់ចំណូលរបស់ ក.ស.ភ. | កាលបរិច្ឆេទកិច្ចសន្យា |
|---|---|---|---|---|---|---|
| Sovereign | ដងយោងបណ្តែតទី១ | ១ | ៨០ | ៨០% | ២០% | ០១/០២/២០១៦-៣១/០១/២០១៩ |
| | ដងយោងបណ្តែតទី២ | ១ | ៦០ | ៨០% | ២០% | |
| Kamsab | ដងយោងចល័ត៨០T | ១ | ៨០ | ៩០% | ១០% | ១១/០៣/២០០៨-១០/០៣/២០០៩ |
| | | | | ៨៥% | ១៥% | ១១/០៣/២០០៩-១០/០៣/២០១០ |
| | | | | ៨០% | ២០% | *១១/០៣/២០១១ ដល់បច្ចុប្បន្ន* |
| | ដងយោងចល័តទី២ | ១ | ៨១ | ៩០% | ១០% | ០១/០៧/២០១៣-៣១/០៦/២០១៥ |
| | | | | ៨៥% | ១៥% | ០១/០៧/២០១៥-៣១/០៦/២០១៦ |
| | | | | ៨០% | ២០% | *០១/០៧/២០១៦-៣១/០៦/២០៣៣* |
| | ដងយោងចល័តទី៣ | ១ | ៨១ | ៩០% | ១០% | ០១/០៧/២០១៣-៣១/០៦/២០១៥ |
| | | | | ៨៥% | ១៥% | ០១/០៧/២០១៥-៣១/០៦/២០១៦ |
| | | | | ៨០% | ២០% | *០១/០៧/២០១៦-៣១/០៦/២០៣៣* |
| Sungkwang | ដងយោងចល័តទី១ | ១ | ៨១ | ៩០% | ១០% | ០១/០១/២០១៣-៣១/១២/២០១៣ |
| | | | | ៨៥% | ១៥% | ០១/០១/២០១៤-៣១/១២/២០១៤ |
| | | | | ៨០% | ២០% | *០១/០១/២០១៥-៣១/១២/២០២៤* |

## *គ.កាតព្វកិច្ចពន្ធផ្សេងៗ*

ក.ស.ភ.ស្ថិតក្រោមច្បាប់សហគ្រាសពាណិជ្ជកម្មពាក់ព័ន្ធនឹងបញ្ហាពន្ធដារ។ ក.ស.ភ. ស្ថិតនៅក្រោមរបបស្វ័យប្រកាសនិងចាត់ទុកជាអ្នកជាប់ពន្ធធំចំពោះការបង់ពន្ធ។ ដូចនេះ ក.ស.ភ. មានកាតព្វកិច្ចបង់ពន្ធនិងអាករតាមការកំណត់នៃច្បាប់និងបទប្បញ្ញត្តិជាធរមាន។

### គ.១. *ពន្ធលើប្រាក់ចំណេញ*

ក.ស.ភ. មានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណេញក្នុងអត្រា២០% ដោយបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ១% នៃផលរបរប្រចាំខែ។ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ១% ប្រចាំខែនឹងត្រូវទូទាត់កាត់កងជាមួយពន្ធលើប្រាក់ចំណេញ២០% នៃចុងឆ្នាំសារពើពន្ធនីមួយៗ។ ក.ស.ភ. ធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥។ យោងតាមអនុក្រឹត្យលេខ០១អនក្រ.បកចុះថ្ងៃទី៨ខែមករា ឆ្នាំ២០១៥ ស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រសហគ្រាសបោះផ្សាយលក់មូលបត្រកម្មសិទ្ធិទទួលបានការលើកទឹកចិត្តដោយបន្ថយពន្ធលើប្រាក់ចំណេញចំនួន ៥០% នៃពន្ធលើប្រាក់ចំណេញត្រូវបង់សម្រាប់រយៈពេល៣ឆ្នាំគិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន។ ដូច្នេះក្រោយពីការអនុគ្រោះនេះត្រូវបានបញ្ចប់នោះ ក.ស.ភ. នឹងអនុវត្តកាតព្វកិច្ចពន្ធលើប្រាក់ចំណេញដូចធម្មតាវិញ។

### គ.២. *អាករលើតម្លៃបន្ថែម*

ក.ស.ភ.ជាក្រុមហ៊ុនដែលចុះបញ្ជីអាករលើតម្លៃបន្ថែម។ ក.ស.ភ.បានគិតអាករលើតម្លៃបន្ថែមតាមអត្រា១០% នៃចំនួនទឹកប្រាក់លើវិក្កយបត្រពេលដែលចេញវិក្កយបត្រទៅអតិថិជន។ ក.ស.ភ. ជាភ្នាក់ងារប្រមូលពន្ធនេះជូនរាជរដ្ឋាភិបាលព្រោះនេះជាអាករលើធាតុចេញរបស់ក.ស.ភ.។ អាករលើធាតុចេញនេះនឹងត្រូវកាត់កងជាមួយអាករលើធាតុចូល១០%នៅពេលដែលក.ស.ភ.បង់ប្រាក់ទៅអ្នកផ្គត់ផ្គង់សម្រាប់ការទិញ។

### គ.៣. *ពន្ធកាត់ទុកលើចំណូលការប្រាក់*

ក.ស.ភ.មានកាតព្វកិច្ចបង់ពន្ធកាត់ទុកលើចំណូលការប្រាក់តាមអត្រា៤% លើបញ្ញើទូទៅនិង ៦% លើបញ្ញើមានកាលកំណត់។ បច្ចុប្បន្ន ក.ស.ភ.មានបញ្ញើមានកាលកំណត់នៅធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា (FTB) និងធនាគារវឌ្ឍនៈអាស៊ីចំកាត់(ABA)។

### គ.៤. *ពន្ធនាំចូល*

ក.ស.ភ.មានកាតព្វកិច្ចបង់ពន្ធនាំចូលលើសម្ភារ និងវត្ថុធាតុដើមតាមអត្រាចន្លោះពី៧% ទៅ ៣៥%អាស្រ័យលើប្រភេទទំនិញនីមួយៗដែលកំណត់ដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករ។ យោងតាមគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផែដំណាក់កាលទី២នៅចំណតផែកុងតឺន័រLM១៧នៅឆ្នាំ២០១៧ ក.ស.ភ. និងគ្រោងនាំចូលគ្រឿងចក្រលើកដាក់កុងតឺន័រ ដូចនេះ ចំណាយលើពន្ធនាំចូលនឹងមានការកើនឡើង។

## ៣. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ចំណូលសំខាន់របស់ ក.ស.ភ. រួមមានប្រាក់ចំណូលពីការលើកដាក់ក្រោមដងយោង (Stevedoring) ការលើកដាក់នៅទីលាន (LOLO) និងចំណូលកិច្ចការផែដែលពាក់ព័ន្ធនឹងការដឹកជញ្ជូនកុងតឺន័រ ដែលស្មើប្រមាណ **៩៣%** ធៀបនឹងចំណូលសរុបពីផលអាជីវកម្ម និងសេវាកម្មក្នុងឆ្នាំ២០១៧។កត្តាសំខាន់នៃការកើនឡើងប្រាក់ចំណូល គឺបានមកពីកំណើនចំនួនកុងតឺន័រ, ទំនិញរាយ, នាវាឆ្លងកាត់ និងចំណុះនាវា ស្របតាមការលូតលាស់ ១វិស័យសំណង់ វិស័យកសិកម្មវិស័យពាណិជ្ជកម្ម និងវិស័យឧស្សាហកម្មវាយនភណ្ឌ(សំលៀកបំពាក់និងស្បែកជើង)។ ជាមួយគ្នានេះ ការដាក់ឱ្យដំណើរការនូវកំពង់ផែមេ **កៃម៉េប**ប្រទេសវៀតណាម ក៏ជាប្រភពនៃកំណើនបរិមាណកុងតឺន័រឆ្លងកាត់ក.ស.ភ.។ ជាក់ស្តែង ការដឹកជញ្ជូនឆ្លងកាត់ ក.ស.ភ. ទៅកាន់កំពង់ផែមេ **កៃម៉េប** មានការចំណេញពេលវេលាដោយដឹកជញ្ជូនទៅផ្ទាល់ទៅកាន់ប្រទេសក្នុងតំបន់ប៉ាស៊ីហ្វិកប៉ែកខាងកើត និងសហរដ្ឋអាមេរិកប៉ែកខាងលិច។

## ៤.ផលប៉ះពាល់នៃការប្តូររូបិយបណ្ណអត្រាការប្រាក់និងថ្លៃទំនិញ

### *ក. ផលប៉ះពាល់ពីអត្រាប្តូរប្រាក់*

ក.ស.ភ.បានកត់ត្រាបញ្ជីគណនេយ្យ ដោយប្រើប្រាស់រូបិយបណ្ណដុល្លារអាមេរិក ដោយសារចំណូលពីប្រតិបត្តិការអាជីវកម្ម និងសេវាកម្មភាគច្រើនជាប្រាក់ដុល្លារអាមេរិក និងការទូទាត់លើការងារជួសជុលគ្រឿងចក្រធំៗ ប្រេងឥន្ធនៈ និងចំណាយផ្សេងៗមួយចំនួនទៀត ក៏ជាប្រាក់ដុល្លារអាមេរិកដែរ លើកលែងតែការចំណាយលើប្រាក់បៀវត្ស និងការបង់ពន្ធ។ហេតុដូចនេះផលប៉ះពាល់ពីអត្រាប្តូរប្រាក់សម្រាប់ ក.ស.ភ.គឺមានកម្រិតអប្បបរមា។

### *ខ. ផលប៉ះពាល់ពីអត្រាការប្រាក់*

ក.ស.ភ.មិនបានកត់ត្រាបំណុលហិរញ្ញវត្ថុដែលមានអត្រាការប្រាក់ថេរតាមតម្លៃទីផ្សារដោយសារភាពលំអៀង ត្រូវបានបញ្ចូលក្នុងរបាយការណ៍លចំណេញ ឬខាតនោះទេហើយ ក.ស.ភ. ក៏ពុំមានឧបករណ៍ហិរញ្ញវត្ថុដេរីវេទីវនាចុងការិយបរិច្ឆេទនេះដែរ។ដូច្នេះការផ្លាស់ប្តូរអត្រាការប្រាក់នាចុងការិយបរិច្ឆេទពុំមានផលប៉ះពាល់ដល់ប្រាក់ចំណេញ ឬខាតនោះទេ របស់ ក.ស.ភ.។

### *គ. ផលប៉ះពាល់ពីការប្រែប្រួលតម្លៃប្រេងឥន្ធនៈ*

ប្រតិបត្តិការរបស់ ក.ស.ភ. ពឹងផ្អែកយ៉ាងខ្លាំងទៅលើគ្រឿងចក្រ ដែលមានតម្រូវការប្រើប្រាស់ប្រេងឥន្ធនៈខ្ពស់។ ការប្រែប្រួលតម្លៃប្រេងឥន្ធនៈ នឹងប៉ះពាល់ដល់ថ្លៃដើមសេវាកម្ម។ អាស្រ័យហេតុនេះ ក.ស.ភ. បានពង្រឹងការគ្រប់គ្រងលើចំណាយប្រតិបត្តិការតាមរយៈការបង្កើនប្រសិទ្ធភាពការងារលើកដាក់ ការរៀបចំទីលានស្តុកកុងតឺន័រ ដែលអាចកាត់បន្ថយការលើកដាក់ និងការចល័តគ្រឿងចក្រច្រើនដែលមិនចាំបាច់។ ជាមួយគ្នានេះដែរ ក.ស.ភ. បានបំពាក់គ្រឿងចក្រទំនើបៗក្នុងការលើកដាក់ដែលប្រើប្រាស់ថាមពលអគ្គិសនីជំនួសវិញ។

## ៥.ផលប៉ះពាល់ពីអតិផរណា

កំណើននៃត្រាអតិផរណាអាចមានផលប៉ះពាល់ដល់ការចំណាយ និងការវិនិយោគរបស់ក្រុមហ៊ុន ព្រោះតម្លៃទំនិញមានការកើនឡើង ហើយអំណាចទិញបានថយចុះ។ ប៉ុន្តែ យោងតាមរបាយការណ៍របស់ធនាគារពិភពលោកកម្ពុជាមានអត្រាអតិផរណាជាមធ្យម៣,៨% ពីឆ្នាំ២០១១ ដល់ ឆ្នាំ២០១៤ ដែលកម្រិតអតិផរណានេះ ពុំប៉ះពាល់ធ្ងន់ធ្ងរដល់ស្ថានភាពហិរញ្ញវត្ថុនិងលទ្ធផលប្រតិបត្តិការ ក.ស.ភ. នោះទេ។

## ៦.គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

ក.ស.ភ.បាននិងកំពុងទទួលផលពីគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល ដែលក្នុងនោះរួមមាន ដូចខាងក្រោម៖

- គោលនយោបាយស្តីពីការជម្រុញការនាំចេញអង្ករ បាននិងកំពុងផ្តល់ផលវិជ្ជមានដល់កំណើននៃការនាំចេញផលិតផលនេះតាមក.ស.ភ.

- គោលនយោបាយក្នុងការអនុគ្រោះពន្ធលើការនាំចូលឧបករណ៍/គ្រឿងចក្រកសិកម្មនាំឱ្យមានការវិនិយោគខ្លាំងលើវិស័យកសិកម្ម
- កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការស្វែងរកការអនុគ្រោះពន្ធនិងកូតា ពីប្រទេសជាដៃគូបាននិងកំពុងជម្រុញឱ្យមានការនាំចេញខ្ពស់
- ការរៀបចំឱ្យមានតំបន់សេដ្ឋកិច្ចពិសេសនិងភណ្ឌាគារគយមានដែនកំណត់ បាននិងកំពុងទាក់ទាញឱ្យមានការវិនិយោគដោយផ្ទាល់ពីបរទេស
- គោលនយោបាយឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ បាននិងកំពុងទាក់ទាញវិនិយោគិនឱ្យមកវិនិយោគនៅប្រទេសកម្ពុជានិងការបង្កើតរោងចក្រធុនធ្ងន់ព្រមទាំងសហគ្រាសធុនតូចនិងមធ្យម
- គោលនយោបាយរបស់រាជរដ្ឋាភិបាលជម្រុញការដឹកជញ្ជូនតាមផ្លូវទឹក
- ធនាគារជាតិនៃកម្ពុជា បាននិងកំពង់បន្តអនុវត្តគោលនយោបាយរូបិយវត្ថុតឹងរឹងនិងអត្រាប្តូរប្រាក់សេរីដែលមានការគ្រប់គ្រង។គោលនយោបាយនេះបាននិងកំពុងរួមចំណែកក្នុងការបង្កើនទំនុកចិត្តសាធារណៈក្នុងបរិស្ថានម៉ាក្រូសេដ្ឋកិច្ចនៃប្រទេសកម្ពុជានិងជម្រុញការធ្វើអាជីវកម្មពីវិស័យឯកជន
- ការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រដល់សហគ្រាសបោះផ្សាយលក់មូលបត្រនៅកម្ពុជាបាននិងកំពុងជម្រុញឱ្យក្រុមហ៊ុនឯកជន និងសហគ្រាសរដ្ឋចូលទីផ្សារមូលបត្រកាន់តែច្រើន ដែលចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

# ផ្នែកទី ១០

# ស្ថិតិប្រចាំឆ្នាំសង្ខេបពីលទ្ធផលអាជីវកម្មរបស់ ក.ស.ក.

## ស្ថិតិនាវាដឹកទំនិញឆ្លងកាត់ ក.ស.ភ.

ឯកតា (គ្រឿង)

| ឆ្នាំ | ឆ្នាំ២០១៧ | ឆ្នាំ២០១៦ | ឆ្នាំ២០១៥ |
|---|---|---|---|
| នាវា.សាឡង់អន្តរជាតិ | ១០៨៣ | ១០៧៥ | ៩៩០ |
| នាវាប្រេង | ៥២២ | ៥០២ | ៥០៥ |
| នាវាកម្ពុជា | ៧១ | ១០២ | ១០១ |
| សាឡង់កម្ពុជា | 0 | 0 | 0 |
| **សរុប** | **១៦៧៦** | **១៦៧៩** | **១៥៩៦** |

## ស្ថិតិកុងតឺន័រឆ្លងកាត់ ក.ស.ភ.

ឯកតា (ធីអ៊ីយូ)

| ឆ្នាំ | | ឆ្នាំ២០១៧ | ឆ្នាំ២០១៦ | ឆ្នាំ២០១៥ |
|---|---|---|---|---|
| នាំចូល | គ្មានទំនិញ | ៣២.៦១៤ | ២៥.៨៥២ | ២៨.៥៧៥ |
| | មានទំនិញ | ៥៦.៨៩៥ | ៤៩.១២៣ | ៤៥.៧៥១ |
| សរុបនាំចូល | | ៨៩.៥០៩ | ៧៤.៩៧៥ | ៧៤.៣២៦ |
| នាំចេញ | គ្មានទំនិញ | ១៥.២០៧ | ១០.៦៥០ | ១១.៧៣១ |
| | មានទំនិញ | ៨០.០៨៩ | ៦៦.១៥៦ | ៥៨.៧៥៦ |
| សរុបនាំចេញ | | ៩៥.២៩៦ | ៧៦.៨០៦ | ៧០.៤៨៧ |
| **សរុប** | | ១៨៤.៨០៥ | ១៥១.៧៨១ | ១៤៤.៨១៣ |

## ស្ថិតិនាវាទេសចរណ៍អន្តរជាតិឆ្លងកាត់ ក.ស.ភ.

| ឆ្នាំ | | ឆ្នាំ២០១៧ | ឆ្នាំ២០១៦ | ឆ្នាំ២០១៥ |
|---|---|---|---|---|
| នាវាទេសចរណ៍អន្តរជាតិ | អ្នកដំណើរ(នាក់) | ២៦.៧១៥ | ២៥.២៤២ | ២៥.០៣៣ |
| | នាវា(ជើង) | ៦២៣ | ៥៩៧ | ៦០៤ |

# ផ្នែកទី ១១

# ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការការពារវិនិយោគិន

**សម្រាប់ឆ្នាំ២០១៧ ក. ស. ភ. មានព័ត៌មានចាំបាច់សម្រាប់ការពារវិនិយោគិនដូចខាងក្រោម៖**

- បានពិនិត្យ និងអនុម័តលើរបាយការណ៍ស្តីពីលទ្ធផលការងារអាជីវកម្ម/សេវាកម្មឆ្នាំ២០១៦
- បានពិនិត្យ និងសម្រេចឯកភាពលើការស្នើសុំតែងតាំង និងផ្ទេរភារកិច្ចថ្នាក់ដឹកនាំមួយចំនួនរបស់ ក. ស. ភ. ដូចខាងក្រោម ÷
  ១. ផ្ទេរភារកិច្ចឯកឧត្តម ណៃម ធីម ពីអគ្គនាយករងអាជីវកម្ម/ប្រតិបត្តិការផែ មកជាអគ្គនាយករងរដ្ឋបាល/ហិរញ្ញវត្ថុ
  ២. តែងតាំងលោកស្រី ហ៊ី ផានិន ជាអគ្គនាយករងអាជីវកម្ម/ប្រតិបត្តិការផែ ជំនួសឯកឧត្តម ណៃម ធីម ដែលបានផ្ទេរភារកិច្ចទៅជាអគ្គនាយករងរដ្ឋបាល/ហិរញ្ញវត្ថុ បន្ទាប់ពីលោកជំទាវ គឹម សែន ចូលនិវត្តន៍
  ៣. ផ្ទេរភារកិច្ច និងតែងតាំងថ្នាក់ប្រធាននាយកដ្ឋានមួយចំនួនដែលនៅទំនេរ រួមមាន÷
  - តែងតាំង លោក តោ នី ជាប្រធាននាយកដ្ឋានសេវាកម្មនាវាចរណ៍
  - ប្រគល់ភារកិច្ចជូន លោក គង់ សុធា ជាប្រធាននាយកដ្ឋានបុគ្គលិកធនធាន/មនុស្សវិញ
  - ផ្ទេរភារកិច្ច លោក ជី វិចិត្រ ពីប្រធាននាយកដ្ឋានបុគ្គលិក ទៅជាប្រធាននាយកដ្ឋានវិស្វកម្ម
  - តែងតាំង លោក ហ៊ុន សុខាល័យ ជាប្រធានស្តីទីនាយកដ្ឋានផែនការ/ទីផ្សារ
- បានពិនិត្យ និងសម្រេចយល់ព្រមជាគោលការណ៍បន្តកិច្ចសន្យាជូនទីប្រឹក្សាអមក. ស. ភ. ចំនួន ៦ រូប នាពេលបច្ចុប្បន្ន និងបានសម្រេចយល់ព្រមជាគោលការណ៍តែងតាំងអគ្គនាយករង ចំនួន ២ រូប គឺលោកជំទាវ គឹម សែន និងឯកឧត្តម ណៃម ធីម ជាទីប្រឹក្សាអម ក. ស. ភ. បន្ទាប់ពីចូលនិវត្តន៍ រហូតដល់បំណាច់ឆ្នាំ២០១៨
- បានពិនិត្យ និងសម្រេចយល់ព្រមជាគោលការណ៍ឱ្យ ក. ស. ភ. អនុវត្តតាមគោលការណ៍របស់រាជរដ្ឋាភិបាលដំឡើងប្រាក់ឧបត្ថម្ភប្រពន្ធ ១៥.០០០ រៀល និងកូន ១០.០០០ រៀល និងមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សចាប់ពី ១.០០០.០០១ រៀល
- បានពិនិត្យ និងសម្រេចឯកភាពឱ្យ ក. ស. ភ. បន្តជួលសេវា របស់ក្រុមហ៊ុនសវនកម្មឯករាជ្យ KPMG សម្រាប់ការធ្វើសវនកម្ម និងសេវាត្រួតពិនិត្យលើរបាយការណ៍ប្រចាំ ត្រីមាសនីមួយៗ សម្រាប់ឆ្នាំ២០១៧ បន្តទៀត
- បានពិនិត្យ និងធ្វើការវាយតម្លៃខ្ពស់លើកិច្ចសហប្រតិបត្តិការរវាង ក. ស. ភ. និងក្រុមហ៊ុនយុនណាន សេងមៅ អ៊ិនវេសម៉ិន (ខេមបូឌា) ឯ.ក ដើម្បីវិនិយោគដីទីលានស្តុកសំបកកុងតឺន័រ (ICD) ឱ្យទៅជាមជ្ឈមណ្ឌលផ្គត់ផ្គង់គ្រឿងសំណង់ (CMSC)
- បានពិនិត្យ និងសម្រេចឱ្យ ក. ស. ភ. ពិគ្រោះយោបល់ជាមុនជាមួយគណៈកម្មការមូលបត្រកម្ពុជា (គ. ម. ក.) លើសេចក្តីព្រាងតារាងពេលវេលា និងកម្មវិធីការងារសម្រាប់បែងចែក ភាគលាភ

ឆ្នាំ២០១៦ និងដំណើរការរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី២ មុននឹងដាក់ជូនអង្គប្រជុំក្រុមប្រឹក្សាភិបាល (នៅដើមខែមីនា ឆ្នាំ២០១៧) នាពេលក្រោយដើម្បីធ្វើការសម្រេចជាផ្លូវការ

- បានពិនិត្យ និងអនុម័តលើរបាយការណ៍លទ្ធផលហិរញ្ញវត្ថុ សម្រាប់ការិយបរិច្ឆេទ២០១៦ ដែលបានធ្វើសវនកម្មដោយសវនករឯករាជ្យ KPMG
- បានពិនិត្យ និងសម្រេចលើការកំណត់បែងចែកប្រាក់ថ្លៃងសរសើរជូនថ្នាក់ដឹកនាំ និងនិយោជិត ក. ស. ភ. ស្មើនឹងចំនួន ៣ខែ នៃប្រាក់បៀវត្សរ៍សរុបជាមធ្យមប្រចាំឆ្នាំ និងការបែងចែកប្រាក់ចំណេញចូលមូលនិធិនានាប្រចាំឆ្នាំ២០១៦
- បានពិនិត្យ និងសម្រេច លើការបែងចែកភាគលាភជូនភាគហ៊ុនិក ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតប្រភេទ "ក" និងប្រភេទ "ខ" ឆ្នាំ២០១៦ និងភាគលាភបង្គរឆ្នាំ២០១៥
- បានពិនិត្យ និងសម្រេចលើកាលបរិច្ឆេទ របៀបវារៈ និងទីកន្លែង នៃការរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី២ របស់ ក. ស. ភ.
- បានពិនិត្យ និងសម្រេចអនុញ្ញាតឱ្យក្រុមហ៊ុន CHEAN CHHOENG THAI GROUP ធ្វើការសិក្សាលម្អិតអំពីគម្រោង, អំពីផលសេដ្ឋកិច្ចនៃគម្រោង, អំពីផលប៉ះពាល់ពាក់ព័ន្ធពីគម្រោង និងលើកគម្រោងជាក់ស្តែងដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេច ហើយក្នុងករណីចាំបាច់ នឹងអនុញ្ញាតឱ្យ ក. ស. ភ លើកសំណើជូនក្រសួងអាណាព្យាបាលទាំងពីរ ដើម្បីពិនិត្យ សម្រេច
- បានពិនិត្យ និងអនុម័តរបាយការណ៍សកម្មភាពការងាររយៈពេល ៦ខែ ឆ្នាំ២០១៧
- បានពិនិត្យ និងអនុម័តរបាយការណ៍របស់សវនករឯករាជ្យ KPMG ប្រចាំត្រីមាសទី២ ឆ្នាំ២០១៧
- បានពិនិត្យ និងអនុម័តរបាយការណ៍របស់សវនកម្មផ្ទៃក្នុងប្រចាំត្រីមាសទី២ ឆ្នាំ២០១៧
- បានពិនិត្យ និងសម្រេចលើការជ្រើសរើសយកក្រុមហ៊ុនសវនកម្មឯករាជ្យ BOD ដើម្បីធ្វើការត្រួតពិនិត្យលើរបាយការណ៍ប្រចាំត្រីមាសនីមួយៗ និងធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំសម្រាប់រយៈពេល ៣ ឆ្នាំ ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២០
- បានពិនិត្យ និងឯកភាពឱ្យ ក. ស. ភ. បន្តជួលសេវារបស់ក្រុមហ៊ុន Ernst & Young សម្រាប់គណនាប្រាក់សោធននិវត្តន៍របស់បុគ្គលិក ក. ស. ភ. រយៈពេល ៣ ឆ្នាំ ចាប់ពីឆ្នាំ២០១៧ រហូតដល់ឆ្នាំ២០១៩
- បានពិនិត្យ និងពិភាក្សាលើគម្រោងអភិវឌ្ឍន៍មជ្ឈមណ្ឌលពាណិជ្ជកម្មចំរុះ "THE CITY GATE" របស់ក្រុមហ៊ុនចៀន ឈឹង ថៃ គ្រុប នៅលើទីតាំងចំណតផែបណ្តែត TS១ និងចំណតផែថ្មTS៣
- បានពិនិត្យ និងសម្រេចលើការកែសម្រួលសមាសភាពគណៈកម្មាធិការតែងតាំង នៃក្រុម-ប្រឹក្សាភិបាល
- បានពិនិត្យ និងសម្រេចលើការស្នើសុំពន្យារពេលបង់ថ្លៃជួលដីនៅទីលានស្តុកទុកសំបក កុងតឺន័រ (ICD) របស់ក្រុមហ៊ុន យុនណាន សេងមៅ អ៊ិនវេសមិន ឯ.ក (ខេមបូឌា)
- បានពិនិត្យ និងសម្រេចដាក់នាយកដ្ឋានសវនកម្មផ្ទៃក្នុង ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការសវនកម្ម នៃក្រុមប្រឹក្សាភិបាល ក. ស. ភ.

- បានពិនិត្យ និងសម្រេចលើសំណើសុំជំរះបញ្ជីគ្រឿងចក្រ និងសម្ភារចាស់ៗ ចេញពីបញ្ជី ដោយអចលនទ្រព្យរបស់ ក. ស. ភ. ស្នើសុំការសម្រេចពីក្រសួងអាណាព្យាបាលទាំងពីរ និងអនុញ្ញាតឱ្យ ក. ស. ភ. ធ្វើលិខិតស្នើសុំឧបត្ថម្ភរថយន្តរដ្ឋបាលចំនួន ៣ គ្រឿងជូនអតីតអគ្គនាយករង ក. ស. ភ. ចំនួន ៣ រូបទៅក្រសួងអាណាព្យាបាលទាំងពីរ
- បានពិនិត្យ និងសម្រេចអនុញ្ញាតឱ្យ ក. ស. ភ. អនុវត្តការងាររៀបចំពង្រីងទីលានផ្ទុកសំបកកុងតឺន័រ LM១៧ នៅលើទំហំ ១ ហិកតា បន្ថែម ប៉ែកខាងត្បូងនៃអគាររដ្ឋបាល ដោយធ្វើនិយ័តឥណទានថវិកាពីគម្រោងមិនទាន់ចាំបាច់ពាក់ព័ន្ធ សម្រាប់ការអនុវត្តគម្រោងនេះ
- បានពិនិត្យ និងសម្រេចអនុញ្ញាតឱ្យ ក. ស. ភ. ធ្វើការសិក្សាជាមួយក្រុមហ៊ុន Solar Partner Asia (Cambodia) Ltd. លើលទ្ធភាពធ្វើកិច្ចសហប្រតិបត្តិការ ដើម្បីបង្កើតប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ដោយពន្លឺព្រះអាទិត្យនៅចំណតផែកុងតឺន័រ LM១៧
- បានពិនិត្យ និងសម្រេចអនុញ្ញាតឱ្យ ក. ស. ភ. ធ្វើការសិក្សាជាមួយក្រុមហ៊ុនមកពីខេត្ត Anhui នៃសាធារណរដ្ឋប្រជាមានិតចិន លើលទ្ធភាពធ្វើកិច្ចសហប្រតិបត្តិការបង្កើតចំណតផែលើកដាក់ផ្ទេរផ្ទុក ធ្យូងថ្ម ស៊ីម៉ង់ត៍ និងវត្ថុធាតុដើមគ្រឿងសំណង់ក្នុងស្រុក
- បានពិនិត្យ និងសម្រេចអនុញ្ញាតឱ្យ ក. ស. ភ. ធ្វើការសិក្សាជាមួយក្រុមហ៊ុន Mekong Oryza Trading Co., Ltd. លើលទ្ធភាពធ្វើកិច្ចសហប្រតិបត្តិការបង្កើតឃ្លាំងត្រជាក់ សម្រាប់ប្រមូល ផ្លែឈើវេចខ្ចប់នាំចេញ
- បានពិនិត្យ និងសម្រេចអនុញ្ញាតឱ្យ ក. ស. ភ. ធ្វើការសិក្សាជាមួយក្រុមហ៊ុន Green Trade លើលទ្ធភាពធ្វើកិច្ចសហប្រតិបត្តិការ ដើម្បីបង្កើតរោងចក្រកែច្នៃស្រូវ អង្ករ (Rice Processing Facility) តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP) សម្រាប់ការនាំចេញអង្ករ និង កសិផលផ្សេងៗ
- បានពិនិត្យ និងសម្រេចអនុញ្ញាតឲ្យ ក.ស.ភ. ធ្វើការសិក្សាលើករណីក្រុមហ៊ុន Mekong Sentosa Logistics (MSL) ដែលមានបំណងបញ្ឈប់អាជីវកម្ម ថាតើ ក.ស.ភ. គួរទទួលយកការងារនេះបន្ត ឬយ៉ាងណា
- បានពិនិត្យ និងអនុម័តលើរបាយការណ៍ស្តីពីលទ្ធផលការងារបឋមរយៈពេល ៩ខែ ឆ្នាំ២០១៧ របស់ ក. ស. ភ.
- បានពិនិត្យ និងសម្រេចតែងតាំង លោក តោ នី ជាអគ្គនាយករងរដ្ឋបាល/ហិរញ្ញវត្ថុ ជំនួសឯកឧត្តម ឈែម ធីម ដែលចូលនិវត្តន៍ និងផ្ទេរភារកិច្ចលោក តុល សុខុម ពីប្រធាននាយកដ្ឋានប្រតិបត្តិការចំណតផែTS៣ មកជាប្រធាននាយកដ្ឋានសេវាកម្មនាវាចរណ៍ជំនួសលោក តោ នី
- បានពិនិត្យ និងគាំទ្រលទ្ធផលនៃកិច្ចប្រជុំរបស់គណៈកម្មការអន្តរក្រសួង លើការសិក្សាវាយតម្លៃទីតាំងចំណតផែថ្មTS៣ និងចំណតផែបណ្តែតTS១ របស់ ក. ស. ភ. ដែលត្រូវជួលឱ្យក្រុមហ៊ុនចៀន ឈឹង ថៃ គ្រុប
- បានពិនិត្យ និងសម្រេចពិចារណាលើការបង្កើនភាគលាភ ជូនភាគហ៊ុនិកមានសិទ្ធិបោះឆ្នោតប្រភេទ “ក” ក្នុងចំនួន ៦% សម្រាប់ឆ្នាំ២០១៧ បើលទ្ធផលអាជីវកម្ម/ហិរញ្ញវត្ថុប្រចាំឆ្នាំ២០១៧សម្រេចបានតាមការប៉ាន់ស្មានទុក

- បានពិនិត្យ និងសម្រេចឱ្យក្រុមហ៊ុន យុនណាន សេងមៅ អ៊ិនវេសម៉ិន (ខេមបូឌា) ឯ.ក ប្តូរឈ្មោះគម្រោងពី "មជ្ឈមណ្ឌលផ្គត់ផ្គង់គ្រឿងសំណង់ (CMSC)" ទៅជា "មជ្ឈមណ្ឌលពាណិជ្ជ-កម្ម Triumph កម្ពុជា" ដោយត្រូវអនុវត្តតាមនីតិវិធីច្បាប់ជាធរមាន
- បានពិភាក្សា និងអនុម័តផែនការអាជីវកម្ម សេវាកម្ម និងហិរញ្ញវត្ថុ ឆ្នាំ២០១៨ របស់ ក. ស. ភ.
- បានពិនិត្យ និងសម្រេចអនុញ្ញាតឱ្យ ក. ស. ភ. ធ្វើកិច្ចសហការជាមួយក្រុមហ៊ុន Infunde Development Pte. Ltd. លើការសិក្សាគម្រោងផ្គត់ផ្គង់ថាមពលអគ្គិសនី ដើរដោយពន្លឺព្រះអាទិត្យ (Solar Power) នៅចំណតផែកុងតឺន័រ LM១៧។

## ហត្ថលេខារបស់អភិបាលកំពង់ផែស្វយ័តភ្នំពេញ

ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨
បានអាន និងឯកភាព

ហត្ថលេខា
**ហ៊ី បាទី**
ប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយក

ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨
បានអាន និងឯកភាព

ហត្ថលេខា
**សួន រចនា**
សមាជិកក្រុមប្រឹក្សាភិបាល
តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន

ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨
បានអាន និងឯកភាព

ហត្ថលេខា
**កែន សម្បត្តិ**
សមាជិកក្រុមប្រឹក្សាភិបាល
តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨
បានអាន និងឯកភាព

ហត្ថលេខា
**ម៉ែន សុទិជាតិ**
សមាជិកក្រុមប្រឹក្សាភិបាល
តំណាងក្រសួងពាណិជ្ជកម្ម

ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨
បានអាន និងឯកភាព

ហត្ថលេខា
**ហ្គី អានថ៉ានិថ**
សមាជិកក្រុមប្រឹក្សាភិបាល
អភិបាលឯករាជ្យ

ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨
បានអាន និងឯកភាព

ហត្ថលេខា
**ឱត សុចល**
សមាជិកក្រុមប្រឹក្សាភិបាល
អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន

ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨
បានអាន និងឯកភាព

ហត្ថលេខា
**ជួន សុខេម**
សមាជិកក្រុមប្រឹក្សាភិបាល
តំណាងនិយោជិត ក.ស.ភ.

កំពង់ផែស្វយ័តភ្នំពេញ

PHNOM PENH AUTONOMOUS PORT

## អាសយដ្ឋាន / Address

**១.ចំណតផែកុងតឺន័រ LM១៧**

ភូមិកណ្ដាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល

Container Terminal LM17 : Kandal Leu Village, Bantey Dek Commune, Kien Svay District, Kandal Province.

**២.ចំណតផែ អ្នកដំណើរ និងទេសចរ TS១**

តិរៈវិថីព្រះស៊ីសុវត្ថិ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

Passenger and Tourist Terminal TS1 : Street 1 (Preah Sisowath), Sangkat Wat Phnom, Khan Daun Penh, Phnom Penh.

**៣.ចំណតផែកុងតឺន័រ TS៣**

#៦៤៩ តិរៈវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

Container Terminal TS3 : #649, Street 1 (Preah Sisowath), Sangkat Sras Chork, Khan Daun Penh, Phnom Penh.

**៤.ទីលានស្តុកទុកកុងតឺន័រ ICD**

ភូមិបឹងសាឡាង សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

Inland Container Deport (ICD) : Phum Boeung Salang, Sangkat Reusseykeo, Khan Reusseykeo, Phnom Penh.

**៥.ចំណតផែទន្លេបិទ UM២**

ភូមិទន្លេបិទ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ

Tonle Bet Port UM2 : Tonle Bet Village, Tonle Bet Commune, Thbong Khmoum District, Thbong Khmoum Province.

**ទំនាក់ទំនង / Contact**

Email : ppapmpwt@online.com.kh

Tel/Fax : +855 23 427802

Website : www.ppap.com.kh